PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

# របាយការណ៍ប្រចាំឆ្នាំ 2025

## ព្រូដិនសល (ខេមបូឌា)

គោលបំណងរបស់យើង

# សម្រាប់ ព្រូដិនសល

យើងប្តេជ្ញាក្នុងការក្លាយជាដៃគូការពារ សម្រាប់មនុស្សគ្រប់រូប
យើងក៏បន្តឆ្ពោះទៅមុខឥតឈប់ឈរ ដើម្បីការពាររាល់អនាគតរបស់អ្នកគ្រប់គ្នា



# មាតិកា


| | ទំព័រ |
|---|---|
| **I. ព័ត៌មានសង្ខេបអំពីអាជីវកម្ម** | |
| 1. សាររបស់ប្រធានក្រុមប្រឹក្សាភិបាល | 4 |
| 2. សាររបស់អគ្គនាយក | 6 |
| 3. ព័ត៌មានហិរញ្ញវត្ថុសង្ខេប | 8 |
| **II. ព័ត៌មានអំពីអាជីវកម្ម** | |
| 1. អំពីក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) | 12 |
| 2. ផលិតផលធានារ៉ាប់រង និងសេវាកម្ម | 14 |
| 3. ការចាប់ដៃគូ និងប្រព័ន្ធចែកចាយ | 16 |
| 4. អតិថិជន | 18 |
| **III. ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម** | |
| 1. រចនាសម្ព័ន្ធក្រុមហ៊ុន | 22 |
| ក. ក្រុមប្រឹក្សាភិបាល | 26 |
| ខ. គណៈគ្រប់គ្រង | 28 |
| 2. របាយការណ៍របស់គណៈកម្មាធិការ | 30 |
| ក. គណៈកម្មាធិការសវនកម្ម | 30 |
| ខ. គណៈកម្មាធិការវិនិយោគ | 32 |
| គ. គណៈកម្មាធិការហានិភ័យ | 33 |
| 3. របាយការណ៍អំពីអភិបាលកិច្ចសាជីវកម្ម | 34 |
| **IV. ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម** | |
| 1. ដើមទុន និងកម្រិតសាធនភាព | 38 |
| 2. ការវិនិយោគ | 40 |
| 3. ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង | 44 |
| 4. លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម | 46 |
| 5. ការធានារ៉ាប់រងបន្ត | 48 |
| 6. ការគ្រប់គ្រងហានិភ័យ | 50 |
| 7. ព័ត៌មានអំពីចីរភាព | 52 |
| **V. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ** | |
| 1. ព័ត៌មានអំពីក្រុមហ៊ុន | 68 |
| 2. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 69 |
| 3. របាយការណ៍របស់សវនករឯករាជ្យ | 72 |
| 4. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | 75 |
| 5. របាយការណ៍លទ្ធផលពេញលេញ | 76 |
| 6. របាយការណ៍បម្រែបម្រួលមូលធន | 77 |
| 7. របាយការណ៍លំហូរសាច់ប្រាក់ | 78 |
| 8. កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 80 |

# ព័ត៌មានសង្ខេប អំពីអាជីវកម្ម


ទំព័រ

1. សាររបស់ប្រធានក្រុមប្រឹក្សាភិបាល 4
2. សាររបស់អគ្គនាយក 6
3. ព័ត៌មានហិរញ្ញវត្ថុសង្ខេប 8




# សាររបស់ ប្រធានក្រុមប្រឹក្សាភិបាល



តាងនាមឱ្យក្រុមប្រឹក្សាភិបាល យើងខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយលើការបង្ហាញរបាយការណ៍ប្រចាំឆ្នាំ ២០២៥ របស់ក្រុមហ៊ុនព្រូដិនសលកម្ពុជា ដែលក្នុងឆ្នាំនេះ ក្រុមហ៊ុនបានឆ្លុះបញ្ចាំងពីការបន្តផ្ដោតការយកចិត្តទុកដាក់ខ្ពស់ទៅលើលទ្ធផល ដើម្បីផ្ដល់ជូនអតិថិជនរបស់យើង ដោយក្នុងខណៈពេលតែមួយនេះ ក្រុមហ៊ុនក៏កំពុងបន្តកសាងភាពធន់ នៃការគ្រប់គ្រងអភិបាលកិច្ចអាជីវកម្ម ដែលអាចបង្កើតនូវតម្លៃប្រកបដោយចីរភាពរយៈពេលវែង។

បរិយាកាសប្រតិបត្តិការទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅតែបន្តមានភាពស្វាហាប់ ដោយមានការចូលរួមយ៉ាងសកម្មពីឥរិយាបថអ្នកប្រើប្រាស់ វឌ្ឍនភាពនៃក្របខណ្ឌបទប្បញ្ញត្តិ និងការទទួលយកវឌ្ឍនភាពដ៏ឆាប់រហ័សនៃប្រព័ន្ធឌីជីថល។ ក្នុងបរិបទនេះ តម្រូវការការពារហិរញ្ញវត្ថុនៅតែបន្តកើនឡើង ខណៈដែលអត្រាការជៀតចូលនូវការធានារ៉ាប់រងនៅតែស្ថិតក្រោម ២% នៃផលិតផលក្នុងស្រុកសរុប (GDP)។ នេះបានបង្ហាញពីឱកាសដ៏សំខាន់ និងនិរន្តរភាពក្នុងការពង្រីកដំណើរការនៃដំណោះស្រាយផ្នែកការពារ ការសន្សំ និងសុខុមាលភាពសម្រាប់គ្រួសារកម្ពុជា។

យុទ្ធសាស្ត្ររបស់យើង គឺបានឆ្លើយតបទៅនឹងតម្រូវការទាំងអស់នេះ ដោយក្នុងឆ្នាំ ២០២៥ ក្រុមហ៊ុនព្រូដិនសលកម្ពុជា បានពង្រឹងតម្រូវការចាំបាច់របស់អតិថិជន កែលម្អនូវសេវាកម្មបម្រើអតិថិជន និងបង្កើនការចូលរួមរបស់អតិថិជនតាមរយៈបណ្ដាញ ឌីជីថល និងដោយផ្ទាល់។ យើងនៅតែបន្តផ្ដោតសំខាន់លើការពង្រឹងបណ្ដោយចែកចាយប្រកបដោយការទទួលខុសត្រូវ ដោយធានានូវលទ្ធផលល្អសម្រាប់អតិថិជន គុណភាព និងនិរន្តរភាពដែលនៅតែជាចំណុចស្នូលនៃការអភិវឌ្ឍន៍របស់យើង។

នៅពេលដំណាលគ្នានេះ យើងបានរក្សាវិន័យយ៉ាងតឹងរឹងក្នុងការអនុវត្ត និងការគ្រប់គ្រងមូលធន។ ក្រុមហ៊ុនបានបន្តពង្រឹងស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន តាមរយៈយុទ្ធសាស្ត្រពិពិធកម្មវិនិយោគ ជាមួយនឹងការបង្កើនការបែងចែកទ្រព្យសកម្មរយៈពេលវែង។ នេះបានជួយលើកកម្ពស់ភាពសមកាលរវាងការផ្គូរផ្គងទ្រព្យសកម្ម និងកាតព្វកិច្ច និងបង្កើនផលចំណេញដែលបានមកពីការបង្រួមហានិភ័យ ដែលគាំទ្រដល់ការផ្ដល់តម្លៃមានស្ថេរភាព និងនិរន្តរភាពសម្រាប់ម្ចាស់បណ្ណសន្យារ៉ាប់រង និងម្ចាស់ភាគហ៊ុនរបស់យើង។ យើងក៏នៅតែមានការប្ដេជ្ញាចិត្តក្នុងការគាំទ្រការអភិវឌ្ឍទីផ្សារមូលធនរបស់កម្ពុជា ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រវិនិយោគរយៈពេលវែងរបស់យើង។

អភិបាលកិច្ចដ៏រឹងមាំ និងការគ្រប់គ្រងហានិភ័យ នៅតែជាមូលដ្ឋានសំខាន់ក្នុងបន្តរក្សាជំនឿទុកចិត្តរបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាភិបាល បានត្រួតពិនិត្យយ៉ាងសកម្មលើយុទ្ធសាស្ត្រ លទ្ធផលប្រតិបត្តិការ និងហានិភ័យ ដោយផ្ដោតជាពិសេសលើអតិថិជន ការអនុលោមតាមបទបញ្ញត្តិ សុវត្ថិភាពប្រព័ន្ធអ៊ីនធឺណេត ការការពារទិន្នន័យ និងភាពធន់នៃប្រតិបត្តិការ។ អាទិភាពទាំងនេះ មានសារៈសំខាន់ក្នុងការការពារអតិថិជនរបស់យើង និងរក្សាការជឿជាក់លើប្រតិបត្តិការអាជីវកម្ម។

បុគ្គលិក និងដៃគូអាជីវកម្មរបស់យើង គឺជាចំណុចស្នូលសំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្ររបស់យើង។ យើងនៅបន្តវិនិយោគក្នុងការអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំ និងកសាងវប្បធម៌ការងារផ្អែកលើសុចរិតភាព ការទទួលខុសត្រូវ និងការរួបរួម។ ទាំងអស់នេះ បានបន្តអនុញ្ញាតឱ្យយើងបម្រើអតិថិជនបានកាន់តែល្អប្រសើរ ស្របពេលដែលអាចរក្សាបាននូវស្តង់ដារខ្ពស់នៃវិជ្ជាជីវៈ និងវិន័យប្រតិបត្តិ។

សម្លឹងទៅថ្ងៃអនាគត មូលដ្ឋានគ្រឹះនៃទីផ្សារក្នុងកម្ពុជានៅតែមានសក្ដានុពលខ្ពស់ ដោយសារកំណើននៃប្រជាជនជំនាន់ក្រោយ ការកើនឡើងនូវប្រាក់ចំណូល និងការយល់ដឹងកាន់តែទូលំទូលាយអំពីតម្រូវការការពារហិរញ្ញវត្ថុ និងសុខភាព បានអនុញ្ញាតឱ្យក្រុមហ៊ុនយើង ស្ថិតនៅក្នុងតំណែងដល់ល្អសម្រាប់និរន្តរភាពយូរអង្វែង។ ក្រុមហ៊ុនព្រូដិនសលកម្ពុជា នឹងបន្តទទួលយកឱកាសនេះ តាមរយៈការកែលម្អប្រសិទ្ធភាពក្នុងការអនុវត្ត បង្កើនផលិតភាពនៃបណ្ដាញចែកចាយ និងផ្ដល់បទពិសោធន៍ជូនអតិថិជនប្រកបដោយសាមញ្ញភាព និងរលូនជាងមុន។





យើងនឹងបន្តពង្រឹងសំណើរបស់យើងលើការការពារ ការសន្សំ និងសុខុមាលភាព ខណៈដែលវិនិយោគបន្ថែមលើបច្ចេកវិទ្យា ទិន្នន័យ និងភាពរលូននៃប្រតិបត្តិការ ដើម្បីគាំទ្រដល់ការរីកចម្រើន និងការផ្ដល់សេវាកម្មប្រកបដោយស្ថិរភាព។ ជាមួយនឹងការប្រតិបត្តិប្រកបដោយវិន័យ អភិបាលកិច្ចរឹងមាំ និងការគ្រប់គ្រងមូលធនយ៉ាងប្រុងប្រយ័ត្ន យើងនៅតែមានទំនុកចិត្តលើសមត្ថភាពក្នុងការផ្ដល់ផលចំណេញប្រកបដោយនិរន្តរភាព ខណៈដែលគាំទ្រក្នុងការការពារអ្វីដែលមានសារៈសំខាន់បំផុតសម្រាប់អតិថិជន។

ជាថ្មីម្ដងទៀត តាងនាមឱ្យក្រុមប្រឹក្សាភិបាល យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះគណៈគ្រប់គ្រង បុគ្គលិក និយ័តករ និងដៃគូអាជីវកម្មទាំងអស់ សម្រាប់ការប្ដេជ្ញាចិត្ត និងបន្តកិច្ចសហការប្រតិបត្តិការដ៏ល្អកន្លងមក។ ជាសារវន្ត យើងខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះអតិថិជនរបស់យើង សម្រាប់ការជឿទុកចិត្តមកលើក្រុមហ៊ុនព្រូដិនសលកម្ពុជា។




ដោយសេចក្ដីគោរព

លោកបណ្ឌិត ម៉ី កល្យាណ
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦

# សាររបស់អគ្គនាយក



ក្នុងឆ្នាំ ២០២៥ ក្រុមហ៊ុន ព្រូដិនសល កម្ពុជា នៅតែបន្តផ្តោតការយកចិត្តទុកដាក់យ៉ាងច្បាស់លាស់លើការផ្តល់ជូនសេវាកម្មប្រកបដោយវិន័យ និងការបង្កើតតម្លៃរយៈពេលវែង។ ដោយផ្អែកលើគោលបំណងចម្បងរបស់យើងគឺ—« យើងគឺជាដៃគូ និងជាអ្នកការពារ For every life, for every future »—យើងបានពង្រឹងមូលដ្ឋានគ្រឹះអាជីវកម្មស្ថូល ព្រមទាំងបន្តផ្តល់ជូនទូវដំណោះស្រាយហិរញ្ញវត្ថុ និងសុខភាពដ៏សាមញ្ញ និងងាយស្រួលទទួលបាន សម្រាប់ក្រុមគ្រួសារកម្ពុជា។

យើងបានធ្វើការសម្រេចចិត្តយ៉ាងច្បាស់លាស់ក្នុងការកសាងអាជីវកម្មសម្រាប់រយៈពេលវែង ដោយផ្លាស់ប្តូរការផ្តោតអារម្មណ៍ពីកំណើនដែលផ្អែកលើបរិមាណ មកផ្តោតលើគុណភាព និរន្តរភាព និងលទ្ធផលល្អសម្រាប់អតិថិជនវិញ។ យើងបានពង្រឹងការវាយតម្លៃហានិភ័យធានារ៉ាប់រង (Underwriting) និងប្រព័ន្ធត្រួតពិនិត្យ បង្កើនភាពច្បាស់លាស់ក្នុងការបែងចែកក្រុមអតិថិជនគោលដៅ និងការរក្សាសុពលភាពបណ្ណសន្យារ៉ាប់រង (Persistency) ព្រមទាំងបន្តវិនិយោគលើសមត្ថភាពបណ្តាញចែកចាយ។ ទន្ទឹមនឹងនេះ យើងបានលើកកម្ពស់ស្តង់ដារនៃបទពិសោធន៍អតិថិជនដោយកែលម្អដំណើរការសេវាកម្មទាំងលើការលក់ ការគ្រប់គ្រងបណ្ណសន្យារ៉ាប់រង និងការទាមទារសំណង។

យុទ្ធសាស្ត្ររបស់យើងនៅតែរក្សាភាពច្បាស់លាស់៖ អភិវឌ្ឍន៍ប្រកបដោយការទទួលខុសត្រូវតាមរយៈបណ្តាញចែកចាយដែលគួរឱ្យទុកចិត្ត និងផ្តោតលើអតិថិជនជាចម្បង កសាងផលិតផលនិងសេវាកម្មការពារ ការសន្សំ និងសុខភាពឱ្យកាន់តែរឹងមាំ និងផ្តល់ជូននូវសេវាកម្មដ៏ឆ្នើមតាមរយៈដំណើរការឌីជីថលដ៏សាមញ្ញ និងកាន់តែងាយស្រួល។ ក្នុងឆ្នាំ ២០២៥ យើងបានបន្តពង្រឹងប្រព័ន្ធប្រតិបត្តិការរបស់យើង ដើម្បីអាចពង្រីកវិសាលភាពអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព រួមទាំងការវិនិយោគលើទិន្នន័យ វិន័យនៃដំណើរការការងារ និងសន្តិសុខសាយប័រ (Cybersecurity)។ យើងក៏បានបន្តពង្រឹងនិងពង្រីកជម្រើសសេវាស្វ័យគ្រប់គ្រង (Self-service) ដែលជួយឱ្យអតិថិជនគ្រប់គ្រងបណ្ណសន្យារ៉ាប់រងរបស់ពួកគេកាន់តែមានភាពងាយស្រួល និងរក្សាការទំនាក់ទំនងជាមួយយើងតាមរយៈបណ្តាញឌីជីថល។

ចំពោះបណ្តាញចែកចាយ យើងបានបន្តលើកកម្ពស់វិជ្ជាជីវៈភ្នាក់ងាររបស់យើង តាមរយៈការបង្កើនប្រសិទ្ធភាពនៃការជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាល និងការគ្រប់គ្រងផលិតភាព ព្រមទាំងពង្រឹងកិច្ចសហការឱ្យកាន់តែស៊ីជម្រៅជាមួយដៃគូរបស់យើង។ យើងបានផ្តោតលើការលក់ប្រកបដោយការទទួលខុសត្រូវ និងធានាថាការប្រឹក្សាយោបល់ ព្រមទាំងដំណោះស្រាយនានា គឺស្របទៅនឹងតម្រូវការ និងលទ្ធភាពហិរញ្ញវត្ថុរបស់អតិថិជន — ពីព្រោះថាកំណើនប្រកបដោយនិរន្តរភាព គឺចាប់ផ្តើមចេញពីទំនុកចិត្ត។

ចំពោះផ្នែកសុខភាព និងការគាំពារ យើងបានរក្សាវិន័យយ៉ាងម៉ឺងម៉ាត់លើការរចនាផលិតផល ការកំណត់តម្លៃ និងការគ្រប់គ្រងការទាមទារសំណង ព្រមទាំងបន្តធ្វើអោយកាន់តែប្រសើរចំពោះបទពិសោធន៍ដែលអតិថិជនទទួលបានតាមរយៈការគាំទ្ររបស់យើងក្នុងអំឡុងពេលដ៏សំខាន់ៗ។ ការទាមទារសំណង គឺជាចំណុចដែលយើងបានសន្យាជាមួយអតិថិជន ឥឡូវនេះយើងធ្វើបានសម្រេចតាមការសន្យា ហើយយើងប្តេជ្ញាចិត្តធ្វើឱ្យដំណើរការនេះកាន់តែមានភាពច្បាស់លាស់ រហ័ស និងកាន់តែយកចិត្តទុកដាក់ទៅលើអតិថិជន ដោយមានការគាំទ្រពីប្រព័ន្ធត្រួតពិនិត្យដ៏រឹងមាំដើម្បីការពារអតិថិជន។

ក្នុងផ្នែកប្រតិបត្តិការ យើងបានបន្តពង្រឹងមូលដ្ឋានគ្រឹះបច្ចេកវិទ្យា និងទិន្នន័យរបស់យើង លើកកម្ពស់សន្តិសុខសាយប័រ និងកែលម្អប្រសិទ្ធភាពនៃដំណើរការការងារ។ យើងក៏បានសហការជាមួយដៃគូនានា ដើម្បីធ្វើឱ្យការបង់បុព្វលាភរ៉ាប់រង និងការបម្រើសេវាកម្មកាន់តែមានភាពងាយស្រួលសម្រាប់អតិថិជន ដែលនេះជួយគាំទ្រដល់បទពិសោធន៍ដ៏រលូនឥតទាស់ ទាំងតាមរយៈប្រព័ន្ធឌីជីថល និងការជួបផ្ទាល់។ ការវិនិយោគទាំងនេះគឺចាំបាច់ណាស់ក្នុងការផ្តល់ជូនសេវាកម្មប្រកបដោយភាពស៊ីសង្វាក់គ្នា គ្រប់គ្រងហានិភ័យបានល្អ និងគាំទ្រដល់ដំណាក់កាលបន្ទាប់នៃកំណើនអាជីវកម្ម ជាពិសេសនៅពេលដែលអតិថិជនកាន់តែរំពឹងចង់បានភាពងាយស្រួលផ្នែកឌីជីថល រួមផ្សំជាមួយនឹងការប្រឹក្សាយោបល់ដ៏គួរឱ្យទុកចិត្តពីមនុស្សផ្ទាល់។

ក្នុងឆ្នាំ ២០២៥ ដែលជាឆ្នាំទី ១៣ នៃប្រតិបត្តិការរបស់យើង យើងបានបន្តពង្រឹងវិសាលភាព និងឥទ្ធិពលរបស់យើង។ យើងបានបញ្ចប់ឆ្នាំនេះជាមួយនឹងបណ្ណសន្យាដែលមានសុពលភាព (In-force policies) ជិត ២០ ម៉ឺនបណ្ណសន្យា ដោយមានការគាំទ្រពីការរីកចម្រើននៃបណ្តាញចែកចាយភ្នាក់ងារ និងដៃគូរបស់យើង។





អស់រយៈពេលជាងមួយទសវត្សរ៍មកនេះ យើងបានផ្តល់ការការពារដល់អតិថិជនជិតកន្លះលាននាក់ និងបានបំពេញតាមការសន្យារបស់យើងតាមរយៈការទូទាត់សំណងចំនួន ៣៣,៤ លានដុល្លារអាមេរិក គិតត្រឹមខែមេសា ឆ្នាំ ២០២៦។ យើងបានបញ្ចប់ឆ្នាំនេះជាមួយនឹងបណ្ណសន្យាដែលមានសុពលភាពជិត ២០ ម៉ឺនបណ្ណសន្យា ដោយមានការគាំទ្រពីការរីកចម្រើននៃបណ្តាញចែកចាយភ្នាក់ងារ និងដៃគូរបស់យើង។

វឌ្ឍនភាពទាំងអស់នេះនឹងមិនអាចសម្រេចទៅបានឡើយ បើគ្មានបុគ្គលិករបស់យើង។ ក្នុងឆ្នាំ ២០២៥ យើងបានបន្តកសាងវប្បធម៌ការងារដែលផ្អែកលើលទ្ធផលការងារ និងដឹកនាំដោយតម្រូវការអតិថិជន ដោយឈរលើមូលដ្ឋានគ្រឹះនៃភាពស្មោះត្រង់ និងគុណតម្លៃរបស់យើង។ យើងបានវិនិយោគលើការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងពង្រឹងសមត្ថភាពដឹកនាំ។

និរន្តរភាព (Sustainability)
ការគាំទ្រដល់សហគមន៍របស់យើង គឺជាបេសកកម្មស្នូលរបស់យើង។ ចាប់តាំងពីឆ្នាំ ២០១៦ មក កម្មវិធីចំណេះដឹងហិរញ្ញវត្ថុឈានមុខគេរបស់យើងគឺកម្មវិធី «ចាឆីង» (Cha-Ching) បានផ្តើមចែកចាយការអប់រំចំណេះដឹងដល់សិស្សានុសិស្សកម្ពុជាជិត ១៤៩,៤៥១ នាក់ នៅតាមសាលារៀនចំនួន ៣០០។ តាមរយៈការបង្រៀនអំពីទម្លាប់នៃការគ្រប់គ្រងលុយកាក់សំខាន់ៗរួមមាន៖ ការរកប្រាក់ ការសន្សំ ការចំណាយ និងការបរិច្ចាគ (Earn, Save, Spend, and Donate) យើងកំពុងចូលរួមកសាងគ្រឹះដ៏រឹងមាំសម្រាប់សេដ្ឋកិច្ចដែលមានភាពធន់។ នៅពេលយើងសម្លឹងទៅអនាគត យុទ្ធសាស្ត្រវិនិយោគសហគមន៍របស់យើងបានវិវត្តទៅមុខបន្ថែមទៀត។ បន្ទាប់ពីការប្រគល់ជូន និងការបញ្ចប់ជាដំណាក់កាលប្រកបដោយជោគជ័យនូវកម្មវិធី «សុវត្ថិភាពផ្លូវគោក» (Road Safety) និង «សាលារៀនសុវត្ថិភាព» (Safe School) ដែលមានរយៈពេលយូរអង្វែងរបស់យើងក្នុងឆ្នាំ ២០២៥ រួចមក យើងបានបង្វែរធនធានរបស់យើងទៅរកចំណុចប្រសព្វដ៏សំខាន់រវាង អាកាសធាតុ និងសុខភាព វិញ។

តាមរយៈគំនិតផ្តួចផ្តើមថ្មីៗ ដូចជាការដាក់ពង្រាយទូកពេទ្យសង្គ្រោះបន្ទាន់ (Ambulance boats) និងការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលដើម្បីប្រយុទ្ធប្រឆាំងនឹងការគំរាមកំហែងដល់សុខភាពដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ យើងកំពុងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និងកាត់បន្ថយសម្ពាធបរិស្ថាន។ តាមរយៈការរួមបញ្ចូលសេវាធានារ៉ាប់រងបរិយាបន្ន (Inclusive insurance) របស់យើងជាមួយនឹងការអន្តរាគមន៍កម្រិតសហគមន៍ យើងបន្តបំពេញតាមការសន្យារបស់យើងក្នុងការធ្វើឱ្យការការពារមានភាពសាមញ្ញ ធូរថ្លៃ អាចរកបាន និងយុត្តិធម៌សម្រាប់ទាំងអស់គ្នា។

ទស្សនវិស័យទៅថ្ងៃមុខ (Outlook)
យើងឈានចូលឆ្នាំ ២០២៦ ដោយក្តីទុកចិត្ត និងមហិច្ឆតាយ៉ាងច្បាស់លាស់ក្នុងការបង្កើនល្បឿន មិនត្រឹមតែលើល្បឿនការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកំណើន គុណភាព និងប្រសិទ្ធភាពផងដែរ។

យើងនឹងបន្តធ្វើឱ្យបទពិសោធន៍របស់អតិថិជនកាន់តែមានភាពសាមញ្ញ តាមរយៈសេវាស្វ័យគ្រប់គ្រងតាមប្រព័ន្ធឌីជីថល ព្រមទាំងការបង់ប្រាក់ និងការបម្រើសេវាកម្មកាន់តែងាយស្រួល។ ទន្ទឹមនឹងនេះ យើងនឹងបន្តរក្សាការប្រុងប្រយ័ត្នខ្ពស់ក្នុងការគ្រប់គ្រងហានិភ័យ ដើមទុន និង ការគោរពតាមបទប្បញ្ញត្តិ។ ជាមួយនឹងអាទិភាពទាំងនេះ យើងជឿជាក់ថា ក្រុមហ៊ុន ព្រូដិនសល កម្ពុជា មានជំហរយ៉ាងល្អក្នុងការការពារក្រុមគ្រួសារកម្ពុជាឱ្យបានកាន់តែច្រើន និងផ្តល់នូវតម្លៃប្រកបដោយនិរន្តរភាព និងរយៈពេលវែងសម្រាប់អតិថិជន ដៃគូ និងម្ចាស់ភាគហ៊ុនរបស់យើង។

សូមថ្លែងអំណរគុណចំពោះការបន្តផ្តល់ទំនុកចិត្ត និងការគាំទ្ររបស់អស់លោកអ្នក




ដោយសេចក្តីគោរព

លោក ពន្លឺ តុលា
អគ្គនាយក នៃក្រុមហុនព្រូដិនសល កម្ពុជា ឡាវ និងមីយ៉ានម៉ា

ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦

# ព័ត៌មានហិរញ្ញវត្ថុ សង្ខេប

| តារាងតុល្យការ (គិតជាលានដុល្លារអាមេរិក) | 2025 លានដុល្លារអាមេរិក | 2024 លានដុល្លារអាមេរិក | 2023 លានដុល្លារអាមេរិក |
|---|---|---|---|
| សេចក្តីសង្ខេបអំពីសំពៀតវិនិយោគ | 379.52 | 330.39 | 292.82 |
| ទ្រព្យសកម្មអរូបី | 55.95 | 21.75 | 24.95 |
| ទ្រព្យសកម្មសរុប | 462.75 | 415.70 | 361.20 |
| មូលធនសរុប | 94.15 | 93.17 | 89.63 |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | 353.89 | 301.34 | 249.62 |

| តារាងចំណេញ ឬខាត (គិតជាលានដុល្លារអាមេរិក) | 2025 លានដុល្លារអាមេរិក | 2024 លានដុល្លារអាមេរិក | 2023 លានដុល្លារអាមេរិក |
|---|---|---|---|
| បុព្វលាភសុទ្ធ | 72.29 | 83.39 | 75.67 |
| ចំណូលហិរញ្ញវត្ថុ | 21.16 | 19.39 | 17.06 |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាលផ្សេងៗ | 33.12 | 40.39 | 32.96 |
| ចំណាយពន្ធលើប្រាក់ចំណូល | 0.39 | 1.46 | 3.80 |
| ប្រាក់ចំណេញពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ | 0.98 | 3.54 | 14.13 |

| អនុបាតសាធនភាព និងមូលធន | 2025 | 2024 | 2023 |
|---|---|---|---|
| អនុបាតមូលនិធិម្ចាស់ភាគហ៊ុនទៅនឹងទ្រព្យសកម្ម | 20.35% | 22.41% | 24.81% |
| អត្រាកំណើនទ្រព្យសកម្ម | 11.32% | 15.09% | 16.55% |
| អនុបាតកម្រិតសាធនភាពតម្រូវ | 137% | 140% | 154% |
| អត្រាប្រាក់ចំណេញពីការវិនិយោគ | 5.64% | 5.97% | 6.00% |

| ទិន្នន័យអំពីទីផ្សារធានារ៉ាប់រងនៅកម្ពុជា | 2025 លានដុល្លារអាមេរិក | 2024 លានដុល្លារអាមេរិក | 2023 លានដុល្លារអាមេរិក |
|---|---|---|---|
| ចំណែកទីផ្សាររបស់ព្រូដិនសល ក្នុងចំណោមប្រាក់ធានារ៉ាប់រងសរុបទាំងមូលនៃទីផ្សារ* | 36.0% | 42.0% | 39.4% |
| បុព្វលាភធានារ៉ាប់រងដុលសរុបក្រុមហ៊ុន ព្រូដិនសល | 72.29 | 83.39 | 75.67 |
| បុព្វលាភធានារ៉ាប់រងដុលសរុបក្នុងទីផ្សារធានារ៉ាប់រងអាយុជីវិត** | 205 | 200 | 194 |

*ប្រភពពីរបាយការណ៍ទីផ្សារធានារ៉ាប់រងអាយុជីវិត ចេញផ្សាយដោយសមាគមធានារ៉ាប់រងកម្ពុជា (ស.ធ.ក.)

**ប្រភពពីរពីនិយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.)





# ព័ត៌មានហិរញ្ញវត្ថុ សង្ខេប

សំពៀត **វិនិយោគ**

គិតជាលានដុល្លារអាមេរិក

15% កំណើនធៀបនឹងឆ្នាំ 2024




ចំណាយប្រតិបត្តិការ និង **រដ្ឋបាលផ្សេងៗ**

គិតជាលានដុល្លារអាមេរិក

18% យុទ្ធសាស្ត្រគ្រប់គ្រងចំណាយប្រកបដោយប្រសិទ្ធភាពធៀបនឹង 2024




**ប្រាក់ចំណេញសុទ្ធ**

បន្តរក្សាបានភាពវិជ្ជមានជាបន្តបន្ទាប់ពីពីមួយឆ្នាំទៅមួយឆ្នាំ

1លាន គិតជាលានដុល្លារអាមេរិក

**ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា)**

បន្តរក្សាបានភាពវិជ្ជមាន ក្នុងនាមក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេនៅទីផ្សារ

កាន់កាប់ចំណែកទីផ្សារដ៏មានឧត្តមភាពរហូតដល់ 36%

នៃបុព្វលាភធានារ៉ាប់រងដុលសរុប ដោយបន្តពង្រឹងភាពជាអ្នកដឹកនាំដ៏រឹងមាំក្នុងវិស័យធានារ៉ាប់រង

# ព័ត៌មាន
# អំពីអាជីវកម្ម

ទំព័រ


1. អំពីក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) 12
2. ផលិតផលធានារ៉ាប់រង និងសេវាកម្ម 14
3. ការចាប់ដៃគូ និងប្រព័ន្ធចែកចាយ 16
4. អតិថិជន 18




# អំពីក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា)

## អំពីយើង

ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឺសួរិនស៍ ម.ក (“ព្រូដិនសល (ខេមបូឌា)”) បានចាប់ផ្តើមប្រតិបត្តិការក្នុងខែមករា ឆ្នាំ២០១៣ ក្នុងនាមជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលគ្រប់គ្រងដោយក្រុមហ៊ុន ព្រូដិនសល ភីអិលស៊ី ដែល ផ្តល់ជូននូវសេវាធានារ៉ាប់រងអាយុជីវិត សុខភាព និងការគ្រប់គ្រងទ្រព្យសកម្ម នៅក្នុងប្រទេសចិន តំបន់អាស៊ាន តណ្ហា និងអាហ្វ្រិក។

ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) បាន ដើរតួនាទីជាប្រតិបត្តិករស្នូលមួយនៅក្នុងវិស័យធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា។ គោលដៅចម្បងនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) គឺការប្តេជ្ញាក្នុងការក្លាយជាអ្នកផ្តល់ជូនការការពារដ៏ប្រសើរសម្រាប់អនាគតរបស់ប្រជាជនគ្រប់រូប។ តាមរយៈដំណោះស្រាយធានារ៉ាប់រងអាយុជីវិត និងសុខភាពដែលមានភាព សាមញ្ញ ងាយស្រួល និង អាចបត់បែនតម្រូវតាមតម្រូវការ ក្រុមហ៊ុនបានជួយគាំទ្រដល់បុគ្គលម្នាក់ៗ និងក្រុមគ្រួសារក្នុងការគ្រប់គ្រងរាល់ហានិភ័យដែលអាចនឹងកើតឡើងរាប់ចាប់ពីបញ្ហាប្រឈមផ្នែកសុខភាព រហូតដល់ការរៀបចំផែនការហិរញ្ញវត្ថុរយៈពេលវែង —ដោយផ្តល់ជូននូវ សុវត្ថិភាព និងភាពកក់ក្តៅក្នុងចិត្ត នៅគ្រប់ដំណាក់កាលដ៏សំខាន់បំផុតនៃជីវិត។

អស់រយៈពេលជាងមួយទសវត្សរ៍មកនេះ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) បានដើរតួ ជាគ្រឹះដ៏សំខាន់នៃភាពធន់របស់សហគមន៍ ដោយបាន និងកំពុងលើកកម្ពស់វិធីសាស្ត្របរិយាបន្នយ៉ាងសកម្ម ដើម្បីធានាថាគ្រប់គ្នារីកចម្រើនទៅមុខជាមួយគ្នា ព្រមទាំងធានាយ៉ាងម៉ឺងម៉ាត់ថាមិនមាននរណាម្នាក់ត្រូវបាន បោះបង់ចោលឡើយ ចំពេលមានបញ្ហាប្រឈមដែលកំពុងកើនឡើងនៃការប្រែប្រួលអាកាសធាតុ។
តាមរយៈមូលនិធិវិនិយោគសហគមន៍ បង្កើតឡើងដោយក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) បានចូលរួមយ៉ាងសកម្មក្នុងការកសាងសាលារៀនស្ថិតនៅខេត្តនៃតំបន់ភាគឦសាន ស្ទឹងត្រែង និង រតនគីរី ព្រមទាំងបានកែលម្អហេដ្ឋារចនាសម្ព័ន្ធសុវត្ថិភាពចរាចរណ៍ផ្លូវថ្នល់សំខាន់ៗនៅតាមតំបន់សាលារៀនដែលមានហានិភ័យខ្ពស់ដល់គ្រោះថ្នាក់ចរាចរណ៍ក្នុងខេត្តកំពត និងជំរុញការយល់ដឹងផ្នែកហិរញ្ញវត្ថុ ដោយបំពាក់បំប៉នជំនាញគ្រប់គ្រងថវិកាដ៏មានសារៈសំខាន់ដល់កុមារ និងលោកគ្រូ-អ្នកគ្រូតាមរយៈកម្មវិធី «ឆា-ឈីង» (Cha-Ching)។
តាមរយៈការរួមបញ្ចូលគ្នាយ៉ាងរលូនរវាងបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព ការយល់ដឹងផ្នែកសុខភាព និងការពង្រឹងសមត្ថភាពហិរញ្ញវត្ថុ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) នៅតែបន្តផ្តល់ការការពារដល់ក្រុមប្រជាជនងាយរងគ្រោះ និងបើកផ្លូវឆ្ពោះទៅរកអនាគតមួយដែលប្រកបដោយចីរភាព និងនិងផ្តល់ផលប្រយោជន៍ដល់មនុស្សគ្រប់រូប។

## 13ឆ្នាំ នៃការការពារហិរញ្ញវត្ថុ និងសុខភាពជូនក្រុមគ្រួសារកម្ពុជា និងឆ្ពោះទៅថ្ងៃអនាគត

អស់រយៈពេល ១៣ ឆ្នាំ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) បានរួមដំណើរយ៉ាងជិតស្និទ្ធគ្រួសារខ្មែរ ក្នុងនាមជាដៃគូដ៏គួរឱ្យទុកចិត្តដើម្បី ការពារ និងថែរក្សានូវរាល់អត្ថប្រយោជន៍ជូនចំពោះអតិថិជនគ្រប់រូប។ ក្រុមហ៊ុនបានផ្តល់ការគាំទ្រដល់អតិថិជនជាងកន្លះលាននាក់ តាមរយៈដំណោះស្រាយគាំពារអាយុជីវិត និងសុខភាព ដោយបាននាំយកការការពារដ៏កក់ក្តៅនេះទៅដល់ក្រុមគ្រួសារនៅទូទាំងប្រទេស តាមរយៈដៃគូធានារ៉ាប់រង តាមប្រព័ន្ធធនាគារ (Bancassurance) និងបណ្តាញភ្នាក់ងាររាប់ពាន់នាក់ទូទាំងប្រទេស។

គិតត្រឹមខែមេសា ឆ្នាំ២០២៦ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) បានអនុម័តសំណងធានារ៉ាប់រងច្រើនជាង 33.4 លានដុល្លារអាមេរិក ដើម្បីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុបានទាន់ពេលវេលាចំពេលដែលអតិថិជនត្រូវការបំផុត។ សម្លឹងទៅថ្ងៃអនាគត ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) នៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបង្កើនឥទ្ធិពលជាវិជ្ជមានរបស់ខ្លួនឱ្យកាន់តែស៊ីជម្រៅតាមរយៈការបន្តបម្រើ គាំពារ និងជំរុញសក្តានុពលដល់ក្រុមគ្រួសារកម្ពុជា ជាច្រើនជំនាន់តទៅមុខទៀត។

## គោលបំណង និងបេសកកម្មរបស់យើង

**បង្កើតការទង្គិចវិជ្ជមានតាមរយៈអ្វីគ្រប់យ៉ាងដែលយើងធ្វើ**

គោលបំណងរបស់យើងគឺ **សម្រាប់ជីវិតគ្រប់រូប សម្រាប់អនាគតគ្រប់រូប**។ សម្រាប់ ព្រូដិនសល យើងប្តេជ្ញាក្នុងការក្លាយជាដៃគូការពារ សម្រាប់មនុស្សគ្រប់រូបយើងក៏បន្តឆ្ពោះទៅមុខឥតឈប់ឈរ ដើម្បីការពាររាល់អនាគតរបស់អ្នកគ្រប់គ្នា

បេសកម្មរបស់ក្រុមហ៊ុន ព្រូដិនសល គឺក្លាយជាដៃគូ និងជាអ្នកការពារដែលគួរឱ្យទុកចិត្តបំផុតសម្រាប់ជំនាន់នេះ និងជំនាន់ក្រោយៗទៀត តាមរយៈការផ្តល់ជូននូវដំណោះស្រាយហិរញ្ញវត្ថុ និងសុខភាព ដែលសមរម្យ និងងាយស្រួលសម្រាប់អតិថិជន។





## វត្តមានរបស់យើងនៅលើឆាកអន្តរជាតិ

សម្ព័ន្ធក្រុមហ៊ុន ព្រូដិនសល ភីអិលស៊ី ផ្តល់ជូននូវសេវាធានារ៉ាប់រងអាយុជីវិត សុខភាព និងការគ្រប់គ្រងទ្រព្យសកម្មជូនដល់អតិថិជន ១៧ លាននាក់ នៅទូទាំង ២០ ទីផ្សារ នៅក្នុងប្រទេសចិន តំបន់អាស៊ាន តណ្ហា និងអាហ្វ្រិក។

ក្នុងទីផ្សារអាស៊ី ក្រុមហ៊ុន ព្រូដិនសល ភីអិលស៊ី បន្តផ្តល់ជូននូវផលិតផលធានារ៉ាប់រងប្រភេទសន្សំ និងការពារ ដោយគ្របដណ្តប់យ៉ាងទូលំទូលាយ បើទោះបីជាអត្រាដំណើរការធានារ៉ាប់រងនៅក្នុងទីផ្សារនៅមានកម្រិតទាប និងគម្លាតមូលនិធិសោធននិវត្តន៍ក៏ដោយ ខណៈនៅទ្វីបអាហ្វ្រិក អត្រាដំណើរការធានារ៉ាប់រងនៅតែមានកម្រិតទាបបំផុតមួយនៅលើពិភពលោក ក្រុមហ៊ុននៅតែបន្តអភិវឌ្ឍ និងពង្រីកអាជីវកម្មយ៉ាងសកម្ម។

បេសកកម្មរបស់ក្រុមហ៊ុន ព្រូដិនសល គឺក្លាយជាដៃគូ និងជាអ្នកការពារដ៏គួរឱ្យទុកចិត្តបំផុតសម្រាប់មនុស្សជំនាន់នេះ និងជំនាន់ក្រោយៗទៀត តាមរយៈការផ្តល់ជូននូវដំណោះស្រាយហិរញ្ញវត្ថុ និងសុខភាពដ៏សាមញ្ញ និងងាយស្រួលទទួលបាន។ អាជីវកម្មរបស់ក្រុមហ៊ុន មានការចុះបញ្ជីបឋមទ្វេភាគ នៅលើផ្សារភាគហ៊ុនហុងកុង (HKEX: 2378) និងផ្សារភាគហ៊ុនឡុងដ៍ (LSE: PRU)។ ក្រុមហ៊ុនក៏មានការចុះបញ្ជីលំដាប់ទីពីរ (Secondary Listing) នៅលើផ្សារភាគហ៊ុនសិង្ហបុរី (SGX: K6S) និងចុះបញ្ជីនៅលើផ្សារភាគហ៊ុនញូវយ៉ក (NYSE: PUK) ក្នុងទម្រង់ជាបង្កាន់ដៃបញ្ញើអាមេរិក (American Depositary Receipts)។ ក្រុមហ៊ុនក៏ជាសមាសភាគមួយនៃសន្ទស្សន៍ Hang Seng Composite Index និងត្រូវបានរួមបញ្ចូលសម្រាប់ការជួញដូរនៅក្នុងកម្មវិធីតភ្ជាប់ផ្សារភាគហ៊ុន Shenzhen-Hong Kong Stock Connect និងកម្មវិធីតភ្ជាប់ផ្សារភាគហ៊ុន Shanghai-Hong Kong Stock Connect ផងដែរ។

ក្រុមហ៊ុន ព្រូដិនសល ពុំមានការទាក់ទងពាក់ព័ន្ធក្នុងទម្រង់ណាមួយជាមួយក្រុមហ៊ុន ព្រូដិនសល ហ្វាយណែនសល (Prudential Financial, Inc.) ដែលមានទីស្នាក់ការកណ្តាលស្ថិតនៅសហរដ្ឋអាមេរិកនោះទេ ហើយក៏ពុំមានការពាក់ព័ន្ធជាមួយក្រុមហ៊ុន ឌឹ ព្រូដិនសល អឹស្សួរេនស៍ ខម្ពេនី លីមីធីត (The Prudential Assurance Company Limited) ដែលជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន អឹមអ៊ែនជី ភីអិលស៊ី (M&G plc) និងជាក្រុមហ៊ុនដែលបានចុះបញ្ជីបង្កើតឡើងនៅចក្រភពអង់គ្លេសនោះដែរ។



# ផលិតផលធានារ៉ាប់រង និងសេវាកម្ម

## ព័ត៌មានអំពីប្រភេទ និងទិន្នន័យនៃផលិតផលធានារ៉ាប់រង

ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ផ្តល់ជូននូវផលិតផលធានារ៉ាប់រងយ៉ាងសម្បូរបែប ដែលត្រូវបានរចនាឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការការពារ និងការរៀបចំផែនការហិរញ្ញវត្ថុដ៏ចម្រុះរបស់អតិថិជន។ ផ្នែកខាងក្រោមនេះផ្តល់នូវនិយមន័យ និងចំណាត់ថ្នាក់នៃប្រភេទផលិតផលធានារ៉ាប់រង៖

ធានារ៉ាប់រងអាយុជីវិតមានកំណត់កំណត់ (Term Life Insurance)៖ គឺជាធានារ៉ាប់រងអាយុជីវិត ដែលបង់ប្រាក់វត្ថុបំណងធានារ៉ាប់រង (ប្រាក់ឧបត្ថម្ភ) ជូនទៅអ្នកទទួលផលដែលបានកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងបានទទួលមរណភាពក្នុងកំឡុងពេលជាក់លាក់ណាមួយ ដូចជា ៥ (ប្រាំ) ឆ្នាំ ឬ ១០ (ដប់) ឆ្នាំ ឬទទួលមរណភាពមុនអាយុដែលបានកំណត់។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅមានជីវិតក្រោយកាលកំណត់នៃកិច្ចសន្យា អ្នកទទួលផលនឹងមិនទទួលបានប្រាក់ឧបត្ថម្ភណាមួយពីការធានារ៉ាប់រងនេះឡើយ។

ធានារ៉ាប់រងអាយុជីវិតអស់មួយជីវិត (Whole Life Insurance)៖ គឺជាកិច្ចសន្យាធានារ៉ាប់រងដែលធានាលើមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រង ហើយបុព្វលាភធានារ៉ាប់រង (ថ្លៃធានារ៉ាប់រង) អាចត្រូវបានបង់ក្នុងរយៈពេលជាក់លាក់ណាមួយ ឬបង់អស់មួយជីវិត។ ក្រុមហ៊ុនធានារ៉ាប់រងត្រូវបង់ប្រាក់ឧបត្ថម្ភជូនក្រុមគ្រួសារនៃសព ឬអ្នកទទួលផលដែលបានចាត់តាំងណាម្នាក់ នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព។

ធានារ៉ាប់រងអាយុជីវិតមានការសន្សំ (Endowment Insurance)៖ គឺជាធានារ៉ាប់រងអាយុជីវិតដែលប្រាក់ឧបត្ថម្ភអាចនឹងត្រូវបង់ជូនអ្នកត្រូវបានធានារ៉ាប់រង ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅមានជីវិតរហូតដល់ផុតសុពលភាពនៃកិច្ចសន្យា។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពមុនកាលបរិច្ឆេទដែលបានកំណត់ក្នុងកិច្ចសន្យា ប្រាក់ឧបត្ថម្ភត្រូវប្រគល់ជូនទៅអ្នកទទួលផល។

ធានារ៉ាប់រងការប្រាក់ប្រចាំឆ្នាំ/សោធននិវត្តន៍ (Annuity Insurance)៖ គឺជាកិច្ចសន្យាធានារ៉ាប់រងដែលផ្តល់ចំណូលជាទៀងទាត់ជូនដល់អ្នកត្រូវបានធានារ៉ាប់រងសម្រាប់វ័យចូលនិវត្តន៍។

ខសន្យាបន្ថែមការពារសុខភាព និងកិច្ចការពារ (Health and Protection Rider)៖ គឺជាអត្ថប្រយោជន៍បន្ថែមដែលភ្ជាប់ជាមួយបណ្ណសន្យារ៉ាប់រងអាយុជីវិតគោល ដើម្បីផ្តល់កិច្ចការពារបន្ថែម និងការរ៉ាប់រងហិរញ្ញវត្ថុសម្រាប់ការព្យាបាលវេជ្ជសាស្ត្រ ជំងឺ របួសស្នាម ឧបទ្ទវហេតុ និងការចំណាយផ្សេងៗទៀតដែលទាក់ទងនឹងការថែទាំសុខភាព រាប់បញ្ចូលទាំងការថែទាំរយៈពេលវែងសម្រាប់អ្នកជំងឺត្រូវបានធានារ៉ាប់រង ដែលរងរបួសរាងកាយ ឬរងផលប៉ះពាល់ដោយសារជំងឺ។

| ល.រ | ប្រភេទផលិតផលធានារ៉ាប់រង | ទិន្នន័យនៃផលិតផលធានារ៉ាប់រងដែលបានដាក់លក់ |
|---|---|---|
| 1 | មានកាលកំណត់ | 7 |
| 2 | មួយជីវិតកាល | 0 |
| 3 | ទាយជ្ជទាន | 4 |
| 4 | ធនលាភ | 0 |
| 5 | ខសន្យាធានារ៉ាប់រងបន្ថែមនៃកិច្ចការពារ និងសុខភាព | 16 |

**ការសន្សំ** និងការពារ















ព័ត៌មានសង្ខេបអំពីអាជីវកម្ម | **ព័ត៌មានអំពីអាជីវកម្ម** | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

# ផលិតផលធានារ៉ាប់រង និងសេវាកម្ម

## និន្នាការនៃតម្រូវការទីផ្សារធានារ៉ាប់រង

ផលិតផលធានារ៉ាប់រងទាយជ្ជទាន ផ្តល់ការការពារលើករណីមរណភាព ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដោយគ្រោះថ្នាក់មិនចៃដន្យ និងមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដោយគ្រោះថ្នាក់ចៃដន្យ រួមទាំងផ្តល់នូវអត្ថប្រយោជន៍ដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រងនៅថ្ងៃផុតកំណត់នៃរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង។ ផលិតផលធានារ៉ាប់រងនេះរួមបញ្ចូលគ្នាទាំងការការពារ និងការសន្សំ ដែលធ្វើឱ្យមានភាពទាក់ទាញដល់អតិថិជន ដែលស្វែងរកសុវត្ថិភាពផ្នែកហិរញ្ញវត្ថុ រួមជាមួយនឹងការសន្សំរយៈពេលវែង។

ផ្ទុយទៅវិញ ផលិតផលធានារ៉ាប់រងមានកាលកំណត់ ដូចបានរៀបរាប់ខាងលើត្រូវបានរចនាឡើងជាចម្បងដើម្បីផ្តល់នូវការការពារសុទ្ធលើអាយុជីវិត ដោយមិនមានផ្តល់នូវអត្ថប្រយោជន៍ដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រងឡើយ។ ផលិតផលធានារ៉ាប់រងនេះ ផ្តោតលើការផ្តល់ការការពារផ្នែកហិរញ្ញវត្ថុ ក្នុងករណីមានហេតុការណ៍អកុសលណាមួយកើតឡើង។

ទីផ្សារធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា មានអាយុកាលនៅខ្ចីនៅឡើយ ដោយទើបតែបានអភិវឌ្ឍជាងមួយទសវត្សរ៍ប៉ុណ្ណោះ។ ក្នុងទីផ្សារដែលកំពុងអភិវឌ្ឍនេះ តម្រូវការរបស់អតិថិជនភាគច្រើនចាប់អារម្មណ៍លើដំណោះស្រាយការសន្សំ និងការការពាររួមបញ្ចូលគ្នា ខណៈដែលការយល់ដឹង និងតម្រូវការសម្រាប់ផលិតផលធានារ៉ាប់រងលើការពារសុទ្ធនៅកំពុងអភិវឌ្ឍនៅឡើយ។ តរិយាបថទីផ្សារនេះត្រូវបានបង្ហាញនៅក្នុងផលប័ត្រផលិតផលធានារ៉ាប់រងរបស់ក្រុមហ៊ុនព្រូដិនសលកម្ពុជា ដែលផលិតផលធានារ៉ាប់រងទាយជ្ជទានមានភាពលេចធ្លោជាង និងលក់បានច្រើនជាងផលិតផលធានារ៉ាប់រងមានកាលកំណត់។

លើសពីនេះ ការទិញភ្ជាប់ផលិតផលធានារ៉ាប់រងបន្ថែមនៅក្នុងបណ្ណសន្យារ៉ាប់រងតែមួយ ឆ្លុះបញ្ចាំងពីការកើនឡើងពីការយល់ដឹងរបស់អតិថិជនទៅលើហានិភ័យហិរញ្ញវត្ថុដែលទាក់ទងនឹងស្ថានភាពសុខភាពធ្ងន់ធ្ងរ។ នៅពេលដែលថ្លៃព្យាបាលបន្តកើនឡើង ហើយការយល់ដឹងអំពីតម្រូវការការពារសុខភាពមានភាពប្រសើរឡើង មានអតិថិជនកាន់តែច្រើនកំពុងទទួលស្គាល់តម្លៃនៃការពង្រឹងការធានារ៉ាប់រងលើការការពារអាយុជីវិតរបស់ពួកគេ ជាមួយនឹងអត្ថប្រយោជន៍ព្យាបាលជំងឺធ្ងន់ធ្ងរ ជាពិសេសបន្ទាប់ពីផលប៉ះពាល់នៃជំងឺរាតត្បាត COVID-19។ និន្នាការនេះបង្ហាញពីការផ្លាស់ប្តូរបន្តិចម្តងៗនៃចំណូលចិត្តរបស់អតិថិជនឆ្ពោះទៅរកដំណោះស្រាយការការពារដ៏ទូលំទូលាយ លើសពីការសន្សំ និងការការពារអាយុជីវិត។

ខណៈពេលដែលនិន្នាការទីផ្សារបន្តវិវត្ត ក្រុមហ៊ុនព្រូដិនសលកម្ពុជាបានបញ្ចូលការវិភាគតម្រូវការទីផ្សារ ជាផ្នែកសំខាន់នៃដំណើរការអភិវឌ្ឍផលិតផលរបស់យើង។ មុនពេលចាប់ផ្តើមដាក់ចេញនូវផលិតផលណាមួយ ក្រុមហ៊ុនធ្វើការវាយតម្លៃស្រាវជ្រាវទីផ្សារដើម្បីធានាថាដំណោះស្រាយធានារ៉ាប់រងដែលគ្រោងនឹងបង្កើតឡើង ស្របទៅនឹងតម្រូវការអតិថិជន និងនិន្នាការទីផ្សារដែលកំពុងរីកចម្រើន។ បន្ទាប់ពីការចេញលក់ផលិតផល យើងបន្តតាមដានការលក់នៃផលិតផល និងការអភិវឌ្ឍន៍ទីផ្សារ ដើម្បីវាយតម្លៃលើការឆ្លើយតបរបស់អតិថិជន កំណត់សម្គាល់លើការផ្លាស់ប្តូរចំណូលចិត្ត និងធានាថាការផ្តល់ជូនផលិតផលរបស់យើងនៅតែឆ្លើយតបទៅនឹងតម្រូវការ និង អាចប្រកួតប្រជែងនៅក្នុងទីផ្សារ។

ការធានាសុវត្ថិភាព**ប្រាក់កម្ចី**







**ការការពារ**អាយុជីវិត






# បណ្ដាញចែកចាយ



## បណ្ដាញចែកចាយតាមរយៈដៃគូ
ការពង្រីកវិសាលភាពនៃការទទួលសេវា តាមរយៈដៃគូធានារ៉ាប់រងតាមប្រព័ន្ធធនាគារជាយុទ្ធសាស្ត្រ

ការចែកចាយផលិតផលតាមរយៈដៃគូសហការ គឺជាកត្តាលីករជំរុញកំណើនដ៏សំខាន់សម្រាប់ក្រុមហ៊ុន ព្រូដិនសល កម្ពុជា ដែលជួយពង្រីកវិសាលភាពនៃការទទួលបានសេវាធានារ៉ាប់រង តាមរយៈប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុដែលគួរឱ្យទុកចិត្តនៅទូទាំងប្រទេស។ ការចែកចាយផលិតផលតាមរយៈដៃគូសហការ គឺជាកត្តាលីករជំរុញកំណើនដ៏សំខាន់សម្រាប់ក្រុមហ៊ុន ព្រូដិនសល កម្ពុជា ដែលជួយពង្រីកវិសាលភាពនៃការទទួលបានសេវាធានារ៉ាប់រង តាមរយៈប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុដែលគួរឱ្យទុកចិត្តនៅទូទាំងប្រទេស។ តាមរយៈការបញ្ជ្រាបការការពារទៅក្នុង ជីវិតហិរញ្ញវត្ថុប្រចាំថ្ងៃរបស់អតិថិជន កិច្ចសហការទាំងនេះបានធ្វើឱ្យការធានារ៉ាប់រងកាន់តែងាយស្រួលទទួលបាន ឆ្លើយតបចំតម្រូវការ និងផ្តល់ភាពងាយស្រួលជាងមុន។ ដោយរួមបញ្ចូលគ្នារវាងវិសាលភាពទីផ្សារ និងការយល់ដឹងពីអតិថិជនរបស់ធនាគារ ជាមួយនឹងជំនាញកម្រិតស្តងសកលផ្នែកធានារ៉ាប់រងអាយុជីវិតរបស់ព្រូដិនសល ការធ្វើអាជីវកម្មប៊េងកាសួរេន (Bancassurance) នេះបានជួយពង្រឹងបរិយាបន្នហិរញ្ញវត្ថុ និងគាំទ្រដល់ភាពធន់រយៈពេលវែងរបស់អតិថិជន។ ដំណោះស្រាយធានារ៉ាប់រងដែលផ្តល់ជូនតាមរយៈកិច្ចសហការទាំងនេះ ត្រូវបានរចនាឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការស្នូល ទាំងលើការការពារអាយុជីវិតនិងសុខភាព ការសន្សំ និងការការពារហានិភ័យពាក់ព័ន្ធនឹងកម្ចី។

### ការពង្រឹងវិសាលភាព និងឥទ្ធិពលវិជ្ជមាន
នៅក្នុងឆ្នាំ ២០២៥ បណ្ដាញធានារ៉ាប់រងតាមប្រព័ន្ធធនាគារ នៅតែបន្តបង្ហាញពីលទ្ធផលការងារដ៏រឹងមាំ និងដើរតួនាទីជាយុទ្ធសាស្ត្រយ៉ាងសំខាន់សម្រាប់ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា)។

នៅក្នុងឆ្នាំ ២០២៥ ដដែលនេះ បណ្ដាញធានារ៉ាប់រងតាមប្រព័ន្ធធនាគារសម្រេចបានបណ្ណសន្យាថ្មីចំនួន ៣៦.៨៨៧ បណ្ណ។ គិតជាទំហំបុព្វលាភធានារ៉ាប់រង បណ្ដាញនេះទទួលបាន ១០,៤០ លានដុល្លារអាមេរិក ពីបុព្វលាភរ៉ាប់រងបង់ជាទៀងទាត់ (Regular Premium) និង ២,៤១ លានដុល្លារអាមេរិក ពីបុព្វលាភរ៉ាប់រងបង់តែម្តង (Single Premium) ដែលធ្វើឱ្យបុព្វលាភធានារ៉ាប់រងឆ្នាំដំបូងសរុប (Total First-Year Premium) កើនឡើងដល់ ១២,៨២ លានដុល្លារអាមេរិក។

លទ្ធផលទាំងនេះបានស្តែងឱ្យឃើញពីការរីកចម្រើនជាបន្តបន្ទាប់នៃសមត្ថភាពធានារ៉ាប់រងតាមប្រព័ន្ធធនាគារ និងប្រសិទ្ធភាពនៃបណ្ដាញចែកចាយផ្អែកលើដៃគូក្នុងការឈានទៅដល់មូលដ្ឋានអតិថិជនកាន់តែទូលំទូលាយ។

បន្ថែមលើលទ្ធផលការងារផ្នែកអាជីវកម្ម កិច្ចសហការជាដៃគូរបស់ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) បានរួមចំណែកដល់វឌ្ឍនភាពនេះ តាមរយៈការផ្តល់ជូននូវដំណោះស្រាយប្រកបដោយគុណភាពខ្ពស់ ស្របតាមអនុលោមភាព និងផ្តោតលើអតិថិជនជាចម្បង ដែលជួយកសាងទំនុកចិត្ត និងភាពជឿជាក់លើវិស័យធានារ៉ាប់រង។

### ការផ្តល់ជូនបទពិសោធន៍ដែលផ្តោតលើអតិថិជនជាចម្បង
ចំណុចស្នូលនៃវិធីសាស្ត្រអភិវឌ្ឍន៍ដៃគូរបស់ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) គឺការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការតម្កល់អតិថិជនជាចម្បង។

នៅគ្រប់ចំណុចទំនាក់ទំនងនៃសេវាធានារ៉ាប់រងតាមប្រព័ន្ធធនាគារ ក្រុមហ៊ុនបានអនុវត្តស្តង់ដារសេវាកម្មប្រកបដោយសន្ទិធិ និងការប្រតិបត្តិការយ៉ាងម៉ឺងម៉ាត់ ដើម្បីផ្តល់ជូននូវបទពិសោធន៍អតិថិជនដ៏រលូន និងគួរឱ្យទុកចិត្ត។ អតិថិជននឹងទទួលបានអត្ថប្រយោជន៍ពី៖

- ការទទួលបានដំណោះស្រាយធានារ៉ាប់រងយ៉ាងងាយស្រួល តាមរយៈសាខាធនាគារដៃគូនៅទូទាំងប្រទេស
- ការពិគ្រោះយោបល់ដ៏គួរឱ្យទុកចិត្ត ពីសំណាក់បុគ្គលិកលក់ និង ទីប្រឹក្សាធានារ៉ាប់រងជារូបវន្តបុគ្គលជួរមុខ ដែលទទួលបានការបណ្តុះបណ្តាលយ៉ាងជំនាញ
- សេវាកម្មចម្រុះរួមបញ្ចូលគ្នា ដែលឆ្លើយតបទាំងតម្រូវការធនាគារ និងតម្រូវការគាំពារហិរញ្ញវត្ថុ
- ការគាំទ្រជាបន្តបន្ទាប់ នៅគ្រប់ដំណាក់កាលនៃបណ្ណសន្យា ចាប់តាំងពីការចាប់ផ្តើមទិញ រហូតដល់ការទាមទារសំណង

តាមរយៈការបញ្ជ្រាបការធានារ៉ាប់រងទៅក្នុងបរិយាកាសហិរញ្ញវត្ថុដែលអតិថិជនមានភាពស្និទ្ធស្នាលរួចជាស្រេច ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) បានជួយឱ្យអតិថិជនអាចធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង និងមានភាពជឿជាក់ខ្ពស់ ព្រមទាំងជួយលើកកម្ពស់ការយល់ដឹង និងការទទួលយកដំណោះស្រាយគាំពារកាន់តែទូលំទូលាយ។

### ការកសាងឆ្ពោះទៅថ្ងៃអនាគត
សម្លឹងទៅថ្ងៃអនាគត ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) នៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការឈានទៅពង្រឹងសមត្ថភាពនៃបណ្ដាញចែកចាយតាមរយៈដៃគូរបស់ខ្លួន ដែលនេះជាផ្នែកមួយនៃយុទ្ធសាស្ត្រកំណើនរយៈពេលវែង។
ក្រុមហ៊ុននឹងបន្ត៖

- បង្កើនកិច្ចសហការឱ្យកាន់តែស៊ីជម្រៅ ជាមួយដៃគូធនាគារបច្ចុប្បន្ន
- ពង្រីកលទ្ធភាពទទួលបានដំណោះស្រាយគាំពារ ទៅកាន់ផ្នែកទីផ្សារដែលមិនទាន់ទទួលបានការបម្រើសេវាពេញលេញ (Underserved segments)
- លើកកម្ពស់ការរួមបញ្ចូលគ្នានៃប្រព័ន្ធឌីជីថល ដើម្បីផ្តល់ជូននូវបទពិសោធន៍ដ៏រលូន និងឆ្លើយតបចំតម្រូវការរបស់បុគ្គលម្នាក់ៗ
- រក្សាអភិបាលកិច្ចដ៏រឹងមាំ និងគោលការណ៍តម្កល់អតិថិជនជាចម្បង នៅគ្រប់បណ្ដាញចែកចាយទាំងអស់





# បណ្ដាញចែកចាយ



## បណ្ដាញចែកចាយតាមរយៈភ្នាក់ងារ
ការកសាងទំនុកចិត្ត តាមរយៈទីប្រឹក្សាហិរញ្ញវត្ថុអាជីព

បណ្ដាញភ្នាក់ងារលក់ នៅតែជាបណ្ដាញចែកចាយជាយុទ្ធសាស្ត្ររបស់ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជូននូវការណែនាំហិរញ្ញវត្ថុ និងដំណោះស្រាយគាំពារដែលឆ្លើយតប ចំតម្រូវការជាក់ស្តែងរបស់អតិថិជនម្នាក់ៗនៅទូទាំងប្រទេស។

តាមរយៈបណ្ដាញទីប្រឹក្សាធានារ៉ាប់រងអាយុជីវិតដែលមានអាជ្ញាប័ណ្ណប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) នៅតែបន្តធ្វើឱ្យគោលបំណងរបស់ខ្លួនក្លាយជាការពិត—ក្នុងការធានាថា បុគ្គលម្នាក់ៗ និងក្រុមគ្រួសារទទួលបាននូវការពិគ្រោះយោបល់ដ៏គួរឱ្យទុកចិត្ត ដំណោះស្រាយដែលរចនាឡើងជាពិសេស និងការគាំពារហិរញ្ញវត្ថុរយៈពេលវែង។

បណ្ដាញភ្នាក់ងារនេះ ជួយបង្កើនការផ្សារភ្ជាប់ទំនាក់ទំនងកាន់តែស៊ីជម្រៅជាមួយអតិថិជន ដោយផ្តោតលើការកសាងទំនាក់ទំនង ការអប់រំផ្នែកហិរញ្ញវត្ថុ និងការផ្តល់ការពិគ្រោះយោបល់ផ្អែកលើតម្រូវការជាក់ស្តែង។

### ការពង្រឹងសមត្ថភាព និងស្តង់ដារវិជ្ជាជីវៈ
ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) នៅតែបន្តវិនិយោគលើការអភិវឌ្ឍ និងការលើកកម្ពស់វិជ្ជាជីវៈនៃបណ្ដាញភ្នាក់ងារ របស់ខ្លួន ដើម្បីធានាបាននូវការផ្តល់សេវាកម្មជូនអតិថិជនប្រកបដោយគុណភាពខ្ពស់ និងភាពស៊ីសង្វាក់គ្នា។ នៅក្នុងកំឡុងឆ្នាំ ២០២៥ បណ្ដាញភ្នាក់ងារសម្រេចបានបណ្ណសន្យាថ្មីចំនួន ៤.០១៧ បណ្ណ ដោយបង្កើតបាន បុព្វលាភធានារ៉ាប់រងឆ្នាំដំបូងសរុបចំនួន ២,៧៧ លានដុល្លារអាមេរិក។

ក្រុមហ៊ុនបានផ្តល់ជូននូវកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍ច្បាស់លាស់ ដោយផ្តោតលើ៖

- ការរៀបចំផែនការហិរញ្ញវត្ថុ និងការពិគ្រោះយោបល់ផ្អែកលើតម្រូវការជាក់ស្តែង
- ចំណេះដឹងផ្នែកផលិតផល និងការរៀបចំរចនាដំណោះស្រាយ
- ស្តង់ដារសេវាកម្មអតិថិជន និងការអនុវត្តការលក់ប្រកបដោយក្រមសីលធម៌
- ឧបករណ៍ និងប្រព័ន្ធឌីជីថល ដើម្បីបង្កើនផលិតភាព និងការផ្សារភ្ជាប់ទំនាក់ទំនង

តាមរយៈគំនិតផ្តួចផ្តើមទាំងនេះ ទីប្រឹក្សាហិរញ្ញវត្ថុមិនត្រឹមតែទទួលបានចំណេះដឹងបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែថែម ទាំងទទួលបាននូវជំនាញ និងផ្នត់គំនិតដែលចាំបាច់ក្នុងការផ្តល់ជូននូវបទពិសោធន៍តម្កល់អតិថិជនជាចម្បង ស្រប តាមតម្លៃស្នូលរបស់ព្រូដិនសល។

បន្ថែមលើនេះ ក្របខ័ណ្ឌអភិបាលកិច្ច និងអនុលោមភាព ត្រូវបានបញ្ជ្រាបចូលទៅក្នុងគ្រប់បណ្ដាញភ្នាក់ងារ ដើម្បីធានាបាននូវការអនុវត្តការលក់ប្រកបដោយការទទួលខុសត្រូវ តម្លាភាព និងការគោរពតាមបទប្បញ្ញត្តិច្បាប់ ដែលជួយពង្រឹងបន្ថែមនូវទំនុកចិត្ត និងភាពជឿជាក់របស់អតិថិជន។

### ការលើកកម្ពស់បទពិសោធន៍អតិថិជន
គោលការណ៍គ្រឹះនៃបណ្ដាញភ្នាក់ងារ គឺការផ្តោតសំខាន់លើការផ្តល់ជូនបទពិសោធន៍ដ៏មានន័យ និងគួរឱ្យទុកចិត្តបំផុតសម្រាប់អតិថិជនគ្រប់រូប។ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) តែងតែធានាថា គ្រប់ចំណុចទំនាក់ទំនងជាមួយអតិថិជនសុទ្ធតែមានស្តង់ដារសេវាកម្មច្បាស់លាស់ និងស្របតាមគោលការណ៍ «អតិថិជនជាចម្បង»។ ផ្អែកលើការទទួលមតិកែលម្អ និងការបណ្តុះបណ្តាលសមត្ថភាពជាប្រចាំ បណ្ដាញភ្នាក់ងាររបស់យើងតែងតែអភិវឌ្ឍខ្លួន ដើម្បីចូលរួមប្រាស្រ័យទាក់ទង ផ្តល់ការប្រឹក្សា និងគាំទ្រអតិថិជនឱ្យកាន់តែមានប្រសិទ្ធភាព។

### ការកសាងបណ្ដាញភ្នាក់ងារដែលត្រៀមលក្ខណៈរួចជាស្រេចសម្រាប់ថ្ងៃអនាគត
សម្លឹងទៅថ្ងៃអនាគត ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) នៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់សមត្ថភាពបណ្ដាញភ្នាក់ងាររបស់ខ្លួន ដើម្បីគាំទ្រដល់កំណើនអាជីវកម្មប្រកបដោយចីរភាព។

អាទិភាពគន្លឹះៗរួមមាន៖

- លើកកម្ពស់វិជ្ជាជីវៈនៃបណ្ដាញភ្នាក់ងារ៖ តាមរយៈការជ្រើសរើសបុគ្គលិកដោយសម្រិតសម្រាំង និងការកសាងសមត្ថភាពយ៉ាងដិតដល់។
- បង្កើនផលិតភាពរបស់ភ្នាក់ងារលក់៖ តាមរយៈការជំរុញ និងគាំទ្រឱ្យពួកគាត់អភិវឌ្ឍខ្លួនទៅជាក្រុមភ្នាក់ងារឆ្នើមលំដាប់កំពូល (Top-tier performers)។
- គាំទ្រភ្នាក់ងារលក់ជាមួយបច្ចេកវិទ្យា៖ តាមរយៈការផ្តល់ជូននូវឧបករណ៍ឌីជីថលថ្មីៗ ដែលត្រូវបានអភិវឌ្ឍឱ្យកាន់តែទំនើប និងមានប្រសិទ្ធភាពជាងមុន។
- ពង្រឹងវប្បធម៌ការងារ៖ ដោយផ្តោតលើឥរិយាបថតម្កល់អតិថិជនជាចម្បង និងការប្រាស្រ័យទាក់ទងដែលផ្តោតលើលទ្ធផលជាក់ស្តែង។

តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ បណ្ដាញភ្នាក់ងារលក់នឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកវិសាលភាព នៃការទទួលបានការគាំពារផ្នែកហិរញ្ញវត្ថុ—ដើម្បីធានាថាគ្រួសារកម្ពុជាកាន់តែច្រើន នឹងទទួលបានអត្ថប្រយោជន៍ពីការពិគ្រោះយោបល់ដ៏គួរឱ្យទុកចិត្ត និងសន្តិសុខហិរញ្ញវត្ថុរយៈពេលវែង។

# អតិថិជន

## ផ្តោតលើអតិថិជនជាស្នូល នៃរាល់ការប្រាស្រ័យទាក់ទង

នៅក្រុមហ៊ុនព្រូដិនសល គោលការណ៍ដែលផ្តោតសំខាន់ថា “អតិថិជនជាទិសដៅរបស់ក្រុមហ៊ុន” មិនមែនជាគ្រាន់ តែជាអ្វីដែលចង់បានប៉ុណ្ណោះទេ ប៉ុន្តែបានបង្កប់នៅក្នុងរបៀបបែបបទនៃការដឹកនាំការ សម្រេចចិត្ត រចនាដំណើរអតិថិជន និងការផ្តល់បទពិសោធន៍។ រាល់អន្តរកម្មដែលយើងបង្កើត តែងតែផ្អែកលើការជួយឲ្យអតិថិជនមាន អារម្មណ៍ថាត្រូវបានការពារ យកចិត្តទុកដាក់ និងទទួលបានការគាំទ្រ រៀងរាល់ពេលវេលា ដែលពេលទាំងនោះពិត ជាសំខាន់បំផុត។ ចាប់ពីការទិញបណ្ណសន្យារ៉ាប់រងដំបូង ទន្ទឹមនឹងការបម្រើសេវាបន្តបន្ទាប់ រហូតដល់ការទាមទារ សំណង និងការទូទាត់អត្ថប្រយោជន៍ពេលចុងគ្រានៃបណ្ណសន្យារ៉ាប់រង យើងអនុវត្តនូវស្តង់ដាសេវាកម្មដែលមាន ភាពស្មើគ្នា និងការអនុវត្តយ៉ាងមានវិន័យ ដើម្បីធានាបាននូវបទពិសោធន៍ដែលអាចទុកចិត្តបាន និងមានគុណភាព ខ្ពស់នៅគ្រប់ផ្នែកទាំងអស់។

វិធីសាស្ត្រដឹកនាំដោយអតិថិជននេះ បង្កើនទំនុកចិត្ត បង្កើតភាពស្មោះត្រង់រយៈពេលវែង និងនាំមកនូវ ការកែលម្អជាក់ស្តែងក្នុងការពេញចិត្តរបស់អតិថិជន។ ដោយផ្អែកលើទស្សនវិស័យនៃដំណាក់កាលនីមួយៗនៃជីវិត យើងមិនត្រឹមតែសម្លឹងមើលម្ចាស់បណ្ណសន្យារ៉ាប់រងនាពេលបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ាន់ប្រមាណពីតម្រូវការគាំពារនាពេលអនាគតផងដែរ—ដែលនេះជាការអនុវត្តតាមគោលបំណងរបស់យើងក្នុងការការពារអនាគត ស្របតាមការប្តេជ្ញាចិត្តរបស់យើង៖ ៖ “សម្រាប់ជីវិតគ្រប់រូប សម្រាប់អនាគតគ្រប់យ៉ាង”។

តាមរយៈការស្តាប់មតិយោបល់របស់អតិថិជនយ៉ាងសកម្ម តាមរយៈប្រព័ន្ធទទួលមតិកែលម្អច្បាស់លាស់ និងការកែលម្អប្រតិបត្តិការរបស់យើងជាបន្តបន្ទាប់ យើងបានពង្រឹងគុណភាព វិសាលភាព និងភាពស៊ីសង្វាក់គ្នានៃការផ្សារភ្ជាប់ទំនាក់ទំនងជាមួយអតិថិជននៅទូទាំងប្រទេស។ វិធីសាស្ត្រដែលដឹកនាំដោយតម្រូវការអតិថិជនជាចម្បងនេះ ជួយជំរុញទំនុកចិត្តឱ្យកាន់តែស៊ីជម្រៅ បង្កើតភាពស្មោះត្រង់រយៈពេលវែង និងនាំមកនូវការកែលម្អជាក់ស្តែងនៃកម្រិតពេញចិត្តរបស់អតិថិជន។ ដោយផ្អែកលើទស្សនវិស័យនៃដំណាក់កាលនីមួយៗនៃជីវិត យើងមិនត្រឹមតែសម្លឹងមើលម្ចាស់បណ្ណសន្យានាពេលបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ាន់ប្រមាណពីតម្រូវការគាំពារនាពេលអនាគតផងដែរ—ដែលនេះជាការអនុវត្តតាមគោលបំណងរបស់យើងក្នុងការការពារអនាគត ស្របតាមការប្តេជ្ញាចិត្តរបស់យើង៖ «ដើម្បីគ្រប់ជីវិត ដើម្បីគ្រប់អនាគត»។

**ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា)** បានផ្តល់ការគាំពារដល់អតិថិជនជិតកន្លះលាននាក់ និងបានអនុម័តសំណងធានារ៉ាប់រងសរុបប្រមាណ **៣៣,៤ លានដុល្លារអាមេរិក** គិតត្រឹមខែមេសា ឆ្នាំ ២០២៦ នេះ ដើម្បីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុបានទាន់ពេលវេលាដល់ក្រុមគ្រួសារទាំងឡាយ ក្នុងអំឡុងពេលនៃរបត់ជីវិតដែលបានគ្រោងទុក និងព្រឹត្តិការណ៍ជីវិតដែលកើតឡើងមិនរំពឹងទុក។

### *បទពិសោធន៍អតិថិជន – ការទាមទារសំណង៖ សេង ចាន់ណា*

*“ដំបូងឡើយ ក្រុមការងារ ព្រូដិនសល បានណែនាំឲ្យយើងទិញផែនការធានារ៉ាប់រងជីវិត។ បន្ទាប់ពីពិភាក្សាជាមួយស្វាមី ខ្ញុំបានយល់ថាវានឹងផ្តល់សុវត្ថិភាពអនាគតដល់កូនៗរបស់យើង ដូច្នេះខ្ញុំបានសម្រេចចិត្តទិញផែនការរបស់ព្រូដិនសល l ឈ្មោះ PRUអនាគតកូនខ្ញុំ។ ទោះបីអ្នកដទៃសួរថាហេតុអ្វីខ្ញុំត្រូវចំណាយលើធានារ៉ាប់រងក៏ដោយ ស្វាមីខ្ញុំបានរំលឹកឲ្យខ្ញុំផ្តោតលើការពាររយៈពេលវែងសម្រាប់គ្រួសារយើង។*

*នៅឆ្នាំ ២០២៤ ស្វាមីខ្ញុំត្រូវបានវិនិច្ឆ័យថាមានមហារីកដំណាក់កាលទី ៤។ គាត់បានប្រាប់ខ្ញុំថា យើងបានរៀបចំសម្រាប់អនាគតរួចហើយជាមួយ ព្រូដិនសល ហើយឲ្យខ្ញុំទាក់ទងពួកគេ ប្រសិនបើមានអ្វីកើតឡើងចំពោះគាត់។ បន្ទាប់ពីការព្យាបាល គាត់បានទទួលមរណភាព។ ក្នុងអំឡុងពេលដ៏លំបាកនេះ ក្រុមការងារ ព្រូដិនសល បាននៅក្បែរខ្ញុំ ជួយគាំទ្រខ្ញុំក្នុងការរៀបចំឯកសារដែលត្រូវការ និងធ្វើឲ្យខ្ញុំបានដឹងព័ត៌មានគ្រប់ជំហាននៃដំណើរការទាមទារសំណង។”*



**បទពិសោធន៍នេះបង្ហាញពីការប្តេជ្ញាចិត្តរបស់យើងចំពោះការយល់ចិត្ត ភាពច្បាស់លាស់ និងការគាំទ្រដោយមិនរអាក់រអួល ធានាថា អតិថិជនមិនត្រូវទុកឲ្យនៅឯកាឡើយ នៅពេលដែលពួកគេប្រឈមមុខនឹងពេលវេលាដ៏លំបាកបំផុត។**

### *បទពិសោធន៍អតិថិជន – ការប្តេជ្ញាបំពេញតាមសន្យា ប្រកបដោយនិរន្តរភាព និងភាពរលូន*



*“ខ្ញុំគិតថាដំណើរការទទួលអត្ថប្រយោជន៍ពេលបញ្ចប់កិច្ចសន្យា នឹងចំណាយពេលយូរ ប៉ុន្តែខ្ញុំទុកចិត្តថាក្រុមហ៊ុនដូចជា ព្រូដិនសល នឹងគោរពតាមការប្តេជ្ញារបស់ខ្លួន។ ពេលផែនការរបស់ខ្ញុំដល់កាលបរិច្ឆេទបញ្ចប់ អត្ថប្រយោជន៍ត្រូវបានដាក់ចូលគណនីធនាគាររបស់ខ្ញុំដោយផ្ទាល់ ដោយស្វ័យប្រវត្តិ និងមិនចាំបាច់មានជំហានស្មុគស្មាញ។ គ្មានការងារឯកសារ គ្មានការពន្យារពេល ហើយគ្មានភាពតានតឹង។ ព្រូដិនសលបានអនុវត្តតាមអ្វីដែលបានសន្យា។”*

**បទពិសោធន៍ដែលរលូននេះ បញ្ជាក់ឲ្យឃើញថា យើងផ្តោតលើភាពអាចទុកចិត្តបាន ភាពសាមញ្ញ និងការអនុវត្តតាមការប្តេជ្ញារបស់យើង។**





### ការកសាងទំនុកចិត្តចាប់ពីការជួបគ្នាដំបូង៖ ដំណាក់កាលទទួលបានអតិថិជន

នៅក្នុងដំណាក់កាលស្វែងរក និងទទួលបានអតិថិជន យើងផ្តោតសំខាន់លើការកសាងភាពជឿជាក់ តាមរយៈការផ្តល់ការពិគ្រោះយោបល់ប្រកបដោយវិជ្ជាជីវៈ ភាពច្បាស់លាស់ និងអភិបាលកិច្ចដ៏ត្រឹមត្រូវ។ អតិថិជននឹងទទួលបានការជួយជ្រោមជ្រែងពីភ្នាក់ងារលក់ និងទីប្រឹក្សាធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណ និងឆ្លងកាត់ការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ ដើម្បីជួយណែនាំពួកគាត់ក្នុងការវាយតម្លៃពីលទ្ធភាពហិរញ្ញវត្ថុ និងភាពសមស្របនៃដំណោះស្រាយនីមួយៗ។ បន្ថែមលើនេះ ការហៅទូរស័ព្ទទៅកាន់អតិថិជនថ្មីដើម្បីស្វាគមន៍ (Welcome Call) យ៉ាងសកម្ម នឹងជួយបញ្ជាក់បន្ថែមពីការយល់ដឹង ឆ្លើយតបរាល់ចម្ងល់នានា និងធានាថាអតិថិជនចាប់ផ្តើមដំណើរជីវិតជាមួយយើងដោយភាពច្បាស់លាស់ និងក្តីទំនុកចិត្តខ្ពស់។

### ទីប្រឹក្សាធានារ៉ាប់រងដ៏គួរឱ្យទុកចិត្ត

អតិថិជនអាចទទួលបានការពិគ្រោះយោបល់តាមរយៈក្រុមការងារលក់របស់ធនាគារដៃគូ ឬបណ្តាញភ្នាក់ងារលក់ទូទាំងប្រទេសរបស់យើង។ ទីប្រឹក្សាទាំងអស់សុទ្ធតែមានអាជ្ញាប័ណ្ណត្រឹមត្រូវ និងទទួលបានការគាំទ្រពីប្រព័ន្ធអភិបាលកិច្ចដ៏រឹងមាំ កម្មវិធីបណ្តុះបណ្តាលច្បាស់លាស់ និងស្តង់ដារលក់ដ៏តឹងរ៉ឹង ដើម្បីធានាថាការផ្តល់យោបល់គឺប្រកបដោយក្រមសីលធម៌ ឆ្លើយតបផ្អែកលើតម្រូវការជាក់ស្តែង និងផ្តល់ជូនដោយស្មារតីតម្កល់អតិថិជនជាចម្បង។

> ការពិគ្រោះយោបល់ផ្អែកលើតម្រូវការជាក់ស្តែង៖ យើងធ្វើការវិភាគលើតម្រូវការហិរញ្ញវត្ថុនៅពេលអតិថិជនសម្រេចចិត្តទិញ ដើម្បីស្វែងយល់ពីតម្រូវការការពារ លទ្ធភាពបង់ប្រាក់ និងចន្លោះខ្វះខាតនៃការការពាររបស់ពួកគាត់។ វិធីសាស្ត្រនេះជួយធានាថា រាល់ការណែនាំគឺពិតជាសមស្រប មាននិរន្តរភាព និងស្របតាមការធ្វើសេចក្តីសម្រេចចិត្តរយៈពេលវែងប្រកបដោយការយល់ដឹងច្បាស់លាស់។

> ការបណ្តុះបណ្តាល និងការត្រួតពិនិត្យផ្តោតលើគុណភាពជាចម្បង ៖ ការផ្តល់ការប្រឹក្សាប្រកបដោយការទទួលខុសត្រូវ ត្រូវបានពង្រឹងបន្ថែមតាមរយៈការបណ្តុះបណ្តាលជាបន្តបន្ទាប់ ការតាមដានការអនុវត្តការលក់ និងការផ្ទៀងផ្ទាត់ក្រោយការលក់ ដូចជាការហៅទូរស័ព្ទស្វាគមន៍អតិថិជនថ្មីជាដើម។ វិធានការការពារទាំងនេះ ជួយបញ្ជាក់ពីការយល់ដឹងរបស់អតិថិជន ប្រមូលមតិកែលម្អ និងជួយដោះស្រាយក្តីបារម្ភនានាបានទាន់ពេលវេលា ដែលជួយពង្រឹងទំនុកចិត្តចាប់តាំងពីជំហានដំបូង។

### ការចាប់ផ្តើមបណ្ណសន្យារ៉ាប់រងបែបឌីជីថល

ព័ត៌មានរបស់អតិថិជនត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធឌីជីថលភ្លាមៗនៅពេលលក់ ដោយកាត់បន្ថយការប្រើប្រាស់ក្រដាសស្នាម។ ដំណើរការនេះជួយកាត់បន្ថយកំហុសឆ្គងដោយផ្ទាល់ដៃ ពង្រឹងសុវត្ថិភាពទិន្នន័យ និងធានាបាននូវបទពិសោធន៍ចាប់ផ្តើមបណ្ណសន្យារ៉ាប់រងដ៏រលូន និងមានប្រសិទ្ធភាពខ្ពស់។

### សេវាកម្មបន្ត និងការទាមទារសំណង៖ ការយកចិត្តទុកដាក់ដែលបន្តទៅមុខ

ពេញមួយដំណើរសេវាកម្មអតិថិជន និងការទាមទារសំណង យើងធ្វើឲ្យមានតុល្យភាពរវាងការយកចិត្តទុកដាក់ ពីមនុស្ស និងភាពងាយស្រួលតាមឌីជីថល។ បុគ្គលិកសេវាអតិថិជនរបស់យើងផ្តល់ការសម្របសម្រួលដែលមានភាពផ្ទាល់ខ្លួនទៅតាមតម្រូវការរបស់អតិថិជន និងយល់ចិត្ត ខណៈដែលមានបណ្តាញទំនាក់ទំនងច្រើនដែលបាន សម្រួល ធានាការឆ្លើយតបតាមពេលវេលា និងការទំនាក់ទំនងច្បាស់លាស់។ ពេលតម្រូវការអតិថិជនផ្លាស់ប្តូរ យើងបន្តពង្រីកសមត្ថភាពឌីជីថល និងសំណើដែលមានភាពខុសគ្នា ដើម្បីគាំទ្រអតិថិជននៅគ្រប់ដំណាក់កាល ជីវិត។

### ការថែទាំពីភ្នាក់ងារ ដែលបង្កើតឡើងនៅលើទំនុកចិត្ត

បណ្តាញភ្នាក់ងារលក់ទូទាំងប្រទេស និងទីប្រឹក្សារបស់ធនាគារដៃគូរបស់យើងផ្តល់ជូននូវការថែទាំដែលដឹកនាំដោយការកសាងទំនាក់ទំនង—ដោយដើរតួជាអ្នកស្តាប់មុនគេ រួចទើបផ្តល់ការណែនាំដ៏ច្បាស់លាស់ និងប្រកបដោយការទទួលខុសត្រូវ។ ជាមួយនឹងផ្នត់គំនិតប្រកបដោយក្រមសីលធម៌ និងតម្កល់អតិថិជនជាចម្បង ភ្នាក់ងាររបស់យើងនឹងនៅក្បែរគាំទ្រអតិថិជនតាំងពីដើមរហូតដល់ចប់ ដើម្បីធានាថាពួកគាត់មានអារម្មណ៍ថាទទួលបានការយល់ចិត្ត ការគោរព និងការ គាំទ្រពេញមួយដំណើរការការពារ។

### សេវាស្វ័យប្រវត្តិបែបឌីជីថល

តាមរយៈ PRUServices និង Telegram Bot របស់យើង អតិថិជនអាចប្រើប្រាស់សេវាកម្មនានាបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ មុខងារទាំងនេះអនុញ្ញាតឱ្យអតិថិជនពិនិត្យមើលព័ត៌មានបណ្ណសន្យា ធ្វើបច្ចុប្បន្នភាពព័ត៌មានផ្ទាល់ខ្លួន បង់បុព្វលាភធានារ៉ាប់រង និងដាក់ពាក្យទាមទារសំណង—ដែលផ្តល់នូវភាពងាយស្រួល និងការគ្រប់គ្រងសេវាកម្មដោយផ្ទាល់នៅក្នុងដៃរបស់អតិថិជន។

### ការជជែកផ្ទាល់ និងការគាំទ្រផ្នែកបម្រើសេវាអតិថិជន

សម្រាប់ការគាំទ្រភ្លាមៗទាន់ចិត្ត អតិថិជនអាចទាក់ទងមកព្រូដិនសល តាមរយៈគណនីផ្លូវការ Facebook Messenger និង Telegram Live Chat ដើម្បីទទួលបានការឆ្លើយតបពីរផ្លូវយ៉ាងរហ័ស ព្រមទាំងការភ្ជាប់ទៅកាន់បុគ្គលិកផ្នែកសេវាកម្មដោយរលូន នៅពេលដែលត្រូវការការគាំទ្រលក្ខណៈបុគ្គល។

ផ្នែកបម្រើសេវាអតិថិជន របស់យើង ផ្តល់ជូននូវការគាំទ្រដ៏គួរឱ្យទុកចិត្តពីសំណាក់បុគ្គលិកផ្ទាល់ តាមរយៈលេខទូរស័ព្ទឥតគិតថ្លៃ ខ្សែទូរស័ព្ទផ្ទាល់ និងអ៊ីមែល។ ក្នុងករណីដែលបញ្ហាចាំបាច់ត្រូវពិនិត្យបន្ថែម ក្រុមការងាររបស់យើងនឹងទទួលខុសត្រូវទាំងស្រុងក្នុងការតាមដាន និងផ្តល់ព័ត៌មានបច្ចុប្បន្នភាពយ៉ាងច្បាស់លាស់ ដើម្បីធានាថាអតិថិជនមានអារម្មណ៍ថាទទួលបានការយកចិត្តទុកដាក់ និងការគាំទ្រនៅគ្រប់ជំហាន ។

# ព័ត៌មានអំពី
# អភិបាលកិច្ចសាជីវកម្ម

ទំព័រ


1. រចនាសម្ព័ន្ធក្រុមហ៊ុន 22

   ក. ក្រុមប្រឹក្សាភិបាល 26

   ខ. គណៈគ្រប់គ្រង 28

2. របាយការណ៍របស់គណៈកម្មាធិការ 30

   ក. គណៈកម្មាធិការសវនកម្ម 30

   ខ. គណៈកម្មាធិការវិនិយោគ 32

   គ. គណៈកម្មាធិការហានិភ័យ 33

3. របាយការណ៍អំពីអភិបាលកិច្ចសាជីវកម្ម 34




ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | **ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម** | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

# រចនាសម្ព័ន្ធក្រុមហ៊ុន



# រចនាសម្ព័ន្ធក្រុមហ៊ុន

## ម្ចាស់ភាគហ៊ុន

ក្រុមហ៊ុនបានរៀបចំមហាសន្និបាតប្រចាំឆ្នាំរបស់ម្ចាស់ភាគហ៊ុន ដោយបានអនុវត្តស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងលក្ខន្តិកៈរបស់ក្រុមហ៊ុន។ មហាសន្និបាតប្រចាំឆ្នាំរបស់ក្រុមហ៊ុន ត្រូវតែរៀបចំមិនឲ្យលើសពី ១៥ ខែ បន្ទាប់ពីមហាសន្និបាតប្រចាំឆ្នាំមុន។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសតាំងដោយម្ចាស់ភាគហ៊ុន សម្រាប់អាណត្តិរយៈពេល ៣ (បី) ឆ្នាំ និងមានភារៈកិច្ចផ្តល់នូវការដឹកនាំ និងការត្រួតពិនិត្យរួម ដើម្បីធានាប្រសិទ្ធិភាពរយៈពេលវែង ចីរភាព និងស្តង់ដារគ្រប់គ្រងរបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាល ដំណើរការប្រព្រឹត្តស្របទៅតាមបទដ្ឋានគោលការណ៍ផ្ទៃក្នុង លក្ខន្តិកៈក្រុមហ៊ុន និងបទបញ្ញាត្តិដែលមានជាធរមាន។ ភារៈកិច្ចសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាលរួមមាន៖ ការអនុម័តគោលការណ៍ផ្ទៃក្នុងសំខាន់ៗ ការកំណត់លក្ខខណ្ឌ គុណវឌ្ឍិ និងនីតិវិធីក្នុងការជ្រើសរើសសមាសភាពអភិបាល ព្រមទាំងការពិនិត្យវាយតម្លៃទៅលើសមាសភាព និងការអនុវត្តកិច្ចការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងប្រតិបត្តិ។ ក្រុមប្រឹក្សាភិបាល ក៏ទទួលខុសត្រូវលើការបង្កើតរចនាសម្ព័ន្ធអភិបាលកិច្ចក្រុមហ៊ុនដ៏រឹងមាំ ដើម្បីលើកកម្ពស់វិជ្ជាជីវៈ សុចរិតភាព និងតម្លាភាព ក្នុងពេលធានាឲ្យបាននូវការអនុលោមភាពស្របទៅតាមបទប្បញ្ញត្តិគតិយុត្តិទាំងឡាយដែលពាក់ព័ន្ធ។ ក្រុមប្រឹក្សាភិបាល បានដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងប្រតិបត្តិការសំខាន់ៗ ព្រមទាំងការពិនិត្យឡើងវិញជាប្រចាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

លើសពីនេះទៀត ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យសវនកម្មផ្ទៃក្នុង ដែលកំណត់កម្រិតទទួលយកហានិភ័យរបស់ក្រុមហ៊ុន និងធានាឱ្យមានការបង្ហាញព័ត៌មានដល់និយ័តករ និងស្ថាប័នពាក់ព័ន្ធឲ្យបានទាន់ពេលវេលា។ ដើម្បីពង្រឹងអភិបាលកិច្ច និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពខ្ពស់ ក្រុមប្រឹក្សាភិបាលបានប្រគល់សិទ្ធិមួយចំនួនទៅកាន់គណៈកម្មាធិការ ឯកទេសផ្សេងៗ រួមមាន គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការវិនិយោគ និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ព្រមទាំងគណៈគ្រប់គ្រងប្រតិបត្តិ ដោយនៅតែបន្តទទួលខុសត្រូវលើការពិនិត្យសម្រេច និងធានាឱ្យបានថាសមាសភាពគ្រប់គ្រងបានបំពេញកិច្ចការសមស្របទៅតាមជំនាញ និងឯករាជ្យភាពរបស់សមាជិកនីមួយៗ។

ផ្អែកតាមរយៈសកម្មភាពទាំងនេះ ក្រុមប្រឹក្សាភិបាលមានគោលបំណងការពារតម្លៃរបស់ម្ចាស់ភាគហ៊ុន គាំទ្រការរីកចម្រើនប្រកបដោយចីរភាព និងរក្សាទំនុកចិត្តពីភាគីពាក់ព័ន្ធទាំងអស់។ ក្រុមប្រឹក្សាភិបាល ក៏បានបំពេញភារៈកិច្ចលើការកំណត់ទិសដៅយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន អនុម័តយុទ្ធសាស្ត្រ និងផែនការប្រចាំឆ្នាំ ព្រមទាំងត្រួតពិនិត្យលទ្ធផលសមិទ្ធផល ដើម្បីធានាប្រតិបត្តិការដោយប្រុងប្រយ័ត្ន និងស្របតាមតម្លៃ និងគោលបំណងរបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលប្រជុំចំនួន ៤ (បួន) ដងក្នុងមួយឆ្នាំ ស្របទៅតាមបទបញ្ញត្តិច្បាប់ តាមរយៈប្រព័ន្ធអនឡាញ ឬ ប្រជុំដោយផ្ទាល់ យោងទៅតាមកាលវិភាគដែលបានកំណត់ក្នុងត្រីមាសនីមួយៗ។

# ក្រុមប្រឹក្សាភិបាល



**លោកបណ្ឌិត ម៉ី កល្យាណ** គឺជាអភិបាលឯករាជ្យ និងមិនប្រតិបត្តិនៃក្រុមហ៊ុន ចាប់តាំងពី ២០១៤។ លោក បណ្ឌិត ម៉ី កល្យាណ មានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ច ការផ្តល់យោបល់ផ្នែកគោលនយោបាយសាធារណៈ និងការអភិវឌ្ឍន៍ហិរញ្ញវត្ថុអន្តរជាតិ។ លោកបានបម្រើការងារជា ទីប្រឹក្សាដល់រាជរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីឆ្នាំ ២០០៨ ដោយផ្តល់យោបល់ដល់ស្ថាប័នជាតិសំខាន់ៗរួមមាន ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ធនាគារអភិវឌ្ឍន៍ជនបទ និងគណៈកម្មការជាតិ "ភូមិមួយ ផលិតផលមួយ"។ តាមរយៈតួនាទីទាំងនេះ លោកបានចូលរួមចំណែកក្នុងការរៀបចំផែនការសេដ្ឋកិច្ចជាតិ និងការរៀបចំគោលនយោបាយនៅកម្រិតគណៈរដ្ឋមន្ត្រី។

**លោកបណ្ឌិត ម៉ី កល្យាណ** ក៏បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ថ្នាក់អនុបណ្ឌិត និងថ្នាក់បរិញ្ញាបត្រ ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច ពីសាកលវិទ្យាល័យ Kobe ប្រទេសជប៉ុន។

**លោកបណ្ឌិត ម៉ី កល្យាណ**

អភិបាលឯករាជ្យ និងមិនប្រតិបត្តិ



**លោកស្រីបណ្ឌិត សូ ផនណារី** គឺជាអភិបាលឯករាជ្យ និងមិនប្រតិបត្តិ និងជាប្រធាននៃគណៈកម្មាធិការ វិនិយោគនៃក្រុមហ៊ុន ចាប់តាំងពីឆ្នាំ ២០២៤ មក ដោយលោកស្រីបណ្ឌិត បានចូលរួមចំណែកក្នុងការត្រួតពិនិត្យឯករាជ្យលើអភិបាលកិច្ច ទិសដៅយុទ្ធសាស្ត្រ និងទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល។ លោកស្រីបណ្ឌិត ត្រូវបានទទួលស្គាល់ថា មានឯករាជ្យភាព ស្របតាមតម្រូវការបទបញ្ញត្តិច្បាប់ និងលក្ខខណ្ឌនៃអភិបាលកិច្ចដែលពាក់ព័ន្ធ និងបានចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

ជាមួយនឹងអាជីពដ៏លេចធ្លោក្នុងតួនាទីជាអនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិការប្រតិបត្តិប្រតិបត្តិការរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ **លោកស្រីបណ្ឌិត សូ ផនណារី** ក៏បានដើរតួនាទីសំខាន់ៗលើការពង្រឹងការអភិវឌ្ឍន៍ និងប្រតិបត្តិការរបស់ធនាគារ មុនឈានដល់ការចូលនិវត្តន៍តាមផែនការ ដោយនាំមកនូវជំនាញ និងបទពិសោធន៍ភាពដឹកនាំដ៏សម្បូរបែបមកកាន់តួនាទីបច្ចុប្បន្នរបស់លោកស្រីបណ្ឌិត។

**លោកស្រីបណ្ឌិត សូ ផនណារី**

អភិបាលឯករាជ្យ និងមិនប្រតិបត្តិ



**លោក ហួរ វរៈបុត្ត** ជាអភិបាលឯករាជ្យ និងមិនប្រតិបត្តិ របស់ក្រុមហ៊ុនចាប់តាំងពីឆ្នាំ ២០២៣ ដោយលោកបាននាំមកនូវបទពិសោធន៍ជាង ២៥ ឆ្នាំ ក្នុងវិស័យធនាគារ ហិរញ្ញវត្ថុ និងការគ្រប់គ្រងការវិនិយោគ នៅប្រទេសអឺរ៉ុប និងតំបន់អាស៊ីប៉ាស៊ីហ្វិក។ លោកក៏ជាសាស្ត្រាចារ្យផ្នែកហិរញ្ញវត្ថុនៅវិទ្យាស្ថាន ខេមអេដ ("CamEd Business School") និងជាទីប្រឹក្សាផ្តល់យោបល់ដល់គណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ និងវិទ្យាស្ថានពិភពលោកសម្រាប់កំណើនបៃតង។ បច្ចុប្បន្នលោកក៏ជាអនុប្រធានគណៈកម្មាធិការធុរកិច្ចបៃតងនៃសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំកម្ពុជា។ ប្រវត្តិការងាររបស់លោកក៏រួមមាននូវតួនាទីជាន់ខ្ពស់នៅស្ថាប័នហិរញ្ញវត្ថុ Credit Suisse នៃប្រទេសស្វីស ក្រុមហ៊ុនគ្រប់គ្រង Aberdeen Asset Management, ក្រុមហ៊ុនធានារ៉ាប់រង AXA នៃប្រទេសបារាំង និងធនាគារ Banque Hottinguer។

**លោក វរៈបុត្ត** ក៏បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតពីសាកលវិទ្យាល័យ Chicago Booth School of Business និងជាសមាជិកដែលបានបញ្ជាក់វិជ្ជាជីវៈជាអ្នកវិភាគហិរញ្ញវត្ថុនៃអឺរ៉ុប ("Certified European Financial Analyst")។ ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការសវនកម្ម លោកផ្តល់ការនូវការវិនិច្ឆ័យឯករាជ្យ និងទស្សនវិស័យយុទ្ធសាស្ត្រដល់ក្រុមហ៊ុន ផងដែរ។

**លោក ហួរ វរៈបុត្ត**

អភិបាលឯករាជ្យ និងមិនប្រតិបត្តិ





# ក្រុមប្រឹក្សាភិបាល



**លោកស្រី Ng Sim Kheng** គឺជាអភិបាលមិនប្រតិបត្តិរបស់ក្រុមហ៊ុន ចាប់តាំងពីឆ្នាំ ២០២៤ មក។ លោកស្រីជាអ្នកជំនាញផ្នែកហិរញ្ញវត្ថុ និងធានារ៉ាប់រង ដែលមានបទពិសោធន៍ប្រមាណ ៣០ ឆ្នាំ ក្នុងប្រទេសអូស្ត្រាលី ហុងកុង ចិន និងតំបន់អាស៊ាន។ ក្នុងរយៈពេលជាង ២៥ ឆ្នាំ លោកស្រីបានបម្រើការងារ និងកាន់តួនាទីជាន់ខ្ពស់ជាច្រើន ដូចជា នាយិកាផ្នែកហិរញ្ញវត្ថុ អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង អ្នកត្រួតពិនិត្យក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងទូទៅថ្នាក់តំបន់។ បច្ចុប្បន្នលោកស្រី មានតួនាទីជា នាយិកាផ្នែកពិនិត្យគ្រប់គ្រងហិរញ្ញវត្ថុនៃក្រុមហ៊ុនមេ សមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Prudential Services Asia និងក្រុមហ៊ុន Prudential Services Singapore និងធ្លាប់កាន់តួនាទីជានាយិកាផ្នែកហិរញ្ញវត្ថុនៃក្រុមហ៊ុន Prudential Assurance Malaysia Berhad។ លោកស្រីបានចូលរួមចំណែកក្នុងអភិបាលកិច្ចក្រុមហ៊ុន តាមរយៈការត្រួតពិនិត្យ និងផ្តល់យោបល់ដល់ក្រុមប្រឹក្សាភិបាលផងដែរ។

**លោកស្រី Ng Sim Kheng** បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត និងបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ (ជ័យលាភីកិត្តិយសទីមួយ) ពីសាកលវិទ្យាល័យ Melbourne។ លោកស្រី ជាសមាជិក Fellow នៃសមាគមអ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង និងជាសមាជិកគណនេយ្យករជំនាញនៃប្រទេសអូស្ត្រាលី។ លោកស្រី ក៏ជាសាស្ត្រាចារ្យរង (Adjunct Professor) នៅសាកលវិទ្យាល័យ The Chinese University of Hong Kong ព្រមទាំងកាន់តួនាទីជាទីប្រឹក្សាវិជ្ជាជីវៈ ដែលទាំងអស់នេះបានឆ្លុះបញ្ចាំងពីការចូលរួមចំណែកយូរអង្វែងរបស់គាត់លើការគ្រប់គ្រងអភិបាលកិច្ច និងវិជ្ជាជីវៈរបស់អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង។

**លោកស្រី Ng Sim Kheng**

អភិបាលមិនប្រតិបត្តិ



**លោក ពន្លឺ តុលា** គឺជាថ្នាក់ដឹកនាំអាជីវកម្មដ៏មានបទពិសោធន៍ និងជាបុគ្គលឈានមុខគេមួយរូបដែលត្រូវបានទទួលស្គាល់ក្នុងវិស័យធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា តាមរយៈស្នាដៃលេចធ្លោក្នុងការជំរុញកំណើន ការច្នៃប្រឌិត និងការអភិវឌ្ឍទីផ្សារ។ បច្ចុប្បន្ន លោកកាន់តំណែងជា នាយកប្រតិបត្តិ ដែលទទួលបន្ទុកដឹកនាំលើប្រតិបត្តិការអាជីវកម្ម និងយុទ្ធសាស្ត្រនៅទូទាំងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។

**លោក តុលា** ជាអ្នកដឹកនាំផ្ទាល់លើការរីកចម្រើនផ្នែកយុទ្ធសាស្ត្រ និងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ហើយលោកក៏ជាបុគ្គលសំខាន់ក្នុងការរួមចំណែករៀបចំរចនាសម្ព័ន្ធនៃវិស័យនេះឱ្យមានការរីកចម្រើន។ ក្នុងដំណើរផ្លាស់ប្តូរនៃបទពិសោធន៍ដឹកនាំអស់រយៈពេលជាច្រើនទសវត្សរ៍ លោកបានកាន់តំណែងជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើននៅក្នុងស្ថាប័នធានារ៉ាប់រងអាយុជីវិតឈានមុខគេនៅកម្ពុជា។

**លោក តុលា** បានបញ្ចប់ការសិក្សាថ្នាក់គ្រប់គ្រងអាជីវកម្មកម្រិតខ្ពស់ពីសាកលវិទ្យាល័យ Auckland និងសាកលវិទ្យាល័យ Massey នៃប្រទេសនូវែលសេឡង់។

**លោក ពន្លឺ តុលា**

អភិបាលប្រតិបត្តិ

# រចនាសម្ព័ន្ធក្រុមហ៊ុន
# គណៈគ្រប់គ្រងប្រតិបត្តិ

គណៈគ្រប់គ្រងប្រតិបត្តិ គឺជាគណៈកម្មាធិការគ្រប់គ្រងមួយ (**«គណៈកម្មាធិការប្រតិបត្តិ»**) ដែលត្រូវបានបង្កើតឡើង ដោយក្រុមប្រឹក្សាភិបាល ដើម្បីគាំទ្រដល់អភិបាលកិច្ចសាជីវកម្មប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងក្រុមហ៊ុន ឱ្យមានប្រសិទ្ធភាពខ្ពស់។ គណៈកម្មាធិការប្រតិបត្តិ បំពេញការងារក្រោមសិទ្ធិអំណាចដែលបានផ្ទេរពី ក្រុមប្រឹក្សាភិបាល និងស្របតាមលក្ខខណ្ឌការងារ ដែលបានអនុម័ត។ គណៈកម្មាធិការនេះ ដើរតួជាវេទិកាប្រតិបត្តិ ឈានមុខគេ ដែលមានភារកិច្ចត្រួតពិនិត្យលើការអនុវត្តយុទ្ធសាស្ត្រអាជីវកម្ម និងផែនការនានារបស់ក្រុមហ៊ុន ដែល បានអនុម័តរួច។

គណៈកម្មាធិការប្រតិបត្តិ ត្រូវបានដឹកនាំដោយមាន នាយកប្រតិបត្តិ (Chief Executive Officer) ជាប្រធាន និងរួមមានសមាជិកជាថ្នាក់ដឹកនាំជាន់ខ្ពស់ដែលត្រូវបានតែងតាំងដោយអគ្គនាយក។ ក្រោមសិទ្ធិអំណាចដែលបានផ្ទេរជូននេះ គណៈកម្មាធិការប្រតិបត្តិមានទំនួលខុសត្រូវក្នុងការធ្វើសេចក្ដីសម្រេចចិត្តលើគំនិតផ្ដួចផ្ដើមអាជីវកម្ម និងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន ដើម្បីធានាថារាល់សកម្មភាពទាំងអស់ត្រូវបានអនុវត្តស្របទៅតាមគោលដៅយុទ្ធសាស្ត្រ និងក្របខណ្ឌអភិបាលកិច្ចរបស់ក្រុមហ៊ុន។

ក្នុងការបំពេញតួនាទីរបស់ខ្លួន គណៈកម្មាធិការប្រតិបត្តិធ្វើការពិនិត្យ និងពិភាក្សាលើលទ្ធផលការងារអាជីវកម្ម គំនិតផ្ដួចផ្ដើមយុទ្ធសាស្ត្រ និងកិច្ចការប្រតិបត្តិការ ព្រមទាំងដាក់ចេញនូវវិធានការគ្រប់គ្រងសមស្របនានា ដើម្បីគាំទ្រដល់លទ្ធផលការងារអាជីវកម្មប្រកបដោយចីរភាព។ ចំពោះកិច្ចការទាំងឡាយណាដែលតម្រូវ ឱ្យមានការអនុម័តជាពិសេសពីក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬគោលការណ៍អភិបាលកិច្ចផ្ទៃក្នុងរបស់ក្រុមហ៊ុន គណៈកម្មាធិការប្រតិបត្តិត្រូវដាក់កិច្ចការទាំងនោះជូនក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ និងធ្វើសេចក្ដីសម្រេច។

## ជីវប្រវត្តិនៃគណៈគ្រប់គ្រងប្រតិបត្តិ



**លោក ពន្លឺ តុលា** គឺជាថ្នាក់ដឹកនាំអាជីវកម្មដ៏មានបទពិសោធន៍ និងជាបុគ្គលឈានមុខគេមួយរូបដែលត្រូវបានទទួលស្គាល់ក្នុងវិស័យធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា តាមរយៈស្នាដៃលេចធ្លោក្នុងការជំរុញកំណើន ការច្នៃប្រឌិត និងការអភិវឌ្ឍទីផ្សារ។ បច្ចុប្បន្ន លោកកាន់តំណែងជា នាយកប្រតិបត្តិ ដែលទទួលបន្ទុកដឹកនាំលើប្រតិបត្តិការអាជីវកម្ម និងយុទ្ធសាស្ត្រនៅទូទាំងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។

លោក តុលា ជាអ្នកដឹកនាំផ្ទាល់លើការរីកចម្រើនផ្នែកយុទ្ធសាស្ត្រ និងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ហើយលោកក៏ជាបុគ្គលសំខាន់ក្នុងការរួមចំណែករៀបចំរចនាសម្ព័ន្ធនៃវិស័យនេះឱ្យមានការរីកចម្រើន។ ក្នុងដំណើរផ្លាស់ប្ដូរនៃបទពិសោធន៍ដឹកនាំអស់រយៈពេលជាច្រើនទសវត្សរ៍ លោកបានកាន់តំណែងជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើននៅក្នុងស្ថាប័នធានារ៉ាប់រងអាយុជីវិតឈានមុខគេនៅកម្ពុជា។ លោក តុលា បានបញ្ចប់ការសិក្សាថ្នាក់គ្រប់គ្រងអាជីវកម្មកម្រិតខ្ពស់ពីសាកលវិទ្យាល័យ Auckland និងសាកលវិទ្យាល័យ Massey នៃប្រទេសនូវែលសេឡង់។

**លោក ពន្លឺ តុលា**

អគ្គនាយក នៃក្រុមហុនព្រូដិនសល កម្ពុជា ឡាវ និងមីយ៉ានម៉ា



**លោក Chi Chung Wong** ទទួលបន្ទុកដឹកនាំលើការរៀបចំ យុទ្ធសាស្ត្រហិរញ្ញវត្ថុ របាយការណ៍ និងអភិបាលកិច្ចវិនិយោគ ក្នុងទីផ្សារ ប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រស្ថិតិធានារ៉ាប់រង (Actuarial Science) ពីសាកលវិទ្យាល័យហុងកុង និងជាសមាជិកជាន់ខ្ពស់នៃសមាគមអ្នកគណនីស្ថិតិធានារ៉ាប់រង (Fellow of the Society of Actuaries)។

នៅក្នុងឆ្នាំ ២០២១ លោកបានបង្កើត ក្រុមការងារគណនីធានារ៉ាប់រងកម្ពុជា (CAWG) ដើម្បីអភិវឌ្ឍវិជ្ជាជីវៈគណនីធានារ៉ាប់រង និងជួយជ្រោមជ្រែងដល់និស្សិតកម្ពុជាក្នុងការទទួលបានគុណវុឌ្ឍិវិជ្ជាជីវៈកម្រិតអន្តរជាតិ។ លោកក៏ជាសមាជិកនៃគណៈកម្មាធិការវាយតម្លៃនៃ ទីភ្នាក់ងារវាយតម្លៃចំណាត់ថ្នាក់កម្ពុជា (RAC) ផងដែរ។

**លោក Chi Chung Wong**

នាយកផ្នែកហិរញ្ញវត្ថុនៃ នៃក្រុមហ៊ុន ព្រូដិនសល កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា






# រចនាសម្ព័ន្ធក្រុមហ៊ុន
# គណៈគ្រប់គ្រងប្រតិបត្តិ




**លោក សុក ហេង** ទទួលបន្ទុកដឹកនាំលើការធ្វើបរិវត្តកម្មឌីជីថល (Digital Transformation) និងការជំរុញឧត្តមភាពនៃប្រតិបត្តិការអាជីវកម្មឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់នៅទូទាំងទីផ្សារទាំងបីដែលរួមមាន ប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ លោកមានជំនាញនិងបទពិសោធន៍ការងារចម្រុះ និងទូលំទូលាយ ដែលគ្របដណ្ដប់លើវិស័យធានារ៉ាប់រង ការសិក្សាអប់រំ និងការអភិវឌ្ឍអន្តរជាតិ និង ធ្លាប់បម្រើការងារនៅធនាគារពិភពលោក (World Bank) ផងដែរ។ លោក ហេង ទទួលបានសញ្ញាបត្រអនុបណ្ឌិតពីសាកលវិទ្យាល័យ Chapman និងមានវិញ្ញាបនបត្រជំនាញកម្រិតអន្តរជាតិជាច្រើនទៀត រួមមាន គណនេយ្យករជំនាញ (CPA), ជំនាញគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (FRM) និងជំនាញគ្រប់គ្រងគម្រោង (PMP) ជាដើម។

**លោក សុក ហេង**

នាយកផ្នែកបច្ចេកវិទ្យា និងប្រតិបត្តិការ នៃក្រុមហ៊ុនព្រូដិនសល កម្ពុជាឡាវ និងមីយ៉ាន់ម៉ា



**លោកស្រី តេង សុផាន់ណា** បន្ទុកដឹកនាំលើយុទ្ធសាស្ត្រគ្រប់គ្រងបុគ្គលិក ការអភិវឌ្ឍទេពកោសល្យនិងសមត្ថភាពបុគ្គលិក និងការកសាងវប្បធម៌ស្ថាប័ន នៅ ទីផ្សារទាំងបីដែលរួមមាន ប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ មុនពេលចូលរួមជាមួយក្រុមហ៊ុន ព្រូដិនសល លោកស្រីធ្លាប់បានកាន់តំណែងជាថ្នាក់ដឹកនាំជាន់ខ្ពស់ផ្នែកធនធានមនុស្សនៅក្រុមហ៊ុនអន្តរជាតិផ្សេងៗទៀតផងដែរ ។ លោកស្រីទទួលបានសញ្ញាបត្រ អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម (MBA) ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ។

**លោកស្រី តេង សុផាន់ណា**

នាយិកាផ្នែកធនធានមនុស្ស នៃក្រុមហ៊ុនព្រូដិនសល កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា



**កញ្ញា Chu Ing Shin** ទទួលបន្ទុកដឹកនាំលើការកំណត់ថ្លៃធានារ៉ាប់រង ការអភិវឌ្ឍផលិតផល និងការវាយតម្លៃផ្នែកគណនីធានារ៉ាប់រង នៃក្រុមហ៊ុនព្រូដិនសលកម្ពុជា។ ជាមួយនឹងបទពិសោធន៍ជាង ១៧ ឆ្នាំក្នុងវិស័យធានារ៉ាប់រងអាយុជីវិត កញ្ញាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការធានានូវនិរន្តរភាពនៃផលិតផល និងការផ្ដល់តម្លៃជូនអតិថិជនឱ្យបានកាន់តែប្រសើរ។ កញ្ញាបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Melbourne និងជាសមាជិកជាន់ខ្ពស់នៃសមាគមអ្នកគណនីធានារ៉ាប់រង (FSA)។

**កញ្ញា Chu Ing Shin**

នាយិកាផ្នែកជំនាញគណនាបុព្វលាភធានារ៉ាប់រង និងផលិតផល នៃក្រុមហ៊ុនព្រូដិនសល កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា



**លោក John Masvongo** គឺជាថ្នាក់ដឹកនាំដែលទទួលបន្ទុកដឹកនាំលើការគ្រប់គ្រងហានិភ័យសហគ្រាស និងក្របខ័ណ្ឌដើមទុន ទូទាំងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ ។ លោកនាំមកនូវបទពិសោធន៍យ៉ាងស៊ីជម្រៅជាង ១៥ ឆ្នាំ ក្នុងវិស័យធានារ៉ាប់រងអាយុជីវិត លោកទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រ និងទិន្នន័យពី សកវិទ្យាល័យ Johns Hopkins Whiting School of Engineering និងសញ្ញាបត្រ អនុបណ្ឌិតគ្រប់គ្រងអាជីវកម្ម ពីមហាវិទ្យាល័យ Saïd Business School នៃសាកលវិទ្យាល័យ Oxford។ គាត់ក៏បានទទួលសញ្ញាបត្រ បរិញ្ញាបត្រពាណិជ្ជកម្ម ផ្នែកជំនាញគណនាបុព្វលាភធានារ៉ាប់រងពី សាកលវិទ្យាល័យជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ប្រទេសស៊ីមបាបវេ) ព្រមទាំងជាសមាជិកជាន់ខ្ពស់កម្រិត នៃវិទ្យាស្ថាន និងមហាវិទ្យាល័យ ជំនាញគណនាបុព្វលាភធានារ៉ាប់រង (Institute and Faculty of Actuaries - IFoA) ផងដែរ។

**លោក John Masvongo**

នាយកផ្នែកហានិភ័យ នៃក្រុមហ៊ុនព្រូដិនសល កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា

# របាយការណ៍របស់គណៈកម្មាធិការ

## ក. គណៈកម្មាធិការសវនកម្ម

### វិសាលភាព និង គោលបំណង

គណៈកម្មាធិការសវនកម្មត្រូវបានបង្កើតឡើង និងផ្តល់សិទ្ធិដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ព្រូដិនសលកម្ពុជា ក្នុងគោលបំណងត្រួតពិនិត្យ និងតាមដានសុចរិតភាពនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក៏ដូចជាប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ រួមទាំងការត្រួតពិនិត្យការរាយការណ៍ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ព្រមទាំងប្រសិទ្ធភាពនៃអភិបាលកិច្ចទូទៅរបស់ក្រុមហ៊ុន។

### តួនាទី និងភារកិច្ចសំខាន់ៗរបស់គណៈកម្មាធិការសវនកម្ម

#### ការរាយការណ៍ និងការបង្ហាញព័ត៌មានហិរញ្ញវត្ថុ

ពិនិត្យមើលសុចរិតភាព និងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ការវិនិច្ឆ័យ និងការប៉ាន់ប្រមាណ ប្រតិបត្តិការមិនប្រក្រតី ការកែតម្រូវសវនកម្ម និងការវាយតម្លៃលទ្ធភាពក្នុងការបន្តប្រតិបត្តិការ (going concern)។

#### ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

ត្រួតពិនិត្យប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន។ ពិនិត្យឯកសារហានិភ័យសំខាន់ៗ កម្រិតហានិភ័យ ហានិភ័យសំខាន់ៗ ការកើតមាននៃហានិភ័យថ្មីៗ និងវិធានការកាត់បន្ថយហានិភ័យ។

#### សវនកម្មខាងក្រៅ និងសវនកម្មផ្ទៃក្នុង

ត្រួតពិនិត្យដំណើរការសវនកម្មខាងក្រៅតាមរយៈការពិនិត្យផែនការ និងវិសាលភាពសវនកម្ម ការវាយតម្លៃគុណភាពសវនកម្ម ការធានាភាពឯករាជ្យ និងប្រសិទ្ធភាពរបស់សវនករខាងក្រៅ។ ពិនិត្យលទ្ធផលសវនកម្ម និងពិចារណាចំពោះការឆ្លើយតបចំពោះអនុសាសន៍សវនកម្មសំខាន់ៗ។

លើសពីនេះទៀត គណៈកម្មាធិការសវនកម្មបានពិនិត្យប្រសិទ្ធភាព និងភាពឯករាជ្យនៃសវនកម្មផ្ទៃក្នុង អនុម័តផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ពិនិត្យលទ្ធផលសំខាន់ៗ និងវឌ្ឍនភាពនៃការកែសម្រួល និងធានាថាបញ្ហាសំខាន់ៗត្រូវបានរាយការណ៍តាមភាពសមស្រប។





#### ការគោរពច្បាប់ និងឧក្រិដ្ឋកម្មហិរញ្ញវត្ថុ

ត្រួតពិនិត្យប្រសិទ្ធភាពនៃអនុលោមភាពតាមគោលការណ៍របស់ក្រុមហ៊ុន អនុម័តផែនការនៃក្រុមការងារប្រតិបត្តិតាមប្រចាំឆ្នាំ និងពិនិត្យរបាយការណ៍នៃការប្រតិបត្តិតាម រួមទាំងបញ្ហាសំខាន់ៗដែលទាក់ទងនឹងនិយតកម្ម។ ពិនិត្យគោលនយោបាយ និងនីតិវិធីពាក់ព័ន្ធនឹងហានិភ័យឧក្រិដ្ឋកម្មហិរញ្ញវត្ថុ រួមមាន ការប្រឆាំងការសម្អាតប្រាក់ (AML) ការក្លែងបន្លំ ទណ្ឌកម្ម និងការប្រឆាំងអំពើសំណូក និងអំពើពុករលួយ។

#### អភិបាលកិច្ច និងការបញ្ជាក់

ពិនិត្យប្រសិទ្ធភាពនៃក្របខ័ណ្ឌអភិបាលកិច្ចរបស់ក្រុមហ៊ុន និងការអនុវត្តរបស់គណៈគ្រប់គ្រងឱ្យស្របតាមស្តង់ដារអភិបាលកិច្ចរបស់ព្រូដិនសលគ្រុប រួមទាំងការបញ្ជាក់ដែលត្រូវការពីភាគីខាងក្រៅ។ កំណត់កម្រិតការធានាដែលត្រូវការ និងពិនិត្យរបាយការណ៍ដែលផ្តល់ដោយខ្សែការពារទីពីរ និង ទីបី។

### សមាសភាពគណៈកម្មាធិការ

គណៈកម្មាធិការសវនកម្មរួមមានសមាសភាពចំនួន ០៣ រូបដែលជាអភិបាលឯករាជ្យ រួមមាន ប្រធាន ០១ រូប និង សមាជិក ០២ រូប។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ សមាសភាពគណៈកម្មាធិការ ០១ រូប កំពុងត្រូវបានជ្រើសរើសបន្ទាប់ពីមានការលាលែងពីតំណែងថ្មីៗរបស់សមាជិកម្នាក់។

### ចំណុចសំខាន់ៗរបស់គណៈកម្មាធិការក្នុងឆ្នាំ ២០២៥

ក្នុងឆ្នាំ ២០២៥ គណៈកម្មាធិការសវនកម្មបានប្រជុំចំនួន ៤ លើក ក្នុងខែមីនា ខែមិថុនា ខែកញ្ញា និងខែធ្នូ ដែលផ្តោតលើការពង្រឹងការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ច។ សកម្មភាពសំខាន់ៗរួមមាន ការពិនិត្យ និងអនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងឯកសារដាក់ស្នើផ្សេងៗ មុនពេលដាក់ជូននិយ័តករ ការអនុម័តផែនការសវនកម្មផ្ទៃក្នុង និងផែនការនៃការប្រតិបត្តិតាមប្រចាំឆ្នាំ និងពិនិត្យរបាយការណ៍សវនកម្មផ្ទៃក្នុង ក៏ដូចជារបាយការណ៍នៃការប្រតិបត្តិតាម។ គណៈកម្មាធិការសវនកម្មក៏បានធ្វើការពិភាក្សាអំពីហានិភ័យមិនមែនហិរញ្ញវត្ថុសំខាន់ៗ ដោយផ្តោតលើនិន្នាការហានិភ័យ មូលហេតុគ្រឹះ និងវិធានការការពារ រួមទាំងវិធានការកាត់បន្ថយហានិភ័យរបស់គ្រប់គ្រង ដោយនៅតែបន្តតាមដានប្រសិទ្ធភាពនៃក្របខ័ណ្ឌនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចរបស់ក្រុមហ៊ុន។

# របាយការណ៍របស់គណៈកម្មាធិការ
# ខ. គណៈកម្មាធិការវិនិយោគ

## គោលបំណងនៃគណៈកម្មាធិការ

គណៈកម្មាធិការវិនិយោគ ត្រូវបានបង្កើតឡើងដើម្បីគាំទ្រក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យសកម្មភាពគ្រប់គ្រងការវិនិយោគរបស់ក្រុមហ៊ុន។ គណៈកម្មាធិការវិនិយោគត្រួតពិនិត្យលើយុទ្ធសាស្ត្រ លទ្ធផល ប្រតិបត្តិការ និងហានិភ័យចម្បងៗនៃការវិនិយោគរបស់ក្រុមហ៊ុន និងធានាថាសកម្មភាពវិនិយោគត្រូវបានធ្វើឡើងសមស្រប តាមគោលដៅ ដូចបានចែងក្នុងគោលការណ៍វិនិយោគរបស់ក្រុមហ៊ុន។ គណៈកម្មាធិការក៏ធ្វើការត្រួតពិនិត្យលើអនុលោមភាពតាមគោលការណ៍វិនិយោគរបស់ក្រុមហ៊ុនមេផងដែរ។

## តួនាទី និងកាតព្វកិច្ចរបស់គណៈកម្មាធិការវិនិយោគ

គណៈកម្មាធិការវិនិយោគ មានតួនាទី និងកាតព្វកិច្ចសំខាន់ៗដូចខាងក្រោម ៖

- កំណត់ និងអនុម័តយុទ្ធសាស្ត្រវិនិយោគទាំងមូល រួមមានយុទ្ធសាស្ត្របែងចែកទ្រព្យសកម្ម (“Strategic Asset Allocation ឬ SAA”) និងយុទ្ធវិធីបែងចែកទ្រព្យសកម្ម (“Tactical Asset Allocation ឬ TAA”) ប្រសិនបើមាន។
- បង្កើត ត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំ និងគោលការណ៍វិនិយោគប្រចាំគ្រា។
- រៀបចំផែនការវិនិយោគរយៈពេល ៣ ឆ្នាំ ជារៀងរាល់ឆ្នាំ។
- ត្រួតពិនិត្យហានិភ័យវិនិយោគ រួមមាន ហានិភ័យទីផ្សារ ហានិភ័យឥណទាន ហានិភ័យសទ្ធនីយភាព និងហានិភ័យនៃភាគីម្ខាងទៀត។
- ធានាការអនុលោមតាមលក្ខខណ្ឌតម្រូវនៃអនុលោមភាពផ្ទៃក្នុង និងផ្នែកខាងក្រៅទាំងអស់ ជៀសវាងការប៉ះទង្គិចផលប្រយោជន៍ក្នុងការសម្រេចចិត្តទាំងឡាយ និងរក្សាភាពរឹងមាំនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- កំណត់ស្តង់ដារវាស់ស្ទង់លទ្ធផលវិនិយោគ ធ្វើការវាយតម្លៃលទ្ធផល ដោយរួមបញ្ចូលនូវកត្តាបម្រែបម្រួលសេដ្ឋកិច្ច វិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិនានា និងរាយការណ៍អំពីលទ្ធផលប្រចាំគ្រាជូនក្រុមប្រឹក្សាភិបាល។
- ប្រើប្រាស់ធនធានដោយមានប្រសិទ្ធភាពខ្ពស់ ក្នុងសកម្មភាពវិនិយោគ និងការគ្រប់គ្រងទ្រព្យសកម្ម។
- រាល់ការបំពានលើអនុលោមភាពដោយប្រការណាមួយ គណៈកម្មាធិការវិនិយោគត្រូវចាត់វិធានការភ្លាមៗ និងប្រសិនបើតម្រូវទទួលបានការអនុម័តពីក្រុមប្រឹក្សាភិបាល ដោយពិចារណាអំពីតម្រូវការអាជីវកម្ម និងស្ថានភាពទីផ្សារ។

### សមាសភាពសមាជិក

គណៈកម្មាធិការវិនិយោគមានសមាសភាពចំនួន ៨ រូប ដែលក្នុងនោះរួមមានអភិបាលមិនប្រតិបត្តិចំនួន ២ រូប (១ រូប ជាអភិបាលឯករាជ្យ) សមាជិកគណៈគ្រប់គ្រងប្រតិបត្តិចំនួន ៤ រូប និងតំណាង ១ រូបពីផ្នែកហានិភ័យឥណទានរបស់ក្រុមហ៊ុនមេ និងតំណាង ១ រូបពីផ្នែកវិនិយោគរបស់ក្រុមហ៊ុនមេ។ សមាសភាពនៃគណៈកម្មាធិការវិនិយោគអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិតម្រូវ។

### លទ្ធផលសម្រេចបានរបស់គណៈកម្មាធិការក្នុងឆ្នាំ ២០២៥

នៅក្នុងឆ្នាំ ២០២៥ គណៈកម្មាធិការវិនិយោគបានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសយ៉ាងតិច ៤ ដង ដោយមានការចូលរួមយ៉ាងសកម្មពីសមាជិក សមាជិកា។ តាមរយៈកិច្ចប្រជុំដែលបានរៀបចំឡើង គណៈកម្មាធិការបានត្រួតពិនិត្យទៅលើយុទ្ធសាស្ត្រ និងអភិបាលកិច្ច ដើម្បីធានាភាពសមស្របគ្នានឹងកាតព្វកិច្ចចំពោះម្ចាស់បណ្ណសន្យារ៉ាប់រង ដោយបានត្រួតពិនិត្យ និងអនុម័តលើការកែប្រែសំពៀតវិនិយោគដើម្បីបង្កើនប្រសិទ្ធភាពនៃផលចំណេញពីការវិនិយោគបន្ទាប់ពីទូទាត់ហានិភ័យឥណទាន (risk-adjusted returns) និងការផ្គូរផ្គងទ្រព្យសកម្ម និងបំណុល (asset–liability matching) រួមទាំងការអនុម័តលើមូលបត្របំណុលជាដុល្លារអាមេរិកដែលមានរយៈពេលវែងផងដែរ។ គណៈកម្មាធិការវិនិយោគក៏បានត្រួតពិនិត្យ និងអនុម័តលើការធ្វើបច្ចុប្បន្នភាពគោលការណ៍វិនិយោគ និងនីតិវិធីប្រតិបត្តិការស្តង់ដារនានា ដើម្បីធានាអនុលោមភាពទៅនឹងគោលការណ៍របស់ក្រុមហ៊ុនមេ និងបទប្បញ្ញត្តិជាធរមាន។ ក្នុងអំឡុងពេលពេញមួយឆ្នាំ គណៈកម្មាធិការបានត្រួតពិនិត្យ និងអនុម័តលើលទ្ធផលវិនិយោគ និងសំពៀតវិនិយោគជាក់ស្តែង រក្សាបានក្នុងទំហំហានិភ័យដែលអាចទទួលយក (Risk Appetite) និងដែនកំណត់ដូចបានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងបានពង្រឹងការត្រួតពិនិត្យហានិភ័យវិនិយោគតាមរយៈការរាយការណ៍ និងការតាមដានជាប្រចាំ។ គណៈកម្មាធិការរក្សាបន្តតាមដានការអភិវឌ្ឍន៍ទីផ្សារក្នុងស្រុក ដើម្បីស្វែងរកឱកាសវិនិយោគថ្មីៗដែលមានសក្តានុពល។



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | **ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម** | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

# របាយការណ៍របស់គណៈកម្មាធិការ
# គ. គណៈកម្មាធិការហានិភ័យ

## គោលបំណងនៃគណៈកម្មាធិការ

គណៈកម្មាធិការហានិភ័យមានភារកិច្ចក្នុងការត្រួតពិនិត្យ និងពិនិត្យឡើងវិញលើកម្រិតអត្រាទ្រាំទ្រ ហានិភ័យ កម្រិតអតិបរមាអនុញ្ញាត និងយុទ្ធសាស្ត្រហានិភ័យរបស់ក្រុមហ៊ុន។ គណៈកម្មាធិការតាមដានហានិភ័យបច្ចុប្បន្ន និង អនាគតដែលអាចកើតមាន ប្រសិទ្ធភាពនៃក្របខណ្ឌគ្រប់គ្រងហានិភ័យ និងការអនុវត្តតាមគោលនយោបាយហានិភ័យ និងបទប្បញ្ញត្តិដែលអនុវត្តបាន។

## តួនាទី និងភារកិច្ចសំខាន់ៗរបស់គណៈកម្មាធិការហានិភ័យ

គណៈកម្មាធិការហានិភ័យមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ជម្រុញវប្បធម៌នៃការគ្រប់គ្រងហានិភ័យ និងការអនុលោមតាមច្បាប់ឱ្យមានប្រសិទ្ធភាព ដែលបានបញ្ចូលនៅទូទាំងក្រុមហ៊ុន។
- ពិនិត្យឡើងវិញ ឬ អនុម័តឯកសារហានិភ័យរបស់ក្រុមហ៊ុន រួមមានយុទ្ធសាស្ត្រហានិភ័យ ការរៀបចំអភិបាលកិច្ចហានិភ័យ គោលនយោបាយ និងស្តង់ដារហានិភ័យ របាយការណ៍ផ្ទៀងផ្ទាត់ម៉ូឌែលផ្ទៃក្នុង និងសំណើសុំផ្លាស់ប្តូរ សំណើផ្លាស់ប្តូរនិយមន័យ និងការចាត់ថ្នាក់ហានិភ័យ និងឯកសារពាក់ព័ន្ធផ្សេងទៀត តាមសមស្រប។
- កំណត់ និងពិភាក្សាអំពីហានិភ័យថ្មី និងកំពុងកើតឡើង ព្រមទាំងនិន្នាការហានិភ័យ និងពិនិត្យវិធានការគ្រប់គ្រង និងសកម្មភាពដែលពាក់ព័ន្ធ។
- ត្រួតពិនិត្យការត្រៀមខ្លួនរបស់ក្រុមហ៊ុន សម្រាប់ការគ្រប់គ្រងបន្តអាជីវកម្ម (BCM) និងពិនិត្យជាប្រចាំលើផែនការបន្តអាជីវកម្ម (BCP)។
- តាមដានការប៉ះពាល់ហានិភ័យ ការទទួលយកហានិភ័យ និងកម្រិតកំណត់ រួមទាំងករណីលើសកម្រិត និងសកម្មភាពកែតម្រូវ។

### សមាសភាពសមាជិក

គណៈកម្មាធិការមានសមាជិកចំនួន ៦ នាក់ ពីគណៈកម្មាធិការប្រតិបត្តិ។ គណៈកម្មាធិការអាចអញ្ជើញសមាជិកគ្រប់គ្រង ឬតំណាងពីក្រុមហ៊ុនមេចូលរួមប្រជុំទាំងមូល ឬមួយផ្នែក ដើម្បីផ្តល់ព័ត៌មាន និងការពន្យល់បន្ថែម តាមការចាំបាច់។

### លទ្ធផលសម្រេចបានរបស់គណៈកម្មាធិការក្នុងឆ្នាំ ២០២៥

ក្នុងឆ្នាំ ២០២៥ គណៈកម្មាធិការគ្រប់គ្រងហានិភ័យបានរៀបចំប្រជុំចំនួន ៤ លើក ក្នុងខែ មីនា មិថុនា កញ្ញា និងធ្នូ។ គណៈកម្មាធិការបានពិនិត្យជាប្រចាំលើទម្រង់ហានិភ័យរបស់ក្រុមហ៊ុន ដើម្បីធានាថាហានិភ័យសំខាន់ៗត្រូវបានកំណត់ តាមដាន និងគ្រប់គ្រងយ៉ាងសមស្រប ស្របតាមកម្រិតទទួលយក កម្រិតកំណត់ និងតម្រូវការបទប្បញ្ញត្តិដែលបានអនុម័ត។ គណៈកម្មាធិការបានវាយតម្លៃហានិភ័យយុទ្ធសាស្ត្រ និងហានិភ័យកំពុងកើតឡើងដែលមានឥទ្ធិពលលើនិរន្តរភាព សមត្ថភាពនៃប្រតិបត្តិការ និងលទ្ធផលសម្រាប់អតិថិជន ព្រមទាំងពិនិត្យប្រសិទ្ធភាពនៃក្របខណ្ឌគ្រប់គ្រងហានិភ័យ រួមមានវិធីសាស្ត្រ សូចនាករ ការគ្រប់គ្រង និងដំណើរការបញ្ជូនបញ្ហា។ គណៈកម្មាធិការក៏បានតាមដានសមត្ថភាពផ្នែកហិរញ្ញវត្ថុ ពិនិត្យហានិភ័យមិនមែនផ្នែកហិរញ្ញវត្ថុ និងហានិភ័យពាក់ព័ន្ធអតិថិជន គ្រប់គ្រងហេតុការណ៍សំខាន់ៗ សកម្មភាពកែតម្រូវ និងពិចារណាការអភិវឌ្ឍន៍បទប្បញ្ញត្តិ ដើម្បីពង្រឹងវប្បធម៌ហានិភ័យ ការទទួលខុសត្រូវច្បាស់លាស់ និងអភិបាលកិច្ចហានិភ័យយ៉ាងមានវិន័យទូទាំងក្រុមហ៊ុន។

# របាយការណ៍អភិបាលកិច្ចសាជីវកម្ម

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ ២០២៥ ក្រុមប្រឹក្សាភិបាល បានរៀបចំកិច្ចប្រជុំចំនួន ៤ (បួន) ដង ដែលរួមមាន ការប្រជុំដោយផ្ទាល់មួយលើកនៅត្រីមាសទីមួយ និងការប្រជុំតាមប្រព័ន្ធអនឡាញចំនួន ៣ (បី) លើកផ្សេងទៀត។ ការប្រជុំនីមួយៗ រួមមានការធ្វើបច្ចុប្បន្នភាពលើសកម្មភាពអាជីវកម្ម និងរបាយការណ៍ពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលនីមួយៗ។ ក្នុងកិច្ចប្រជុំទាំងនេះ បញ្ហាដែលតម្រូវឲ្យមានការអនុម័តពីក្រុមប្រឹក្សាភិបាល ត្រូវបានដាក់ជូនក្រុមប្រឹក្សាភិបាលសម្រាប់ពិចារណា និងក្នុងករណីខ្លះការអនុម័ត ត្រូវបានធ្វើឡើងតាមរយៈអ៊ីម៉ែលជារឿយៗ។

នៅឆ្នាំ ២០២៥ ក្រុមប្រឹក្សាភិបាលបានអនុម័តលើបញ្ហាសំខាន់ៗទាក់ទងនឹងការត្រួតពិនិត្យការវិនិយោគ រចនាសម្ព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងរបស់ក្រុមហ៊ុន ប្រតិបត្តិការសាខាក្រុមហ៊ុន របាយការណ៍ហិរញ្ញវត្ថុ និងសវនកម្ម លក្ខខណ្ឌបទប្បញ្ញត្តិ និងការអនុលោមភាពតាមច្បាប់ រួមទាំងគោលការណ៍ផ្ទៃក្នុង និងផែនការអាជីវកម្មជាយុទ្ធសាស្ត្រ។

## របាយការណ៍ស្តីពីការគ្រប់គ្រងប្រតិបត្តិ

ក្រោមការប្រគល់សិទ្ធិដោយក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងបានទទួលនូវសិទ្ធិអនុម័តលើទិដ្ឋភាពមួយចំនួននៃ ប្រតិបត្តិការអាជីវកម្ម។ នៅឆ្នាំ ២០២៥ គណៈកម្មាធិការប្រតិបត្តិបានសម្រេចអនុម័តកិច្ចការពាក់ព័ន្ធនឹងផលិតផលថ្មី និងចូលរួមជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងបន្ត ដើម្បីគាំទ្រដល់ប្រតិបត្តិការអាជីវកម្ម និងគោលបំណងជាយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន។

# ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម


| | ទំព័រ |
|---|---|
| 1. ដើមទុន និងកម្រិតសាធនភាព | 38 |
| 2. ការវិនិយោគ | 40 |
| 3. ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង | 44 |
| 4. លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម | 46 |
| 5. ការធានារ៉ាប់រងបន្ត | 48 |
| 6. ការគ្រប់គ្រងហានិភ័យ | 50 |
| 7. ព័ត៌មានអំពីចីរភាព | 52 |




# ដើមទុន និងកម្រិតសាធនភាព



កម្មវត្ថុចម្បងនៃការគ្រប់គ្រងដើមទុនរបស់ក្រុមហ៊ុន គឺការរក្សានូវមូលដ្ឋានដើមទុនដ៏រឹងមាំដើម្បី គាំទ្រដល់ការអភិវឌ្ឍអាជីវកម្មរបស់ខ្លួន និងដើម្បីអនុលោមតាមលក្ខខណ្ឌតម្រូវដើមទុនតាមបទប្បញ្ញត្តិគ្រប់ពេលវេលា។ ក្រុមហ៊ុន ទទួលស្គាល់នូវឥទ្ធិពលទៅលើផលត្រឡប់នៃកម្រិតទុនរបស់ភាគទុនិក ដែលត្រូវបានប្រើប្រាស់ និងព្យាយាមរក្សាសមតុល្យដោយប្រុងប្រយ័ត្ន។

ក្រុមហ៊ុនបានអនុវត្តតាមវិធីសាស្រ្ត នីតិវិធីដើម្បីគ្រប់គ្រងថែរក្សាកម្រិតសាធនភាពឱ្យសមប្រកបក្នុងគោលបំណងធានានូវប្រសិទ្ធភាពនៃកាតព្វកិច្ចសំណងធានារ៉ាប់រង និងចំណាយដែលកើតឡើងពីកិច្ចសន្យាធានារ៉ាប់រង ដូចដែលបានចែងនៅក្នុងប្រកាសស្តីពីនីតិវិធីនិងវិធាននៃការគណនាប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង។

កម្រិតសាធនភាពរបស់ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឺស្សួរិនស៍ ម.ក គឺត្រូវបានគណនាដោយយោងតាមប្រការ៤ របស់ប្រកាសលើកម្រិតសាធនភាពដែលជាផលធៀបនៃទ្រព្យសកម្មសុទ្ធដោយការសម្រេចពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុន និងសាធនភាពតម្រូវរបស់ក្រុមហ៊ុន។គិតត្រឹមខែធ្នូឆ្នាំ២០២៥ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឺស្សួរិនស៍ ម.ក បានរក្សាកម្រិតសាធភាពចំនួន ១៣៧ (មួយរយសាមសិបប្រាំពីរ) ភាគរយ ដែលឋិតនៅកម្រិតខ្ពស់ជាងកម្រិតសាធនភាពចំនួន ១២០% ដែល ត្រូវបានតម្រូវឱ្យរក្សាដោយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត។

របាយការណ៍សាធនភាពរបស់ក្រុមហ៊ុននិងការបែងចែកនៃប្រាក់បម្រុងនៅបញ្ចប់ឆ្នាំ២០២៥គឺដូចមានបង្ហាញក្នុងតារាង ខាងក្រោម។ តួលេខនីមួយៗ គឺបង្ហាញជាលានដុល្លារអាមេរិក។

## ដើមទុន និង កម្រិតសាធនភាព

**ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា)**

រក្សាបាននូវអនុបាតសាធនភាពក្នុងកម្រិត

**137%**

*គិតត្រឹមខែធ្នូ ឆ្នាំ2025

**ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា)**

រក្សាបាននូវអនុបាតសាធនភាពខ្ពស់ជាងអត្រាសាធនភាពតម្រូវ **120%** ដែលត្រូវបានកំណត់ឱ្យក្រុមហ៊ុនធានារ៉ាប់រងជីវិតនីមួយៗត្រូវរក្សាទុក





# ដើមទុន និងកម្រិតសាធនភាព

## ដើមទុនតម្រូវ

| ល.រ. | បរិយាយ | ឆ្នាំ2025 | ឆ្នាំ2024 |
|---|---|---|---|
| 1 | ប្រាក់តម្កល់ធានាអាជីវកម្ម | 0.7 | 0.7 |
| 2 | សាធនភាពតម្រូវ | 25.6 | 26.8 |
| 3 | អចលនទ្រព្យប្រើប្រាស់ផ្ទាល់ដោយក្រុមហ៊ុន ឬសាច់ប្រាក់ | 2.8 | 2.8 |
| ក | ដើមទុនតម្រូវ (ក=1+2+3) | **29.1** | **30.3** |

ដើមទុនតម្រូវសរុបមានកម្រិតទាបជាងឆ្នាំមុន ដែលភាគច្រើនបណ្តាលមកពីការថយចុះនៃតម្រូវការសាធនភាព ដែលជាលទ្ធផលធ្វើឱ្យមានការកាត់បន្ថយការប៉ះពាល់ហានិភ័យ។ ប្រាក់តម្កល់ធានាអាជីវកម្មនិងអចលនទ្រព្យប្រើប្រាស់ផ្ទាល់ដោយក្រុមហ៊ុន ឬសាច់ប្រាក់ គឺនៅកម្រិតស្របគ្នា។

## ទ្រព្យសកម្មសុទ្ធ

| ល.រ. | បរិយាយ | ឆ្នាំ2025 | ឆ្នាំ2024 |
|---|---|---|---|
| 1 | **ទ្រព្យសកម្មសរុប** | **462.8** | **415.2** |
| 2 | ទ្រព្យសកម្មសរុបដែលមិនអនុញ្ញាត | **58.9** | **55.7** |
| | - គណនីត្រូវទទួលដែលមានរយៈពេលលើសពី ១៨០ ថ្ងៃ | - | - |
| | - ប្រាក់បុរេប្រទាន និងចំណាយបង់មុន | 2.4 | 1.1 |
| | - ប្រាក់កម្ចីទៅឱ្យភាគីពាក់ព័ន្ធ | 0.6 | 0.5 |
| | - ថ្លៃដើមទិញពន្យារ | 51.3 | 48.6 |
| | - ប្រាក់អតិរេកពីការវាយតម្លៃឡើងវិញនៃអចលនទ្រព្យ | - | - |
| | - ទ្រព្យសកម្មអរូបីយ | 4.6 | 5.4 |
| | - ទ្រព្យសកម្មជាប់កាតព្វកិច្ច | - | - |
| 3 | **បំណុលសរុប** | **368.6** | **322.0** |
| | **ទ្រព្យសកម្មសុទ្ធ = (1-2-3)** | **35.2** | **37.5** |

- ទ្រព្យសកម្មសរុបមានការកើនឡើងបើប្រៀបធៀបនឹងឆ្នាំមុន ដែលជាចម្បងបណ្តាលមកពីការកើនឡើងនៃមូលដ្ឋានសកម្មដែលអនុញ្ញាត ដោយរួមមានប្រាក់ដាក់បញ្ញើនៅធនាគារ និងការវិនិយោគដែលកំណត់រក្សាទុកដល់ថ្ងៃកំណត់។ លើសពីនេះទៀត ក៏មានការកើនឡើងនៃទ្រព្យសកម្មដែលមិនអនុញ្ញាត ជាពិសេសថ្លៃដើមទិញធានារ៉ាប់រងដែលពន្យារពេល និងផ្សេងៗទៀត ហើយត្រូវបានបន្ថយផ្នែកខ្លះដោយការថយចុះនៃទ្រព្យសកម្មអរូបី។
- បំណុលសរុបមានក៏មានការកើនឡើងធៀបនឹងឆ្នាំមុន ដែលជាចម្បងបណ្តាលមកពីការកើនឡើងនៃបំណុលធានារ៉ាប់រងដោយសារអាជីវកម្មមានការរីកចម្រើន។ ជាលទ្ធផលរវាងបំណុលដែលកើនឡើង និងការកើនឡើងនៃសកម្មដែលមិនអនុញ្ញាត គឺទ្រព្យសកម្មសុទ្ធ បានថយចុះក្នុងឆ្នាំ2025 បើធៀបនឹង ឆ្នាំ2024។

## សាធនភាព

| ល.រ. | បរិយាយ | ឆ្នាំ2025 | ឆ្នាំ2024 |
|---|---|---|---|
| 1 | ទ្រព្យសកម្មសុទ្ធ | 35.2 | 37.5 |
| 2 | សាធនភាពតម្រូវ = MAX(2.1,2.2) | 25.6 | 26.8 |
| | 2.1 សាធនភាពតម្រូវអប្បបរមា | 3.5 | 3.5 |
| | 2.2 សាធនភាពតម្រូវតាមហានិភ័យ | 25.6 | 26.8 |
| 3 | **កម្រិតសាធនភាព (>120%) = (1/2)** | **137%** | **140%** |

- ទ្រព្យសកម្មសុទ្ធ មានការថយចុះបើប្រៀបធៀបនឹងឆ្នាំមុន ដែលជាចម្បងបណ្តាលមកពីការផ្លាស់ប្តូរនៃមូលដ្ឋានទ្រព្យសកម្មដែលអនុញ្ញាត និងបំណុលធានារ៉ាប់រង។
- សាធនភាពតម្រូវ ត្រូវបានកំណត់ដោយយកតម្លៃដែលខ្ពស់ជាងគេ រវាងសាធនភាពតម្រូវអប្បបរមា និងសាធនភាពតម្រូវតាមហានិភ័យ។ ក្នុងនោះ សាធនភាពតម្រូវតាមហានិភ័យនៅតែជាកត្តាកំណត់សំខាន់សម្រាប់ទាំងឆ្នាំ2025 និង ឆ្នាំ2024។
- កម្រិតសាធនភាព មានការថយចុះបន្តិចបើប្រៀបធៀបនឹងឆ្នាំ2024 ប៉ុន្តែក្រុមហ៊ុននៅតែរក្សាបានស្ថានភាពសាធនភាពរឹងមាំដោយមានការគ្រប់គ្រងដើមទុនខ្ពស់លើសពីតម្រូវការអប្បបរមាតាមបទប្បញ្ញត្តិ។

ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | **ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម** | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

# ការវិនិយោគ

## យុទ្ធសាស្ត្រ និងគោលដៅនៃការវិនិយោគ

យុទ្ធសាស្ត្រវិនិយោគរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងដោយផ្តោតលើការវិនិយោគក្នុងទ្រព្យសកម្មរយៈពេលវែង ដើម្បីគាំទ្រដល់ការបំពេញកាតព្វកិច្ចរយៈពេលវែងរបស់ក្រុមហ៊ុន ចំពោះម្ចាស់បណ្ណសន្យារ៉ាប់រង ខណៈធានាបាននូវសន្ទនីយភាពគ្រប់គ្រាន់ពីការវិនិយោគរយៈពេលខ្លី និងមធ្យម។ យុទ្ធសាស្ត្រនេះមានគោលដៅក្នុងការបង្កើតផលចំណេញប្រកបដោយចីរភាព និងផ្តោតសំខាន់លើសុវត្ថិភាព សន្ទនីយភាព និងពិពិធកម្ម។ សកម្មភាពវិនិយោគត្រូវបានគ្រប់គ្រង ដោយពិចារណាលើស្ថានភាព និងរយៈពេលនៃបំណុលធានារ៉ាប់រងរបស់ក្រុមហ៊ុន ហើយត្រូវបានវិនិយោគលើតែឧបករណ៍ហិរញ្ញវត្ថុដែលមានហានិភ័យអាចធ្វើការវាយតម្លៃ តាមដាន និងគ្រប់គ្រងបានតែប៉ុណ្ណោះ។

សកម្មភាពវិនិយោគ ត្រូវបានគ្រប់គ្រងក្រោមក្របខ័ណ្ឌត្រួតពិនិត្យ រួមមានការត្រួតពិនិត្យជាប្រចាំលើលទ្ធផលវិនិយោគ និងការប្រឈមនឹងហានិភ័យចម្បងៗ។ យុទ្ធសាស្ត្រវិនិយោគរបស់ក្រុមហ៊ុន គឺផ្អែកលើគោលការណ៍វិនិយោគ និងគោលការណ៍អភិបាលកិច្ចពាក់ព័ន្ធនានា និងអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន រួមមានប្រកាសលេខ០៤៩ ស្តីពីការអនុញ្ញាតលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ចេញដោយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (“Non-Bank Financial Services Authority ឬ NBFSA”) ។

ដោយផ្អែកលើការវិនិយោគដែលអាចធ្វើបានសម្រាប់ទីផ្សារក្នុងស្រុក សំពៀតវិនិយោគរបស់ក្រុមហ៊ុនភាគច្រើនត្រូវបានវិនិយោគលើប្រាក់បញ្ញើដែលមានគុណភាពខ្ពស់ជាមួយស្ថាប័នហិរញ្ញវត្ថុ និងការទិញមូលបត្រផ្តល់ចំណូលថេរ (fixed income securities) ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រួមមានមូលបត្ររដ្ឋ និងសញ្ញាបណ្ណសាជីវកម្ម។ រយៈពេលដល់កាលកំណត់ ឬតណប្រតិទាននៃការវិនិយោគ ត្រូវបានជ្រើសរើសដើម្បីបង្កើតឲ្យមានតុល្យភាពរវាងផលចំណូលវិនិយោគ ការរក្សាដើមទុន និងតម្រូវការសាច់ប្រាក់។ ក្រុមហ៊ុនក៏អាចពិចារណាធ្វើការវិនិយោគលើប្រភេទទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងៗទៀតផងដែរ ក្នុងករណីសមស្រប និងនៅក្នុងដែនកំណត់អនុម័តដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនដាក់បញ្ចូលការពិចារណាអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) នៅក្នុងការសម្រេចចិត្តលើការវិនិយោគណាមួយ ស្របតាមយុទ្ធសាស្ត្រ និងស្តង់ដាវិនិយោគប្រកបដោយការទទួលខុសត្រូវរបស់ក្រុមហ៊ុនមេ (“Group Responsible Investment Standards”)។

## សេចក្តីសង្ខេបអំពីសំពៀតវិនិយោគ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ សំពៀតវិនិយោគរបស់ក្រុមហ៊ុន (រួមបញ្ចូលសាច់ប្រាក់នៅធនាគារ) មានចំនួនសរុប ៣៨០ លានដុល្លារអាមេរិក ដែលបានកើនឡើងប្រហែល ១៥% បើប្រៀបធៀបជាមួយឆ្នាំមុន។

ដោយផ្អែកលើការវិនិយោគដែលអាចធ្វើបាននៅក្នុងទីផ្សារក្នុងស្រុក ទ្រព្យសកម្មដែលបានវិនិយោគជាចម្បងរួមមាន ប្រាក់បញ្ញើជាមួយធនាគារពាណិជ្ជក្នុងស្រុក និងមូលបត្របំណុល។ សំពៀតវិនិយោគនេះត្រូវបានរក្សាជារូបិយប័ណ្ណ ដុល្លារអាមេរិក សមស្របជាមួយនឹងរូបិយប័ណ្ណនៃបំណុលធានារ៉ាប់រង ដើម្បីកាត់បន្ថយហានិភ័យពីការប្តូររូបិយ ប័ណ្ណនាពេលអនាគត។

ក្នុងការគ្រប់គ្រងទ្រព្យសកម្ម និង បំណុលរបស់ក្រុមហ៊ុន រយៈពេលនៃការវិនិយោគត្រូវបានធ្វើឡើងលើឧបករណ៍ដែលមានរយៈពេលមធ្យម និងវែង (ដែលមានរយៈពេលរហូតដល់ ១៥ ឆ្នាំ) ដើម្បីផ្គូរផ្គងរយៈពេលនៃទ្រព្យសកម្ម និងបំណុល ព្រមទាំងគ្រប់គ្រងហានិភ័យនៃការវិនិយោគឡើងវិញ។

សំពៀតវិនិយោគត្រូវបានត្រួតពិនិត្យ និងតាមដានក្រោមក្របខ័ណ្ឌអភិបាលកិច្ចលើការវិនិយោគរបស់ក្រុមហ៊ុន ដើម្បីធានាការអនុលោមតាមគោលការណ៍ផ្ទៃក្នុង ច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងការគ្រប់គ្រងហានិភ័យនៃភាគីម្ខាងទៀត ហានិភ័យប្រមូលផ្តុំ និងហានិភ័យនៃការវិនិយោគឡើងវិញ ខណៈបង្កើនប្រសិទ្ធភាពពីផលចំណេញវិនិយោគ រក្សាទំហំហានិភ័យដែលអាចទទួលយក (Risk Appetite) នៅក្នុងដែនកំណត់បានអនុម័ត។

## ការវិភាគអំពីហានិភ័យនៃការវិនិយោគ

ក្រុមហ៊ុនប្រឈមនឹងហានិភ័យជាច្រើនប្រភេទពីការវិនិយោគ ដែលហានិភ័យទាំងនោះកើតចេញពីលក្ខណៈសម្បត្តិនៃទ្រព្យសកម្មដែលបានកាន់កាប់ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនក្នុងការទូទាត់បំណុលជូនម្ចាស់បណ្ណសន្យារ៉ាប់រង។ ស្របតាមគោលការណ៍វិនិយោគ និងគោលការណ៍គ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេ ហានិភ័យទាំងឡាយរបស់ក្រុមហ៊ុនត្រូវបានតាមដាន និងគ្រប់គ្រងក្រោមក្របខ័ណ្ឌអភិបាលកិច្ច គោលការណ៍ណែនាំលើការវិនិយោគ ការកម្រិតទំហំវិនិយោគ និងការរាយការណ៍ជាប្រចាំ។

# ការវិនិយោគ

## ហានិភ័យទីផ្សារ៖

**ហានិភ័យអត្រាការប្រាក់៖**

ហានិភ័យនៃការប្រែប្រួលអត្រាការប្រាក់ទីផ្សារ អាចប៉ះពាល់ដល់តម្លៃទីផ្សារនៃទ្រព្យសកម្មវិនិយោគផ្តល់ចំណូលថេរ និងក្នុងស្ថានភាពខ្លះ អាចប៉ះពាល់ដល់កម្រិតសាធនភាព និងតម្រូវការដើមទុនរបស់ក្រុមហ៊ុនផងដែរ។ ហានិភ័យនេះត្រូវបានគ្រប់គ្រងតាមរយៈក្របខ័ណ្ឌគ្រប់គ្រងទ្រព្យសកម្ម និង បំណុល (“asset–liability management framework”) ដើម្បីធានាការបំពេញកាតួកិច្ចក្នុងការទូទាត់បំណុលជូនម្ចាស់បណ្ណសន្យារ៉ាប់រងតាមរយៈផលចំណេញប្រកបដោយចីរភាព ពីទ្រព្យសកម្មវិនិយោគ និងរក្សាការពារភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃដើមទុន និងសាធនភាពរបស់ក្រុមហ៊ុន។ ហានិភ័យអត្រាការប្រាក់ក៏ត្រូវបានគ្រប់គ្រង តាមរយៈការតាមដានរយៈពេល (duration) ការវិភាគសេណារីយ៉ូ (scenario analysis) និងការធ្វើតេស្តរេទយិតភាព (sensitivity testing) និង ការកំណត់សំពៀតវិនិយោគប្រកបដោយការប្រុងប្រយ័ត្ន ស្របតាមស្ថានភាពបំណុលរបស់ក្រុមហ៊ុន និង ទំហំហានិភ័យដែលអាចទទួលយក (risk Appetite) ។

---

**ហានិភ័យរូបិយប័ណ្ណ៖**

ហានិភ័យនៃបម្រែបម្រួលអត្រាប្តូររូបិយប័ណ្ណ ដែលអាចផ្តល់ផលអវិជ្ជមានដល់សមត្ថភាពក្នុងការទូទាត់បំណុល ប្រសិនបើមានភាពមិនសមស្របគ្នារវាងរូបិយប័ណ្ណនៃទ្រព្យសកម្ម និងបំណុលធានារ៉ាប់រង។ ក្រុមហ៊ុនកាត់បន្ថយហានិភ័យប្រភេទនេះ ដោយរក្សាសំពៀតវិនិយោគក្នុងរូបិយប័ណ្ណដុល្លារអាមេរិក ដែលដូចគ្នាទៅនឹងរូបិយប័ណ្ណនៃបំណុលធានារ៉ាប់រង។

---

**ហានិភ័យសន្ទនីយភាព៖**

ហានិភ័យនេះកើតឡើងពីកង្វះខាតទ្រព្យសកម្មដែលមានសន្ទនីយភាពគ្រប់គ្រាន់ ដើម្បីទូទាត់បំណុលទៅកាន់ម្ចាស់បណ្ណសន្យារ៉ាប់រង និងភាគីទីបី នៅពេលដល់កំណត់ នៅក្នុងស្ថានភាពទូទៅ និង ស្ថានភាពមានវិបត្តិ។ ហានិភ័យសន្ទនីយភាព រួមមានហានិភ័យដែលបណ្តាលមកពីទ្រព្យសកម្មមិនមានសន្ទនីយភាពដែលមិនអាចបម្លែងជាសា ច់ប្រាក់ដោយងាយស្រួល និងភាពមិនសមស្របគ្នារវាងទ្រព្យសកម្ម និងបំណុល។ ហានិភ័យសន្ទនីយភាពរបស់ក្រុមហ៊ុនត្រូវបានតាមដានដោយប្រើប្រាស់ អនុបាតសន្ទនីយភាព (“Liquidity Coverage Ratio”) ដែលបានកំណត់ដោយបទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ផ្ទៃក្នុង ដោយការធ្វើតេស្តភាពធន់ (stress testing) និងការធ្វើតេស្តរេទយិតភាគ (sensitivity analysis) លើយុទ្ធសាស្រ្តការបែងចែកទ្រព្យសកម្ម និងធ្វើការរាយការណ៍ប្រចាំត្រីមាសជូនគណៈកម្មាធិការវិនិយោគ។

---

**ហានិភ័យឥណទាន៖**

ហានិភ័យឥណទាន គឺជាការខាតបង់ដែលបណ្តាលមកពីការខកខានសងបំណុលរបស់អ្នកខ្ចី និងកើតមាននៅក្នុងការវិនិយោគលើឧបករណ៍បំណុល។ បម្រែបម្រួលនៃគម្លាតឥណទាន (volatility in credit spreads) អាចបង្ហាញពីការធ្លាក់ចុះនៃគុណភាពឥណទាន បើទោះបីការជ្រើសរើសឥណទាន មានភាពប្រុងប្រយ័ត្ន និងឆ្លងកាត់ការជ្រើសរើសយ៉ាងតឹងរ៉ឹង ដោយក្រុមហ៊ុនមានបំណងកាន់កាប់រហូតដល់ឥណប្រតិទាន ក៏ដោយ។ ហានិភ័យនៃភាគីម្ខាងទៀត ដែលជាប្រភេទមួយនៃហានិភ័យឥណទាន គឺជាការខាតបង់ដែលបណ្តាលមកពីភាគីម្ខាងទៀតខកខានក្នុងការបំពេញកាតព្វកិច្ចតាមកិច្ចសន្យា។

ហានិភ័យឥណទាន និង ហានិភ័យឥណទាននៃភាគីម្ខាងទៀត ត្រូវបានគ្រប់គ្រងតាមរយៈការអនុវត្តតាមក្របខ័ណ្ឌវិនិយោគក្នុងស្រុក និងគោលការណ៍ហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេ ការអនុលោមយ៉ាងតឹងរ៉ឹងទៅតាមកម្រិតនៃទំហំវិនិយោគជាមួយភាគីនីមួយៗ និង កម្រិតលើការប្រមូលផ្តុំដែលបានអនុម័ត ដោយផ្តល់អាទិភាពលើដៃគូវិនិយោគដែលមានគុណភាពខ្ពស់ ជាមួយនឹងមូលដ្ឋានគ្រឹះហិរញ្ញវត្ថុរឹងមាំ។ ការប្រឈមនឹងហានិភ័យត្រូវបានតាមដានតាមរយៈការវាយតម្លៃឥណទានប្រចាំគ្រា ដែលទទួលបានការអនុម័តពីគណៈកម្មាធិការវិនិយោគ ការធ្វើពិពិធកម្ម និងការរាយការណ៍ជាប្រចាំជូនគណៈកម្មាធិការ។ ការកើនឡើងនៃហានិភ័យឥណទាន ត្រូវបានចាត់ទុកថាកើតមាននៅពេលដែលចំណាត់ថ្នាក់ឥណទានមានការធ្លាក់ចុះដល់កម្រិតមួយដែលមានភាពមិនសមស្របទៅតាមការកំណត់ ហើយការធ្លាក់ចុះនោះអាចកត់សម្គាល់តាមរយៈការវាយតម្លៃពីភ្នាក់ងារផ្តល់ចំណាត់ថ្នាក់ខាងក្រៅ ការវាយតម្លៃឥណទានផ្ទៃក្នុង ឬការតាមដានប្រវត្តិហានិភ័យឥណទាន។ នៅពេលរកឃើញថាមានការធ្លាក់ចុះនៃគុណភាពឥណទាន វិធានការកាត់បន្ថយហានិភ័យអាចរួមមាន ការកាត់បន្ថយកម្រិតប្រឈម ការកែសម្រួលរយៈពេលវិនិយោគ ឬការផ្ទេរការវិនិយោគទៅកាន់ភាគី ឬឧបករណ៍វិនិយោគផ្សេងទៀតដែលមានលក្ខណៈសម្បត្តិសមស្របតាមលក្ខខណ្ឌ។





# ការវិនិយោគ

## ឱកាសនៃការវិនិយោគ

ទីផ្សារមូលធននៅក្នុងប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលកំពុងអភិវឌ្ឍ ដែលសបង្ហាញឲ្យឃើញពីសក្តានុពលខ្ពស់ក្នុងការពង្រីកវិសាលភាពនៃការវិនិយោគក្នុងស្រុក របស់ក្រុមហ៊ុន នាពេលអនាគត។ ក្រុមហ៊ុននឹងបន្តស្វែងរកឱកាសវិនិយោគយ៉ាងសកម្ម ដើម្បីបង្កើនផលចំណេញពីការវិនិយោគបន្ទាប់ពីទូទាត់ហានិភ័យឥណទាន ខណៈបន្ត រក្សាការពារអត្ថប្រយោជន៍របស់ម្ចាស់បណ្ណសន្យារ៉ាប់រង។

ឱកាសវិនិយោគទាំងនេះរួមមាន ការបង្កើនប្រសិទ្ធភាពនៃការបែងចែកទ្រព្យសកម្មទៅតាមឧបករណ៍ហិរញ្ញវត្ថុដែលទទួលបានការអនុម័ត ការពង្រីករយៈពេលវិនិយោគឲ្យកាន់តែសមស្របសម្រាប់ការផ្គូរផ្គងរវាងទ្រព្យសកម្ម និងបំណុលរបស់ក្រុមហ៊ុន និងការពង្រឹងពិពិធកម្មលើការវិនិយោគតាមវិស័យ និងទីតាំងភូមិសាស្រ្តផ្សេងៗគ្នាផងដែរ។ ក្រុមហ៊ុនក៏នឹងបន្តដើរតួនាទីយ៉ាងសកម្មក្នុងការគាំទ្រដល់ការអភិវឌ្ឍទីផ្សារមូលធនក្នុងស្រុក ដើម្បីរួមចំណែកក្នុងការពង្រីកមូលដ្ឋានអ្នកចូលរួមក្នុងទីផ្សារ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងពង្រីកទីផ្សារវិនិយោគឲ្យកាន់តែធំទូលាយ។

ការវិវត្តន៍ និងការផ្លាស់ប្តូរក្របខ័ណ្ឌបទប្បញ្ញត្តិណាមួយនាពេលអនាគត ដែលផ្តល់ការអនុម័តលើការវិនិយោគក្នុងទ្រព្យសកម្មថ្មី បន្ថែមពីលើទ្រព្យសកម្មដែលទទួលបានការអនុម័តដូចបានចែងក្នុងប្រកាសស្តីពីការអនុញ្ញាតលើការវិនិយោគ នឹងផ្តល់ឱកាសឲ្យក្រុមហ៊ុនអាចវិនិយោគបន្ថែម និងកាន់តែស៊ីជម្រៅលើឧបករណ៍ហិរញ្ញវត្ថុដែលអាចមានសន្ទនីយភាពខ្ពស់ និងច្រើនប្រភេទខុសគ្នា។ ការវិវត្តន៍ទាំងនេះនឹងជួយគាំទ្រដល់ក្រុមហ៊ុនក្នុងការធ្វើពិពិធកម្ម ការគ្រប់គ្រងផលចំណេញបន្ទាប់ពីទូទាត់ហានិភ័យ និងការគ្រប់គ្រងរយៈពេលវិនិយោគ។ ការវិវត្តន៍ណាមួយនឹងត្រូវបានសិក្សា និងវិភាគដោយយកចិត្តទុកដាក់ និងល្អិតល្អន់ សមស្របទៅតាមក្របខ័ណ្ឌអភិបាលកិច្ច ដំណើរការគ្រប់គ្រងហានិភ័យ និងទំហំដែលអាចវិនិយោគបានរបស់ក្រុមហ៊ុន។

## ទស្សនវិស័យវិនិយោគរយៈពេល ៣ ឆ្នាំ

ក្នុងរយៈពេលមធ្យមកាល ក្រុមហ៊ុនរំពឹងថាគោលដៅចម្បងនៃការវិនិយោគនឹងបន្តផ្តោតលើការធានាចំពោះកាតព្វកិច្ចបំណុលជូនម្ចាស់បណ្ណសន្យារ៉ាប់រង ដោយប្រើប្រាស់វិធីសាស្រ្តវិនិយោគប្រកបដោយវិន័យ និងការប្រុងប្រយ័ត្នខ្ពស់។ យុទ្ធសាស្រ្តវិនិយោគនឹងបន្តផ្តោតសំខាន់លើការរក្សាដើមទុន ការគ្រប់គ្រងសន្ទនីយភាព ការទទួលបានផលចំណេញដែលមានស្ថិរភាព ស្របតាមបុគ្គលិកលក្ខណៈ និងរយៈពេលនៃកាតព្វកិច្ចធានារ៉ាប់រងរបស់ក្រុមហ៊ុន។

ដោយផ្អែកលើលក្ខណៈសម្បត្តិនៃទីផ្សារវិនិយោគក្នុងស្រុក និងបរិបទបទប្បញ្ញត្តិ ការបែងចែកទ្រព្យសកម្មត្រូវបានរំពឹងថានឹងបន្តផ្តោតចម្បងលើឧបករណ៍ហិរញ្ញវត្ថុផ្តល់ចំណូលថេរ រួមមានប្រាក់បញ្ញើនៅធនាគារ និងមូលបត្របំណុលដែលមានគុណភាពខ្ពស់ និងទទួលបានការអនុម័ត។ ក្រុមហ៊ុននឹងបន្តតាមដានស្ថានភាពទីផ្សារ និងការវិវឌ្ឍន៍នៃស្ថានភាពបំណុលធានារ៉ាប់រងរបស់ខ្លួន និងធ្វើការកែប្រែការបែងចែងទ្រព្យសកម្មវិនិយោគ នៅពេលសមស្រប ដើម្បីបំពេញនូវតម្រូវការរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង និងសមស្របទៅតាមទំហំហានិភ័យដែលអាចទទួលយក (risk appetite) របស់ក្រុមហ៊ុន។

ប្រសិនបើមានឱកាសវិនិយោគថ្មីៗកើតមានឡើង យុទ្ធសាស្រ្តវិនិយោគនឹងត្រូវបានកែសម្រួលទៅតាមស្ថានភាពសមស្រប ដោយមានការពិចារណាដូចដែលបានរៀបរាប់ផ្នែកខាងលើ ខណៈពេលដែលនៅតែរក្សាការសមស្របជាមួយបំណុលរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង និងទំហំហានិភ័យដែលអាចទទួលយករបស់ក្រុមហ៊ុន។



## ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង

ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង (Insurance Technical Reserves) ត្រូវបានបង្កើតឡើង ដើម្បីធានាថាមានមូលនិធិគ្រប់គ្រាន់សម្រាប់បំពេញកាតព្វកិច្ចទាំងអស់នាពេលអនាគត ដែលកើតឡើងពីកិច្ចសន្យាធានារ៉ាប់រងដែលកំពុងមានសុពលភាព។ ប្រាក់បម្រុងទាំងនេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រវាយតម្លៃបុព្វលាភសរុប (Gross Premium Valuation – GPV) ដោយមានភាពប្រុងប្រយ័ត្ន ហើយតំណាងឱ្យការប៉ាន់ប្រមាណល្អបំផុតរបស់ Actuary ចំពោះបំណុលនាពេលអនាគត រួមទាំងការបន្ថែមកម្រិតសមស្រប តាមដែលបទប្បញ្ញត្តិកំណត់។



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | **ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម** | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

# ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង

## ការផ្លាស់ប្តូរនៃប្រាក់បម្រុង

បំណុលសរុបរបស់ព្រូដិនសលកម្ពុជារួមមានប្រាក់បម្រុងសរុប និង បំណុលផ្សេងៗទៀត។ ប្រាក់បម្រុងសរុបរួមមានប្រាក់បម្រុងតាមវិធីសាស្ត្រវាយតម្លៃបុព្វលាភធានារ៉ាប់រងដុល (GPV) ឬប្រាក់បម្រុងគណិតវិទ្យា ប្រាក់បម្រុងតាមវិធីសាស្ត្របុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល (UPR) ប្រាក់បម្រុងសំណងធានារ៉ាប់រងដែលបានកើតឡើងប៉ុន្តែមិនទាន់ទទួលរបាយការណ៍ (IBNR) និងប្រាក់បម្រុងសំណងធានារ៉ាប់រងដែលទទួលរបាយការណ៍ប៉ុន្តែមិនទាន់បានទូទាត់ (RBNS) ដូចខាងក្រោម:

| ល.រ. | បរិយាយ | ឆ្នាំ2025 | ឆ្នាំ2024 |
|---|---|---|---|
| 1 | **ទ្រព្យសកម្មសរុបដែលអនុញ្ញាត (A)** | **403.8** | **359.5** |
| 2 | **បំណុលសរុប (L)** | **368.6** | **322.0** |
| | វិធីសាស្ត្រវាយតម្លៃបុព្វលាភធានារ៉ាប់រងដុល (GPV) | 352.4 | **300.1** |
| | វិធីសាស្ត្របុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល (UPR) | 0.2 | 0.2 |
| | ប្រាក់បម្រុងសំណងធានារ៉ាប់រងដែលបានកើតឡើងប៉ុន្តែមិនទាន់ទទួលរបាយការណ៍ (IBNR) | 0.0 | 0.0 |
| | ប្រាក់បម្រុងសំណងធានារ៉ាប់រងដែលទទួលរបាយការណ៍ប៉ុន្តែមិនទាន់បានទូទាត់ (RBNS) | 0.7 | 0.7 |
| | *ប្រាក់បម្រុងសរុប* | **353.3** | **301.0** |
| | *បំណុលផ្សេងៗទៀត* | **15.1** | **21.0** |
| 3 | **ទ្រព្យសកម្មសុទ្ធ (NA = A – L)** | 35.2 | 37.5 |

## ប្រាក់បម្រុងគណិតវិទ្យាសុទ្ធ

| ល.រ. | បរិយាយ | ឆ្នាំ2025 | ឆ្នាំ2024 |
|---|---|---|---|
| 1 | ប្រាក់បម្រុងគណិតវិទ្យាដុល | 352.9 | 300.6 |
| 2 | ប្រាក់បម្រុងគណិតវិទ្យា តាមរយៈការធានារ៉ាប់រងបន្ត | 0.5 | 0.5 |
| 3 | ប្រាក់បម្រុងគណិតវិទ្យាសុទ្ធ | 352.4 | 300.1 |
| 4 | ប្រាក់បម្រុងគណិតវិទ្យាសុទ្ធ/ប្រាក់បម្រុងគណិតវិទ្យាដុល | 100% | 100% |
| | **ប្រាក់បម្រុងគណិតវិទ្យាសុទ្ធត្រូវកំណត់យ៉ាងតិច ៨៥%នៃប្រាក់បម្រុងគណិតវិទ្យាដុល** | **352.4** | **300.1** |

## ប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ

| ល.រ. | បរិយាយ | ឆ្នាំ2025 | ឆ្នាំ2024 |
|---|---|---|---|
| 1 | ប្រាក់ធានារ៉ាប់រងតាមហានិភ័យដុល | 4,368.5 | 5,911.5 |
| 2 | ប្រាក់ធានារ៉ាប់រងតាមហានិភ័យ តាមរយៈការធានារ៉ាប់រងបន្ត | 530.7 | 972.4 |
| 3 | ប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ | 3,837.8 | 4,939.0 |
| 4 | ប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ/ប្រាក់ធានារ៉ាប់រងតាមហានិភ័យដុល | 88% | 84% |
| | **ប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធត្រូវកំណត់យ៉ាងតិច ៥០%នៃប្រាក់ធានារ៉ាប់រងតាមហានិភ័យដុល** | **3,837.8** | **4,939.0** |

## សាធនភាពតម្រូវតាមហានិភ័យ

| | | |
|---|---|---|
| (ក.) ៤% នៃប្រាក់បម្រុងគណិតវិទ្យាសុទ្ធ | **14.1** | **14.8** |
| (ខ.) ០,៣% នៃប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ | **11.5** | **12.0** |
| *សាធនភាពតម្រូវតាមហានិភ័យ = (ក+ខ)* | 25.6 | 26.8 |

- សាធនភាពតម្រូវតាមហានិភ័យបានថយចុះក្នុងឆ្នាំ2025 ដែលជាចម្បងបណ្តាលមកពីការថយចុះនៃប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ។ ទោះយ៉ាងណា ការថយចុះនេះត្រូវបានបន្ថយដោយការកើនឡើងនៃប្រាក់បម្រុងគណិតវិទ្យាសុទ្ធ។ដើមទុនតម្រូវនៅតែអនុវត្តតាមវិធាន ដែលបានកំណត់តាមបទប្បញ្ញត្តិ លើប្រាក់បម្រុងគណិតវិទ្យាសុទ្ធ និងប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ ។
- ការថយចុះនៃសាធនភាពតម្រូវតាមហានិភ័យបង្ហាញថា កម្រិតហានិភ័យសរុបរបស់ក្រុមហ៊ុនមានការថយចុះ បើប្រៀបធៀបនឹងឆ្នាំ 2024។

# លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម

ក្នុងឆ្នាំ 2025 ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) សម្រេចបាននូវសមិទ្ធផលការងារដ៏រឹងមាំ និងឈរជើងបានយ៉ាងគង់វង្សក្នុងទីផ្សារធានារ៉ាប់រង ទោះបីជាមានការប្រឈមនឹងបរិបទដ៏តានតឹង និងសម្ពាធពីមជ្ឈដ្ឋានខាងក្រៅ។ ចំណូលបុព្វលាភធានារ៉ាប់រងសរុប សម្រាប់ឆ្នាំនេះ មានចំនួន 72,3 លានដុល្លារអាមេរិក (បន្ទាប់ពីដកបុព្វលាភធានារ៉ាប់រងបន្ត) បើធៀបនឹងចំនួន 83,4 លានដុល្លារអាមេរិក ក្នុងឆ្នាំ 2024។ ការថយចុះ ១៣% ធៀបនឹងឆ្នាំមុននេះ គឺឆ្លុះបញ្ចាំងពីស្ថានភាពនៃផលប៉ះពាល់ផ្នែកវិបត្តិម៉ាក្រូសេដ្ឋកិច្ចទៅលើអាជីវកម្មវិស័យធានារ៉ាប់រងក្នុងស្រុក ស្របគ្នានឹងភាពតានតឹងនៃវិបត្តិម៉ាក្រូសេដ្ឋកិច្ច ក្រុមហ៊ុនមានការផ្លាស់ប្តូរយុទ្ធសាស្រ្តពីការជំរុញកំណើនដែលផ្អែកលើបរិមាណ មកជាអាជីវកម្មប្រកបដោយនិរន្តរភាព និងផ្តោតលើគុណភាពវិញ។ ក្នុងកំឡុងឆ្នាំ 2025 ក្រុមហ៊ុននៅតែដើរតួជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនាំមុខ ស្របពេលដែរមានការផ្តោតសំខាន់ទៅលើការវាយតម្លៃហានិភ័យធានារ៉ាប់រង ពិនិត្យ វិភាគ និងវាយតម្លៃ លើប្រវត្តិ ក៏ដូចជាកម្រិតហានិភ័យរបស់អតិថិជនម្នាក់ៗ ដើម្បីធានាឱ្យបាននូវការផ្តល់ជូនសំណងដែលអតិថិជនទទួលបានទៅថ្ងៃអនាគត គឺពិតជាមានតម្លៃ និងឆ្លើយតបទៅនឹងអ្វីដែលអតិថិជនបានវិនិយោគជាមួយក្រុមហ៊ុន។




ក្រុមហ៊ុនបានបង្ហាញពីចីរភាពនៃការប្រើប្រាស់ថវិកា ការគ្រប់គ្រង និងការកាត់បន្ថយចំណាយមិនចាំបាច់ផ្សេងៗប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងឆ្នាំ 2025 ។ ស្របគ្នានេះដែរចំណាយប្រតិបត្តិការ និងរដ្ឋបាលបានថយចុះប្រហែល 18% ប្រៀបធៀបទៅនឹងឆ្នាំមុន ដោយមានចំនួនចំណាយសរុប 33.1 លានដុល្លារអាមេរិក ក្នុងឆ្នាំ 2025 (ឆ្នាំ 2024៖ 40.4 លានដុល្លារអាមេរិក)។ ការថយចុះចំណាយប្រតិបត្តិការបានឆ្លុះបញ្ចាំងពីភាពវិជ្ជមានលើវិធានការគ្រប់គ្រងចំណាយសកម្ម និងការកែលម្អផលិតភាព រួមបញ្ចូលនូវការរៀបចំ កែសម្រួល និងកាត់បន្ថយរាល់ចំណាយប្រតិបត្តិការទូទៅដែរមិនមានគ្រោងក្នុងប្រតិបត្តិការចំណាយ។ អនុបាតចំណាយក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុមានការប្រសើរឡើង 45.8% ធៀបនឹង 48.4% ក្នុងឆ្នាំ 2024 ដែលបង្ហាញការគ្រប់គ្រងចំណាយ និងការកែលម្អផលិតភាពដ៏រឹងមាំ។ សកម្មភាពនៃការកែលម្អផលិតភាពហាក់បានកាត់បន្ថយនៃចំណូលប្រចាំឆ្នាំ បុ◌ន្តែបានសាងមូលដ្ឋានដ៏រឹងមាំសម្រាប់ការរីកចម្រើននាពេលអនាគត។







ទោះបីជាស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចដ៏តានតឹង ក៏ក្រុមហ៊ុននៅតែអាចរក្សាបាននូវប្រាក់ចំណេញក្នុងឆ្នាំ 2025។ ប្រាក់ចំណេញសុទ្ធក្រោយកាត់ពន្ធសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះមានចំនួន 0.98 លានដុល្លារអាមេរិក បើប្រៀបធៀបនឹងចំនួន 3.54 លានដុល្លារអាមេរិក ក្នុងឆ្នាំ 2024។ សម្ពាធពីមជ្ឈដ្ឋានខាងក្រៅបានប្រែក្លាយការថយចុះចំណូលបុព្វលាភរ៉ាប់រងទៅជាឱកាសក្នុងការពង្រឹងយុទ្ធសាស្រ្តអាជីវកម្ម ដោយផ្តោតលើវិធានការគ្រប់គ្រងគុណភាពអាជីវកម្មឆ្ពោះទៅរកផលចំណេញយូរអង្វែង។ ក្នុងស្ថានភាពសេដ្ឋកិច្ចដ៏តានតឹង ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) បានបង្ហាញពីភាពចាស់ទុំក្នុងការគ្រប់គ្រងហានិភ័យយ៉ាងប្រុងប្រយ័ត្ន ដោយសម្រេចបាននូវប្រាក់ចំណេញរយៈពេល ៦ ឆ្នាំជាប់ៗគ្នា។ ផលលាភពីមូលធនរបស់ក្រុមហ៊ុននៅតែស្ថិតក្នុងកម្រិតវិជ្ជមានពោលគឺ 1.0% (ឆ្នាំ 2024៖ 3.8%) និងកម្រិតប្រាក់ចំណេញនៅតែវិជ្ជមានពោលគឺ 1% បើទោះបីជាមានការកែទម្រង់រចនាសម្ព័ន្ធ ដោយផ្តោតទៅលើនិរន្តរភាពបណ្តូលសន្យារ៉ាប់រង និងពង្រឹងយុទ្ធសាស្រ្តអាជីវកម្មនឹងវិធានការគ្រប់គ្រងអាជីវកម្មដ៏យូរអង្វែង។ ស្ថានភាពមូលធននៃដើមទុនដ៏រឹងមាំរបស់ក្រុមហ៊ុន បានសបញ្ជាក់ឱ្យឃើញនៅភាពធន់ក្នុងការគ្រប់គ្រងហានិភ័យ ស្របជាមួយនឹងកម្រិតអនុបាតសាធនភាព ដែលស្ថិតនៅខ្ពស់ជាងតម្រូវការបទប្បញ្ញត្តិយ៉ាងខ្លាំង។ ក្នុងការបោះជំហានទៅមុខក្នុងបរិបទធុរកិច្ចឆ្នាំ 2026 បានបង្ហាញនៅស្ថានភាពហិរញ្ញវត្ថុប្រកបដោយស្ថេរភាព និងផ្តោតការយកចិត្តទុកដាក់លើការរក្សាតុល្យភាពរវាងកំណើនអាជីវកម្ម ជាមួយនឹងយុទ្ធសាស្រ្តពង្រីកអាជីវកម្ម និងការជម្រុញការលក់ឱ្យកាន់តែមានផលិតភាពខ្លាំងក្លា ភ្ជាប់ជាមួយនឹងការគ្រប់គ្រងចំណាយចំគោលដៅ ដើម្បីបង្កើនប្រាក់ចំណេញប្រកបដោយលំនឹងយូរអង្វែង។

## ដំណើរការទាមទារសំណង

ចាប់តាំងពីឆ្នាំ2013មក ក្រុមហ៊ុនព្រូដិនសលកម្ពុជា បានផ្តល់ការការពារធានារ៉ាប់រងដល់អតិថិជនជិតកន្លះលាននាក់ និង

**បានអនុម័តសំណងប្រមាណ**

**33.4**

**លានដុល្លារអាមេរិក**

គិតត្រឹមខែមេសា ឆ្នាំ2026 ដែលឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនចំពោះការការពាររបស់អតិថិជន។



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | **ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម** | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

# លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម

### ការសន្យាលើ ការផ្តល់សំណង

បណ្ណសន្យារ៉ាប់រងរបស់ព្រូដិនសលកម្ពុជា បានការពារអតិថិជន និងក្រុមគ្រួសាររបស់អតិថិជន ក្នុងពេលវេលាមួយដែលជីវិតយើងជួបប្រទះនូវហេតុការណ៍អកុសលដែលមិនបានព្រៀងទុក។ យើងខ្ញុំបានផ្តល់សេវាលើការទូទាត់សំណងយ៉ាងឆាប់រហ័ស និងប្រកបដោយការយកចិត្តទុកដាក់ជាទីបំផុត។ យើងខ្ញុំបានផ្តល់ជូននូវសេវាកម្មដែលមានភាពសាមញ្ញ និងងាយស្រួល ដោយការស្នើសុំតែព័ត៌មានណាដែលចាំបាច់ប៉ុណ្ណោះសម្រាប់ដំណើរការនៃការទាមទារសំណងរបស់អតិថិជន។

### របៀបដែលយើងនឹងផ្តល់ជូន<br>វិធីសាស្រ្តរបស់យើង

ដំណើរការនៃការទាមទារសំណងរបស់យើងគឺមានភាពសាមញ្ញ និងតម្លាភាព។ បុគ្គលិក និងភ្នាក់ងាររបស់យើងទាំងអស់ ត្រូវបានបណ្តុះបណ្តាលយ៉ាងស្ទាត់ជំនាញ ដើម្បីជួយអ្នកប្រកបដោយវិជ្ជាជីវៈ ភាពស្និទ្ធស្នាល និង រួសរាយរាក់ទាក់។

### នៅពេលដែលអ្នកធ្វើការទាមទារសំណង

យើងនឹងធ្វើការវាយតម្លៃ និងផ្តល់ជូននូវសំណងលើករណីនីមួយៗ ដោយយកចិត្តទុកដាក់ជាទីបំផុត។ យើងនឹងធ្វើការស្នើសុំព័ត៌មានណាដែលពាក់ព័ន្ធ និងធ្វើបច្ចុប្បន្នភាពជូនអ្នកជានិច្ច អំពីដំណើរការនៃការទាមទារសំណងរបស់អ្នក នៅពេលដែលអ្នកត្រូវការ។ យើងផ្តល់ជូនការពន្យល់អំពីការសម្រេចចិត្តរបស់យើងលើការទាមទារសំណងរបស់អ្នកដែលងាយស្រួលយល់ និងមានភាពច្បាស់លាស់។

### ការប្តេជ្ញាចិត្តរបស់យើង

**ភាពទាន់ពេលវេលា**

យើងដោះស្រាយការទាមទារសំណងនីមួយៗភ្លាមៗនៅពេលដែលយើងទទួលបានសំណើរ ហើយនឹងបន្តផ្តល់ព័ត៌មានជូនអតិថិជនរបស់យើងអំពីវឌ្ឍនភាពនៃដំណើរការនេះ។

**ការទំនាក់ទំនងដោយយកចិត្តទុកដាក់**

ក្រុមហ៊ុនជូនដំណឹងដល់អតិថិជនរបស់យើង នៅពេលយើងទទួលបានការទាមទារសំណងរបស់ពួកគាត់ នៅពេលត្រូវការឯកសារបន្ថែម និងអំពីលទ្ធផលនៃការទាមទារសំណងនោះ។ បុគ្គលិក និងភ្នាក់ងាររបស់យើងត្រូវបានបណ្តុះបណ្តាលយ៉ាងជំនាញ ដើម្បីជួយណែនាំ។

**បទពិសោធន៍អតិថិជន**

មតិកែលម្អរបស់អ្នកគឺមានសារៈសំខាន់ដើម្បីជួយក្រុមហ៊ុនបម្រើអ្នកបានកាន់តែប្រសើរ។ ប្រសិនបើអ្នកមានពាក្យ បណ្តឹង យើងនឹងដោះស្រាយវាដោយយកចិត្តទុកដាក់។

**ភាពត្រឹមត្រូវ និងយុត្តិធម៌**

ក្រុមហ៊ុនយល់ច្បាស់ថាការទាមទារសំណងរបស់អតិថិជនគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ពួកគាត់។។ យើងផ្តល់សេវាចំពោះអតិថិជនគ្រប់រូបដោយយុត្តិធម៌។ ដំណើរការការទាមទារសំណងរបស់យើងគឺច្បាស់លាស់ មានតម្លាភាព និងមិនមានភាពលំអៀងចំពោះអតិថិជនឡើយ។

**ភាពឯកជន**

យើងយកចិត្តទុកដាក់ខ្ពស់បំផុតលើឯកជនភាពរបស់អតិថិជនរបស់យើង ហើយនឹងការពារព័ត៌មានទាំងនោះគ្រប់ពេលវេលា។




ក្រុមហ៊ុនព្រូដិនសលកម្ពុជា មានទីតាំងស្ថិតនៅចំណែកឯកជន L១៩ L២០ និង L២១ នៃជាន់ទី១៩ ២០ និង២១ អគារជីបម៉ុង ថៅវើ។

*រូបភាពនេះសម្រាប់តែគោលបំណងបង្ហាញប៉ុណ្ណោះ។*



# ធានារ៉ាប់រងបន្ត

## យុទ្ធសាស្ត្រធានារ៉ាប់រងបន្ត៖

ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) បានអនុវត្តការធានារ៉ាប់រងបន្ត ដើម្បីគ្រប់គ្រង និង កាត់បន្ថយហានិភ័យទាក់ទងនឹងការទាមទារសំណងទៅលើករណីមរណភាព ពិការភាព គ្រោះថ្នាក់ និង ជំងឺ ដែលជួយរក្សាលំនឹងស្ថានភាពហិរញ្ញវត្ថុ និងកម្រិតសោធនភាពរបស់ក្រុមហ៊ុន។

យុទ្ធសាស្ត្រធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុនព្រូដិនសល បានពិចារណាយ៉ាងសមស្របទៅលើកត្តាដូចខាងក្រោម៖

- ប្រភេទនៃកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត ត្រូវស្របតាមគោលបំណង និងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យទាំងមូលរបស់ក្រុមហ៊ុន
- ទំហំទុនបម្រុងធានារ៉ាប់រងរបស់ក្រុមហ៊ុន និងសមត្ថភាពទូទាត់សំណងអត្ថប្រយោជន៍ដែលមានទំហំធំ
- ការវិភាគបទពិសោធន៍នៃការទូទាត់សំណងជាក់ស្តែង ប្រៀបធៀបនឹងការរំពឹងទុក ផ្អែកតាមទិន្នន័យដែលអាចប្រើប្រាស់បាន
- សមត្ថភាព និងលទ្ធភាពរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តដែលមានក្រុមការងារមានជំនាញខ្ពស់ក្នុងការផ្តល់ជំនួយបច្ចេកទេស និងការបណ្តុះបណ្តាល ទាក់ទងនឹងការបង្កើតផលិតផលថ្មី និង ការគ្រប់គ្រងហានិភ័យកំពុងកើតមានជាដើម
- ការអនុវត្តក្នុងវិស័យ និងការអនុលោមទៅតាមបទបញ្ញត្តិច្បាប់ដែលជាធរមាន
- ដើមទុនរបស់ម្ចាស់ភាគហ៊ុនដែលអាចប្រើប្រាស់បាន និងទំហំហានិភ័យដែលក្រុមហ៊ុនព្រូដិនសលអាចទទួលយកបាន (risk appetite)
- តម្លៃធានារ៉ាប់រងបន្ត (អត្រាបុព្វលាភធានារ៉ាប់រងបន្ត)



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | **ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម** | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

# ធានារ៉ាប់រងបន្ត

ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) កំណត់កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តឲ្យសមស្រប តាមលក្ខខណ្ឌហានិភ័យរបស់ផលិតផល និងអាជីវកម្មនីមួយៗ ដែលអាចមានដូចខាងក្រោម៖

**កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តបែបមិនសមាមាត្រ (Surplus Arrangement) ៖**

- កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តបែបមិនសមាមាត្រ សំដៅលើការផ្ទេរហានិភ័យធានារ៉ាប់រងដែលលើសពីកម្រិតដែលក្រុមហ៊ុនអាចទទួលយកបាន ទាក់ទងនឹងហានិភ័យដូចជា មរណភាព ឬ ពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ (TPD)។
- ក្រុមហ៊ុនព្រូដិនសលកម្ពុជា ក៏អាចជ្រើសរើសកម្រិតរក្សាទុកហានិភ័យ (retention limit) ខុសៗគ្នាសម្រាប់ផលិតផលផ្សេងៗដែលមានហានិភ័យស្រដៀងគ្នា បន្ទាប់ពីពិចារណាទៅលើបណ្តាញចែកចាយ កម្រិតការវិនិច្ឆ័យការចេញបណ្ណសន្យារ៉ាប់រង(underwriting) របស់ផលិតផលនោះ ព្រមទាំងកត្តាផ្សេងៗទៀតដែលពាក់ព័ន្ធ។
- 

**កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តបែបសមាមាត្រ (Quota Share Arrangement) ៖**

- កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តបែបសមាមាត្រ សំដៅលើការបែងចែកហានិភ័យជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្ត តាមអនុបាត ឬ សមាមាត្រថេរ។ កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តនេះ ជាទូទៅត្រូវបានអនុវត្តទៅលើប្រភេទហានិភ័យកំណត់ជាក់លាក់ណាមួយ ដូចជា អត្ថប្រយោជន៍ដោយគ្រោះថ្នាក់ចៃដន្យ អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរ និងអត្ថប្រយោជន៍វេជ្ជសាស្ត្រជាដើម។
- ក្រុមហ៊ុនក៏អាចសម្រេចអនុវត្តការលាយបញ្ចូលគ្នារវាងកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តបែបមិនសមាមាត្រ (Surplus) និង សមាមាត្រ (Quota share) ទៅលើហានិភ័យដូចគ្នា ដោយអាស្រ័យលើកម្រិតហានិភ័យដែលក្រុមហ៊ុនអាចទទួលយកបាន ស្ថានភាពហិរញ្ញវត្ថុ និងកត្តាផ្សេងៗទៀតដែលពាក់ព័ន្ធ។

**កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តលើហានិភ័យគ្រោះមហន្តរាយ (ការខាតបង់លើសកំណត់) (Catastrophe Excess of Loss Arrangement) ៖**

- កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តលើហានិភ័យគ្រោះមហន្តរាយ សំដៅលើការផ្ទេរហានិភ័យជាលក្ខណៈទ្រង់ទ្រាយធំ ដែលកើតមកពីព្រឹត្តិការណ៍គ្រោះមហន្តរាយដូចជា ទឹកជំនន់ រញ្ជួយដី និង គ្រោះមហន្តរាយផ្សេងៗទៀត។ កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តនេះ ផ្តល់ការធានារ៉ាប់រងលើករណីមរណភាព និងពិការភាព ដែលបណ្តាលមកពីព្រឹត្តិការណ៍គ្រោះមហន្តរាយទាំងនោះ។

យុទ្ធសាស្ត្រធានារ៉ាប់រងបន្តរបស់យើង ស្របតាមគោលការណ៍របស់ក្រុមហ៊ុនព្រូដិនសលគ្រុប ព្រមទាំងអនុលោមទៅតាមបទបញ្ញត្តិច្បាប់ដែលជាធរមាន។

## ការជ្រើសរើស និងការវាយតម្លៃក្រុមហ៊ុនធានារ៉ាប់រងបន្ត ៖

ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) ធ្វើការពិចារណាជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងបន្តដែលសមស្របសម្រាប់អាជីវកម្ម ដោយផ្អែកលើកត្តាដូចខាងក្រោម៖

- អនុវត្តតាម បទបញ្ញត្តិច្បាប់ដែលជាធរមាន និង គោលការណ៍របស់ក្រុមហ៊ុនព្រូដិនសលគ្រុប ។
- ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងចំណាត់ថ្នាក់ឥណទានរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត៖ ក្រុមហ៊ុនព្រូដិនសលកម្ពុជា នឹងជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងបន្តណាដែលមានចំណាត់ថ្នាក់អត្រាហិរញ្ញប្បទាន ស្របតាមតម្រូវការបទបញ្ញត្តិច្បាប់ដែលជាធរមានព្រមទាំងគោលការណ៍របស់ក្រុមហ៊ុនព្រូដិនសលគ្រុប។
- តម្លៃធានារ៉ាប់រងបន្ត៖ នេះគឺជាសេចក្តីសម្រេចផ្នែកពាណិជ្ជកម្ម ក្នុងការជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងបន្តដែលមានតម្លៃសមរម្យ ដើម្បីធ្វើឲ្យមានតុល្យភាពរវាងតម្លៃ និងអត្ថប្រយោជន៍។
- ជំនាញ និងសមត្ថភាពរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត ក្នុងការគាំទ្រការអភិវឌ្ឍផលិតផលធានារ៉ាប់រង ការវិនិច្ឆ័យការចេញបណ្ណសន្យារ៉ាប់រង (underwriting) ការវិនិច្ឆ័យការទាមទារសំណង និង ដំណើរការប្រតិបត្តិការផ្សេងៗទៀត។
- ភាពបត់បែន និងភាពស្របគ្នានៃរចនាសម្ព័ន្ធ ព្រមទាំងខ និងលក្ខខណ្ឌរបស់ការធានារ៉ាប់រងបន្ត ជាមួយនឹងយុទ្ធសាស្ត្រផលិតផល និងអាជីវកម្មទូទៅរបស់ក្រុមហ៊ុន។

**កត្តាទាំងលើនេះគឺជាយុទ្ធសាស្ត្រធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុនព្រូដិនសលកម្ពុជា តាំងពីការចាប់ផ្តើមប្រតិបត្តិការដំបូងរបស់យើងរហូតដល់ពេលបច្ចុប្បន្ន ដោយពុំមានការផ្លាស់ប្តូរអ្វីគួរឲ្យកត់សម្គាល់ឡើយ។ ក្រុមហ៊ុនព្រូដិនសលកម្ពុជានឹងបន្តធ្វើការត្រួតពិនិត្យលើប្រសិទ្ធភាពតម្លៃធានារ៉ាប់រងបន្ត ដែលជាផ្នែកនៃការគ្រប់គ្រងការធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុន។**

# ការគ្រប់គ្រងហានិភ័យ

## ទស្សនវិស័យទូទៅនៃវិធីសាស្ត្រគ្រប់គ្រងហានិភ័យ

ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) ធានារ៉ាប់រងអាយុជីវិតកម្ពុជា ប្រតិបត្តិការក្រោមក្របខណ្ឌគ្រប់គ្រងហានិភ័យទូទាំងសហគ្រាសរបស់ ព្រូដិនសលគ្រុប ដែលត្រូវបានរចនាឡើងដើម្បីគាំទ្រការបង្កើតតម្លៃប្រកបដោយចីរភាព ខណៈពេលការពារផលប្រយោជន៍របស់ម្ចាស់បណ្ណសន្យារ៉ាប់រង ម្ចាស់ភាគហ៊ុន និយ័តករ បុគ្គលិក និងសហគមន៍ទូទៅ។ ក្របខណ្ឌនេះលើកកម្ពស់វិធីសាស្ត្រដែលមានវិន័យ មានទស្សនវិស័យទៅមុខ និងមានសមមូលភាពក្នុងការគ្រប់គ្រងហានិភ័យ ដោយពិចារណាអំពីបរិបទប្រតិបត្តិការ និងបទប្បញ្ញត្តិមូលដ្ឋាននៅកម្ពុជា។

ការគ្រប់គ្រងហានិភ័យត្រូវបានបញ្ចូលជាផ្នែកមួយនៃការធ្វើផែនការអាជីវកម្ម ការធ្វើសេចក្តីសម្រេចចិត្ត និងប្រតិបត្តិការប្រចាំថ្ងៃ។ ហានិភ័យត្រូវបានសម្គាល់ វាយតម្លៃ គ្រប់គ្រង និងត្រួតពិនិត្យជាបន្តបន្ទាប់ ដោយមានរចនាសម្ព័ន្ធអភិបាលកិច្ច និងការទទួលខុសត្រូវច្បាស់លាស់។ វិធីសាស្ត្រនេះគាំទ្រដល់ភាពអាចអនុវត្តការបានរបស់ប្រតិបត្តិការ ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

### វដ្តនៃការគ្រប់គ្រងហានិភ័យ

ដំណើរការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុនព្រូដិនសលធានារ៉ាប់រងអាយុជីវិតកម្ពុជាប្រព្រឹត្តទៅតាមវដ្តជាបន្តបន្ទាប់ ដែលមានសមាសភាគដូចខាងក្រោម៖

- **ការសម្គាល់ហានិភ័យ៖** ការសម្គាល់ហានិភ័យសំខាន់ និងហានិភ័យកើតឡើងថ្មីៗ តាមរយៈការវាយតម្លៃពីលើចុះក្រោម និងពីក្រោមឡើងលើ រួមទាំងការពិចារណាអំពីការផ្លាស់ប្តូរនៅក្នុងបរិយាកាសខាងក្រៅ។
- **ការវាយតម្លៃហានិភ័យ៖** ការវាយតម្លៃហានិភ័យផ្អែកលើផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការ កេរ្តិ៍ឈ្មោះ និងបទប្បញ្ញត្តិ។
- **ការត្រួតពិនិត្យ និងបន្ថយហានិភ័យ៖** ការអនុវត្តគោលនយោបាយ ការត្រួតពិនិត្យ និងសកម្មភាពគ្រប់គ្រង ដើម្បីរក្សាហានិភ័យឱ្យស្ថិតក្នុងកម្រិតអាចទទួលយកបាន។
- **ការតាមដាន និងរាយការណ៍៖** ការរាយការណ៍ជាប្រចាំទៅកាន់អ្នកគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល អំពីការប៉ះពាល់ហានិភ័យសំខាន់ និងបញ្ហាថ្មីៗដែលកំពុងកើតឡើង។

ការធ្វើតេស្តសម្ពាធ និងការវិភាគសេណារីយោ ត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃភាពរឹងមាំ នៅក្រោមស្ថានការណ៍អវិជ្ជមានតែអាចកើតមានបាន ដើម្បីគាំទ្រការគ្រប់គ្រងមូលនិធិ និងសាច់ប្រាក់សាច់ដៃ ព្រមទាំងផែនការបន្តអាជីវកម្ម។

### អភិបាលកិច្ច និងវប្បធម៌ហានិភ័យ

ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) ធានារ៉ាប់រងអាយុជីវិតកម្ពុជា អនុវត្តគំរូ “ខ្សែការពារបីជួរ” នៃអភិបាលកិច្ចហានិភ័យរបស់ គ្រុប ដូចខាងក្រោម៖

- **ជួរទីមួយ៖** នាយកដ្ឋាននានាដែលគ្រប់គ្រង និងម្ចាស់របស់ហានិភ័យក្នុងកម្រិតដែលបានអនុម័ត។
- **ជួរទីពីរ៖** នាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាម ដែលមានឯករាជ្យ ផ្តល់ការត្រួតពិនិត្យ ការបញ្ចេញមតិបញ្ហា និងជំនាញជាក់លាក់។
- **ជួរទីបី៖** សវនកម្មផ្ទៃក្នុង ផ្តល់ការធានាឯករាជ្យអំពីប្រសិទ្ធភាពនៃអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងផ្ទៃក្នុង។

វប្បធម៌ហានិភ័យដ៏រឹងមាំត្រូវបានលើកកម្ពស់តាមរយៈគោលនយោបាយច្បាស់លាស់ ស្តង់ដារសីលធម៌ និងការទទួលខុសត្រូវរបស់បុគ្គលិក។ ការប្រព្រឹត្តិដោយសុចរិតភាព យុត្តិធម៌ចំពោះអតិថិជន និងការពិចារណាអំពីចីរភាព ត្រូវបានបញ្ចូលក្នុងការគ្រប់គ្រងប្រសិទ្ធភាពការងារ និងការធ្វើសេចក្តីសម្រេចចិត្ត។ បុគ្គលិកត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍បញ្ហាតាមប្រព័ន្ធ “Speak Out” ដែលបានកំណត់ ដើម្បីគាំទ្រតម្លាភាព និងភាពស្មោះត្រង់។

### កម្រិតហានិភ័យដែលអាចទទួលយកបាន

ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) ធានារ៉ាប់រងអាយុជីវិតកម្ពុជាប្រតិបត្តិការក្រោមក្របខណ្ឌកម្រិតហានិភ័យដែលអាចទទួលយកបានដែលបានកំណត់យ៉ាងច្បាស់ស្របតាមគោលការណ៍របស់ Group និងការរំពឹងទុករបស់អាជ្ញាធរបទប្បញ្ញត្តិមូលដ្ឋាន។ ក្របខណ្ឌនេះថ្លឹងថ្លែងរវាងហានិភ័យ និងប្រាក់ចំណេញ ដោយទទួលស្គាល់ថាការទទួលយកហានិភ័យគឺជាផ្នែកមួយនៃសកម្មភាពធានារ៉ាប់រង និងវិនិយោគ ប៉ុន្តែមាត្រាហានិភ័យត្រូវស្របនឹងភាពរឹងមាំហិរញ្ញវត្ថុរយៈពេលវែង និងការការពារអតិថិជន។
កម្រិតហានិភ័យដែលអាចទទួលយកបានគ្របដណ្តប់ទាំងហានិភ័យហិរញ្ញវត្ថុ (ដូចជាមូលនិធិ និងសាច់ប្រាក់) និងហានិភ័យមិនមែនហិរញ្ញវត្ថុ (រួមមានហានិភ័យប្រតិបត្តិការ ការប្រព្រឹត្ត ផ្នែកច្បាប់ និងបច្ចេកវិទ្យា) ដោយមានសេចក្តីថ្លែងការណ៍គុណភាព កម្រិតកំណត់ និងតាមដានព្រឹត្តិការណ៍រំលោភ។





# ការគ្រប់គ្រងហានិភ័យ

## ហានិភ័យសំខាន់ៗ

### ហានិភ័យប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុ

ក្រុមហ៊ុនព្រូដិនសល ធានារ៉ាប់រងអាយុជីវិតកម្ពុជាប្រឈមនឹងការផ្លាស់ប្តូរសេដ្ឋកិច្ចម៉ាក្រូ និងទីផ្សារ ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពវិនិយោគ តម្លៃទ្រព្យសកម្ម និងរចនាសម្ព័ន្ធបំណុល។ ចំណុចសំខាន់ៗរួមមាន៖

- **ហានិភ័យទីផ្សារ ៖** ការផ្លាស់ប្តូរអត្រាការប្រាក់ អត្រាប្តូរប្រាក់ និងកត្តាទីផ្សារផ្សេងៗ ដែលអាចប៉ះពាល់ដល់ទ្រព្យសកម្ម និងបំណុល។ ក្រុមហ៊ុនត្រួតពិនិត្យហានិភ័យទីផ្សារជាប្រចាំ ដោយប្រើសូចនាករហិរញ្ញវត្ថុសមស្រប រួមទាំងប្រាក់ចំណេញអាជីវកម្មថ្មីតាមគំរូ European Embedded Value។ សូចនាករទាំងនេះត្រូវបានពិនិត្យប្រៀបធៀបនឹងកម្រិតហានិភ័យដែលអាចទទួលយកបានដែលបានកំណត់ ដើម្បីធានាថាហានិភ័យទីផ្សារស្ថិតក្នុងកម្រិតអាចទទួលយកបាន។
- **ហានិភ័យឥណទាន ៖** ហានិភ័យនៃការខកខានបំពេញការបង់ប្រាក់របស់ដៃគូពីការវិនិយោគ កិច្ចសន្យាធានារ៉ាប់រងបន្ត ឬដៃគូហិរញ្ញវត្ថុផ្សេងៗ។ ក្រុមហ៊ុនកំណត់កម្រិតអនុម័តហានិភ័យដោយផ្អែកលើភាពអាចទុកចិត្តបាននៃដៃគូ និងឧបករណ៍វិនិយោគ រួមទាំងចំណាត់ថ្នាក់ឥណទាន។ ប្រសិនបើការប៉ះពាល់ដែលបានស្នើលើសពីកម្រិតកំណត់ ការកើនឡើងនៃកម្រិតហានិភ័យត្រូវទទួលបានការអនុម័តពីក្រុមហ៊ុនមេ។
- **ហានិភ័យសន្ទនីយ ៖** ហានិភ័យនេះត្រូវបានត្រួតពិនិត្យដោយប្រើប្រាស់អនុបាតសន្ទនីយភាព (Liquidity Coverage Ratio - LCR) ដែលគណនាជារៀងរាល់ត្រីមាស សម្រាប់រយៈពេល ១២ ខែខាងមុខ ដើម្បីវាយតម្លៃថាតើផលប័ត្រវិនិយោគតែមួយគត់ អាចគ្របដណ្តប់ការចំណាយសាច់ប្រាក់ដែលអាចកើតមានបានទាន់ពេលវេលា ក្រោមស្ថានភាពអាជីវកម្មធម្មតា និងស្ថានភាពមានសម្ពាធ ដោយមិនពឹងផ្អែកលើប្រភពហិរញ្ញវត្ថុខាងក្នុង ឬខាងក្រៅ។

ក្រុមហ៊ុនបានកំណត់កម្រិតរំញោច សម្រាប់របាយការណ៍ LCR និងដែនកំណត់អប្បបរមា។ ក្រុមហ៊ុនរក្សាទុកភាគរយយ៉ាងច្រើននៃទ្រព្យសម្បត្តិនៅក្នុងឧបករណ៍ដែលមានភាពបត់បែនខ្ពស់ ហើយសន្ទនីយភាពនៅតែខ្ពស់លើសកម្រិតដែលបានកំណត់។

### ហានិភ័យធានារ៉ាប់រង

ក្រុមហ៊ុនត្រួតពិនិត្យបទពិសោធន៍តាមកត្តាសំខាន់ទាំងនេះជាប្រចាំ និងប្រៀបធៀបលទ្ធផលពិតប្រាកដជាមួយការសន្មត និងគោលដៅដែលបានកំណត់។ នៅពេលហានិភ័យចាប់ផ្តើមខុសពីកម្រិតដែលអាចទទួលយកហានិភ័យ គណៈគ្រប់គ្រងនឹងចាត់វិធានការភ្លាមៗ ដើម្បីបន្ថយ និងគ្រប់គ្រងបញ្ហានោះ។

### ហានិភ័យមិនមែនហិរញ្ញវត្ថុ

- **ហានិភ័យប្រតិបត្តិការ** ហានិភ័យប្រតិបត្តិការត្រូវបានគ្រប់គ្រងយ៉ាងសកម្មតាមរយៈគ្រប់គ្រងភាពជាអធិបតីដែលបានបង្កើតឡើងរបស់ក្រុមហ៊ុន ដែលគ្របដណ្តប់ទៅលើការអនុលោមតាមស្តង់ដារប្រត្តិបត្តិ និងច្បាប់កំណត់ ការប្រតិបត្តិការលក់ និងលទ្ធផលអតិថិជន ហានិភ័យឧក្រិដ្ឋកម្មហិរញ្ញវត្ថុ សុវត្ថិភាពបច្ចេកវិទ្យា និងសុវត្ថិភាពសាយប័រ (Cyber Security) ការគ្រប់គ្រងភាគីទីបី ហានិភ័យទាក់ទងនឹងបុគ្គលិក និងការផ្ទេរតួនាទី ហានិភ័យការអនុវត្តការផ្លាស់ប្តូរ និងភាពធន់នៃអាជីវកម្ម។ គណៈកម្មាធិការហានិភ័យបានត្រួតពិនិត្យហានិភ័យទាំងនេះតាមរយៈការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងជាប្រចាំ ការតាមដានសូចនាករហានិភ័យសំខាន់ៗ ការគ្រប់គ្រងហេតុការណ៍ និងបញ្ហា និងការពិនិត្យប្រសិទ្ធភាពនៃការគ្រប់គ្រង។ សកម្មភាពរបស់គណៈគ្រប់គ្រងត្រូវបានអនុវត្ត ដើម្បីដោះស្រាយចន្លោះប្រហោងដែលមាន ពង្រឹងការត្រួតពិនិត្យលើការរៀបចំជាមួយភាគីទីបី កែលម្អការគ្រប់គ្រងបច្ចេកវិទ្យា និងទិន្នន័យ ពង្រឹងស្តង់ដារប្រតិបត្តិ និងលើកកម្ពស់ភាពធន់នៃប្រតិបត្តិការ។ ជាទូទៅ ហានិភ័យប្រតិបត្តិការនៅតែស្ថិតក្រោមការត្រួតពិនិត្យយ៉ាងជាប់ ដោយមានការកែលម្អ និងដោះស្រាយបន្តបន្ទាប់ ដែលគាំទ្រដល់ប្រតិបត្តិការដែលមាននិរន្តរភាព និងការការពារអតិថិជន។
- **ហានិភ័យយុទ្ធសាស្ត្រ និងហានិភ័យផ្សេងៗ** ហានិភ័យយុទ្ធសាស្ត្រ រួមមានហានិភ័យទិសដៅយុទ្ធសាស្ត្រ និងការអនុវត្ត ព្រមទាំងហានិភ័យដែលកើតឡើងពីការផ្លាស់ប្តូរច្បាប់កំណត់ និងបរិបទប្រតិបត្តិការខាងក្រៅ ត្រូវបានវាយតម្លៃដោយយោងទៅលើគោលបំណងអាជីវកម្មរបស់ក្រុមហ៊ុន និងភាពនិរន្តរភាពរយៈពេលវែង។
- **នីតិវិធីនៃការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន និង ដៃគូពាក់ព័ន្ធ** រាល់គ្រប់អតិថិជន និង ដៃគូពាក់ព័ន្ធរបស់ក្រុមហ៊ុន ព្រូដិនសល ត្រូវស្ថិតក្រោមនីតិវិធីនៃការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន និង ដៃគូពាក់ព័ន្ធ ដោយផ្អែកលើកម្រិតហានិភ័យដែលត្រូវបានបង្កើតឡើងដើម្បីធានាការអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិដែលអនុវត្តទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងគោលនយោបាយប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្មរបស់ព្រូដិនសលគ្រុបដែលមានការិយាល័យកណ្តាលនៅទីក្រុង ហុងកុង។ នៅក្នុងប្រទេសកម្ពុជា នីតិវិធីនៃការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន និង ដៃគូពាក់ព័ន្ធ ត្រូវបានអនុវត្តស្របតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងប្រកាស បទប្បញ្ញត្តិ និងសេចក្តីណែនាំពាក់ព័ន្ធ ដែលចេញដោយអង្គភាពស៊ើបការហិរញ្ញវត្ថុកម្ពុជា និង និយ័តករធានារ៉ាប់រងកម្ពុជា ហើយក៏ស្របតាមស្តង់ដារអន្តរជាតិ រួមមាន អនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុអន្តរជាតិ (FATF) បទប្បញ្ញត្តិអំពីទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ និងការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ដែលអនុវត្តដោយចក្រភពអង់គ្លេស។

នីតិវិធីនេះគ្របដណ្តប់លើការវាយតម្លៃហានិភ័យអតិថិជន ការកំណត់អត្តសញ្ញាណ និងការផ្ទៀងផ្ទាត់អត្តសញ្ញាណ ការអនុវត្តវិធានការបន្ថែមការយកចិត្តទុកដាក់ស្គាល់អតិថិជនដែលមានហានិភ័យខ្ពស់គ្រប់ប្រភេទ និងការយកចិត្តទុកដាក់ស្គាល់អតិថិជនជាប្រចាំ ដើម្បីធានាថាព័ត៌មានដែលទទួលបាន និងកម្រិតហានិភ័យនៅតែត្រឹមត្រូវ និងមានបច្ចុប្បន្នភាពក្នុងអំឡុងពេលមានទំនាក់ទំនងអាជីវកម្ម។ ភាពហានិភ័យផ្នែក AML និង CTF ត្រូវបានតាមដានយ៉ាងជិតស្និទ្ធ ហើយមិនមានទិន្នាការសំខាន់ណាមួយត្រូវបានកត់សម្គាល់ទាក់ទងនឹងឆ្នាំហិរញ្ញវត្ថុ ២០២៥។



## ចីរភាពនៃក្រុមហ៊ុន

យុទ្ធសាស្ត្រចីរភាពរបស់យើង ឆ្លុះបញ្ចាំងពីបេសកកម្មក្នុងការក្លាយជាដៃគូ និងអ្នកការពារដែលគួរឱ្យទុកចិត្ត ព្រមទាំងទាញយកអត្ថប្រយោជន៍ពីចំណុចខ្លាំងរបស់យើង ដើម្បីបង្កើតតម្លៃរយៈពេលវែងសម្រាប់ភាគីពាក់ព័ន្ធ និងសម្រាប់សង្គមជាតិ។





# យុទ្ធសាស្ត្រចីរភាព

### គោលដៅចីរភាព

ការបង្កើតឱ្យមានផលជះពិតប្រាកដ និងភាពធន់ក្នុងរយៈពេលវែង

#### ការធានារ៉ាប់រងសុខភាព និងហិរញ្ញវត្ថុបែបសាមញ្ញ និងងាយស្រួលទទួលបាន

ការអភិវឌ្ឍផលិតផលប្រកបដោយចីរភាព និងបរិយាបន្ន

ការបង្កើតភាពជាដៃគូ និងនវានុវត្តន៍ឌីជីថល ដើម្បីលទ្ធផលសុខភាពកាន់តែល្អប្រសើរ

ការកសាងសហគមន៍ឱ្យមានភាពធន់ តាមរយៈការវិនិយោគលើសហគមន៍

#### ការវិនិយោគប្រកបដោយការទទួលខុសត្រូវ

ការផ្តល់ហិរញ្ញប្បទានសម្រាប់ការផ្លាស់ប្តូរប្រកបដោយសមធម៌ និងបរិយាបន្ន

ការកាត់បន្ថយការភាយកាបូននៅក្នុងផលបត្រវិនិយោគ

ការជំរុញការវិនិយោគប្រកបដោយការទទួលខុសត្រូវឱ្យទៅជាចរន្តចម្បង នៅក្នុងទីផ្សារដែលកំពុងលេចធ្លោ

#### អាជីវកម្មប្រកបដោយចីរភាព

ការបង្កើតប្រតិបត្តិការ និងខ្សែសង្វាក់តម្លៃប្រកបដោយចីរភាព

ការបង្កើនសមត្ថភាព គាំទ្រ និងលើកកម្ពស់បុគ្គលិក

ការប្រើប្រាស់ភាពជាអ្នកដឹកនាំខាងគំនិត ដើម្បីកំណត់របៀបវារៈការងារ

### គ្រឹះនៃអភិបាលកិច្ចល្អ និងការអនុវត្តអាជីវកម្មប្រកបដោយការទទួលខុសត្រូវ

អភិបាលកិច្ចសាជីវកម្ម, ក្រមសីលធម៌ និងការប្រតិបត្តិការងារ, ការគ្រប់គ្រងហានិភ័យ, របាយការណ៍ខាងក្រៅ និងការវាយតម្លៃធៀប

## អភិបាលកិច្ចនៃយុទ្ធសាស្ត្រចីរភាព

ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា ឡាយហ្វ៍ អឺស្វឺរ៉ែន បានបង្កើតគណៈកម្មាធិការចីរភាព CLM ដើម្បីផ្តល់ការត្រួតពិនិត្យជាប្រព័ន្ធលើបញ្ហាចីរភាព និងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) នៅទូទាំងទីផ្សារទាំងបី។ គណៈកម្មាធិការនេះ មានអាណត្តិក្នុងការជំរុញ និងត្រួតពិនិត្យការអភិវឌ្ឍ ការអនុវត្ត និងប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមនិរន្តរភាព ដោយផ្អែកលើយុទ្ធសាស្ត្រចីរភាពរបស់ក្រុមហ៊ុនមេ (Group) និងសម្របទៅតាមស្ថានភាពជាក់ស្តែងនៃទីផ្សារក្នុងស្រុក។ គណៈកម្មាធិការនេះ មានអាណត្តិក្នុងការជំរុញ និងត្រួតពិនិត្យការអភិវឌ្ឍ ការអនុវត្ត និងប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមនិរន្តរភាព ដោយផ្អែកលើយុទ្ធសាស្ត្រនិរន្តរភាពរបស់ក្រុមហ៊ុនមេ (Group) និងសម្របទៅតាមស្ថានភាពជាក់ស្តែងនៃទីផ្សារក្នុងស្រុក។ គណៈកម្មាធិការនេះផ្តល់នូវទិសដៅយុទ្ធសាស្ត្រលើវិស័យសំខាន់ៗ រួមមាន ការទំនាក់ទំនង និងការយល់ដឹង ការគ្រប់គ្រងបរិស្ថាន ការវិនិយោគសហគមន៍ ការឧបត្ថម្ភ និងអភិបាលកិច្ចចីរភាព។

លើសពីនេះ គណៈកម្មាធិការក៏ត្រួតពិនិត្យវឌ្ឍនភាពឆ្ពោះទៅរកគោលដៅបញ្ចេញឧស្ម័នសូន្យ (net-zero) ធានាឱ្យមានការវិនិយោគសហគមន៍ប្រកបដោយការទទួលខុសត្រូវ ដែលស្របតាមមូលនិធិព្រូដិន និងអាទិភាពទីផ្សារ ព្រមទាំងពិនិត្យលើសំណើឧបត្ថម្ភផ្សេងៗ ដើម្បីបង្កើនតម្លៃអាជីវកម្ម និងសង្គមឱ្យបានជាអតិបរមា។ ជាមួយគ្នានេះដែរ គណៈកម្មាធិការដឹកនាំការកំណត់ និងតាមដានអាទិភាពនិរន្តរភាព និងសូចនាកររាស់ស្ទង់សមិទ្ធផលការងារ រាយការណ៍ពីវឌ្ឍនភាពជូនក្រុមប្រឹក្សាភិបាល និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ខ្លួនជាកាលកំណត់ ដើម្បីធានាឱ្យមានការអនុវត្តស្របតាមការរំពឹងទុករបស់ក្រុមហ៊ុនមេ និងតម្រូវការបទប្បញ្ញត្តិ។

# យុទ្ធសាស្ត្រចីរភាព

## ទិដ្ឋភាពទូទៅនៃចីរភាពក្នុងឆ្នាំ២០២៥

### អតិថិជន ១៤០,៩៦៧ នាក់

ទទួលបានការការពារពីហានិភ័យហិរញ្ញវត្ថុនៃជំងឺកាចសាហាវតាមរយៈការបញ្ចូលការធានារ៉ាប់រងបន្ថែម (rider) ទៅក្នុងប័ណ្ណសន្យារ៉ាប់រង។

### សាលារៀនរដ្ឋ ចំនួន ៩៦ ខ្នងត្រូវបានអភិវឌ្ឍ

នៅតាមបណ្ដាលខេត្តស្ទឹងត្រែង រតនគិរី និងសៀមរាប ឱ្យទៅជាកន្លែងសិក្សាដែលមានសុវត្ថិភាព ដែលមានផលជះលើ **សិស្សានុសិស្ស ៧៤,៨៦៩ នាក់** និងសមាជិកសហគមន៍ តាមរយៈគម្រោងសាលារៀនសុវត្ថិភាព។

### វឌ្ឍនភាពនៃការកាត់បន្ថយការបំភាយឧស្ម័នកាបូន ២៤,២២%

កាត់បន្ថយការបំភាយឧស្ម័នកាបូនក្នុងប្រភេទទី ១ និងទី ២ (Scope 1 & 2) ពី ៦០.១៦ មកត្រឹម ៤៥.៥៩ គីឡូក្រាម $CO_2e/m^2$ ចន្លោះឆ្នាំ ២០២៤ និង ២០២៥។




### កុមារ ១៤៩,៤៥១ នាក់

ទទួលបានការអប់រំពីចំណេះដឹងមូលដ្ឋានផ្នែកហិរញ្ញវត្ថុ ចាប់តាំងពីឆ្នាំ ២០១៦ មកតាមរយៈការពង្រីកវិសាលភាពកម្មវិធីអប់រំនៅតាម**សាលារៀនរដ្ឋចំនួន ៣០០**។

### ហានិភ័យគ្រោះថ្នាក់ចរាចរណ៍ត្រូវបានកាត់បន្ថយ

កាត់បន្ថយ នៅជុំវិញ**សាលារៀនរដ្ឋចំនួន ៨** ដើម្បីធានាបាននូវការធ្វើដំណើរ និងបរិស្ថានសិក្សាដែលមានសុវត្ថិភាពជាងមុនសម្រាប់**សិស្សានុសិស្ស ២១,៥១៨ នាក់** នៅក្នុងខេត្ត កំពត កំពង់ធំ និងសៀមរាប។

### ថវិកាចំនួន ៥ លានដុល្លារត្រូវបានវិនិយោគ

លើសញ្ញាបណ្ណបៃតង (Green Infrastructure Bonds) ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនផលបត្រវិនិយោគរយៈពេលវែង។

### គ្រូបង្រៀន ១,៨៦៧ នាក់

ទទួលបានការបញ្ជាក់ការសិក្សា ការកសាងសមត្ថភាពស្ថាប័នត្រូវបានធ្វើឡើងតាមរយៈការបណ្តុះបណ្តាលលោកគ្រូ-អ្នកគ្រូនៅតាមសាលារដ្ឋ ដើម្បីបង្រៀនកម្មវិធីសិក្សា ឆា-ឈីង ប្រកបដោយប្រសិទ្ធភាព។

### ទូកពេទ្យសង្គ្រោះបន្ទាន់ចំនួន ៥ គ្រឿង

ត្រូវបានប្រគល់ជូន ដល់មណ្ឌល សុខភាពដាច់ស្រយាលចំនួន ៥ ក្នុងខេត្តស្ទឹងត្រែង និងរតនគិរី ដើម្បីធានាបាននូវការដឹកជញ្ជូនសង្គ្រោះបន្ទាន់សម្រាប់អ្នក ជំងឺធ្ងន់ធ្ងរដោយសារជំងឺគ្រុនឈាម និងគ្រុនចាញ់។

### សូចនាករ KPI ផ្សារភ្ជាប់នឹង និរន្តរភាព ១០០%

រាល់ថ្នាក់ដឹកនាំគ្រប់គ្រង ត្រូវបានវាយតម្លៃការងារស្របតាមសូចនាករដែលផ្សារភ្ជាប់នឹងនិរន្តរភាព។

ព្រូដិនសលកម្ពុជា បានក្លាយជាហត្ថលេខីនៃ**គោលការណ៍ពង្រឹងអំណាចស្ត្រី (WEPs)**










# ការការពារសុខភាព និងហិរញ្ញវត្ថុដែលសាមញ្ញ និងងាយស្រួលទទួលបាន

សម្រាប់ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា សសរស្តម្ភទីមួយនៃយុទ្ធសាស្ត្រនិរន្តរភាពរបស់យើង មិនមែនគ្រាន់តែជាការណែនាំរបស់សាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាការប្តេជ្ញាចិត្តក្នុងការកែប្រែជោគវាសនានៃជីវិតរបស់គ្រួសារកម្ពុជា។ នៅក្នុងទីផ្សារមួយដែលការចំណាយលើការព្យាបាលដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួន អាចនាំឱ្យមានការធ្លាក់ចូលទៅក្នុងវដ្តនៃបំណុលយ៉ាងឆាប់រហ័សនោះ វិធីសាស្ត្រ «សាមញ្ញ និងងាយស្រួលទទួលបាន» របស់យើង ផ្តោតលើការបំពេញចន្លោះប្រហោងរវាងការសន្សំតាមបែបប្រពៃណី និងតម្រូវការបន្ទាន់សម្រាប់កិច្ចការពារសុខភាពដ៏រឹងមាំ។

### ការដាក់បន្ថែមនូវកិច្ចការពារ និងវិបុលភាព

ក្នុងឆ្នាំ ២០២៥ យុទ្ធសាស្ត្ររបស់យើងបានផ្តោតសំខាន់លើការសម្របគ្នារវាងគោលដៅហិរញ្ញវត្ថុរយៈពេលវែង និងភាពស៊ាំនៃសុខភាពភ្លាមៗ។ យើងបានទទួលស្គាល់ថា សម្រាប់មាតាបិតាជនជាតិខ្មែរជាច្រើន អាទិភាពចម្បងគឺការធានានូវអនាគតរបស់កូនៗរបស់ពួកគេ។ តាមរយៈការដាក់បញ្ចូល ការការពារជំងឺធ្ងន់ធ្ងរ ជាមួយនឹងផលិតផលសន្សំតាមបែបប្រពៃណី យើងបានបង្កើតកញ្ចប់ការពារហិរញ្ញវត្ថុមួយដែលមានគោលបំណងទ្វេដង។ ចំណុចនេះអនុញ្ញាតឱ្យក្រុមគ្រួសារនានាអាចសន្សំថវិកាសម្រាប់គោលដៅអប់រំ ឬព្រឹត្តិការណ៍សំខាន់ៗក្នុងជីវិត ខណៈពេលដែលនៅតែទទួលបានការការពារពីការចំណាយដ៏ធ្ងន់ធ្ងរដែលពាក់ព័ន្ធនឹងជំងឺក្នុងតំបន់ដែលកំពុងកើតមានថ្មីៗ។ ការរចនាផលិតផលដែល «សមស្របបំផុត» នេះ ធានាថាវិបត្តិសុខភាពនឹងមិនមែនជាមូលហេតុដែលនាំឱ្យមានការដកយកថវិកាសម្រាប់អនាគតរបស់កុមារមកប្រើប្រាស់នោះទេ។

តាមរយៈកិច្ចសហការជាមួយសាលារៀនចំនួន ៣០០ យើងបានឈានទៅដល់កុមារចំនួន ១៤៩ ៤៥១ ចាប់តាំងពីឆ្នាំ ២០១៦ ដោយបានបណ្តុះនូវមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុដល់យុវជនជំនាន់ក្រោយ។ យើងជឿជាក់ថា យុវជនដែលមានចំណេះដឹងផ្នែកហិរញ្ញវត្ថុ គឺជាគ្រឹះដ៏រឹងមាំនៃសេដ្ឋកិច្ចដែលមានភាពស៊ាំ។

### ការវិវត្តឆ្ពោះទៅរកភាពស៊ាំនឹងអាកាសធាតុ និងសុខភាព

ក្នុងឆ្នាំ ២០២៥ យើងបានបង្វែរធនធានរបស់យើងឆ្ពោះទៅរកចំណុចប្រសព្វរវាងអាកាសធាតុ និងសុខភាពវិញ។ គំនិតផ្តួចផ្តើមថ្មីៗរបស់យើងត្រូវបានរចនាឡើងដើម្បី៖

- **ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល៖** គាំទ្រដល់មូលដ្ឋានសុខាភិបាលក្នុងតំបន់ ឱ្យកាន់តែមានលទ្ធភាពខ្ពស់ក្នុងការដោះស្រាយការកើនឡើងនៃជំងឺដែលពាក់ព័ន្ធនឹងភាពមិនប្រាកដប្រជានៃអាកាសធាតុ។
- **កាត់បន្ថយសម្ពាធបរិស្ថាន៖** ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធដែលចាំបាច់ ដើម្បីគ្រប់គ្រងបន្ទុកដែលកំពុងកើនឡើងលើប្រព័ន្ធសុខាភិបាលសាធារណៈ។

តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ យើងបានសម្រេចនូវការសន្យារបស់យើងក្នុងការរក្សាកិច្ចការពារឱ្យនៅតែមានភាពសាមញ្ញ តម្លៃសមរម្យ អាចរកបាន និងប្រកបដោយយុត្តិធម៌។

# ព័ត៌មានអំពីចីរភាព

## អំពីកម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុកុមារ ឆាឈីង

ចាប់តាំងពីឆ្នាំ ២០១៦ មក កម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុកុមារ ឆាឈីង បានឈានទៅដល់សិស្សានុសិស្សកម្ពុជាប្រមាណ ១៤៩ ៤៥១ នាក់ នៅតាមសាលារៀនចំនួន ៣០០ ដែលជាការកសាងគ្រឹះដ៏សំខាន់សម្រាប់បរិយាបន្នហិរញ្ញវត្ថុ។ តាមរយៈការធ្វើឱ្យសេដ្ឋកិច្ចមានភាពសាមញ្ញទៅជាឥរិយាបថស្នូលចំនួនបួនគឺ រកប្រាក់ សន្សំ ចាយវាយ និងបរិច្ចាគ គំនិតផ្តួចផ្តើមនេះបានបង្រៀនកុមារដែលមានអាយុចន្លោះពី ៧ ដល់ ១២ ឆ្នាំ ឱ្យចេះគ្រប់គ្រងថវិកាប្រកបដោយក្រមសីលធម៌ និងការអនុវត្តជាក់ស្តែង។ ការចាប់ផ្តើមបង្រៀនតាំងពីវ័យក្មេងនេះ ផ្តល់នូវចំណេះដឹង ដល់សិស្សានុសិស្សក្នុងការកំណត់គោលដៅហិរញ្ញវត្ថុ និងចេះបែងចែករវាង «តម្រូវការចាំបាច់» និង «ការចង់បាន» នៃចំណាយ ដែលធ្វើឲ្យពួកគេក្លាយ ទៅជាអ្នកចូលរួមសកម្មក្នុងវិស័យសេដ្ឋកិច្ច។ ខណៈពេលដែលប្រទេសកម្ពុជាកំពុងរីកចម្រើន កម្មវិធី ឆាឈីង បានធានាថាគ្រាប់ពូជជំនាន់ក្រោយមានភាពស៊ាំ និងចំណេះដឹងដែលចាំបាច់សម្រាប់ស្ថិរភាពជាតិរយៈពេលវែង។



## អំពីគម្រោងសាលារៀនសុវត្ថិភាព (បានបញ្ចប់ក្នុងឆ្នាំ ២០២៥)

គំនិតផ្តួចផ្តើមលើកកម្ពស់សាលារៀនសុវត្ថិភាព (២០១៦–២០២៥) គឺជាកិច្ចសហការរវាងក្រុមហ៊ុន ព្រូដិនសល ខេមបូឌា អង្គការផ្លែនអន្តរជាតិ (Plan International) និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រឹងភាពស៊ាំនឹងគ្រោះមហន្តរាយ។ តាមរយៈការប្រើប្រាស់ក្របខ័ណ្ឌសុវត្ថិភាពសាលារៀនគ្រប់ជ្រុងជ្រោយ គម្រោងនេះបានផ្លាស់ប្តូរសាលារដ្ឋចំនួន ៩៦ ក្នុងខេត្តរតនគិរី សៀមរាប និងស្ទឹងត្រែង ឱ្យទៅជា «សាលារៀនសុវត្ថិភាព» ដែលត្រូវបានទទួលស្គាល់ជាផ្លូវការ។

តាមរយៈការផ្តល់អត្ថប្រយោជន៍ដល់បុគ្គលជិត ៧៥,០០០ នាក់ គំនិតផ្តួចផ្តើមនេះបានកាត់បន្ថយហានិភ័យពីទឹកជំនន់ និងខ្យល់ព្យុះ តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងការបណ្តុះបណ្តាលការគ្រប់គ្រងគ្រោះមហន្តរាយ។ ជាមួយនឹងការប្រគល់ភារកិច្ចចំនួន៣ដំណាក់កាលជូនដល់អាជ្ញាធរខេត្តប្រកបដោយជោគជ័យ កម្មវិធីនេះត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធការងារផ្លូវការ ដែលស្របតាមក្របខ័ណ្ឌសេនដាយ (Sendai Framework) ដើម្បីធានាថាកុមារកម្ពុជាទទួលបានសិទ្ធិក្នុងការអប់រំប្រកបដោយសុវត្ថិភាព និងមិនមានការរំខាន។







ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

# ព័ត៌មានអំពីចីរភាព



## អំពីកម្មវិធីសុវត្ថិភាពចរាចរណ៍ផ្លូវគោក (បានបញ្ចប់ក្នុងឆ្នាំ ២០២៥)

កម្មវិធីសុវត្ថិភាពចរាចរណ៍ផ្លូវគោក Safe Steps ដែលដឹកនាំដោយមូលនិធិ AIP Foundation និងឧបត្ថម្ភថវិកាដោយមូលនិធិព្រូដិន រួមជាមួយក្រុមហ៊ុន ព្រូដិនសល ខេមបូឌា បានដោះស្រាយបញ្ហាគ្រោះថ្នាក់ចរាចរណ៍ក្នុងតំបន់សាលារៀនដែលមានហានិភ័យខ្ពស់ចំនួន ៨ នៅក្នុងខេត្តកំពត សៀមរាប និងខេត្តកំពត។

តាមរយៈការអនុវត្តជាពីរដំណាក់កាល (២០២៣–២០២៦) គំនិតផ្តួចផ្តើមនេះបានផ្តល់អត្ថប្រយោជន៍ដល់សិស្សានុសិស្ស មាតាបិតា និងគ្រូបង្រៀនជាង ៦០,០០០ នាក់។ នៅក្នុងដំណាក់កាលទី ២ កម្មវិធីបានប្រើប្រាស់ប្រព័ន្ធវាយតម្លៃកម្រិតផ្កាយសម្រាប់សាលារៀន (iRAP's Star Rating for Schools) ដើម្បីតម្រង់ទិសការកែលម្អហេដ្ឋារចនាសម្ព័ន្ធ រួមមានការកំណត់តំបន់ល្បឿន ៣០ គីឡូម៉ែត្រក្នុងមួយម៉ោង និងការដំឡើងភ្លើងសញ្ញាព្រមាន។ តាមរយៈការរួមបញ្ចូលគ្នារវាងការកែលម្អរូបវន្ត ជាមួយនឹងយុទ្ធនាការតស៊ូមតិ និងការផ្សព្វផ្សាយ កម្មវិធីនេះបានធ្វើឱ្យឥរិយាបថ និងបរិស្ថានប្រកបដោយសុវត្ថិភាពក្លាយជាផ្នែកមួយនៃប្រព័ន្ធការងារ ដោយមានគោលដៅបង្កើតឱ្យមានការផ្លាស់ប្តូរជាប្រព័ន្ធរយៈពេលវែង និងការពារសហគមន៍កម្ពុជាពីការរងរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍។



## អំពីគម្រោងអាកាសធាតុ និងសុខភាព

«ភាពស៊ាំដែលដឹកនាំដោយសហគមន៍» (២០២៤–២០២៥) គឺជាគំនិតផ្តួចផ្តើមផ្នែកអាកាសធាតុ និងសុខភាព ដោយមូលនិធិភាពស៊ាំព្រូដិនសល (Prudential Resilience Fund) និងអង្គការ CRF ដើម្បីដោះស្រាយហានិភ័យនៃជំងឺដែលបង្កឡើងដោយមូស ដែលកំពុងកើនឡើងក្នុងខេត្តស្ទឹងត្រែង និងរតនគិរី។

តាមរយៈការកំណត់គោលដៅលើតំបន់ដាច់ស្រយាលដែលពឹងផ្អែកលើផ្លូវទឹក គម្រោងនេះបានផ្តល់អត្ថប្រយោជន៍ផ្ទាល់ដល់សមាជិកចំនួន ៥,០០០ នាក់ ដោយការផ្តល់ទូកសង្គ្រោះបន្ទាន់ចំនួន ៥ គ្រឿងសម្រាប់ការដឹកជញ្ជូនក្នុងករណីអាសន្ន និងការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលចំនួន ៥០ នាក់ លើការត្រៀមលក្ខណៈឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ តាមរយៈការបង្កើតក្រុមការងារក្នុងតំបន់ក្រោមក្របខ័ណ្ឌគ្រប់គ្រងគ្រោះមហន្តរាយជាតិ កម្មវិធីនេះផ្តល់អំណាចដល់សហគមន៍ក្នុងការដឹកនាំកិច្ចខិតខំប្រឹងប្រែងបង្ការជំងឺគ្រុនឈាម និងគ្រុនចាញ់។ វិធីសាស្រ្តពហុសសរស្តម្ភនេះ ធានាបាននូវភាពស៊ាំរយៈពេលវែង និងការកែលម្អលទ្ធភាពទទួលបានសេវាសុខភាព សម្រាប់ប្រជាជនជាង ៥៣,០០០ នាក់ ដែលងាយរងគ្រោះដោយសារការគំរាមកំហែងផ្នែកសុខភាពដែលបណ្តាលមកពីអាកាសធាតុ។

# ព័ត៌មានអំពីចីរភាព



## ការវិនិយោគប្រកបដោយការទទួលខុសត្រូវ

នៅក្រុមហ៊ុន ព្រូដិនសល ខេមបូឌា (PCLA) យើងទទួលស្គាល់ថា តួនាទីរបស់យើងក្នុងនាមជាវិនិយោគិនរយៈពេលវែង និងជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកកាន់បណ្ណសន្យារ៉ាប់រង គឺមកជាមួយនូវការទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់។ សសរស្តម្ភទីពីរនៃយុទ្ធសាស្ត្រនិរន្តរភាពរបស់យើង គឺ ការវិនិយោគប្រកបដោយការទទួលខុសត្រូវ និងការយកចិត្តទុកដាក់ខ្ពស់ ដែលត្រូវបានរចនាឡើងដើម្បីធានាថា យើងដើរតួជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិប្រកបដោយការទទួលខុសត្រូវ ជាមួយនឹងការយល់ដឹងយ៉ាងច្បាស់លាស់អំពីឥទ្ធិពលនៃមូលធនរបស់យើង។ សសរស្តម្ភនេះ មិនមែនត្រឹមតែជាការកាត់បន្ថយហានិភ័យប៉ុណ្ណោះទេ ប៉ុន្តែគឺជាការចូលរួមយ៉ាងសកម្មក្នុងការបង្កើតអនាគតដ៏រឹងមាំសម្រាប់ប្រទេសកម្ពុជា។

សម្រាប់ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា សសរស្តម្ភនេះត្រូវបានបកប្រែទៅជាអាទិភាពយុទ្ធសាស្ត្រចំនួនបី៖

- ការពង្រឹងការរាយការណ៍ក្នុងចំណោមក្រុមហ៊ុនដែលទទួលបានការវិនិយោគ៖ យើងគាំទ្រយ៉ាងសកម្មដល់ក្រុមហ៊ុនដែលយើងវិនិយោគ ក្នុងការកត់ត្រា និងរាយការណ៍អំពីការបញ្ចេញឧស្ម័នកាបូនិក។ តាមរយៈការជួយពួកគេឱ្យបង្កើតផែនទីបង្ហាញផ្លូវច្បាស់លាស់ឆ្ពោះទៅរកការបញ្ចេញឧស្ម័នសូន្យ (Net-zero emissions) យើងធានាថា អាជីវកម្មដែលកំពុងជំរុញកំណើនរបស់កម្ពុជា ក៏មានការទទួលខុសត្រូវចំពោះផលប៉ះពាល់បរិស្ថានរបស់ពួកគេផងដែរ។
- ការផ្តល់ហិរញ្ញប្បទានសម្រាប់ការផ្លាស់ប្តូរដែលប្រកបដោយយុត្តិធម៌ និងបរិយាបន្ន៖ យើងយល់ថាការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិកនៅក្នុងទីផ្សារកំពុងរីកចម្រើនដូចជាកម្ពុជា ត្រូវតែធ្វើឡើងដោយការប្រុងប្រយ័ត្ន។ ការដកការវិនិយោគភ្លាមៗពីវិស័យដែលមានការបញ្ចេញឧស្ម័នខ្ពស់ អាចនាំឱ្យមានផលវិបាកដែលមិនបានរំពឹងទុក ដូចជាការបាត់បង់ការងារ និងអស្ថិរភាពសេដ្ឋកិច្ច មុនពេលដែលជម្រើសបៃតងផ្សេងៗមានភាពចាស់ទុំពេញលេញ។ យើងតស៊ូមតិសម្រាប់ការផ្លាស់ប្តូរដែលការពារសហគមន៍ងាយរងគ្រោះ ទាំងពីហានិភ័យអាកាសធាតុ និងការផ្លាស់ប្តូរទីលំនៅសេដ្ឋកិច្ច។
- ការដាក់បញ្ចូលទៅក្នុងចរន្តសំខាន់នៃទីផ្សារកំពុងអភិវឌ្ឍន៍៖ នៅពេលដែលទីផ្សារទាំងនេះអភិវឌ្ឍន៍រីកចម្រើន តម្រូវការសម្រាប់ការការពារសុខភាព និងហិរញ្ញវត្ថុក៏កើនឡើងផងដែរ។ យើងបញ្ចូលនិរន្តរភាពទៅក្នុងគ្រប់ដំណាក់កាលនៃដំណើរការវិនិយោគរបស់យើង ដោយមានគោលដៅកាត់បន្ថយកម្រិតមធ្យមនៃអាំងតង់ស៊ីតេកាបូន (WACI) នៅក្នុងផលប័ត្រវិនិយោគរបស់យើងឱ្យបាន ៥៥% នៅឆ្នាំ ២០៣០។





ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | **ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម** | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

# ព័ត៌មានអំពីចីរភាព

### សមិទ្ធផល និងភាពជាអ្នកដឹកនាំក្នុងទីផ្សារ

ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា កំពុងបោះជំហានលើសពីគោលនយោបាយ ឆ្ពោះទៅរកសកម្មភាពអាកាសធាតុជាក់ស្តែង។ សមិទ្ធផលដ៏សំខាន់មួយនៅក្នុងផលប័ត្ររបស់យើង គឺការវិនិយោគចំនួន ៥ លានដុល្លារ លើសញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធបៃតង ដែលបោះផ្សាយដោយក្រុមហ៊ុន SchneiTec Dynamic។ មូលធននេះគាំទ្រដល់រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យកម្លាំង ៦០ មេហ្គាវ៉ាត់ ដែលបំពាក់ដោយប្រព័ន្ធផ្ទុកថាមពលថ្ម (BESS) នៅក្នុងខេត្តកំពង់ឆ្នាំង។

សញ្ញាបណ្ណនេះ ដែលបានចុះបញ្ជីជាសញ្ញាបណ្ណបៃតង (Green Bond) បានទទួលចំណាត់ថ្នាក់ “Dark Green” ពីស្ថាប័ន S&P Global Ratings ដែលជាការវាយតម្លៃខ្ពស់បំផុត បញ្ជាក់ពីសកម្មភាពដែលស្របតាមអនាគតដែលមានការបញ្ចេញកាបូនទាប និងភាពស៊ាំនឹងអាកាសធាតុ។ ការវិនិយោគនេះ បញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងចំពោះគោលការណ៍សញ្ញាបណ្ណបៃតងរបស់ ICMA និងស្តង់ដារសញ្ញាបណ្ណបៃតងអាស៊ាន (ASEAN Green Bond Standards)។

### ការជំរុញកិច្ចសន្ទនាក្នុងចំណោមដៃគូរពាក់ព័ន្ធ

យើងជឿជាក់លើការដឹកនាំតាមរយៈការធ្វើជាគំរូ និងការចូលរួមចំណែកក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពថ្នាក់ជាតិ។ ក្នុងឆ្នាំ ២០២៥ ក្រុមការងារវិនិយោគរបស់ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចសន្ទនាកម្រិតខ្ពស់ជាច្រើន ដែលរៀបចំឡើងដោយនិយតករមូលបត្រកម្ពុជា (ន.ម.ក.)៖

- **ការជំរុញឲ្យមានការប្រើប្រាស់ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពរបស់កម្ពុជា (ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២៥)៖** ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលានេះ ដែលសហការរៀបចំដោយ UNESCAP និង GGGI។ វគ្គពិភាក្សានេះបានឈានទៅលើសពីសញ្ញាបណ្ណបែបប្រពៃណី ដើម្បីស្វែងយល់អំពីឧបករណ៍ហិរញ្ញវត្ថុដែលផ្សារភ្ជាប់នឹងនិរន្តរភាព(Sustainability -Linked Instruments) ដែលអត្រាការប្រាក់ត្រូវបានផ្សារភ្ជាប់ទៅនឹងការសម្រេចបាននូវគោលដៅបរិស្ថានជាក់លាក់។
- **សញ្ញាបណ្ណបៃតង សង្គម និងនិរន្តរភាព (ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០២៥)៖** យើងបានចូលរួមក្នុងកិច្ចពិភាក្សាដ៏សំខាន់ទាក់ទងនឹង «ហិរញ្ញប្បទានអន្តរកាល» សម្រាប់ឧស្សាហកម្មដែលបញ្ចេញកាបោនកាបូនិចខ្លាំង (Brown industries) ដែលជាវិស័យផលិតកម្មធុនធ្ងន់ដែលមិនទាន់មានភាពបៃតងនៅឡើយ ប៉ុន្តែមានផែនការច្បាស់លាស់ និងអាចផ្ទៀងផ្ទាត់បាន ដើម្បីប្រែក្លាយទៅជានិរន្តរភាព។
- **តុមូលវិនិយោគិនសម្ពោធដំបូង (ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០២៥)៖** ដោយផ្តោតលើ «ការសម្រេចជាស្ថាពរលើកិច្ចព្រមព្រៀង» សម្រាប់គម្រោងដែលអាចផ្តល់ហិរញ្ញប្បទានបាន ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា បានចែករំលែកទស្សនៈអំពីអ្វីដែលវិនិយោគិនស្ថាប័នត្រូវការ រួមមាន៖ របាយការណ៍ច្បាស់លាស់អំពីការប្រើប្រាស់ថវិកាដែលទទួលបាន សូចនាកររង្វាស់វែងផលប៉ះពាល់ដែលអាចផ្ទៀងផ្ទាត់បាន និងគំរូហិរញ្ញវត្ថុដ៏រឹងមាំដែលគិតគូរពីហានិភ័យអាកាសធាតុមករយៈពេលវែង។

តាមរយៈការវិនិយោគ និងការចូលរួមទាំងនេះ ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) នៅតែបន្តឈានមុខគេក្នុងដំណើររបស់ព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅរកសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងបរិយាបន្ន។



# ព័ត៌មានអំពីចីរភាព



## អាជីវកម្មប្រកបដោយនិរន្តរភាព

សសរស្តម្ភទីបីនៃយុទ្ធសាស្ត្រនិរន្តរភាពរបស់ក្រុមហ៊ុន ព្រូដិនសល គឺ អាជីវកម្មប្រកបដោយនិរន្តរភាព ដែលដើរតួជាឆ្អឹងខ្នងនៃប្រតិបត្តិការក្នុងការអនុវត្តការប្តេជ្ញាចិត្តរបស់យើងចំពោះប្រទេសជាតិ។ សម្រាប់នៅក្នុងប្រទេសកម្ពុជា ចំណុចនេះមានន័យថាជាការបោះជំហានលើសពីការសន្យាកម្រិតខ្ពស់ ដើម្បីឈានទៅអនុវត្តវប្បធម៌នៃគណនេយ្យភាព ដែលក្នុងនោះការគ្រប់គ្រងបរិស្ថាន ថាមពលនៃធនធានបុគ្គលិក និងស្តង់ដារសីលធម៌ ត្រូវបានបញ្ជ្រាបទៅក្នុងរចនាសម្ព័ន្ធប្រតិបត្តិការប្រចាំថ្ងៃរបស់យើង។ តាមរយៈការបង្កើនប្រសិទ្ធភាពនៃប្រតិបត្តិការ និងការផ្តល់អំណាចដល់បុគ្គលិករបស់យើង យើងធានាថា ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា នៅតែជាដៃគូដ៏គួរឱ្យទុកចិត្តសម្រាប់ទាំងអតិថិជន និងនិយោជិតរបស់យើង។

### ការគ្រប់គ្រងបរិស្ថាន និងប្រសិទ្ធភាពនៃប្រតិបត្តិការ

ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា បានបោះជំហានយ៉ាងសំខាន់ក្នុងការកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន ដែលឆ្លុះបញ្ចាំងពីមហិច្ឆតារបស់គ្រុប (Group) ទាំងមូល ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិក។ ក្នុងឆ្នាំ ២០២៥ យើងសម្រេចបាននូវការកាត់បន្ថយយ៉ាងខ្លាំងនូវការបញ្ចេញឧស្ម័នក្នុងវិសាលភាពទី ១ និងទី ២ (Scope 1 and 2 emissions) ដោយធ្លាក់ចុះពី ៦០.១៦ គីឡូក្រាម CO2e/ម២ ក្នុងឆ្នាំ ២០២៤ មកត្រឹម ៤៥.៥៩ គីឡូក្រាម CO2e/ម២ សម្រាប់ប្រតិបត្តិការរបស់អាជីវកម្មក្នុងប្រទេសកម្ពុជា។ អត្រាអាំងតង់ស៊ីតេរបស់យើងក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ដោយបានផ្លាស់ប្តូរពី ០.៧២ មកត្រឹម ០.៦៤ tCO2e/FTE។





# ព័ត៌មានអំពីចីរភាព

តួលេខទាំងនេះ មិនមែនគ្រាន់តែជាទិន្នន័យរាស់វែងប៉ុណ្ណោះទេ ប៉ុន្តែវាតំណាងឱ្យការផ្លាស់ប្តូរជាក់ស្តែងឆ្ពោះទៅរកប្រសិទ្ធភាពថាមពល និងការគ្រប់គ្រងធនធានប្រកបដោយការទទួលខុសត្រូវនៅក្នុងការិយាល័យមូលដ្ឋានរបស់យើង ដែលបង្ហាញថា កំណើនអាជីវកម្មអាចដើរទន្ទឹមគ្នាជាមួយនឹងការកាត់បន្ថយនូវផលប៉ះពាល់ទៅលើបរិស្ថាន។

### ការផ្តល់អំណាចដល់អ្នកមានសមត្ថភាព និងភាពជាអ្នកដឹកនាំ

យើងជឿជាក់ថានិរន្តរភាពត្រូវបានជំរុញដោយមនុស្ស។ ដើម្បីធានាថាយុទ្ធសាស្ត្ររបស់យើងត្រូវបានអនុវត្តនៅគ្រប់កម្រិត ពេលនេះ ១០០% នៃអ្នកគ្រប់គ្រងបុគ្គលិក នៅក្នុងប្រទេសកម្ពុជា មានសូចនាកររាស់ស្ទង់សមិទ្ធផលការងារ (KPIs) ផ្សារភ្ជាប់នឹងនិរន្តរភាព ដែលត្រូវបានបញ្ចូលទៅក្នុងគោលដៅប្រចាំឆ្នាំរបស់ពួកគេ។ ចំណុចនេះធ្វើឱ្យការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ ស្របគ្នាជាមួយនឹងលទ្ធផលនានា ដូចជាការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងការប្រើប្រាស់ទិន្នន័យព្រមទាំងបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) ប្រកបដោយការទទួលខុសត្រូវ។

ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរវប្បធម៌នេះ យើងបានផ្តល់អាទិភាពដល់ថាមពលនៃធនធានបុគ្គលិក តាមរយៈកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដ៏រឹងមាំ។

ក្នុងឆ្នាំ២០២៥ យើងបានបំពាក់បំប៉នបុគ្គលិកជាន់ខ្ពស់តាមរយៈ កម្មវិធី ‘Leap’៖ គឺជាកម្មវិធីសិក្សាដែលមានឥទ្ធិពលខ្ពស់ ដោយផ្តោតលើសិក្ខាកាមចំនួន ២០ នាក់ ដើម្បីពន្លឿនការរីកចម្រើនផ្នែកវិជ្ជាជីវៈ និងការគិតបែបយុទ្ធសាស្ត្រ។

### សុខុមាលភាពគ្រប់ជ្រុងជ្រោយ និងសមភាពយេនឌ័រ

អាជីវកម្មប្រកបដោយចីរភាព ត្រូវតែជាអាជីវកម្មដែលមានបរិយាបន្ន និងសុខភាពល្អ។ ក្នុងឆ្នាំ ២០២៥ យើងបានពង្រឹងការគាំទ្រដល់សុខភាពបុគ្គលិក តាមរយៈការចាប់ដៃគូជាមួយ Naluri ដែលជាកម្មវិធីសុខុមាលភាពឌីជីថលផ្អែកលើពត៌មានបុគ្គលិកជាក់ស្តែង។ Naluri ផ្តល់ឱ្យបុគ្គលិករបស់យើងនូវការប្រឹក្សាផ្ទាល់ខ្លួន និងការគាំទ្រសុខភាពផ្លូវចិត្តដោយសម្ងាត់ ដើម្បីដោះស្រាយបញ្ហាស្ត្រេស ការអស់កម្លាំងពីការងារ ដែលអាចបង្ករជាហានិភ័យនៃជំងឺរ៉ាំរ៉ៃ។ តាមរយៈការបណ្តុះនូវភាពស៊ាំផ្នែកផ្លូវចិត្ត និងសុខភាពផ្លូវកាយ យើងធានាថា បុគ្គលិករបស់យើងមានសមត្ថភាពពេញលេញក្នុងការបំពេញការងារប្រកបដោយនិរន្តរភាពក្នុងរយៈពេលវែង។



# ព័ត៌មានអំពីចីរភាព

លើសពីនេះទៅទៀត ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) បានឈានដល់ចំណុចរបត់ប្រវត្តិសាស្ត្រមួយក្នុងដំណើរឆ្ពោះទៅរកសមធម៌សង្គម។ នៅថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០២៥ យើងបានក្លាយជាហត្ថលេខីផ្លូវការនៃ គោលការណ៍ផ្តល់អំណាចដល់ស្ត្រីរបស់អង្គការសហប្រជាជាតិ (WEPs) នៃអង្គការសហប្រជាជាតិដើម្បីសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី។ ការប្តេជ្ញាចិត្តជាសាធារណៈនេះ ដែលត្រូវបានបញ្ជាក់សារជាថ្មីដោយអគ្គនាយកក្រុមហ៊ុនរបស់យើង ធានាថាស្ត្រីនៅក្នុងប្រទេសកម្ពុជានឹងទទួលបានឱកាសស្មើៗគ្នា ក្នុងការតំណាង និងភាពជាអ្នកដឹកនាំ។ តាមរយៈការតស៊ូមតិសម្រាប់សមភាពយេនឌ័រនៅកន្លែងធ្វើការ និងនៅលើទីផ្សារ យើងកំពុងទាញយកសក្តានុពលពេញលេញនៃធនធានបុគ្គលិកដ៏សម្បូរបែបរបស់កម្ពុជា ដែលធ្វើឱ្យអាជីវកម្មរបស់យើងកាន់តែមានភាពច្នៃប្រឌិត និងរឹងមាំ។

តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នាលើប្រសិទ្ធភាពបរិស្ថាន ការអភិវឌ្ឍភាពជាអ្នកដឹកនាំ និងការអនុវត្តបរិយាបន្នទាំងនេះ ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា មិនត្រឹមតែអនុវត្តតាមស្តង់ដារសកលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកំពុងបង្កើតនូវបទដ្ឋានគំរូក្នុងស្រុកមួយ សម្រាប់និយមន័យនៃអាជីវកម្មប្រកបដោយនិរន្តរភាពពិតប្រាកដក្នុងសតវត្សទី ២១ នេះ។

### អំពីសូចនាកររង្វាស់ស្នូង់សមិទ្ធផលការងារ (KPIs) ផ្សារភ្ជាប់នឹងនិរន្តរភាព

នៅក្រុមហ៊ុន ព្រូដិនសល និងព្រូដិនសល ខេមបូឌា និរន្តរភាពគឺជាការទទួលខុសត្រូវដែលត្រូវបានអនុវត្តជាក់ស្តែង មិនមែនគ្រាន់តែជាមុខងារការងារដាច់ដោយឡែកណាមួយនោះទេ។ ដើម្បីផ្សារភ្ជាប់មហិច្ឆតាសកលទៅនឹងការអនុវត្តក្នុងស្រុក យើងបានដាក់បញ្ចូលសូចនាកររង្វាស់ស្នង់សមិទ្ធផលការងារ (KPIs) ផ្សារភ្ជាប់នឹងនិរន្តរភាព ទៅក្នុងក្របខ័ណ្ឌវាយតម្លៃការងាររបស់ថ្នាក់ដឹកនាំរបស់យើងដោយផ្ទាល់។ គំនិតផ្តួចផ្តើមនេះធានាថា ផលប៉ះពាល់ជាវិជ្ជមាននៃបរិស្ថាន និងសង្គមរយៈពេលវែង ត្រូវបានជំរុញតាមរយៈការផ្តល់នូវភាពជាម្ចាស់ការសកម្ម ជាជាងត្រឹមតែជាកិច្ចខិតខំប្រឹងប្រែងតាមស្ម័គ្រចិត្ត។

ដើម្បីរៀបចំថ្នាក់ដឹកនាំរបស់យើងសម្រាប់ការផ្លាស់ប្តូរនេះ អ្នកគ្រប់គ្រងបុគ្គលិកទាំងអស់តម្រូវឱ្យចូលរួមក្នុងវគ្គសិក្សាបង្គោល «មូលដ្ឋានគ្រឹះនៃនិរន្តរភាព» (Sustainability 101)។ ការបណ្តុះបណ្តាលជាមូលដ្ឋាននេះ ធានាថាអ្នកគ្រប់គ្រងម្នាក់ៗយល់ច្បាស់អំពីរបៀបដែលគោលដៅបុគ្គលរបស់ពួកគេ រាប់ចាប់ពីការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិក រហូតដល់ការលើកកម្ពស់ភាពចម្រុះនៃយេនឌ័រ បានរួមចំណែកដល់គោលដៅសកលដ៏ធំទូលាយរបស់ព្រូដិនសល។








# ព័ត៌មានអំពីចីរភាព

តាមរយៈការភ្ជាប់លទ្ធផលទាំងនេះទៅនឹងកញ្ចប់អត្ថប្រយោជន៍លើកទឹកចិត្តសម្រាប់ថ្នាក់ដឹកនាំ យើងបានផ្តល់សញ្ញាថានិរន្តរភាពគឺជាអាទិភាពអាជីវកម្មស្នូល។ ជាមួយនឹងគោលដៅសម្រេចឱ្យបាន ១០០% នៅត្រឹមឆ្នាំ ២០២៦ វិធីសាស្ត្រនេះបានប្រែក្លាយនិរន្តរភាពឱ្យទៅជាវប្បធម៌ដែលមានការរាស់វែងច្បាស់លាស់ និងប្រកបដោយនិរន្តរភាព ដែលពង្រឹងជំនឿទុកចិត្តជាមួយអតិថិជន ដៃគូ និងស្ថាប័ននិយតករនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

### វិធីសាស្ត្រនៃការរាយការណ៍

នៅក្រុមហ៊ុន ព្រូដិនសល ការរាយការណ៍អំពីនិរន្តរភាពគឺជាគោលដៅយុទ្ធសាស្ត្រនៃវឌ្ឍនភាពដែលជំរុញដោយបេសកកម្មរបស់យើង។ ទោះបីជាបច្ចុប្បន្នការរាយការណ៍នេះធ្វើឡើងដោយស្ម័គ្រចិត្តក៏ដោយ ប៉ុន្តែការបកស្រាយព័ត៌មានរបស់យើងអនុលោមយ៉ាងម៉ឹងម៉ាត់តាមច្បាប់ក្រុមហ៊ុនរបស់ចក្រភពអង់គ្លេស (UK Companies Act) វិធាននៃការចុះបញ្ជីរបស់ FCA និងក្រមរាយការណ៍ ESG របស់ផ្សារភាគហ៊ុនហុងកុង (HKEX)។ យើងបានដាក់បញ្ចូលទាំងស្រុងនូវតាមការណែនាំ របស់ TCFD និងតម្រូវការបកស្រាយព័ត៌មានដែលពាក់ព័ន្ធនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ ISSB S2 ថ្មី។

ក្រុមហ៊ុន ព្រូដិនសល ខេមបូឌា បានផ្តល់ទិន្នន័យក្នុងស្រុកជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងស្តង់ដារអន្តរជាតិដ៏តឹងរ៉ឹងទាំងនេះ។ តាមរយៈការបញ្ច្រាបទស្សនៈវិស័យនៃទីផ្សារកម្ពុជាទៅក្នុងរបាយការណ៍កម្រិតគ្រុប (Group) យើងធានាបាននូវការអនុលោមតាមស្តង់ដារបកស្រាយព័ត៌មាននិរន្តរភាព IFRS និងជួយសម្រួលដល់ការធានាដែលមានកម្រិតច្បាស់លាស់ដោយឯករាជ្យលើសូចនាករសំខាន់ៗ រួមទាំងការបញ្ចេញឧស្ម័នក្នុងវិសាលភាពទី ១, ២ និង ៣។ វិធីសាស្ត្រដែលបង្រួបបង្រួមគ្នានេះ បង្ហាញពីការប្តេជ្ញាចិត្តរបស់យើងចំពោះតម្លាភាព និងអភិបាលកិច្ចប្រកបដោយសីលធម៌ ដែលតភ្ជាប់សមិទ្ធផលក្នុងតំបន់ទៅនឹងការរំពឹងទុកជាសកល។ តាមរយៈបេសកកម្មស្របគ្នានេះ ព្រូដិនសល ខេមបូឌា ធានាថាប្រតិបត្តិការក្នុងស្រុករបស់ខ្លួន រួមចំណែកដោយផ្ទាល់ដល់ការបង្កើតតម្លៃរយៈពេលវែងដ៏រឹងមាំរបស់គ្រុប និងការបកស្រាយព័ត៌មានហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងអាកាសធាតុ។

### អភិបាលកិច្ច និងការត្រួតពិនិត្យទិន្នន័យក្នុងរបាយការណ៍ចីរភាព

អភិបាលកិច្ចទិន្នន័យនិរន្តរភាពរបស់ព្រូដិនសល ត្រូវបានផ្អែកលើអភិបាលកិច្ច គោលនយោបាយ និងការត្រួតពិនិត្យកម្រិតគ្រុបដ៏រឹងមាំ ដែលត្រូវបានរចនាឡើងដើម្បីធានានូវភាពត្រឹមត្រូវ សង្គតិភាព និងសុចរិតភាពនៃទិន្នន័យ ESG និងការបកស្រាយព័ត៌មាន។ នៅកម្រិតគ្រុប ទិន្នន័យនិរន្តរភាពត្រូវបានគ្រប់គ្រងតាមរយៈក្របខ័ណ្ឌរាយការណ៍ដែលបានកំណត់ វិសាលភាពទិន្នន័យ និងដំណើរការធានាដែលបានចែងនៅក្នុងរបាយការណ៍និរន្តរភាព និងមូលដ្ឋាននៃការរាយការណ៍របស់ព្រូដិនសល។ សូចនាករចីរភាពសំខាន់ៗដែលបោះពុម្ពផ្សាយដោយព្រូដិនសល គឺស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទៃក្នុង ហើយសម្រាប់សូចនាករដែលបានជ្រើសរើស គឺមានការធានាពីខាងក្រៅដោយឯករាជ្យ ដើម្បីពង្រឹងតម្លាភាព និងគណនេយ្យភាព។

នៅក្នុងទីផ្សារ CLM (កម្ពុជា ឡាវ មីយ៉ាន់ម៉ា) អភិបាលកិច្ចទិន្នន័យនិរន្តរភាពត្រូវបានដាក់ឱ្យដំណើរការតាមរយៈ «ក្រុមប្រឹក្សាអភិបាលកិច្ចទិន្នន័យ CLM» ដែលផ្តល់ការត្រួតពិនិត្យ និងការសម្របសម្រួលអន្តរមុខងារលើទិន្នន័យពាក់ព័ន្ធនឹងនិរន្តរភាព។ តួនាទីរបស់ក្រុមប្រឹក្សាគឺដើម្បីធានាថា ទិន្នន័យនិរន្តរភាពដែលប្រើប្រាស់សម្រាប់ការរាយការណ៍ការសម្រេចចិត្ត និងការបកស្រាយព័ត៌មានខាងក្រៅ ត្រូវបានកំណត់ និងផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ព្រមទាំងស្របតាមវិធីសាស្ត្រ និងស្តង់ដាររាយការណ៍របស់គ្រុប។ ចំណុចនេះរួមបញ្ចូលទាំងការត្រួតពិនិត្យលើភាពជាម្ចាស់នៃទិន្នន័យ ការត្រួតពិនិត្យគុណភាពទិន្នន័យ និងការរាយការណ៍អំពីហានិភ័យដែលពាក់ព័ន្ធនឹងសុចរិតភាពទិន្នន័យ ឬភាពមិនស៊ីសង្វាក់គ្នា ស្របតាមគោលការណ៍អភិបាលកិច្ចទិន្នន័យសហគ្រាស និងនីតិវិធីប្រតិបត្តិការផ្ទៃក្នុងរបស់ព្រូដិនសល។

# ព័ត៌មានអំពីចីរភាព

## ការត្រួតពិនិត្យហានិភ័យនៃការបំភាន់របាយការណ៍

ព្រូដិនសលទទួលស្គាល់ថាការបំភាន់របាយការណ៍(Greenwashing) គឺជាហានិភ័យផ្នែកអភិបាលកិច្ច និងកេរ្តិ៍ឈ្មោះដ៏សំខាន់។ ដើម្បីកាត់បន្ថយបញ្ហានេះ គ្រុបបានបញ្ចូលការការពារការបំភាន់នេះទៅក្នុងគោលនយោបាយចីរភាព ក្រមសីលធម៌អាជីវកម្មរបស់គ្រុប ក្របខ័ណ្ឌហានិភ័យ និងអភិបាលកិច្ចនៃការរាយការណ៍របាយការណ៍ចីរភាព។

គោលនយោបាយទាំងនេះតម្រូវឱ្យរាល់ការអះអាងដែលពាក់ព័ន្ធនឹងនិរន្តរភាពទាំងអស់ ត្រូវតែផ្អែកលើភស្តុតាង គាំទ្រដោយទិន្នន័យដែលអាចផ្ទៀងផ្ទាត់បាន និងស្របតាមនិយមន័យ និងវិធីសាស្ត្រដែលបានអនុម័ត។ ការបកស្រាយព័ត៌មាននិរន្តរភាព ត្រូវបានគ្រប់គ្រងដោយស្តង់ដាររាយការណ៍ដែលមានឯកសារយោង និងដំណើរការពិនិត្យផ្ទៃក្នុង ដើម្បីធានាថាការអះអាងទាំងនោះឆ្លុះបញ្ចាំងពីសមិទ្ធផលការងារពិតប្រាកដ។

ក្នុងផ្នែកប្រតិបត្តិការ នីតិវិធីប្រតិបត្តិការស្តង់ដារ (SOPs) ផ្ទៃក្នុង គាំទ្រដល់គោលនយោបាយទាំងនេះ ដោយបង្កើតតួនាទី និងការត្រួតពិនិត្យច្បាស់លាស់លើការប្រមូលទិន្នន័យ ការផ្ទៀងផ្ទាត់ ការអនុម័ត និងការបកស្រាយព័ត៌មាន។ ទិន្នន័យនិរន្តរភាព ត្រូវស្ថិតក្រោមការពិនិត្យដេញដោល និងការត្រួតពិនិត្យផ្ទៃក្នុង ជាមួយនឹងយន្តការរាយការណ៍ច្បាស់លាស់ នៅពេលដែលរកឃើញនូវចន្លោះប្រហោងនៃទិន្នន័យភាពមិនស៊ីសង្វាក់គ្នា ឬហានិភ័យនៃការបង្ហាញព័ត៌មានមិនត្រឹមត្រូវ។ ការប្តេជ្ញាចិត្តរបស់ព្រូដិនសលចំពោះការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចដ៏រឹងមាំ ធានាថាការផ្សព្វផ្សាយអំពីនិរន្តរភាព រួមទាំងសូចនាករបរិស្ថាន និងការប្តេជ្ញាចិត្តនានា ត្រូវបានត្រួតពិនិត្យក្នុងកម្រិតមួយដែលស្របតាមការរំពឹងទុកនៃបទបញ្ញត្តិ និងស្តង់ដារសកលដែលកំពុងត្រួតពិនិត្យ ស្តីពីការការពារការបំភាន់របាយការណ៍ ។








ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | **ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម** | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

**ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរិនស៍ ម.ក**
(លេខចុះបញ្ជីពាណិជ្ជកម្ម 00012967)

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
និង
របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ដោយអនុលោមទៅតាម
ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”)
ជាមួយការពន្យារពេលលើការអនុវត្តនៃ CIFRS 17 កិច្ចសន្យាធានារ៉ាប់រង និង
CIFRS 9 ឧបករណ៍ហិរញ្ញវត្ថុ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

ទំព័រ


| | |
|---|---|
| 1. ព័ត៌មានអំពីក្រុមហ៊ុន | 68 |
| 2. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 69 |
| 3. របាយការណ៍របស់សវនករឯករាជ្យ | 72 |
| 4. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | 75 |
| 5. របាយការណ៍លទ្ធផលពេញលេញ | 76 |
| 6. របាយការណ៍បម្រែបម្រួលមូលធន | 77 |
| 7. របាយការណ៍លំហូរសាច់ប្រាក់ | 78 |
| 8. កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 80 |




# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សូរិនស៍ ម.ក | |
| លេខចុះបញ្ជីពាណិជ្ជកម្ម | 00012967 | |
| ទីតាំងក្រុមហ៊ុន | #អគារ ជីប ម៉ុង ថៅវើ ចំណែកឯកជន លេខ L19 L20 និង L21 ជាន់ទី19 20 និង21 ផ្លូវសហព័ន្ធរុស្ស៊ី (110) ភូមិ10 សង្កាត់ផ្សារដេប៉ូទី3 ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ភាគទុនិក | Prudential Corporation Holdings Limited<br>PCA IP Services Limited<br>Prudential Holdings Limited | |
| ក្រុមប្រឹក្សាភិបាល | លោក Wilson Wing Yiu Ma | អភិបាលមិនប្រតិបត្តិ/ប្រធានក្រុមប្រឹក្សាភិបាល (ចប់អាណត្តិនៅថ្ងៃទី30 ខែមិថុនា ឆ្នាំ2025) |
| | លោក ពន្លឺ តុលា | អភិបាលប្រតិបត្តិ |
| | លោក ហូរ វរៈបុត្ត | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| | លោកបណ្ឌិត ម៉ី កល្យាណ | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| | លោក ស៊ឹម ហ៊ុយឈីង | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ (ចប់អាណត្តិនៅថ្ងៃទី01 ខែវិច្ឆិកា ឆ្នាំ2025) |
| | លោកស្រី សូ ផុនណារី | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| | លោកស្រី Ng Sim Kheng | អភិបាលមិនប្រតិបត្តិ |
| គណៈគ្រប់គ្រង | លោក ពន្លឺ តុលា | អគ្គនាយក |
| | លោក Chi Chung Wong | នាយកផ្នែកហិរញ្ញវត្ថុ (ត្រូវបានតែងតាំងនៅថ្ងៃទី25 ខែកុម្ភៈ ឆ្នាំ2025) |
| | កញ្ញា Chu Ing Shin | នាយកផ្នែកជំនាញគណនាបុព្វលាភធានារ៉ាប់រង និងផលិតផល (ត្រូវបានតែងតាំងនៅថ្ងៃទី02 ខែឧសភា ឆ្នាំ2025) |
| | លោក សុក ហេង | នាយកផ្នែកព័ត៌មានវិទ្យា និងប្រតិបត្តិការ |
| | លោក Chee Weng Yip | នាយកផ្នែកលក់ និងចែកចាយ |
| | លោក Zameen Zahari | នាយកផ្នែកហានិភ័យ (ចប់អាណត្តិនៅថ្ងៃទី02 ខែកញ្ញា ឆ្នាំ2025) |
| | លោក John Masvongo | នាយកផ្នែកផ្នែកហានិភ័យ និងអនុលោមភាព បណ្តោះអាសន្ន (ត្រូវបានតែងតាំងនៅថ្ងៃទី05 ខែកញ្ញា ឆ្នាំ2025) |
| | លោកស្រី តេង សុផាន់ណា | នាយកផ្នែកធនធានមនុស្ស (ត្រូវបានតែងតាំងនៅថ្ងៃទី14 ខែកក្កដា ឆ្នាំ2025) |
| ធនាគារិកចម្បងៗ | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់<br>ធនាគារ កម្ពុជា សាធារណៈ ភីអិលស៊ី<br>ធនាគារ កាណាឌីយ៉ា ក.អ<br>ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក<br>ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក<br>ធនាគារ ស្ថាបនា ភីអិលស៊ី<br>ធនាគារ វីង (ខេមបូឌា) ម.ក | |
| សវនករ | ក្រុមហ៊ុន អឺនស្ទ៍ អែន យ៉ាំង (ខេមបូឌា) | |





## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការដាក់ជូនរបាយការណ៍របស់ខ្លួន ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សូរិនស៍ ម.ក ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលបានធ្វើសវនកម្មរួចនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាកម្មធានារ៉ាប់រងអាយុជីវិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទមានដូចខាងក្រោម៖

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់លេខ 2.3) |
| ប្រាក់ចំណេញមុនគិតពន្ធ | 1,362,380 | 5,464,508 | 5,000,512 | 20,357,084 |
| ចំណាយពន្ធលើប្រាក់ចំណូល | (386,678) | (1,550,965) | (1,457,387) | (5,933,022) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **975,702** | **3,913,543** | **3,543,125** | **14,424,062** |

## ភាគលាភ

ពុំមានការប្រកាស ឬ ការបែងចែកភាគលាភ ហើយក្រុមប្រឹក្សាភិបាលមិនបានផ្តល់អនុសាសន៍អំពីការទូទាត់ភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

## ដើមទុន

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ក្រុមហ៊ុនមានដើមទុនសរុបចំនួន 61,320,000 ដុល្លារអាមេរិក (ថ្ងៃទី31 ខែធ្នូ

ឆ្នាំ2024៖ 61,320,000 ដុល្លារអាមេរិក) ដូចដែលបានបង្ហាញនៅកំណត់សម្គាល់លេខ 17 នៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

មិនមានការផ្លាស់ប្តូរមូលធន និងរចនាសម្ព័ន្ធភាគទុនិករបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

## ទុនបម្រុង និងសំវិធានធន

រាល់ការបន្ថែម ឬ បន្ថយនៅក្នុងទុនបម្រុង និងសំវិធានធនជាសារវន្តនៅក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| លោក Wilson Wing Yiu Ma | អភិបាលមិនប្រតិបត្តិ/ប្រធានក្រុមប្រឹក្សាភិបាល<br>(ចប់អាណត្តិនៅថ្ងៃទី30 ខែមិថុនា ឆ្នាំ2025) |
| លោក ពន្លឺ តុលា | អភិបាលប្រតិបត្តិ |
| លោក ហូរ វរៈបុត្ត | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| លោកបណ្ឌិត ម៉ី កល្យាណ | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| លោក ស៊ឹម ហ៊ុយឈ័ង | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ<br>(ចប់អាណត្តិនៅថ្ងៃទី01 ខែវិច្ឆិកា ឆ្នាំ2025) |
| លោកស្រី សូ ផុនណារី | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| លោកស្រី Ng Sim Kheng | អភិបាលមិនប្រតិបត្តិ |

## ភាគហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់កាន់កាប់ ឬ មានការទាក់ទិននៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬ ដោយប្រយោល នៅក្នុងការិយបរិច្ឆេទនេះទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយ ដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញប័ណ្ណភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬ ពីក្រុមហ៊ុនដទៃទៀតទេ លើកលែងតែការទូទាត់លើចំណែកភាគហ៊ុនដោយប្រើមូលធនទទួលបាន ដោយក្រុមប្រឹក្សាភិបាលដែលជាផ្នែកមួយ នៃអត្ថប្រយោជន៍ សម្រាប់បុគ្គលិកពេញម៉ោង។

ពុំមានអភិបាលណាម្នាក់ដែលបានទទួលផលប្រយោជន៍ ឬ សិទ្ធិក្នុងការទទួលផលប្រយោជន៍នានា (ក្រៅពី អត្ថប្រយោជន៍ដែលបានទទួលដោយ ឬក៏ជំពាក់ទៅក្រុមប្រឹក្សាភិបាល ឬប្រាក់បៀវត្សរ៍ពីការបំពេញការងារពេញម៉ោង ដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ 24 នៃរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈកិច្ចសន្យាដែលធ្វើឡើងដោយក្រុមហ៊ុន ឬ សហការីរបស់ក្រុមហ៊ុនជាមួយនឹង ក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬ ក៏ជាមួយក្រុមហ៊ុន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែមានការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិតនឹងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ202៥ និងលទ្ធផលហិរញ្ញវត្ថុព្រមទាំងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (“CIFRSs”) ជាមួយការពន្យារពេលលើការអនុវត្តនៃ CIFRS 17 កិច្ចសន្យាធានារ៉ាប់រង និង CIFRS 9 ឧបករណ៍ហិរញ្ញវត្ថុ (“CIFRSs ជាមួយការពន្យារលើ CIFRS 17 និង CIFRS 9) ស្របតាមការអនុម័តរបស់និយ័តករគណនេយ្យ និងសវនកម្ម ដែលអនុញ្ញាតសម្រាប់ការពន្យារលើការអនុវត្ត *(សូមមើលកំណត់សម្គាល់លេខ 2.1)*។





ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យនូវការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដោយគណៈគ្រប់គ្រង ដែលចាំបាច់ត្រូវ៖

- អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។
- អនុលោមតាមលក្ខខណ្ឌតម្រូវរបស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិរបស់កម្ពុជា (“CIFRSs”) ជាមួយនឹងការពន្យារពេលនៃ CIFRS 17 និង CIFRS 9 ហើយប្រសិនបើមានការចាកចេញណាមួយដើម្បីផលប្រយោជន៍នៃបទបង្ហាញដោយយុត្តិធម៌ ត្រូវប្រាកដថាវាត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវ ពន្យល់ និង បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- រក្សាកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានភាពមិនសមរម្យក្នុងការសន្មតថាក្រុមហ៊ុននឹងបន្តប្រតិបត្តិការនាពេលអនាគត ដែលអាចរំពឹងទុកបាន និង
- កំណត់គោលការណ៍រួមសម្រាប់ក្រុមហ៊ុន ផ្តល់សច្ចាប័នលើការសម្រេចចិត្ត និងសកម្មភាពទាំងអស់ដោយអ្នកគ្រប់គ្រងដែលមានឥទ្ធិពលជាសារវន្តដល់ប្រតិបត្តិការ និងការអនុវត្តរបស់ក្រុមហ៊ុន ហើយធានាថាពួកគេត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការធានាថា បញ្ជីគណនេយ្យ ដែលមានភាពសមស្រប ត្រូវបាន រក្សាទុកដែលលាតត្រដាងអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឲ្យបានត្រឹមត្រូវសមហេតុផលគ្រប់ពេលវេលា និងធានាថាបញ្ជីគណនេយ្យទាំងនោះ គោរពតាមប្រព័ន្ធគណនេយ្យដែលអនុវត្ត។ គណៈគ្រប់គ្រង ក៏មានទំនួលខុសត្រូវក្នុងការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដោយហេតុដូច្នេះហើយ គណៈគ្រប់គ្រងត្រូវមានការចាត់វិធានការសមហេតុផលសម្រាប់ការទប់ស្កាត់ និងការរកឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗទៀត។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុស្របតាមមាត្រា 226 នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

ខ្ញុំបាទ ពន្លឺ តុលា តំណាងឲ្យក្រុមប្រឹក្សាភិបាលទាំងមូល សូមបញ្ជាក់នៅទីនេះថា របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ202៥ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាម CIFRSs ជាមួយនឹងការពន្យារពេលនៃ CI-FRS 17 និង CIFRS 9 អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងវិស័យធានារ៉ាប់រង។

*ចុះហត្ថលេខាយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖*

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរ៉ិនស៍ PRUDENTIAL (CAMBODIA) LIFE ASSURANCE PLC KINGDOM OF CAMBODIA

លោក ពន្លឺ តុលា
អគ្គនាយក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី18 ខែមីនា ឆ្នាំ2026

Shape the future
with confidence

(លេខយោង៖ 61038570/69299305)

## របាយការណ៍របស់សវនករឯករាជ្យ

**ជូនចំពោះ៖ ភាគទុនិក និងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនធានារ៉ាប់រង ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរិនស៍ ម.ក**

### មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរិន ម.ក ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 របាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានពត៌មានគោលនយោបាយគណនេយ្យជាសារវន្ត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុនេះ បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”) ជាមួយការពន្យារពេលលើការអនុវត្តនៃ CIFRS 17 កិច្ចសន្យាធានារ៉ាប់រង និង CIFRS 9 ឧបករណ៍ហិរញ្ញវត្ថុ ស្របតាមសេចក្តីជូនដំណឹងរបស់និយតករគណនេយ្យ និងសវនកម្ម ដែលអនុញ្ញាតសម្រាប់ការពន្យារលើការអនុវត្ត។

### មូលដ្ឋាននៃមតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា (“CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំយោងតាមស្តង់ដាទាំងនោះ ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ *ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ដោយយោងទៅតាមប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករជំនាញ ដែលសមស្របចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៃសហគ្រាសដែលទទួលខុសត្រូវជាសាធារណៈចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃកម្ពុជា ជាមួយនឹងតម្រូវការផ្នែកសីលធម៌ ដែលពាក់ព័ន្ធនឹងការងារសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុនៃសហគ្រាសដែលទទួលខុសត្រូវជាសាធារណៈនៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំក៏បានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌របស់យើងខ្ញុំ ដោយស្របតាមតម្រូវការទាំងនេះផងដែរ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន មានលក្ខណៈ គ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ការសង្កត់ធ្ងន់លើបញ្ហា

យើងខ្ញុំ សូមទាញចំណាប់អារម្មណ៍ទៅកំណត់សម្គាល់លេខ 21 នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលរៀបរាប់ ពីការណែនាំលើការពន្យារពេលក្នុងការអនុវត្តនៃ CIFRS 17 និង CIFRS 9។ មតិរបស់យើងមិនមានការកែប្រែ ចំពោះបញ្ហានេះឡើយ។

### ព័ត៌មានផ្សេងៗ ក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ព័ត៌មានដទៃផ្សេងទៀត ដែលទទួលបាននាកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រង មានទំនួលខុសត្រូវ ចំពោះព័ត៌មានផ្សេងៗនេះ។

មតិយោបល់របស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និដ្ឋានធានាអះអាងក្នុងទម្រង់ណាមួយទៅលើព័ត៌មានផ្សេងៗនេះដែរ។

ទាក់ទងនឹងការងារសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺអានព័ត៌មានផ្សេងៗនេះ ហើយធ្វើការពិចារណាថា តើព័ត៌មានផ្សេងៗនេះមានភាពខុសគ្នាជាសារវន្ត ឬទេជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបាននៅក្នុងការងារសវនកម្ម ឬ ថាតើព័ត៌មានផ្សេងៗនេះ មានកំហុសឆ្គងជាសារវន្ត





Shape the future
with confidence

ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវតម្រូវឲ្យរាយការណ៍ តាមភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ចំពោះព័ត៌មានផ្សេងៗនេះទេ។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ច

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម CIFRSs ជាមួយការពន្យារពេលលើ CIFRS 17 និង CIFRS 9 ហើយនិងទទួលខុសត្រូវដូចគ្នាផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធភាពនិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុន និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់ក្រុមហ៊ុន លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬ បញ្ឈប់ប្រតិបត្តិការក្រុមហ៊ុន ឬក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ច មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

### ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករ ដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្មដែលប្រព្រឹត្តទៅដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្ត ដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្តប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”) យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃនូវហានិភ័យនៃកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពី ការក្លែងបន្លំ ឬភាន់ច្រឡំ បង្កើត និងអនុវត្តនូវនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹង ហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានីភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានកម្រិតខ្ពស់ជាង ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គង ដែលបណ្តាលបមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចទាក់ទិននឹងការឃុបឃិត ការបន្លំ ការលុបចោលដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានា ដែលបានធ្វើឡើងដោយគណៈគ្រប់គ្រង។

EY
Shape the future
with confidence

- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៅក្នុងគណនេយ្យរបស់គណៈគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ និងលក្ខខណ្ឌទាំងឡាយណាដែលអាចបង្កឲ្យមានមន្ទិលជាសារវន្តលើនិរន្តភាពដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនដែរ ឬទេ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬ លក្ខខណ្ឌនាពេលអនាគតអាចបង្កឲ្យក្រុមហ៊ុនមិនអាចបន្តនិរន្តរភាពរបស់អាជីវកម្ម។
- វាយតម្លៃលើការដាក់បង្ហាញ ទម្រង់ និងមាតិកាទាំងស្រុងនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធដើម្បីអាចសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

ក្នុងចំណោមបញ្ហាដ៏ទៃទៀត យើងខ្ញុំ បានធ្វើការទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ច វិសាលភាពដែលបានគ្រោងទុក និងពេលវេលានៃការងារសវនកម្ម និងការរកឃើញសវនកម្មសំខាន់ៗ រួមបញ្ចូលផងដែរ នូវកង្វះខ្វះខាតសំខាន់ៗទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងពេលធ្វើសវនកម្ម។

Emmanuel A. Guelas
Partner

អឺនស្ទ័ អែន យ៉ាំង (ខេមបូឌា).
ក្រុមហ៊ុនគណនេយ្យករជំនាញ
សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី18 ខែមីនា ឆ្នាំ2026



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

(លេខយោង៖ 00012967)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | កំណត់សម្គាល់ | 2025 | | 2024 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) (ដូចដែលបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ 30) |
| **ទ្រព្យសកម្ម** | | | | | |
| ទ្រព្យ និងបរិក្ខារ | 7 | 2,249,320 | 9,026,521 | 2,506,177 | 10,087,362 |
| ចំណាយពន្យារ និងទ្រព្យសកម្មអរូបីផ្សេងៗ | 8 | 55,945,922 | 224,510,985 | 54,012,007 | 217,398,328 |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | 10 | 2,290,953 | 9,193,594 | 2,464,465 | 9,919,472 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | 9 | 700,000 | 2,809,100 | 700,000 | 2,817,500 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 20 | 385,310 | 1,546,249 | 272,437 | 1,096,559 |
| គណនីធានារ៉ាប់រង និងគណនីត្រូវទទួលផ្សេងៗ | 11 | 21,098,053 | 84,666,488 | 25,019,098 | 100,701,869 |
| ទ្រព្យសកម្មនៃការធានារ៉ាប់រងបន្ត | 12 | 561,950 | 2,255,105 | 342,237 | 1,377,504 |
| ប្រាក់បញ្ញើនៅធនាគារ | 13 | 315,982,268 | 1,268,036,841 | 289,982,268 | 1,167,178,629 |
| ការវិនិយោគកាន់កាប់រហូតដល់កាលកំណត់ | 14 | 57,681,915 | 231,477,525 | 32,940,668 | 132,586,189 |
| មូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញ ឬខាត | 15 | 1,824,072 | 7,320,000 | 1,873,292 | 7,540,000 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 16 | 4,032,848 | 16,183,819 | 5,591,084 | 22,504,113 |
| **ទ្រព្យសកម្មសរុប** | | 462,752,611 | 1,857,026,227 | 415,703,733 | 1,673,207,525 |
| | | | | | |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | 17 | 61,320,000 | 245,280,000 | 61,320,000 | 245,280,000 |
| ប្រាក់ចំណេញរក្សាទុក | | 32,828,323 | 134,550,872 | 31,852,621 | 130,637,329 |
| លម្អៀងបង្គរពីការប្តូររូបិយប័ណ្ណ | | - | (2,013,652) | - | (897,529) |
| **មូលធនសរុប** | | 94,148,323 | 377,817,220 | 93,172,621 | 375,019,800 |
| | | | | | |
| **បំណុល** | | | | | |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | 18 | 353,893,162 | 1,420,173,259 | 301,335,961 | 1,212,877,243 |
| គណនីធានារ៉ាប់រង និងគណនីត្រូវទូទាត់ផ្សេងៗ | 19 | 12,449,472 | 49,959,730 | 18,931,141 | 76,197,842 |
| បំណុលភតិសន្យា | 10 | 2,261,654 | 9,076,018 | 2,264,010 | 9,112,640 |
| បំណុលពន្ធលើប្រាក់ចំណូល | 20 | - | - | - | - |
| **បំណុលសរុប** | | 368,604,288 | 1,479,209,007 | 322,531,112 | 1,298,187,725 |
| **មូលធន និងបំណុលសរុប** | | 462,752,611 | 1,857,026,227 | 415,703,733 | 1,673,207,525 |

(លេខយោង៖ 00012967)

## របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | កំណត់សម្គាល់ | 2025 | | 2024 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) (ដូចដែលបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ 30) |
| ចំណូលបុព្វលាភធានារ៉ាប់រងដុល | | 73,358,156 | 294,239,564 | 84,110,354 | 342,413,251 |
| បុព្វលាភធានារ៉ាប់រងបន្ត | | (1,068,631) | (4,286,279) | (715,595) | (2,913,187) |
| **បុព្វលាភសុទ្ធ** | | **72,289,525** | **289,953,285** | **83,394,759** | **339,500,064** |
| ចំណូល (ចំណាយ) ផ្សេងៗ | | 256,282 | 1,027,947 | (417,676) | (1,700,359) |
| ចំណូលហិរញ្ញវត្ថុ | 21 | 21,161,780 | 84,879,900 | 19,385,592 | 78,918,745 |
| **ចំណូលប្រតិបត្តិការសរុប** | | **93,707,587** | **375,861,132** | **102,362,675** | **416,718,450** |
| សំណង និងអត្ថប្រយោជន៍ដែលបានកើតឡើង | | (7,241,861) | (29,047,104) | (6,885,328) | (28,030,170) |
| សំណង និងអត្ថប្រយោជន៍ធានារ៉ាប់រងដែលផ្ទេរទៅធានារ៉ាប់រងបន្ត | | 442,958 | 1,776,705 | 1,708,973 | 6,957,229 |
| បម្រែបម្រួលនៃបំណុលកិច្ចសន្យាធានារ៉ាប់រង | 18 | (52,482,572) | (210,507,596) | (51,507,206) | (209,685,836) |
| បម្រែបម្រួលបំណុលនៃកិច្ចសន្យាធានារ៉ាប់រងដែលផ្ទេរទៅធានារ៉ាប់រងបន្ត | 18 | 219,713 | 881,269 | (112,172) | (456,652) |
| **សំណង និងអត្ថប្រយោជន៍សុទ្ធ** | | **(59,061,762)** | **(236,896,726)** | **(56,795,733)** | **(231,215,429)** |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាលផ្សេងៗ | 22 | (33,120,802) | (132,847,537) | (40,394,901) | (164,447,642) |
| ចំណាយហិរញ្ញវត្ថុ | | (162,643) | (652,361) | (171,529) | (698,295) |
| **សំណង អត្ថប្រយោជន៍ និងចំណាយសរុប** | | **(92,345,207)** | **(370,396,624)** | **(97,362,163)** | **(396,361,366)** |
| **ប្រាក់ចំណេញមុនគិតពន្ធ** | | **1,362,380** | **5,464,508** | **5,000,512** | **20,357,084** |
| ចំណាយពន្ធលើប្រាក់ចំណូល | 20 | (386,678) | (1,550,965) | (1,457,387) | (5,933,022) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **975,702** | **3,913,543** | **3,543,125** | **14,424,062** |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (1,116,123) | - | (5,540,753) |
| **ប្រាក់ចំណេញពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ** | | **975,702** | **2,797,420** | **3,543,125** | **8,883,309** |





(លេខយោង៖ 00012967)

## របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងបម្លែងរូបិយប័ណ្ណ | Total | |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2025 | 61,320,000 | 245,280,000 | 31,852,621 | 130,637,329 | (897,529) | 93,172,621 | 375,019,800 |
| ប្រាក់ចំណេញពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ | - | - | 975,702 | 3,913,543 | (1,116,123) | 975,702 | 2,797,420 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025** | **61,320,000** | **245,280,000** | **32,828,323** | **134,550,872** | **(2,013,652)** | **94,148,323** | **377,817,220** |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2024 | 61,320,000 | 245,280,000 | 28,309,496 | 116,213,267 | 4,643,224 | 89,629,496 | 366,136,491 |
| ប្រាក់ចំណេញពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ | - | - | 3,543,125 | 14,424,062 | (5,540,753) | 3,543,125 | 8,883,309 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024** | **61,320,000** | **245,280,000** | **31,852,621** | **130,637,329** | **(897,529)** | **93,172,621** | **375,019,800** |

(លេខយោង៖ 00012967)

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | កំណត់សម្គាល់ | 2025 | | 2024 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់លេខ 2.3) |
| | | | | | (ដូចដែលបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ 30) |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញមុនគិតពន្ធ | | 1,362,380 | 5,464,508 | 5,000,512 | 20,357,084 |
| និយ័តកម្មលើ៖ | | | | | |
| វិលស់ទ្រព្យរូបី និងអរូបី | 8 | 12,798,796 | 51,335,970 | 10,445,689 | 42,524,400 |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | | (71,293) | (285,956) | (26,254) | (106,880) |
| ខាតពីការលុបចោលទ្រព្យ និងបរិក្ខារ | | 6,701 | 26,878 | 5,396 | 21,967 |
| ខាតពីការពេលបញ្ចប់កិច្ចសន្យាជួល | | 16,682 | 66,912 | - | - |
| មូលប័ត្រក្នុងតម្លៃសមស្របតាម | | | | | |
| ចំណេញ ឬខាត | 15 | 49,220 | 197,421 | 589,376 | 2,399,350 |
| ចំណូលការប្រាក់ | 21 | (21,161,780) | (84,879,900) | (19,385,592) | (78,918,745) |
| ការប្រាក់បង្គរ | 10.2 | 180,990 | 725,951 | 193,313 | 786,977 |
| បម្រែបម្រួលនូវទុនបង្វិល៖ | | | | | |
| ចំណាយពន្យារ | 22 | (13,032,366) | (52,272,820) | (16,009,540) | (65,174,837) |
| គណនីធានារ៉ាប់រង និង | | | | | |
| គណនីត្រូវទទួលផ្សេងៗ | | 4,486,306 | 17,994,573 | (5,377,333) | (21,891,123) |
| ទ្រព្យសកម្មនៃការធានារ៉ាប់រងបន្ត | | (219,713) | (881,269) | 112,172 | 456,652 |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | | 52,557,201 | 210,806,933 | 51,714,247 | 210,528,700 |
| ការធានារ៉ាប់រង និងការទូទាត់ផ្សេងទៀត | | (6,718,201) | (26,946,704) | (243,414) | (990,938) |
| ការទូទាត់ជាភាគហ៊ុន | | 339,883 | 1,363,271 | 304,181 | 1,238,321 |
| ពន្ធប្រាក់ចំណូលដែលបានបង់ | 20 | (499,551) | (2,003,699) | (2,901,048) | (11,810,167) |
| ការប្រាក់បានទូទាត់លើបំណុលភតិសន្យា | | (180,990) | (725,951) | (193,313) | (786,977) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | | **29,914,265** | **119,986,118** | **24,228,392** | **98,633,784** |





(លេខយោង៖ 00012967)

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | កំណត់សម្គាល់ | 2025 | | 2024 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់លេខ 2.3) |
| **សកម្មភាពវិនិយោគ** | | | | | |
| ការចំណាយលើ៖ | | | | | |
| ទ្រព្យ និងបរិក្ខារ | 7 | (214,423) | (860,051) | (1,743,229) | (7,096,685) |
| ទ្រព្យសកម្មអរូបីផ្សេងៗ | 8 | (203,791) | (817,406) | (224,983) | (915,906) |
| ការវិនិយោគកាន់កាប់រហូតដល់កាលកំណត់ | | (33,387,043) | (133,915,429) | (5,000,000) | (20,355,000) |
| ប្រាក់បញ្ញើនៅធនាគារ | | (48,300,000) | (193,731,300) | (55,016,500) | (223,972,172) |
| ប្រាក់ទទួលបានពី៖ | | - | - | | |
| ការលក់ទ្រព្យ និងបរិក្ខារ | | 72,479 | 290,713 | 37,763 | 153,733 |
| ការវិនិយោគបានដល់កាលកំណត់ | | 8,683,651 | 34,830,124 | 3,467,864 | 14,117,674 |
| ប្រាក់បញ្ញើជាមួយធនាគារដល់កាលកំណត់ | | 22,300,000 | 89,445,300 | 15,688,000 | 63,865,848 |
| ការប្រាក់បានទទួល | | 20,163,892 | 80,877,371 | 16,599,519 | 67,576,642 |
| **លំហូរសាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | **(30,885,235)** | **(123,880,678)** | **(26,191,566)** | **(106,625,866)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការទូទាត់ប្រាក់ដើមនៃបំណុលភតិសន្យា | 10 | (587,266) | (2,355,524) | (739,912) | (3,012,182) |
| **លំហូរសាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាព ហិរញ្ញប្បទាន** | | **(587,266)** | **(2,355,524)** | **(739,912)** | **(3,012,182)** |
| **តំហយសុទ្ធ នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **(1,558,236)** | **(6,250,084)** | **(2,703,086)** | **(11,004,264)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | | | | | |
| នាថ្ងៃទី1 ខែមករា | | 5,591,084 | 22,504,113 | 8,294,170 | 33,881,684 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (70,210) | - | (373,307) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី31 ខែធ្នូ** | 16 | **4,032,848** | **16,183,819** | **5,591,084** | **22,504,113** |

(លេខយោង៖ 00012967)

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

### 1. អំពីក្រុមហ៊ុន និងសកម្មភាពចម្បង

ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឺស្សួរិនស៍ ម.ក ហៅកាត់ថា (“ក្រុមហ៊ុន”) ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានលេខចុះបញ្ជីពាណិជ្ជកម្មលេខ Co. 2743 E/2012 នៅថ្ងៃទី18 ខែតុលា ឆ្នាំ2012។ នៅថ្ងៃទី26 ខែកក្កដា ឆ្នាំ2016 ក្រុមហ៊ុនទទួលបានបញ្ជីពាណិជ្ជកម្មថ្មីលេខ 00012967 ពីក្រសួងពាណិជ្ជកម្ម។ ក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2012 ក្រោមអាជ្ញាប័ណ្ណដែល ផ្តល់ដោយអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នៅថ្ងៃទី22 ខែសីហា ឆ្នាំ2024 ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ពីនិយតករធានារ៉ាប់រងនៃកម្ពុជា។

ភាគហ៊ុនរបស់ក្រុមហ៊ុនចំនួន 99.999% ត្រូវបានកាន់កាប់ដោយ Prudential Corporation Holdings Limited ដែលជាក្រុមហ៊ុនមេផ្ទាល់។ ក្រុមហ៊ុនមេធំបំផុត គឺ Prudential Public Limited Company។ ក្រុមហ៊ុនមេទាំងពីរ គឺជាក្រុមហ៊ុនបង្កើតនៅចក្រភពអង់គ្លេស។

ការិយាល័យចុះបញ្ជីរបស់ខ្លួនទៅអាគារ ជីប ម៉ុង ថៅវើ, ប្លុក L19 L20 & 21 ជាន់ទី 19 20 និង21 មហាវិថីសហព័ន្ធរុស្ស៊ី (ផ្លូវលេខ110) សង្កាត់ផ្សារដើមថ្កូវ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺការផ្តល់សេវាកម្មធានារ៉ាប់រងអាយុជីវិត នៅក្នុងព្រះរាជាណាចក្រ កម្ពុជា។ ក្រុមហ៊ុនធ្វើការផ្តត់ផ្គង់សេវាកម្មតាមរយៈការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ និងសាខាចំនួន 4 តាមបណ្តាខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ក្រុមហ៊ុនមាននិយោជិកសរុបចំនួន 651នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024៖ មាននិយោជិតចំនួន 770 នាក់)។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានអនុញ្ញាតអោយចេញផ្សាយ ដោយក្រុមប្រឹក្សាភិបាលរបស់ ក្រុមហ៊ុន នៅថ្ងៃទី18 ខែមីនា ឆ្នាំ2026។

### 2. មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងលើមូលដ្ឋានថ្លៃដើមដំបូង លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យបំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប។

ក្រុមហ៊ុនបង្ហាញរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន យ៉ាងទូលំទូលាយតាមលំដាប់លំដោយនៃសន្ទនីយភាព។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយតម្លៃសុទ្ធក្រោយការកាត់កង ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែមានសិទ្ធិអនុវត្តដោយស្របច្បាប់ដើម្បីកាត់កងតម្លៃដែលបានទទួលស្គាល់ ហើយមានបំណងទូទាត់ជាមូលដ្ឋានសុទ្ធ ឬកត់ត្រាជា ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

### *2.1* របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា(“CIFRSs”) ជាមួយនឹងការពន្យារពេលលើ CIFRS 17 *កិច្ចសន្យាធានារ៉ាប់រង* និងCIFRS 9 *ឧបករណ៍ហិរញ្ញវត្ថុ* (“CIFRSs ជាមួយនឹងការពន្យារលើ CIFRS 17 និងCIFRS 9”) ស្របតាមសេចក្តីជូនដំណឹងរបស់និយ័យករគណនេយ្យ និងសវនកម្ម ដែលអនុញ្ញាតការពន្យារពេលក្នុងការអនុវត្ត។ ដូចនេះ ក្រុមហ៊ុនអនុវត្ត CIFRS 4 *កិច្ចសន្យាធានារ៉ាប់រង ក្នុងការកត់ត្រាលើកិច្ចសន្យាធានារ៉ាប់រង* និង CIAS 39 *ឧបករណ៍ហិរញ្ញវត្ថុ ការទទួលស្គាល់ និងការវាស់វែង* ក្នុងការកត់ត្រាលើឧបករណ៍ហិរញ្ញវត្ថុ។ (កំណត់សម្គាល់លេខ 5)

### *2.2* ឆ្នាំសារពើពន្ធ និងការិយបរិច្ឆេទនៃរបាយការណ៍

ឆ្នាំសារពើពន្ធរបស់ក្រុមហ៊ុនចាប់ផ្តើមនៅថ្ងៃទី 1 ខែមករា ហើយបញ្ចប់នៅថ្ងៃទី 31 ខែធ្នូ។



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

### 2.3 រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

រូបិយវត្ថុជាតិនៃប្រទេសកម្ពុជាគឺប្រាក់រៀល (“រៀល”)។ ប៉ុន្តែដោយក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងរក្សាកំណត់ត្រាបញ្ជីគណនេយ្យរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក (“ដុល្លារអាមេរិក”) គណៈគ្រប់គ្រងធ្វើការកំណត់ប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ព្រោះវាឆ្លុះបញ្ចាំងអំពី ព្រឹត្តិការណ៍ និងកាលៈទេសៈស្ថានភាពសេដ្ឋកិច្ចរបស់ក្រុមហ៊ុន។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជារូបិយប័ណ្ណដុល្លារអាមេរិក។ តម្លៃទាំងអស់ ត្រូវបានបង្គត់ទៅជាខ្ទង់ដុល្លារអាមេរិកដែលនៅជិតបំផុត លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ។

*ការបង្ហាញជាប្រាក់រៀល*

ការបកប្រែប្រាក់ដុល្លារអាមេរិកទៅជាពាន់រៀល (“ពាន់រៀល”) ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី11 ខែមេសា ឆ្នាំ2016 ដោយប្រើប្រាស់អត្រាប្តូរប្រាក់ចុងគ្រា និងមធ្យមសម្រាប់ការិយបរិច្ឆេទបញ្ចប់ ដែលបានប្រកាសដោយនិយ័តករគណនេយ្យ និងសវនកម្ម។

ទ្រព្យសកម្ម និងបំណុលដែលរួមបញ្ចូលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានបកប្រែតាម អត្រាចុងគ្រានៃការិយបរិច្ឆេទរាយការណ៍នីមួយៗ ដោយឡែកធាតុនៃប្រាក់ចំណូល និងចំណាយដែលបង្ហាញ ក្នុងរបាយការណ៍លទ្ធផលពេញលេញត្រូវបានបកប្រែតាមអត្រាជាមធ្យមប្រចាំឆ្នាំ ដែលបានបញ្ចប់។ ភាពខុសគ្នានៃការផ្លាស់ប្តូរលទ្ធផលទាំងអស់ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។ ការបកប្រែបែបនេះ មិនគួរត្រូវបានបកស្រាយថា ដុល្លារអាមេរិកដែលបានបង្ហាញ ឬត្រូវបាន ឬអាចត្រូវបានប្តូរទៅជាប្រាក់រៀលតាមអត្រានោះ ឬ អត្រាផ្សេងទៀតនោះទេ។ តម្លៃទាំងអស់ជាប្រាក់រៀលត្រូវបានបង្គត់ទៅជាខ្ទង់ពាន់ (“ពាន់រៀល”) លើកលែងតែមានការចង្អុលបង្ហាញផ្សេងទៀត។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់រៀល ដោយផ្អែកលើអត្រាប្តូរប្រាក់ដែលអាចអនុវត្តបានក្នុង 1 ដុល្លារអាមេរិក ដូចខាងក្រោម៖

| | *2025* | *2024* |
|---|---|---|
| **អត្រាចុងគ្រា** | 4,013 | 4,025 |
| **អត្រាមធ្យម** | 4,011 | 4,071 |

### 3. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត

### 3.1 ចំណាត់ថ្នាក់នៃផលិតផល

កិច្ចសន្យាធានារ៉ាប់រង គឺជាកិច្ចសន្យាដែលក្រុមហ៊ុនទទួលធានាហានិភ័យធានារ៉ាប់រងជាសារវន្តពីភាគីម្ខាងទៀត ដោយយល់ព្រមផ្តល់សំណងដល់អ្នកកាន់ប័ណ្ណធានារ៉ាប់រង ឬ អ្នកទទួលផលផ្សេងទៀត ប្រសិនបើព្រឹត្តិការណ៍មិនមានភាពច្បាស់លាស់នាពេលអនាគតដែលបានបញ្ជាក់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ម្ចាស់ប័ណ្ណធានារ៉ាប់រង ឬអ្នកទទួលផលផ្សេងទៀត។ នៅពេលដែលកិច្ចសន្យាត្រូវបានចាត់ថ្នាក់ថាជាកិច្ចសន្យាធានារ៉ាប់រង វានៅតែជាកិច្ចសន្យាធានារ៉ាប់រងសម្រាប់រយៈពេលដែលនៅសល់នៃកាលកំណត់របស់បណ្ណសន្យាធានារ៉ាប់រង ទោះបីជាហានិភ័យធានារ៉ាប់រងកាត់បន្ថយយ៉ាងខ្លាំងក្នុងអំឡុងពេលនេះក៏ដោយ។ កិច្ចសន្យាឆន្ទានុសិទ្ធិ គឺជាកិច្ចសន្យាដែលមានមូលដ្ឋានលើការការពារជាចម្បង។

### *កិច្ចសន្យាដែលមានលក្ខណៈចូលរួមជាធន្ទានុសិទ្ធិ*

សម្រាប់កិច្ចសន្យាដែលមានមូលដ្ឋានលើការការពារ ជាធម្មតាក្រុមហ៊ុនភាគច្រើនធានានូវកម្រិតអត្ថប្រយោជន៍ថេរដែលត្រូវបង់នៅពេលមានព្រឹត្តិការណ៍ទាមទារសំណង (ឧ. ការស្លាប់ ពិការភាពអចិន្ត្រៃយ៍ ជំងឺធ្ងន់ធ្ងរ) ជាថ្នូរមកវិញ ម្ចាស់ប័ណ្ណធានាធានារ៉ាប់រងតម្រូវឲ្យទូទាត់បុព្វលាភតាមកិច្ចសន្យា ដែលអាចត្រូវបានធានាលើលក្ខខណ្ឌនៃកិច្ចសន្យា។

## 3.2 ទ្រព្យ និងបរិក្ខារ

ទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើមដោយដកចេញរំលស់បង្គរ និង/ឬ ការខាតបង្គរលើអ៊ីមតៃរមិន ប្រសិនបើមាន។ ថ្លៃដើម ត្រូវបានរួមបញ្ចូលនូវចំណាយថ្លៃដើមនៃការផ្លាស់ប្តូរទ្រព្យ និងបរិក្ខារ និងចំណាយលើកម្ចី ប្រសិនបើស្របតាមលក្ខខណ្ឌតម្រូវ។ នៅពេលដែលផ្នែកសំខាន់នៃទ្រព្យ និងបរិក្ខារត្រូវរុះរើផ្លាស់ប្តូរក្នុងចន្លោះពេលមួយ ក្រុមហ៊ុនទទួលស្គាល់ផ្នែកទាំងនោះជាទ្រព្យដាច់ដោយឡែកដែលមានអាយុកាលប្រើប្រាស់ជាក់លាក់ និងការរំលស់។ ដូចគ្នានេះដែរ នៅពេលដែលការត្រួតពិនិត្យសំខាន់ៗត្រូវបានអនុវត្តថ្លៃដើមរបស់ទ្រព្យ ត្រូវបានទទួលស្គាល់ នៅក្នុងតម្លៃយោងនៃបរិក្ខារថាជាការជំនួស ប្រសិនបើសមស្របតាមលក្ខខណ្ឌនៃការទទួលស្គាល់។ រាល់ថ្លៃជួសជុល និងថែទាំផ្សេងទៀតដែលកើតឡើងត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល។

ធាតុនៃទ្រព្យ និងបរិក្ខារមួយត្រូវបានឈប់ទទួលស្គាល់នៅពេលលក់ ឬ នៅពេលមិនមានអត្ថប្រយោជន៍អនាគតត្រូវបានរំពឹងថានឹងទទួលបានពីការប្រើប្រាស់ ឬ ការលក់។ ចំណេញ ឬ ខាត កើតឡើងពីការឈប់ទទួលស្គាល់ទ្រព្យសកម្ម (ត្រូវបានគណនាជាភាពខុសគ្នារវាងទឹកប្រាក់ដែលទទួលបានពីការលក់សុទ្ធ និងតម្លៃយោងសុទ្ធរបស់ទ្រព្យសកម្ម) ត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍លទ្ធផល នៅពេលដែលទ្រព្យសកម្មនោះឈប់ត្រូវបានទទួលស្គាល់។

រំលស់ទ្រព្យ និងបរិក្ខារ ទ្រព្យសកម្មអរូបី គឺត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃប្រភេទទ្រព្យសកម្មនីមួយៗមាន ដូចខាងក្រោម៖

| ការកែលម្អអគារ | អាយុកាលប្រើប្រាស់ និងរយៈពេលនៃការជួលមួយណាខ្លីជាង |
|---|---|
| បរិក្ខារបច្ចេកវិទ្យាព័ត៌មាន | 5ឆ្នាំ |
| គ្រឿងសង្ហារិម និងសម្ភារៈការិយាល័យ | 5ឆ្នាំ |
| យានយន្ត | 5ឆ្នាំ |
| ទ្រព្យផ្សេងៗ | 5ឆ្នាំ |

តម្លៃកាកសំណល់នៃទ្រព្យសកម្ម និងអាយុកាលប្រើប្រាស់ និងប្រើវិធីសាស្ត្ររំលស់ក្នុងការត្រួតពិនិត្យ និងកែសម្រួលនៅការបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុនីមួយៗ និងត្រូវបានកែសម្រួលសម្រាប់ពេលអនាគត បើសិនសមស្រប។

ការត្រួតពិនិត្យលើអ៊ីមតៃរមិន ត្រូវបានធ្វើនៅពេលមានសូចនាករបង្ហាញថា តម្លៃពិតគណនេយ្យមិនអាចប្រមូលមកវិញបាន។ ការខាតលើអ៊ីមតៃរមិន ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុង របាយការណ៍លទ្ធផលពេញលេញ។





## 3.3 ការចំណាយពន្យារ និងទ្រព្យសកម្មអរូបីផ្សេងទៀត

### *ការចំណាយពន្យារ*

ការចំណាយដោយផ្ទាល់ និងដោយប្រយោលក្នុងការលក់ ការវាយតម្លៃហានិភ័យ និងចំណាយដើម្បីទទួលបានកិច្ចសន្យាធានារ៉ាប់រងថ្មី ត្រូវបានពន្យារត្រឹមចំណាយណាដែលពុំទាន់បានទទួលមកវិញ ហើយចំណាយ នោះនឹងត្រូវបានទូទាត់ដោយចំណូលនៅពេលអនាគត ពីកិច្ចសន្យាធានារ៉ាប់រងទាំងនេះ។

បន្ទាប់ពីការទទួលស្គាល់ដំបូង ការចំណាយលើការទិញពន្យារត្រូវបានរំលស់ក្នុងរយៈពេលដែលការចំណាយសុទ្ធកាត់កងនឹងសំវិធានធននៃពន្ធពន្យារដែលពាក់ព័ន្ធ ត្រូវបានគេរំពឹងថានឹងអាច យកមកវិញបានចេញពីអប្បហារចំណូលដែលត្រូវគ្នា ពីគោលនយោបាយដែលពាក់ព័ន្ធ។

ការត្រួតពិនិត្យលើអ៊ីមតៃរមិន ត្រូវបានអនុវត្តនៅកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ឬញឹកញាប់ជាងនេះនៅពេលដែលមានការបង្ហាញអំពីការថយចុះនៃតម្លៃកើតឡើង។ នៅពេលដែលចំនួនទឹកប្រាក់ដែលអាចយកមកវិញបាន គឺតិចជាងតម្លៃយោងគណនេយ្យខាតលើអ៊ីមតៃរមិន ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត។

### *កម្មវិធីកុំព្យូទ័រ*

ការចំណាយដែលទាក់ទងដោយផ្ទាល់ជាមួយការទិញ ឬ ការអភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ ដែលអាចកំណត់ អត្តសញ្ញាណបានដែលមិនមែនជាផ្នែកសំខាន់នៃសម្ភារៈកុំព្យូទ័រដែលរំពឹងទុកថាបង្កើតអត្ថប្រយោជន៍ នាពេលអនាគតចំពោះក្រុមហ៊ុនត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មអរូបី។

រំលស់ នឹងត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតតាមក្នុងវិធីសាស្ត្ររំលស់ថេរ ទៅតាមការប៉ាន់ស្មានអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបី។ ចំណាយលើវឌ្ឍនកម្មនៃសូហ្វវែរ នឹងត្រូវរំលស់ពីថ្ងៃដែលសូហ្វវែរអាចប្រើប្រាស់បាន ហើយមិនលើសពីរយៈពេល 5ឆ្នាំ។

### *កម្រៃភាពជាដៃគូ*

កម្រៃភាពជាដៃគូ គឺជាកម្រៃដែលបានកើតឡើង នៅក្រោមកិច្ចព្រមព្រៀងដៃគូជាមួយធនាគារជាដៃគូ សម្រាប់ការចែកចាយនូវផលិតផលរបស់ក្រុមហ៊ុន។ កម្រៃនេះ ត្រូវបានធ្វើរំលស់ដោយផ្អែកលើមូលដ្ឋាននៃអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលនឹងទទួលបាន តាមអាយុកាលនៃកិច្ចព្រមព្រៀងដៃគូ។

ចំណាយបន្តបន្ទាប់ ត្រូវបានធ្វើមូលធនកម្ម ប្រសិនបើចំណាយនេះអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ទ្រព្យសកម្មជាក់លាក់ដែលពាក់ព័ន្ធ។ រាល់ចំណាយបន្តបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត នៅពេលដែលវាបានកើតឡើង។ រាល់ការផ្លាស់ប្តូរប៉ាន់ស្មាន ផ្សេងទៀតដែលត្រូវបានទទួលស្គាល់នាពេលខាងមុខ ត្រូវចាត់ចូលជាការផ្លាស់ប្តូរប៉ាន់ស្មាន និង បច្ចុប្បន្នភាព។

### *ទ្រព្យសកម្មកំពុងដំណើរការ*

ទ្រព្យសកម្មកំពុងដំណើរការ មិនត្រូវបានធ្វើរំលស់ទេ លុះត្រាតែទ្រព្យសកម្មដែលពាក់ព័ន្ធទាំងនោះត្រូវបានបញ្ចប់ និងដាក់ឲ្យប្រើប្រាស់ក្នុងប្រតិបត្តិការ។

## 3.4 ចំណាយលើកម្ចី

ការចំណាយលើកម្ចីដែលទាក់ទងដោយផ្ទាល់នឹងការទិញ ការសាងសង់ ឬការផលិតទ្រព្យសកម្មមួយ ដែលត្រូវការពេលវេលាយូរមុននឹងរួចរាល់សម្រាប់ការប្រើប្រាស់ ឬលក់ ត្រូវបានរាប់បញ្ចូលជាថ្លៃដើមនៃទ្រព្យសកម្មនោះ។ ការចំណាយលើការខ្ចីប្រាក់ផ្សេងទៀតទាំងអស់ ត្រូវបានកត់ត្រាជាចំណាយក្នុងរយៈពេលដែលវាបានកើតឡើង។

## 3.5 ភតិសន្យា

ក្រុមហ៊ុន វាយតម្លៃនៅពេលចាប់ផ្តើមកិច្ចសន្យាថាតើកិច្ចសន្យាគឺជាកិច្ចសន្យាភតិសន្យា ឬ មាន ធាតុភតិសន្យា។ កិច្ចសន្យាជាភតិសន្យា ប្រសិនបើកិច្ចសន្យាបង្ហាញឲ្យឃើញសិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្ម ដែលបានកំណត់ក្នុងរយៈពេលមួយជាថ្នូរ នឹងការទូទាត់ប្រាក់។

*ក្រុមហ៊ុនជាភតិក:*

នៅពេលចាប់ផ្តើម ឬលើការកែប្រែកិច្ចសន្យា ដែលមានសមាសធាតុភតិសន្យា ក្រុមហ៊ុនបែងចែកតម្លៃក្នុងកិច្ចសន្យាទៅសមាសធាតុភតិសន្យានីមួយៗ ដោយផ្អែកលើតម្លៃឈរតែឯងរបស់សមាសធាតុភតិសន្យា។ ទោះជាយ៉ាងណាក៏ដោយសម្រាប់ភតិសន្យានៃទ្រព្យសម្បត្តិក្រុមហ៊ុនបានជ្រើសរើសមិនបំបែកសមាសធាតុ ដែលមិនមែនជាភតិសន្យា និងគណនីសម្រាប់សមាសធាតុភតិសន្យា និង មិនភតិសន្យាជាសមាសធាតុភតិសន្យាតែមួយ។

### *(i)* សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម

ក្រុមហ៊ុន ទទួលស្គាល់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម (“ROU”) នៅកាលបរិច្ឆេទចាប់ផ្តើមនៃ ភតិសន្យា (ឧទាហរណ៍ កាលបរិច្ឆេទនៃទ្រព្យសកម្មអាចប្រើបាន)។ ROU ត្រូវបានវាស់វែង តាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់អ៊ីមតៃរមិននៃតម្លៃ នឹងត្រូវបានកែសម្រួលលើការវាស់វែងឡើងវិញនៃបំណុលភតិសន្យា។ ថ្លៃដើមនៃ ROU រួមមាន ចំនួននៃបំណុលភតិសន្យាត្រូវបានទទួលស្គាល់ ចំណាយផ្ទាល់ដំបូងបានកើតឡើង និងការទូទាត់ភតិសន្យាធ្វើឡើងនៅ ឬ មុនកាលបរិច្ឆេទចាប់ផ្តើម ដកការលើកលែងនានាដែលបានទទួល។ ROU ត្រូវបានរំលស់ដោយផ្អែកលើមូលដ្ឋានរំលស់ថេរ លើរយៈពេលខ្លីជាងរយៈពេលភតិសន្យា និងអាយុកាលប្រើប្រាស់ដែលបានរំពឹងទុករបស់ទ្រព្យសកម្ម។ ការត្រួតពិនិត្យលើអ៊ីមតៃរមិននៃតម្លៃត្រូវបានធ្វើឡើង នៅពេលដែលមានសូចនាករបង្ហាញថាតម្លៃពិតគណនេយ្យ មិនអាចប្រមូលមកវិញបាន។ ការខាតបង់អ៊ីមតៃរមិននៃតម្លៃត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល។

### *(ii)* បំណុលភតិសន្យា

នៅកាលបរិច្ឆេទចាប់ផ្តើមនៃភតិសន្យា ក្រុមហ៊ុនទទួលស្គាល់បំណុលភតិសន្យា ដោយត្រូវបានវាស់វែង លើការទូទាត់ភតិសន្យាដែលធ្វើឡើងក្នុងរយៈពេលជួល តាមតម្លៃបច្ចុប្បន្ន។ ការទូទាត់ភតិសន្យារួមមានទាំងការទូទាត់ប្រាក់ថេរ ដកការលើកលែងនានាដែលនឹងទទួលបានពីភតិសន្យា ការទូទាត់ភតិសន្យាអថេរ ដែលអាស្រ័យលើសន្ទស្សន៍ ឬអត្រាមួយ និងចំនួនទឹកប្រាក់រំពឹងថានឹងត្រូវទូទាត់ក្រោមការធានានូវតម្លៃនៅសល់។

ការទូទាត់ភតិសន្យាក៏រួមបញ្ចូលទាំងថ្លៃនៃជម្រើសលើការទិញដែលសមហេតុផល និងប្រាកដថាត្រូវបានអនុវត្តដោយក្រុមហ៊ុន និងការទូទាត់ទៅលើការពិន័យសម្រាប់ការបញ្ចប់ភតិសន្យា ប្រសិនបើរយៈពេលនៃការជួលឆ្លុះបញ្ចាំងថាក្រុមហ៊ុនអនុវត្តជម្រើសដើម្បីបញ្ចប់។ ការទូទាត់ភតិសន្យាអថេរ ដែលមិនអាស្រ័យលើសន្ទស្សន៍ ឬ អត្រា ត្រូវបានទទួលស្គាល់ជាចំណាយ (លុះត្រាតែការទូទាត់នោះកើតឡើងក្នុងការផលិតសារពើភណ្ឌ) ក្នុងអំឡុងពេលដែលព្រឹត្តិការណ៍ ឬ លក្ខខណ្ឌដែលបង្កឲ្យមានការទូទាត់កើតឡើង។



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

ក្នុងការគណនាតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យា ក្រុមហ៊ុនប្រើប្រាស់វិធីសាស្ត្រជាសម័្ពន្ធលើអត្រាប្រាក់កម្ចីកើនឡើង (“IBR”) នៅកាលបរិច្ឆេទចាប់ផ្តើមជួល ពីព្រោះអត្រាការប្រាក់ជាក់ស្តែងនៅក្នុងភតិសន្យាមិនអាចកំណត់បានភ្លាមៗ។ បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើម ចំនួនទឹកប្រាក់នៃបំណុលភតិសន្យា ត្រូវបានកើនឡើងដើម្បីឆ្លុះបញ្ចាំងពីការកើនឡើងនៃការប្រាក់ និងកាត់បន្ថយការទូទាត់ថ្លៃជួល។

លើសពីនេះទៀត តម្លៃពិតគណនេយ្យនៃបំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញ ប្រសិនបើមានការកែប្រែ ការផ្លាស់ប្តូរទៅលើលក្ខខណ្ឌភតិសន្យា ការផ្លាស់ប្តូរលើការទូទាត់ភតិសន្យា (ឧទាហរណ៍ ការផ្លាស់ប្តូរទៅលើការទូទាត់នាពេលអនាគតដែលបណ្តាល មកពីការផ្លាស់ប្តូរ សន្ទស្សន៍ ឬ អត្រាប្រើដើម្បីកំណត់ ការទូទាត់ការជួល) ឬ ការផ្លាស់ប្តូរការវាយតម្លៃជម្រើសក្នុងការទិញទ្រព្យសកម្មមូលដ្ឋាន។

### (iii) ភតិសន្យារយៈពេលខ្លី និងភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប

ក្រុមហ៊ុនអនុវត្តការលើកលែងលើការទទួលស្គាល់ភតិសន្យារយៈពេលខ្លី ចំពោះភតិសន្យារយៈពេលខ្លីរបស់ខ្លួន (ឧទាហរណ៍ ភតិសន្យា ដែលមានរយៈពេលជួល 12ខែ ឬ តិចជាង គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើម និងមិនមានជម្រើសទិញ)។ វាក៏មានការអនុវត្តផងដែរទៅលើការលើកលែងការទទួលស្គាល់ភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាប ចំពោះភតិសន្យាណាដែលត្រូវបានគេចាត់ទុកថាមានតម្លៃទាប។ ការទូទាត់ភតិសន្យារយៈពេលខ្លី និងភតិសន្យាលើទ្រព្យសកម្ម ដែលមានតម្លៃទាបត្រូវបានទទួលស្គាល់ជាចំណាយតាមមូលដ្ឋានរំលស់ថេរក្នុងអំឡុងពេលជួល នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

## 3.6 អ៊ីមតៃរមិននៃតម្លៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្ម ដែលស្ថិតនៅក្រោមការរំលស់ ត្រូវបានពិនិត្យឡើងវិញសម្រាប់អ៊ីមតៃរមិននៃតម្លៃ នៅពេលណាដែលព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរក្នុងកាលៈទេសៈបង្ហាញថាតម្លៃយោងគណនេយ្យនឹងមិនអាចប្រមូលបាន។ ការខាតលើអ៊ីមតៃរមិននៃតម្លៃ ត្រូវបានទទួលស្គាល់សម្រាប់ចំនួនដែលតម្លៃយោងគណនេយ្យនៃទ្រព្យសកម្មលើសចំនួនទឹកប្រាក់ដែលអាចប្រមូលបាន។ ចំនួនទឹកប្រាក់ដែលអាចប្រមូលបាន គឺជាតម្លៃដែលខ្ពស់ជាងរវាងតម្លៃសមស្របរបស់ទ្រព្យសកម្មដកតម្លៃក្នុងការលក់ និងតម្លៃប្រើប្រាស់របស់ទ្រព្យសកម្មនោះ។

ការខាតលើអ៊ីមតៃរមិននៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត នៅក្នុងអំឡុងពេលដែលវាកើតឡើង។ ការកត់ត្រាបញ្ច្រាស់ នៃការខាតលើអ៊ីមតៃរមិននៃតម្លៃត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត ក្នុងកម្រិតដែលតម្លៃយោងគណនេយ្យមិនលើសតម្លៃយោងគណនេយ្យដែលត្រូវបានកំណត់ កាត់កងជាមួយរំលស់ មិនត្រូវបានទទួលស្គាល់ការខាតលើអ៊ីមតៃរមិននៃតម្លៃឡើយ។

## 3.7 ធានារ៉ាប់រង និងគណនីត្រូវទទួលផ្សេងៗ

*ធានារ៉ាប់រងត្រូវទទួល*

ធានារ៉ាប់រងត្រូវទទួល ត្រូវបានទទួលស្គាល់នៅពេលដល់កាលកំណត់ត្រូវបង់ និងត្រូវបានវាស់វែងតាមការទទួលស្គាល់លើកដំបូងតាមតម្លៃសមស្របនៃចំនួនទទួលបាន ឬ អាចទទួលបាន។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង គណនីធានារ៉ាប់រងត្រូវទទួលត្រូវបានវាស់វែងតាមការរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។ តម្លៃយោងនៃគណនីធានារ៉ាប់រងត្រូវទទួលត្រូវបានត្រួតពិនិត្យរកអ៊ីមតៃរមិននៃតម្លៃ នៅពេលមានហេតុការណ៍ ឬ ព្រឹត្តិការណ៍បង្ហាញថាតម្លៃកត់ត្រាអាចនឹងមិនអាចស្រង់មកវិញបាន ហើយការខាតបង់អ៊ីមតៃរមិននៃតម្លៃត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល។

កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តដែលបានផ្ទេរចេញ មិនអាចជួយឲ្យក្រុមហ៊ុនរួចផុតពីកាតព្វកិច្ចរបស់ ខ្លួនចំពោះអ្នកកាន់បណ្ណសន្យារ៉ាប់រងបានឡើយ។ បុព្វលាភធានារ៉ាប់រង និងសំណងធានារ៉ាប់រងត្រូវបានបង្ហាញតាមមូលដ្ឋានដុល និងការធានារ៉ាប់រងបន្ត ដែលបានផ្ទេរចេញត្រូវបានបង្ហាញដាច់ដោយឡែក។ ទ្រព្យសកម្មធានារ៉ាប់រងបន្តត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលសិទ្ធិតាមកិច្ចសន្យាត្រូវបានសងផ្តាច់ ឬ ផុតកំណត់។

*គណនីត្រូវទទួលផ្សេងៗ*

គណនីត្រូវទទួលផ្សេងៗ ភាគច្រើនរួមបញ្ចូលចំណាយបង់មុន ប្រាក់កក់ បុរេប្រទាន និងចំនួនជំពាក់មកពីសម្ព័ន្ធញាតិដែលត្រូវបានយោងតាមតម្លៃសម្រេចបានសុទ្ធ។ ការប៉ាន់ស្មានមួយត្រូវបានធ្វើឡើងសម្រាប់អ៊ឹមតែរមិននៃតម្លៃ ដោយផ្អែកលើការពិនិត្យឡើងវិញនូវចំនួនដែលសល់ទាំងអស់ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

*សម្ព័ន្ធញាតិ*

ភាគីដែលពាក់ព័ន្ធទៅនឹងអង្គភាព ប្រសិនជា ដោយផ្ទាល់ ឬដោយប្រយោលឆ្លងកាត់មួយ ឬច្រើនអន្តរការីមានសមត្ថភាពក្នុងការគ្រប់គ្រងភាគីផ្សេងទៀត ឬអនុវត្តឥទ្ធិពលដ៏សំខាន់ទៅលើភាគីផ្សេងទៀតក្នុងការធ្វើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុនិងប្រតិបត្តិការ។ ភាគីដែលពាក់ពន្ធ័ទៅនឹងអង្គភាព ប្រសិនបើត្រូវបានគ្រប់គ្រង ចូលរួមគ្រប់គ្រង ឬរងឥទ្ធិពលយ៉ាងខ្លាំងពីអង្គភាព ឬស្ថិតនៅក្រោមការគ្រប់គ្រងទូទៅជាមួយអង្គភាព ឬមានឥទ្ធិពលយ៉ាងខ្លាំងទៅលើអង្គភាពនេះ។ ភាគីដែលពាក់ព័ន្ធអាចជាបុគ្គល ឬជាអង្គភាពស្របច្បាប់។

ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិទាំងអស់ រួមបញ្ចូលការទូទាត់ជំនួស បុរេប្រទាន ការទូទាត់ផ្សេងៗ ទៀត ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។

## 3.8 ការធានារ៉ាប់រងបន្ត

ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ កើតចេញពីកិច្ចសន្យាធានារ៉ាប់រងបន្ត ត្រូវបានបង្ហាញដាច់ដោយឡែកពីទ្រព្យសកម្ម បំណុល ចំណូល និងចំណាយពីកិច្ចសន្យាធានារ៉ាប់រងពាក់ព័ន្ធ ដោយសារតែការចាត់ចែងធានារ៉ាប់រងបន្តមិនបានធ្វើឲ្យក្រុមហ៊ុនបញ្ចប់កាតព្វកិច្ចពីម្ចាស់ប័ណ្ណធានារ៉ាប់រងនោះទេ។

ទ្រព្យសកម្ម ឬបំណុលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតំណាងឲ្យបុព្វលាភត្រូវទូទាត់ ឬ ចំនួនត្រូវទូទាត់ទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត និងចំណែកនៃអត្ថប្រយោជន៍ និងសំណងត្រលប់ពីការធានារ៉ាប់រងបន្ត។ ចំនួនសុទ្ធត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានសិទ្ធិជាផ្លូវការក្នុងការកាត់កង និងមានបំណងកាត់កងទ្រព្យសកម្ម និងបំណុលនៅពេលដំណាលគ្នា។ ការវាស់វែងទ្រព្យសកម្មធានារ៉ាប់រងបន្ត គឺមានលក្ខណៈសង្គតិភាព ទៅនឹងការវាស់វែងកិច្ចសន្យាធានារ៉ាប់រងដែលពាក់ព័ន្ធ។

ចំនួនដែលត្រូវទទួលបានពីការធានារ៉ាប់រងបន្ត ត្រូវបានវាយតម្លៃចំពោះអ៊ឹមតែរមិននៃតម្លៃនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ។ ទ្រព្យសកម្មទាំងនោះ ចាត់ទុកថាមានអ៊ឹមតែរមិននៃតម្លៃ ប្រសិនបើមានភស្តុតាងជាក់លាក់ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កើតឡើងបន្ទាប់ពីការទទួលស្គាល់ដំបូងថា ក្រុមហ៊ុនមិនអាចប្រមូលបានមកវិញនូវចំនួនទាំងអស់ ហើយព្រឹត្តិការណ៍នោះអាចធ្វើឲ្យការវាស់វែងនូវផលប៉ះពាល់បាន ដោយភាពជឿជាក់លើចំនួន ដែលក្រុមហ៊ុននឹងត្រូវទទួលពីក្រុមហ៊ុនធានារ៉ាប់រងបន្ត។

## 3.9 ការវាស់វែងតម្លៃសមស្រប

គោលនយោបាយគណនេយ្យ និងការបង្ហាញព័ត៌មានមួយចំនួនរបស់ក្រុមហ៊ុនតម្រូវឲ្យមានការវាស់វែងតម្លៃសមស្របទាំងទ្រព្យសកម្ម និង បំណុលហិរញ្ញវត្ថុ ព្រមទាំងទ្រព្យសកម្ម និងបំណុលមិនមែនហិរញ្ញវត្ថុ។





គណៈគ្រប់គ្រងធ្វើការត្រួតពិនិត្យលើការបញ្ចូលទិន្នន័យសំខាន់ៗ ដែលមិនអាចសង្កេតបាន និង និយ័តភាពលើការវាស់វែងតម្លៃ។ ប្រសិនបើព័ត៌មានពីភាគីទីបី ដូចជាសម្រង់តម្លៃពីឈ្មួញកណ្តាល ឬសេវាកម្មផ្តល់តម្លៃត្រូវបានប្រើសម្រាប់ការវាស់វែងតម្លៃសមស្របនោះ គណៈគ្រប់គ្រងនឹងវាយតម្លៃលើភស្តុតាងដែលបានមកពីភាគីទីបី ដើម្បីផ្តល់អំណះអំណាងដល់ការសន្និដ្ឋាន ថាតើការវាយតម្លៃនោះត្រឹមត្រូវទៅតាមស្តង់ដា រួមទាំងឋានានុក្រមតម្លៃសមស្របដែលការវាយតម្លៃនេះបានចាត់ថ្នាក់។

នៅពេលវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម ឬទ្រព្យអសកម្ម ក្រុមហ៊ុនប្រើទិន្នន័យដែលអាច សង្កេតមើលទីផ្សារតាមដែលអាចធ្វើទៅបាន។ តម្លៃសមស្របត្រូវបានចាត់ជាកម្រិតផ្សេងគ្នានៅក្នុងឋានានុក្រមតម្លៃសមស្របដោយផ្អែកលើធាតុដែលប្រើក្នុងវិធីសាស្ត្រវាយតម្លៃដូចខាងក្រោម៖

កម្រិតទី1៖ តម្លៃដកស្រង់ (មិនទាន់មាននិយ័តភាព) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុល ស្រដៀងគ្នា។

កម្រិតទី2៖ ធាតុចូលដ៏ទៃទៀតក្រៅពីតម្លៃដកស្រង់ដែលមាននៅក្នុងកម្រិតទី1 ដែលអាចធ្វើការអង្កេតបានសម្រាប់ទ្រព្យសកម្ម ឬ បំណុល ទោះបីដោយផ្ទាល់ (ឧទាហរណ៍ដូចជាតម្លៃ) ឬមិនផ្ទាល់ (ឧទាហរណ៍ កើតចេញពីតម្លៃ)។

កម្រិតទី3៖ ទិន្នន័យសម្រាប់ទ្រព្យសកម្មឬបំណុលដែលមិនអាស្រ័យលើទិន្នន័យដែលអាចអង្កេតបានទីផ្សារ(ធាតុចូលមិនអាចអង្កេតបាន)។

ប្រសិនបើធាតុចូលដែលបានប្រើដើម្បីវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុល ត្រូវធ្លាក់ចូលទៅក្នុងកម្រិតផ្សេងគ្នានៃឋានានុក្រមតម្លៃសមស្រប នោះការវាស់វែងតម្លៃសមស្របត្រូវបានចាត់ទុកទាំងស្រុងចូលទៅក្នុងកម្រិតទាបបំផុតដូចគ្នា នៃឋានានុក្រមតម្លៃសមស្រប ដែលមានសារៈសំខាន់ចំពោះការវាស់វែងទាំងមូល។

ក្រុមហ៊ុន ទទួលស្គាល់ការផ្ទេរផ្សេងៗ រវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទ របាយការណ៍ក្នុងអំឡុងពេលដែលការផ្លាស់ប្តូលនេះបានកើតឡើង។

ព័ត៌មានពីការសន្មតក្នុងការវាស់វែងតម្លៃសមស្រប ត្រូវបានបញ្ចូលនៅក្នុងកំណត់សម្គាល់លេខ 27 ការគ្រប់គ្រងធានារ៉ាប់រង និងហានិភ័យហិរញ្ញវត្ថុ។

## *3.10* ទ្រព្យសកម្មហិរញ្ញវត្ថុ

### *3.10.1 ការទទួលស្គាល់ និងការវាស់វែង*

ទ្រព្យសកម្មហិរញ្ញវត្ថុដែលស្ថិតនៅក្នុងវិសាលភាពរបស់ CIAS 39 ត្រូវបានចាត់ទុកជាទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្របតាមរយៈចំណេញ ឬ ខាតតណទាន និងគណនីត្រូវទទួល ការវិនិយោគហិរញ្ញវត្ថុដល់អាយុកាលកំណត់។ ក្រុមហ៊ុនកំណត់ប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួននៅការទទួលស្គាល់ដំបូង។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃសមស្របបូកថ្លៃប្រតិបត្តិការពាក់ព័ន្ធផ្ទាល់ ក្នុងករណីការវិនិយោគមិនត្រូវបានវាស់វែងតាម តម្លៃសមស្រប តាមរយៈរបាយការណ៍ចំណេញ ឬ ខាត។

ការបែងចែកប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុ អាស្រ័យទៅលើគោលបំណងដែលការវិនិយោគទទួលបាន ឬ ប្រភពដើម។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានបែងចែកទៅតាមតម្លៃសមស្របតាមរយៈរបាយការណ៍ចំណេញ ឬ ខាត ខណៈយុទ្ធសាស្ត្រវិនិយោគដែលត្រូវបានចងក្រងជាឯកសាររបស់ក្រុមហ៊ុនមានគឺដើម្បីគ្រប់គ្រងការវិនិយោគហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋានតម្លៃសមស្របពីព្រោះ បំណុលដែលពាក់ព័ន្ធក៏ត្រូវបានគ្រប់គ្រងតាមវិធីនេះដែរ។ ប្រភេទនៃទ្រព្យសកម្មកាន់កាប់ដល់កាលកំណត់ និងទ្រព្យសកម្មដែលអាចលក់បាន ត្រូវបានប្រើប្រាស់ នៅពេលដែលបំណុលពាក់ព័ន្ធ (រួមបញ្ចូលទាំងមូលនិធិម្ចាស់ភាគហ៊ុន) ត្រូវបានគ្រប់គ្រង និង/ឬ ចុះអនុវត្តតាមថ្លៃដើមរំលស់។

ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមបញ្ចូលសាច់ប្រាក់ និងសាច់ប្រាក់សមមូល គណនីធានារ៉ាប់រង និងគណនីត្រូវទទួលផ្សេងៗ និងវិនិយោគផ្សេងទៀត។

*ឥណទាន និងគណនីត្រូវទទួល*

អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុជាការទូទាត់ថេរ ឬអាចកំណត់បាន ដែលមិនបានស្រង់តម្លៃតាមទីផ្សារសកម្មត្រូវបានចាត់ថ្នាក់ជាឥណទាន និងគណនីត្រូវទទួល។ ទាំងនេះរួមមាន ចំណូលការប្រាក់ពីការវិនិយោគមូលបត្រលើបំណុល។ ការវិនិយោគទាំងនេះត្រូវបានទទួលស្គាល់ដំបូងតាមថ្លៃដើម ដែលជាតម្លៃសមស្របនៃការចំណាយដើម្បីទទួលបាននូវការវិនិយោគនេះ។ រាល់ចំណាយប្រតិបត្តិការដែលពាក់ព័ន្ធផ្ទាល់ទាំងអស់ ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងចំណាយវិនិយោគផងដែរ។ បន្ទាប់ពីការវាស់វែងដំបូង ឥណទាន និងគណនីត្រូវទទួល ត្រូវបានវាស់វែងជាបន្តបន្ទាប់តាមមូលដ្ឋានថ្លៃដើមរំលស់ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ដកអ៊ីមភែរមិននៃតម្លៃ។ ចំណេញ និងខាតត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល នៅពេលដែលឥណទាន និងគណនីត្រូវទទួល ឈប់ត្រូវបានទទួលស្គាល់ ឬ ត្រូវបានធ្វើអ៊ីមភែរមិននៃតម្លៃក៏ដូចជាតាមរយៈដំណើរការរំលស់។

*ការវិនិយោគកាន់កាប់រហូតដល់កាលកំណត់*

អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុជាការទូទាត់ថេរ ឬអាចកំណត់បាន និងមានកាលកំណត់ថេរ ត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មហិរញ្ញវត្ថុកាន់កាប់រហូតដល់កាលកំណត់ នៅពេលក្រុមហ៊ុនមានបំណង និងសមត្ថភាពវិជ្ជមានក្នុងការកាន់កាប់រហូតដល់កាលកំណត់។ បន្ទាប់ពីការវាស់វែងលើកដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុកាន់កាប់រហូតដល់កាលកំណត់ ត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ ដោយប្រើអត្រាការប្រាក់មានប្រសិទ្ធភាព (EIR) ដកអ៊ីមភែរមិននៃតម្លៃ។ ការរំលស់ដោយអត្រាការប្រាក់មានប្រសិទ្ធិភាព (EIR) ត្រូវបានទទួលស្គាល់ក្នុង “ចំណូលវិនិយោគ” នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ ចំណេញ និងខាតត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត នៅពេលការវិនិយោគ ឈប់ត្រូវបានទទួលស្គាល់ ឬ ត្រូវបានធ្វើអ៊ីមភែរមិននៃតម្លៃក៏ដូចជាតាមរយៈដំណើរការរំលស់។

*ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្របតាមចំណេញ ឬខាត*

ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្របតាមរបាយការណ៍ចំណេញ ឬខាត រួមមានទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកាន់កាប់សម្រាប់ពាណិជ្ជកម្ម និងទ្រព្យសកម្មដែលមានការទទួលស្គាល់ដំបូងតាមតម្លៃពិតប្រាកដតាមចំណេញ ឬខាត។ ជាទូទៅការវិនិយោគ ដែលបានទិញដោយមានបំណងលក់នៅពេលអនាគតដ៏ខ្លី ត្រូវបានចាត់ទុកថាជាការធ្វើពាណិជ្ជកម្ម។ និស្សន្ទ រួមទាំងនិស្សន្ទដែលបានបង្កប់ដាច់ដោយឡែក ក៏ត្រូវបានចាត់ទុកថាជាការជួញដូរផងដែរ លុះត្រាតែវាត្រូវបានកំណត់ថាជាឧបករណ៍បង្ការហានិភ័យដែលមានប្រសិទ្ធិភាពដូចដែលបានកំណត់ដោយ CIAS 39។

## 3.10.2 *អ៊ីមភែរមិននៃតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ*

ក្រុមហ៊ុនធ្វើការវាយតម្លៃ នៅរៀងរាល់កាលបរិច្ឆេទចេញតារាងតុល្យការនីមួយៗថា តើមានភស្តុតាង ពិតប្រាកដណាមួយដែលបង្ហាញថា ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមណាមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺត្រូវបានធ្វើអ៊ីមភែរមិននៃតម្លៃ។



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

*ទ្រព្យសកម្មដែលយោងតាមថ្លៃដើមរំលស់*

ប្រសិនបើមានភស្តុតាងដែលអះអាងថា មានការខាតអ៊ីមភែរមិននៃតម្លៃ ទៅលើឥណទាន និងគណនីត្រូវទទួល ដែលយោងតាមថ្លៃដើមរំលស់ ត្រូវបានកើតឡើង ចំនួនដែលខាតនោះ នឹងត្រូវបានវាស់វែងជាភាពខុសគ្នារវាងតម្លៃយោងទ្រព្យសកម្ម និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់អនាគតរំពឹងទុក ដែលបានធ្វើអប្បហារតាមអត្រាការប្រាក់មានប្រសិទ្ធិភាពដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ (ឧ. អត្រាការប្រាក់មានប្រសិទ្ធភាពត្រូវបានគណនាពេលទទួលស្គាល់ដំបូង)។ តម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្ម នឹងត្រូវបានកាត់បន្ថយតាមរយៈការប្រើគណនីសំវិធានធន។ ចំនួននៃការខាត នឹងត្រូវបានទទួលស្គាល់ជាគណនីចំណេញ ឬ ខាត។

នៅការិយបរិច្ឆេទបន្តបន្ទាប់ ប្រសិនបើចំនួនខាតលើអ៊ីមភែរមិននៃតម្លៃ មានការថយចុះ និងការថយចុះនោះអាចពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ដែលកើតឡើងក្រោយពីអ៊ីមភែរមិននៃតម្លៃ នោះត្រូវបានទទួលស្គាល់ នោះការខាតលើអ៊ីមភែរមិននៃតម្លៃ ដែលត្រូវបានទទួលស្គាល់ពីមុន គឺត្រូវបានកត់ត្រា បញ្ច្រាស់មកវិញដល់កម្រិតមួយដែលតម្លៃយោងគណនេយ្យរបស់ទ្រព្យសកម្មនោះ មិនលើសពីថ្លៃដើមរំលស់ នាកាលបរិច្ឆេទនៃការកត់ត្រាបញ្ច្រាស់នោះ។ ការកត់ត្រាបញ្ច្រាស់បន្តបន្ទាប់នៃការខាតលើអ៊ីមភែរមិននៃតម្លៃ នឹងត្រូវទទួលស្គាល់នៅក្នុងគណនីចំណេញ ឬ ខាត។

## 3.10.3 *ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុ (ឬផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នារបស់ក្រុមហ៊ុន) ត្រូវបានឈប់ទទួលស្គាល់នៅពេល៖

- សិទ្ធិត្រូវទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មបានផុតកំណត់
- ក្រុមហ៊ុនត្រូវផ្ទេរសិទ្ធិទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ឬ មានកាតព្វកិច្ចត្រូវបង់ចំនួនសរុបនៃលំហូរសាច់ប្រាក់ដែលទទួលបានទាំងអស់ពីទ្រព្យសកម្មទៅឲ្យភាគីទីបីទៀត ដោយមិនមានការយឺតយ៉ាវដែលការរៀបចំនេះស្ថិតនៅក្រោមបែបបទ ‘ឆ្លងកាត់’ ឬ
- ណាមួយក្នុងចំណោម (ក) ក្រុមហ៊ុនបានផ្ទេរនូវហានិភ័យ និងអត្ថប្រយោជន៍របស់ទ្រព្យសកម្មទាំងស្រុង ឬ (ខ) ក្រុមហ៊ុនមិនបានផ្ទេរ ឬ រក្សាទុកនូវហានិភ័យ និងអត្ថប្រយោជន៍របស់ទ្រព្យសកម្មទាំងស្រុងទេ ប៉ុន្តែបានផ្ទេរការគ្រប់គ្រងទ្រព្យសកម្ម។

នៅពេលក្រុមហ៊ុនបានផ្ទេរសិទ្ធិទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ឬ ធ្វើតាមបែបបទ ឆ្លងកាត់ហើយក្រុមហ៊ុនមិនបានផ្ទេរ ឬ រក្សាទុកនូវហានិភ័យ និងអត្ថប្រយោជន៍របស់ទ្រព្យសកម្មទាំងស្រុង និងមិនបានផ្ទេរការគ្រប់គ្រងលើទ្រព្យសកម្ម ទ្រព្យសកម្មគឺត្រូវទទួលស្គាល់តាមកម្រិត នៃការបន្តការពាក់ព័ន្ធរបស់ក្រុមហ៊ុនចំពោះទ្រព្យសកម្ម។ ការបន្តការពាក់ព័ន្ធក្នុងទម្រង់ជាការធានាលើទ្រព្យសកម្មដែលបានផ្ទេរ ត្រូវបានវាស់វែងនៅតម្លៃទាបជាង រវាងតម្លៃយោងគណនេយ្យរបស់ទ្រព្យសកម្ម និងតម្លៃអតិបរមានៃទឹកប្រាក់ ដែលក្រុមហ៊ុនអាចតម្រូវឲ្យសង។

## 3.11 សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានគណនីចរន្ត និងគណនីសន្សំ ជាមួយធនាគារក្នុងស្រុក និង សាច់ប្រាក់ក្នុងគណនីជួញដូរ ដែលអាចដកចេញបានតាមតម្រូវការនៅពេលណាក៏បាន។

## 3.12 មូលធន

*ភាគហ៊ុនដើមទុន*

ភាគហ៊ុនធម្មតា ដែលមានភាគលាភឆន្ទានុសិទ្ធិ ត្រូវបានចាត់ទុកថាជាមូលធន។ ការបែងចែកភាគលាភដល់ម្ចាស់ភាគហ៊ុនត្រូវទូទាត់ដោយផ្ទាល់ទៅលើប្រាក់ចំណេញរក្សាទុក។

ភាគលាភលើភាគហ៊ុនធម្មតា ត្រូវបានទទួលស្គាល់ថាជាបំណុល នៅពេលដែលបានប្រកាសមុនកាលបរិច្ឆេទរាយការណ៍។ ភាគលាភបានប្រកាសក្រោយកាលបរិច្ឆេទរាយការណ៍ ប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតអោយបោះផ្សាយ មិនត្រូវបានទទួលស្គាល់ថាជាបំណុលនៅកាលបរិច្ឆេទរាយការណ៍នោះទេ។

## 3.13 បំណុលកិច្ចសន្យាធានារ៉ាប់រង

បំណុលលើអត្ថប្រយោជន៍តាមកិច្ចសន្យា ដែលរំពឹងថានឹងកើតឡើងនាពេលអនាគត ត្រូវបានកត់ត្រានៅពេលដែលកិច្ចសន្យាធានារ៉ាប់រងត្រូវបានទទួលស្គាល់។

បំណុលសម្រាប់ការធានារ៉ាប់រងអាយុជីវិត ដែលមិនចូលរួមចំណែកក្នុងការបែងចែកភាគលាភរបស់ក្រុមហ៊ុន ត្រូវបានកំណត់តាមចំនួនរំពឹងទុកនៃតម្លៃបច្ចុប្បន្ននៃអត្ថប្រយោជន៍ធានានាពេលអនាគត និងចំណាយការគ្រប់គ្រង និងចែកចាយដែលរំពឹងទុក ដកនឹងតម្លៃបច្ចុប្បន្ននៃចំណូលដុលដែលបានមកពីប័ណ្ណធានារ៉ាប់រង ដែលបានអប្បហារតាមអត្រាការប្រាក់ប៉ាន់ស្មានដោយប្រុងប្រយ័ត្ន កើតឡើងដោយយោងទៅតាមផលចំណេញពីទ្រព្យសកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សំវិធានធនបន្ថែមសម្រាប់ការប្រុងប្រយ័ត្ន ត្រូវបានធ្វើឡើងដោយកត្តាសន្មតវាយតម្លៃ ដើម្បីអនុញ្ញាតឲ្យមានគម្លាតអវិជ្ជមានពីកត្តាសន្មតត្រឹមត្រូវបំផុត។ សំវិធានធនដែលធ្វើឡើងសម្រាប់គម្លាតអវិជ្ជមាន គឺផ្អែកលើនិយ័តភាពប្រុងប្រយ័ត្នទៅនឹងកត្តាសន្មតត្រឹមត្រូវបំផុត។ កម្រិតនៃសំវិធានធនត្រូវបានត្រួតពិនិត្យឡើងវិញរៀងរាល់ឆ្នាំ ដោយអ្នកជំនាញគណនាហានិភ័យធានារ៉ាប់រងដើម្បីវាយតម្លៃពីភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់។

មាត្រា 18 នៃប្រកាសស្តីពីនីតិវិធី និងវិធីសាស្រ្តគណនាបម្រុងបច្ចេកទេសវិស័យធានារ៉ាប់រង ចុះថ្ងៃទី 23 ខែធ្នូ ឆ្នាំ 2022 កំណត់ឱ្យបម្រុងគោលនយោបាយដែលកាន់កាប់ ត្រូវដាក់កម្រិតអប្បបរមាតាមតម្លៃសាច់ប្រាក់ (Cash Value) ប្រសិនបើមាន ដែលការដាក់កម្រិតនេះអនុវត្តនៅកម្រិតសរុបមូលនិធិ។ PCLA បានកែប្រែការកំណត់កម្រិតប្រាក់បម្រុងនៃតម្លៃសាច់ប្រាក់ ពីកម្រិតគោលនយោបាយទៅជាកម្រិតផ្អែកផលិតផលក្នុងខែធ្នូ ឆ្នាំ2025។ ប្រាក់បម្រុងដែលកាន់កាប់ទុន មានលក្ខណៈប្រុងប្រយ័ត្នជាងតម្រូវការគ្រប់គ្រងតាមបទប្បញ្ញត្តិ។

## *3.14 បំណុលហិរញ្ញវត្ថុ*

### *3.14.1 ការទទួលស្គាល់ និងការវាស់វែង*

បំណុលហិរញ្ញវត្ថុដែលស្ថិតក្នុងវិសាលភាពរបស់ CIAS 39 ត្រូវបានចាត់ទុកជាបំណុលហិរញ្ញវត្ថុនៅតម្លៃសមស្រប តាមរយៈចំណេញ ឬខាត ឥណទាននិងកម្ចី ឬ កិច្ចសន្យាធានាហិរញ្ញវត្ថុ។ នេះមិនរាប់បញ្ចូលបំណុលលើកិច្ចសន្យាធានារ៉ាប់រង។ ក្រុមហ៊ុនធ្វើការកំណត់លើការបែងចែងប្រភេទបំណុលហិរញ្ញវត្ថុនៅពេលទទួលស្គាល់ដំបូង។

បំណុលហិរញ្ញវត្ថុទាំងអស់ត្រូវទទួលស្គាល់ដំបូងតាមតម្លៃសមស្រប និងក្នុងករណីឥណទាន និងកម្ចី ដកចំណាយប្រតិបត្តិការពាក់ព័ន្ធផ្ទាល់។

បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមាន បំណុលកិច្ចសន្យាធានារ៉ាប់រង ធានារ៉ាប់រង និងបំណុលផ្សេងៗ ដែលមានទាំងចំនួនទឹកប្រាក់ត្រូវសងទៅភាគីពាក់ព័ន្ធ និងបំណុលភតិសន្យា។





### *3.14.2 ការឈប់ទទួលស្គាល់*

បំណុលហិរញ្ញវត្ថុនឹងត្រូវបានឈប់ទទួលស្គាល់ នៅពេលកាតព្វកិច្ចស្ថិតនៅក្រោមបំណុលនោះត្រូវបានទូទាត់ លុបចោល ឬ ផុតកាលកំណត់។ នៅពេលដែលបំណុលហិរញ្ញវត្ថុដែលមានស្រាប់មួយត្រូវបានជំនួសដោយបំណុលមួយទៀតពីម្ចាស់បំណុលតែមួយ យោងតាមលក្ខខណ្ឌខុសគ្នាទាំងស្រុង ឬ លក្ខខណ្ឌរបស់បំណុលដែលមានស្រាប់ត្រូវបានកែប្រែទាំងស្រុង ហើយការកែប្រែ ឬផ្លាស់ប្តូរនេះនឹងត្រូវបានចាត់ទុកជាការឈប់ទទួលស្គាល់បំណុលពីមុន និងចាត់ទុកជាការទទួលស្គាល់បំណុលថ្មី ហើយភាពខុសគ្នារវាងតម្លៃចុះបញ្ជីនីមួយៗ នឹងត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

## *3.15 ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ*

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុនឹងត្រូវយកមកកាត់កងគ្នា ហើយតម្លៃសុទ្ធដែលត្រូវបានកាត់កងរួចនោះនឹងត្រូវបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែមានសិទ្ធិស្របច្បាប់ដែលអាចអនុវត្តបាននាពេលបច្ចុប្បន្នក្នុងការកាត់កងចំនួនដែលត្រូវបានទទួលស្គាល់ និងលុះត្រាតែមានបំណងធ្វើការទូទាត់ដោយ ផ្អែកលើតម្លៃសុទ្ធដែលត្រូវបានកាត់កងរួច ឬ ដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

## *3.16 ការទទួលស្គាល់ចំណូល*

### ក. បុព្វលាភធានារ៉ាប់រង

បុព្វលាភទទួលបានពីអ្នកកាន់កាប់ប័ណ្ណធានារ៉ាប់រង ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតនៅកាលបរិច្ឆេទដល់កំណត់រៀងៗខ្លួន។ បុព្វលាភដែលដល់កាលកំណត់ ប៉ុន្តែមិនទាន់ទទួលបានត្រូវបានទទួលស្គាល់ជាចំណូល ទន្ទឹមនឹងបុព្វលាភត្រូវទទួលដែលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ការចំណាយសំណងអថេរដែលកើតឡើងពីបុព្វលាភ ដែលត្រូវទទួល ត្រូវបានបង្ករនៅក្នុងកាលបរិច្ឆេទរាយការណ៍ដូចគ្នា។

បុព្វលាភដល់កាលបរិច្ឆេទសងក្រោយកាលបរិច្ឆេទរាយការណ៍ ប៉ុន្តែបានទទួលមុនកាលបរិច្ឆេទរាយការណ៍ ត្រូវបានទទួលស្គាល់ជាបំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ខ. ចំណូលការប្រាក់ពីសកម្មភាពធនាគារ

ចំណូលការប្រាក់ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតដោយផ្អែកលើមូលដ្ឋានគណនាបង្ករ។ ការប្រាក់បានទទួលក្នុងការិយបរិច្ឆេទត្រូវបានបង្ហាញក្នុងរបាយការណ៍លំហូរសាច់ប្រាក់ ជាសកម្មភាពវិនិយោគ។

### គ. សំវិធានធន និងកម្រៃជើងសារលើធានារ៉ាប់រងបន្តដែលបានផ្ទេរចេញ

សំវិធានធន និងកម្រៃជើងសារលើធានារ៉ាប់រងបន្តដែលបានផ្ទេរចេញ ត្រូវបានទទួលស្គាល់ដំណាលគ្នា ជារួមនៅពេលទទួលស្គាល់បុព្វលាភធានារ៉ាប់រងបន្ត។

## 3.17 ការទទួលស្គាល់ចំណាយ

### *(i) សំណង និងអត្ថប្រយោជន៍ដែលកើតឡើង*

សំណង និងថ្លៃទូទាត់ ដែលបានកើតឡើងនៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុត្រូវបានទទួលស្គាល់នៅពេលដែលព្រឹត្តិការណ៍សំណងកើតឡើង និង/ឬ ម្ចាស់ធានារ៉ាប់រងបានជូនដំណឹង។

អត្ថប្រយោជន៍ និងសំណងកើតឡើងពីប័ណ្ណធានារ៉ាប់រងអាយុជីវិត ព្រមទាំងចំណាយទូទាត់សំណងដែលត្រូវបានទទួលស្គាល់តាមករណីនីមួយៗ ហើយក្នុងគោលបំណងនេះ អត្ថប្រយោជន៍ដែលត្រូវទូទាត់លើប័ណ្ណធានារ៉ាប់រងអាយុជីវិតត្រូវទទួលស្គាល់ ដូចខាងក្រោម៖

(ក) កាលវសាន្ត ឬអត្ថប្រយោជន៍ដែលត្រូវទូទាត់ក្នុងកាលបរិច្ឆេទជាក់លាក់ណាមួយត្រូវគិតជាសំណង ត្រូវទូទាត់នៅកាលបរិច្ឆេទនោះ។

(ខ) មរណភាព ការមិនបន្តកិច្ចសន្យាធានារ៉ាប់រង និងអត្ថប្រយោជន៍ផ្សេងៗមិនទាន់ដល់កាលកំណត់ត្រូវគិតជាសំណងត្រូវទូទាត់នៅថ្ងៃ ដែលមានការបញ្ជាក់ពីមរណភាពនៃអ្នកត្រូវធានា ឬការកើតឡើងយថាហេតុដែលមានចែងក្នុងការទូទាត់។

### *(ii) បម្រែបម្រួលនៃបំណុលកិច្ចសន្យាធានារ៉ាប់រង*

ប្រាក់បម្រុងគោលនយោបាយអាយុជីវិត ត្រូវបានគណនាដោយប្រើវិធីសាស្ត្រភាពជាក់ស្តែង (“actuarial”) ដោយផ្អែកលើការសន្មតបច្ចុប្បន្ន ឬលើការសន្មតដែលបានបង្កើតឡើងនៅពេលចាប់ផ្តើមគោលនយោបាយ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មានដ៏ល្អបំផុតនៅពេលនោះបានកើនឡើងជាមួយ នឹងកម្រិតនៃហានិភ័យនិងការបង្វែរនិស្សន្ទ។ ការសន្មតសំខាន់ដែលបានប្រើ គឺ អត្រាមរណៈភាព អត្រាជំងឺ អត្រាទីឃាយភាព អត្រាបោះបង់ ចំណាយ និង អត្រាអប្បហារ។ ការផ្លាស់ប្តូរប្រាក់បម្រុង ត្រូវបានទទួលស្គាល់ថាជាការចំណាយក្នុងឆ្នាំ។

### *(iii) ចំណាយហិរញ្ញវត្ថុ*

ចំណាយហិរញ្ញវត្ថុ មានការចំណាយការប្រាក់ ដែលត្រូវកត់ត្រាក្នុងប្រតិបត្តិការ និងបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព។

### *(iv) សំណងអថេរ*

សំណងអថេរ ដែលជាចំណាយបានកើតឡើងដោយផ្ទាល់ក្នុងការធានានូវបុព្វលាភពីប័ណ្ណធានារ៉ាប់រង ដកចំណូលទទួលបានពីធានារ៉ាប់រងបន្ត នៅពេលដែលធ្វើការធានារ៉ាប់រងបន្ត ត្រូវបានកត់ត្រាក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងការិយបរិច្ឆេទដែលកើតឡើង។





## 3.18 ពន្ធ

### *ពន្ធលើប្រាក់ចំណូល*

ពន្ធលើប្រាក់ចំណូលជាទ្រព្យសកម្ម ឬបំណុលសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន និងការិយបរិច្ឆេទពីមុន ត្រូវបានវាស់វែងជាទឹកប្រាក់ដែលត្រូវបានរំពឹងទុកថាត្រូវបានប្រមូលមកវិញពី ឬ ត្រូវបង់ឲ្យអាជ្ញាធរពន្ធដារ។ អត្រាពន្ធ និងច្បាប់ពន្ធដែលកំណត់ដើម្បីគណនាទឹកប្រាក់ពន្ធ គឺជាអត្រា និងច្បាប់សារពើពន្ធ ដែលត្រូវបានអនុម័ត នាកាលបរិច្ឆេទចេញរបាយការណ៍នេះ។

ពន្ធលើប្រាក់ចំណូលទាក់ទងនឹងទ្រព្យ ត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន និងមិនមែននៅក្នុងរបាយការណ៍លទ្ធផលនោះទេ។ គណៈគ្រប់គ្រង នឹងធ្វើការវាយតម្លៃជាទៀងទាត់អំពីជំហរលើការប្រកាសពន្ធដែលទាក់ទងនឹងស្ថានភាពនៃច្បាប់ពន្ធ អាស្រ័យទៅលើការបកស្រាយផ្សេងៗគ្នា និងបង្កើតនូវសំវិធានធននៅពេលសមស្រប។

### *ពន្ធពន្យារ*

ពន្ធពន្យារត្រូវបានគណនា ដោយប្រើវិធីសាស្ត្រតារាងតុល្យការលើចំនួនភាពខុសគ្នាបណ្តោះ អាសន្ន រវាងតម្លៃយោងគណនេយ្យនៃទ្រព្យសកម្ម និងបំណុលសម្រាប់គោលបំណង នៃរបាយការណ៍ហិរញ្ញវត្ថុ និងចំនួនពន្ធដែលត្រូវបានប្រើសម្រាប់គោលបំណងពន្ធដារ។ ចំនួននៃពន្ធពន្យារដែលបានផ្តល់ គឺផ្អែកលើការរំពឹងទុក នៃលក្ខណៈក្នុងការទទួលស្គាល់ ឬ ការទូទាត់នៃតម្លៃយោងរបស់ទ្រព្យសកម្ម ឬ បំណុល ដោយយកអត្រាពន្ធដែលអនុម័តឲ្យប្រើប្រាស់ក្នុងតារាងតុល្យកាល។

ពន្ធពន្យារលើប្រាក់ចំណូលជាបំណុល ត្រូវបានទទួលស្គាល់ សម្រាប់ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធទាំងអស់ លើកលែងតែនៅពេលពន្ធពន្យារលើប្រាក់ចំណូលជាបំណុលកើតឡើងពីការទទួលស្គាល់នៅគ្រាដំបូងនៃទ្រព្យសកម្ម ឬ បំណុល នៅក្នុងប្រតិបត្តិការមួយដែលវាមិនជះឥទ្ធិពល ដល់ប្រាក់ចំណេញតាមវិធីសាស្ត្រគណនេយ្យ និងប្រាក់ចំណេញ ឬខាតតាមវិធីសាស្ត្រពន្ធ។

ពន្ធពន្យារ លើប្រាក់ចំណូលជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់សម្រាប់ភាពខុសគ្នាបណ្តោះ អាសន្នដែលអាចកាត់បានទាំងអស់ ឥណទានពន្ធមិនបានប្រើប្រាស់យោងទៅមុខ និងតម្លៃខាតពន្ធដែលពុំទាន់ប្រើប្រាស់ រហូតដល់ទំហំមួយ ដែលទំនងថាប្រាក់ចំណេញជាប់ពន្ធ នឹងអាចមានដើម្បីកាត់កងជាមួយភាពខុសគ្នាបណ្តោះអាសន្ន និងការទាញយកឥណទានពន្ធ និងតម្លៃពន្ធខាតដែលពុំទាន់ប្រើប្រាស់ នោះអាចប្រើប្រាស់បាន លើកលែងតែនៅពេលពន្ធប្រាក់ចំណូលពន្យារជាទ្រព្យសកម្មទាក់ទងនឹងចំនួនខុសគ្នាបណ្តោះអាសន្នជាប់ពន្ធនោះ កើតឡើងពីការទទួលស្គាល់នាគ្រាដំបូង នៃទ្រព្យសកម្ម ឬ បំណុល នៃប្រតិបត្តិការមួយនៅខណៈពេលប្រតិបត្តិការកើតឡើងនោះមិនមានឥទ្ធិពលដល់ប្រាក់ចំណេញ តាមវិធីសាស្ត្រគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតជាប់ពន្ធ។

តម្លៃយោងនៃពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម ត្រូវបានពិនិត្យឡើងវិញ តាមកាលបរិច្ឆេទចុងក្រោយនៃរបាយការណ៍នីមួយៗ ហើយនិងត្រូវបានកាត់បន្ថយមកត្រឹមទំហំមួយ ដែលមិនទំនងថាមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ នឹងអាចផ្តល់ឲ្យទ្រព្យសកម្មទាំងអស់ ឬ មួយផ្នែក នៃពន្ធលើប្រាក់ចំណេញពន្យារជាទ្រព្យសកម្មដែលអាចប្រើប្រាស់បាន។ ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម ដែលមិនត្រូវបានទទួលស្គាល់នោះ គឺត្រូវបានវាយតម្លៃឡើងវិញតាមកាលបរិច្ឆេទចុងក្រោយនៃរបាយការណ៍នីមួយៗ និងត្រូវបានទទួលស្គាល់ត្រឹមតែទំហំមួយដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតនឹងធ្វើឲ្យពន្ធពន្យារជាទ្រព្យសកម្ម នោះអាចប្រមូលមកវិញបាន។

ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម និងបំណុល ត្រូវបានវាយតម្លៃផ្អែកលើអត្រាពន្ធ ដែលរំពឹងថានឹងយកមកប្រើប្រាស់សម្រាប់ការិយបរិច្ឆេទណាដែល ទ្រព្យសកម្មត្រូវបានទទួលស្គាល់ ឬបំណុលត្រូវបានទូទាត់ ដោយផ្អែកលើអត្រាពន្ធ (និងច្បាប់ពន្ធដារ) ដែលបានអនុម័ត ឬ ត្រូវបានប្រើប្រាស់យ៉ាងជាប់លាប់ក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍នេះ។

ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម និងពន្ធពន្យារលើប្រាក់ចំណូលជាបំណុល ត្រូវបានកាត់កង ប្រសិនបើសិទ្ធិនៃច្បាប់ណាមួយចូលជាធរមានកើតឡើងដើម្បីកាត់កងទ្រព្យសកម្មពន្ធបច្ចុប្បន្ន ប្រឈមនឹងបំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារលើប្រាក់ចំណូលពាក់ព័ន្ធនឹងសហគ្រាសដែលជាប់ពន្ធដូចគ្នា និងអាជ្ញាធរពន្ធដារដូចគ្នា។

## 3.19 អត្ថប្រយោជន៍និយោជិក

### *អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី*

អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី គឺជាចំណាយនៅពេលសេវាកម្មពាក់ព័ន្ធ ត្រូវបានផ្តល់។ បំណុលត្រូវបានទទួលស្គាល់លើចំនួនដែលត្រូវបានរំពឹងថានឹងត្រូវទូទាត់ ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់ ឬប្រយោលក្នុងការទូទាត់ចំនួននេះ ដែលជាលទ្ធផលនៃសេវាកម្ម ដែលបានផ្តល់ដោយនិយោជិតរួចហើយហើយកាតព្វកិច្ចអាចប៉ាន់ស្មានដោយភាពជាក់លាក់។

### *ការទូទាត់ជាភាគហ៊ុន*

ក្រុមហ៊ុន ផ្តល់គម្រោងក្នុងការទូទាត់ជាភាគហ៊ុនដល់និយោជិត របស់ក្រុមហ៊ុន។ សម្រាប់ការទូទាត់គម្រោងភាគហ៊ុនជាមូលធនដោយយោងតាមគោលនយោបាយរបស់ក្រុមហ៊ុនមេចុងក្រោយ ក្រុមហ៊ុនត្រូវចំណាយបង់មុនទៅក្រុមហ៊ុនមេក្នុងការទិញភាគហ៊ុនទុកជាមុន ដើម្បីទូទាត់ទៅឲ្យនិយោជិត ក្នុងតម្លៃភាគហ៊ុនទូទៅ។ ចំណាយបង់មុននេះត្រូវកត់ត្រាជាទ្រព្យសកម្មនៅពេលកើតឡើង។ អត្ថប្រយោជន៍នេះ ត្រូវបានកត់ត្រាជាចំណាយលើនិយោជិតក្នុងប្រាក់ ចំណេញ ឬខាត និងកាត់បន្ថយចំណាយបង់មុនទៅតាមកាលកំណត់ទូទាត់។

ទឹកប្រាក់ដែលកត់ត្រាជាចំណាយ ត្រូវបានធ្វើនិយ័តកម្ម ដើម្បីឆ្លុះបញ្ចាំងនូវចំនួនអត្ថប្រយោជន៍ដែលទាក់ទងនឹងរយៈពេលនៃសេវាកម្ម និងលក្ខខណ្ឌទូទាត់ដែលមិនទាក់ទងនឹងទីផ្សារដែលរំពឹងទុកថានឹងសម្រេចបាន។ ដូច្នេះ ទឹកប្រាក់ចុងក្រោយដែលបានកត់ត្រាជាចំណាយគឺអាស្រ័យលើចំនួនអត្ថប្រយោជន៍ ដែលបានសម្រេចនូវលក្ខខណ្ឌនៃសេវាកម្ម និងលទ្ធផលនៃលក្ខខណ្ឌដែលមិនទាក់ទងនឹងទីផ្សារនាថ្ងៃទូទាត់។ សម្រាប់អត្ថប្រយោជន៍ដែលទូទាត់ជាភាគហ៊ុន ដែលពុំមានលក្ខខណ្ឌក្នុងការទូទាត់ តម្លៃសមស្របនៃការទូទាត់ជាភាគហ៊ុននាថ្ងៃផ្តល់ឲ្យនិយោជិត គឺត្រូវបានវាស់វែង ដើម្បីឆ្លុះបញ្ចាំងនូវលក្ខខណ្ឌទាំងឡាយដែលមានហើយពុំមានការកែតម្រូវនូវភាពខុសគ្នារវាងការសន្មត និងលទ្ធផលជាក់ស្តែង។

### *អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងទៀត*

កាតព្វកិច្ចទូទាត់សុទ្ធរបស់ក្រុមហ៊ុនទៅលើអត្ថប្រយោជន៍រយៈពេលវែងរបស់និយោជិត គឺជាចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍ដែលនិយោជិតទទួលបានពីការផ្តល់សេវាកម្មរបស់ខ្លួន ក្នុងអំឡុងពេលបច្ចុប្បន្ន និងអតីតកាល រួមទាំងប្រាក់អតីតភាពការងារ។ អត្ថប្រយោជន៍នេះ ត្រូវបានធ្វើអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្ន។ ការវាស់វែងឡើងវិញ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬការខាតក្នុងអំឡុងពេលដែលបានកើតឡើង។

## 3.20 សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចស្របច្បាប់ ឬកាតព្វកិច្ចស្ថាបនា ដែលបានពីលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ហើយដែលគួរឲ្យជឿថាការហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងត្រូវបានតម្រូវឲ្យទូទាត់កាតព្វកិច្ចនេះ។ ប្រសិនបើមានផលប៉ះពាល់ជាសារវ័ន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារនៃលំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគត នៅក្នុងអត្រាមុនគិតពន្ធដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃលុយ និងដែលសមស្រប ហានិភ័យជាក់លាក់ចំពោះការទទួលខុសត្រូវ។





## 3.21 ប្រតិបត្តិការជារូបិយប័ណ្ណបរទេស

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ("ដុល្លារអាមេរិក") ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេង ត្រូវបានកត់ត្រាដំបូង តាមអត្រារូបិយប័ណ្ណមុខងារ នាកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុ ជារូបិយប័ណ្ណផ្សេងដែលនឹងត្រូវប្តូរសារជាថ្មីទៅជារូបិយប័ណ្ណមុខងារតាមអត្រាប្តូរប្រាក់ នាកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ រាល់ភាពលម្អៀង នឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផល។ ធាតុមិនមែនរូបិយវត្ថុ ដែលវាស់វែងតាមថ្លៃដើមប្រវត្តិសាស្ត្រ នៅក្នុងរូបិយប័ណ្ណផ្សេង គឺត្រូវប្តូរដោយប្រើអត្រាប្តូរប្រាក់ នាកាលបរិច្ឆេទ នៃប្រតិបត្តិការដំបូងនីមួយៗ។

## 3.22 ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍

ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទបញ្ចប់ ដែលផ្តល់ព័ត៌មានបន្ថែម អំពីគោលជំហររបស់ក្រុមហ៊ុននៅក្នុងកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ការកែសម្រួលព្រឹត្តិការណ៍) ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ព្រឹត្តិការណ៍ក្រោយការិមបរិច្ឆេទបញ្ចប់ ដែលមិនមែនជាព្រឹត្តិការណ៍កែសម្រួលត្រូវបានបង្ហាញនៅក្នុងកំណត់ សម្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅពេលមានភាពជាសារវ័ន្ត។

## 4. ស្តង់ដាថ្មី និងការធ្វើវិសោធនកម្ម និងការបកស្រាយ

គោលនយោបាយគណនេយ្យ ដែលបានអនុម័តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុគឺ ស្របគ្នានឹងការិយបរិច្ឆេទមុន លើកលែងតែការអនុម័តដែលអាចអនុវត្តបាននៃវិសោធនកម្មទៅ លើ CIFRSs ដែលមានប្រសិទ្ធភាពគិតចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2025។ ការអនុម័តលើការកែប្រែ IAS 21 កង្វះនៃការផ្លាស់ប្តូរ មិនមានផលប៉ះពាល់ខ្លាំងទៅលើស្ថានភាពហិរញ្ញវត្ថុ និងដំណើរការរបស់ក្រុមហ៊ុនឡើយ។

## 5. ស្តង់ដាដែលបានចេញផ្សាយប៉ុន្តែមិនទាន់មានប្រសិទ្ធភាព

ស្តង់ដា និងការបកស្រាយដែលត្រូវបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព រហូតដល់កាលបរិច្ឆេទនៃការចេញរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញដូចខាងក្រោម។ ក្រុមហ៊ុន មានបំណងអនុវត្តស្តង់ដាទាំងនេះ ប្រសិនបើអាច អនុវត្តបាននៅពេលដែលស្តង់ដានោះមានប្រសិទ្ធភាព។

(i) វិសោធនកម្ម CIFRS 9 និង CIFRS 7 - ចំណាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ ចូលជាធរមាននា ឬ ក្រោយ ថ្ងៃទី1 ខែមករា ឆ្នាំ2026

(ii) វិសោធនកម្ម CIFRS 9 និង CIFRS 7 - កិច្ចសន្យាដែលយោងទៅលើអគ្គិសនីអាស្រ័យលើធម្មជាតិ (ដែលមុននេះគេហៅថា Power Purchase Agreements) ចូលជាធរមាននា ឬ ក្រោយ ថ្ងៃទី1 ខែមករា ឆ្នាំ2026

(iii) ការកែលម្អប្រចាំឆ្នាំលើស្តង់ដារការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ CIFRS - កម្រងទី 11 ចូលជាធរមាននា ឬ ក្រោយ ថ្ងៃទី1 ខែមករា ឆ្នាំ2026

(iv) CIFRS18-បទបង្ហាញ និងការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ចូលជាធរមាននាឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2027

(v) CIFRS19 - ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលគ្មានគណនេយ្យភាពសាធារណៈ ការបង្ហាញ ចូលជាធរមាននា ឬក្រោយ ថ្ងៃទី1 ខែមករា ឆ្នាំ2027

(vi) វិសោធនកម្ម IAS 21 - ការប្តូរទៅជារូបិមប័ណ្ណបង្ហាញអតិផរណាខ្ពស់ ចូលជាធរមាននា ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2027

(vii) CIFRS 17 កិច្ចសន្យាធានារ៉ាប់រង

នៅក្នុងខែឧសភា ឆ្នាំ2017 ក្រុមប្រឹក្សាភិបាលស្តង់ដាគណនេយ្យអន្តរជាតិបានចេញផ្សាយ IFRS 17 កិច្ចសន្យាធានារ៉ាប់រង ដែលជំនួស CIFRS 4 ដែលបានកំណត់គោលការណ៍ សម្រាប់ទទួលស្គាល់ ការវាស់វែង ការបង្ហាញ និងការលាតត្រដាង នៃកិច្ចសន្យាធានារ៉ាប់រង ស្ថិតក្នុងវិសាលភាពនៃ CIFRS 17។ IFRS 17 បានមានប្រសិទ្ធភាពសម្រាប់រយៈពេលរបាយការណ៍ប្រចាំឆ្នាំ ក្នុងអំឡុងពេលមុន ឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2023។

IFRSs ដែលមានប្រសិទ្ធភាព ដែលចេញផ្សាយដោយ IASB ហើយមានប្រសិទ្ធិភាពដែលអនុម័តក្នុងពេលដំណាលគ្នាក្នុងប្រទេសកម្ពុជាដែលសមមូលនឹងCIFRSs លើកលែងតែមានការសម្រេចចិត្តពីនិយ័តករ។

CIFRS 17 អនុវត្តចំពោះកិច្ចសន្យាធានារ៉ាប់រងគ្រប់ប្រភេទ (ឧទាហរណ៍ អាយុជីវិត មិនមែនអាយុជីវិត ការធានារ៉ាប់រងដោយផ្ទាល់ និងការធានារ៉ាប់រងបន្ត) ដោយមិនគិតពីប្រភេទនៃអង្គភាពដែលចេញឲ្យពួកគេ ក៏ដូចជាការធានាជាក់លាក់ និងឧបករណ៍ហិរញ្ញវត្ថុដែលមានលក្ខណៈពិសេសការចូលរួម ដោយការសម្រេចចិត្ត។ ការលើកលែងមួយចំនួននឹងត្រូវបានអនុវត្ត។ គោលបំណងរួមនៃ CIFRS 17 គឺដើម្បីផ្តល់នូវគំរូគណនេយ្យសម្រាប់កិច្ចសន្យាធានារ៉ាប់រងដែលមានប្រយោជន៍ជាង និងសមស្របសម្រាប់អ្នកធានារ៉ាប់រង។

ផ្ទុយទៅនឹងតម្រូវការនៅក្នុង CIFRS 4 ដែលភាគច្រើនផ្អែកលើគោលនយោបាយគណនេយ្យក្នុងស្រុកពីមុន CIFRS 17 ផ្តល់នូវគំរូដ៏ទូលំទូលាយសម្រាប់កិច្ចសន្យាធានារ៉ាប់រង ដែលគ្រប ដណ្តប់គ្រប់ទិដ្ឋភាពគណនេយ្យពាក់ព័ន្ធទាំងអស់។

- គំរូទូទៅសម្រាប់កិច្ចសន្យាភាគច្រើន ដែលវាស់តម្លៃបំណុលធានារ៉ាប់រងដោយប្រើ “building blocks” ចំនួនបួន (General Measurement Model/Building Block Approach)។
- ការសម្របខ្លួនជាក់លាក់មួយសម្រាប់កិច្ចសន្យា ដែលមានលក្ខណៈជាការចូលរួមដោយផ្ទាល់ (វិធីសាស្ត្រតម្លៃអថេរ)។
- វិធីសាស្ត្រសាមញ្ញ (វិធីសាស្ត្របែងចែកបុព្វលាភ) ជាចម្បងសម្រាប់កិច្ចសន្យារយៈពេលខ្លី។

នៅថ្ងៃទី24 ខែមីនា ឆ្នាំ2023 ន.គ.ស បានចេញនូវសេចក្តីជូនដំណឹង ក្នុងការពន្យារពេលលើការអនុវត្តលើ CIFRS 17 និង CIFRS 9 សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងស្តង់ដា ដែលនេះនឹងមានប្រសិទ្ធភាពសម្រាប់ការិយបរិច្ឆេទរបាយការណ៍ប្រចាំឆ្នាំ ដែលចាប់ផ្តើម ឬ បន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2025។ នៅថ្ងៃទី23 ខែធ្នូ ឆ្នាំ2024 ន.គ.ស បានចេញសេចក្តីជូនដំណឹងមួយទៀត ដើម្បីពន្យារពេលការអនុវត្តបន្ថែមទៀតរហូតដល់ថ្ងៃទី1 ខែមករា ឆ្នាំ2028។

ការពិនិត្យឡើងវិញអំពីភាពពាក់ព័ន្ធ និងផលប៉ះពាល់នៃការអនុម័តស្តង់ដានេះកំពុងបន្ត។

(vii) CIFRS 9 ឧបករណ៍ហិរញ្ញវត្ថុ

CIFRS 9 បានជំនួស CIAS 39 ឧបករណ៍ហិរញ្ញវត្ថុ៖ ការទទួលស្គាល់ និងការវាស់វែង ប៉ុន្តែក្រុមហ៊ុនបានជ្រើសរើសអនុវត្តការលើកលែងបណ្តោះអាសន្នពី CIFRS 9 ស្ថិតក្រោមវិសោធនកម្ម CIFRS 4 ដែលពន្យារកាលបរិច្ឆេទអនុវត្តដំបូង នៃ CIFRS 9 ដើមស្របជាមួយនឹងការទទួលស្គាល់នៃCIFRS 17។ ក្រុមហ៊ុនបានសន្និដ្ឋានថាខ្លួនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការលើកលែងជាបណ្តោះអាសន្នពី CIFRS 9 ពីព្រោះសកម្មភាពរបស់ខ្លួនត្រូវបានភ្ជាប់ជាមួយនឹងការធានារ៉ាប់រង និងមិនមានការផ្លាស់ប្តូរខ្លាំងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## 6. ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងការសន្មតដែលមានឥទ្ធិពលលើចំនួនតួលេខរាយការណ៍នៃ ទ្រព្យសកម្ម និងបំណុលនៃឆ្នាំសារពើពន្ធបន្ទាប់។ ការវិនិច្ឆ័យ និងប៉ាន់ស្មានត្រូវបានវាយតម្លៃបន្ត និងអនុលោមតាមបទពិសោធន៍នាគ្រាមុនៗ និងកត្តាផ្សេងទៀត រួមទាំងការរំពឹងទុកនៃព្រឹត្តិការណ៍អនាគតដែលត្រូវបានជឿជាក់ថាសមហេតុផលតាមកាលៈទេសៈ។

<u>ការវិនិច្ឆ័យ</u>

នៅក្នុងដំណើរការអនុវត្ត គោលការណ៍គណនេយ្យរបស់ក្រុមហ៊ុន គណៈគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ ក្រៅពីអ្នកដែលពាក់ព័ន្ធនឹងការប៉ាន់ស្មាន ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖





*(i) ការបែងចែកផលិតផល*

ក្នុងគោលការណ៍ណែនាំទូទៅក្រុមហ៊ុនបានកំណត់ថា តើវាមានហានិភ័យធានារ៉ាប់រងដ៏សំខាន់ដោយប្រៀបធៀបអត្ថប្រយោជន៍ដែលនឹងត្រូវបង់ លើការកើតឡើងនៃព្រឹត្តិការណ៍ធានារ៉ាប់រងដែលមានអត្ថប្រយោជន៍ដែលនឹងត្រូវបង់ ប្រសិនបើព្រឹត្តិការណ៍ធានារ៉ាប់រងមិនបានកើតឡើង។ ក្រុមហ៊ុន បានកំណត់ថាគោលនយោបាយធានារ៉ាប់រង ដែលខ្លួនចេញមានហានិភ័យធានារ៉ាប់រងជាសារវន្ត ហេតុដូច្នេះហើយបានបំពេញតាមនិយមន័យ នៃកិច្ចសន្យាធានារ៉ាប់រង ហើយគួរតែត្រូវយកមកគិតទុក។

<u>ការប៉ាន់ស្មាន</u>

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងការសន្មតទាក់ទងនាពេលអនាគត។ តាមនិយមន័យ ការប៉ាន់ស្មានគណនេយ្យ កម្រនឹងស្មើនឹងលទ្ធផលជាក់ស្តែងដែលពាក់ព័ន្ធ។ ការប៉ាន់ស្មាន និងការសន្មតដែលមានហានិភ័យគួរឲ្យកត់សម្គាល់នៃការធ្វើឲ្យមាននិយ័តកម្មជាសារវន្តលើតម្លៃយោងគណនេយ្យ នៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបន្ទាប់ត្រូវបានពិភាក្សាដូចខាងក្រោម។

*(i)* ចំណាយពន្យារ

ការសម្រេចចិត្តនៃចំណាយពន្យារ គឺពឹងផ្អែកលើការសន្មតដែលធ្វើឡើងដោយគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន។ ការប៉ាន់ស្មានទាំងនេះត្រូវបានពិនិត្យឡើងវិញ និងកែសម្រួល (ប្រសិនបើចាំបាច់) ជារៀងរាល់ឆ្នាំ ដើម្បីបង្កើតចំណាយពន្យារ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មានដ៏ល្អបំផុត។

*(ii)* បំណុលនៃកិច្ចសន្យាធានារ៉ាប់រង

បំណុលកិច្ចសន្យាធានារ៉ាប់រង សម្រាប់ផលិតផលប្រពៃណី ដែលរួមមានប្រាក់បម្រុងគណិតវិទ្យា ប្រាក់បម្រុងសំណងមិនទាន់បានទូទាត់ និងអត្ថប្រយោជន៍ដែលត្រូវទូទាត់ ត្រូវបានបង្កើតឡើងស្របតាមគោលការណ៍ទូទៅលើការគណនាបុព្វលាភធានារ៉ាប់រង។

ប្រាក់បម្រុងគណិតវិទ្យា គឺជាភាពខុសគ្នារវាងតម្លៃបច្ចុប្បន្ននៃការធានារ៉ាប់រងសរុបដែលត្រូវបង់នាពេលអនាគត និងតម្លៃបច្ចុប្បន្ន នៃបុព្វលាភធានារ៉ាប់រងដែលអាចទទួលបាននាពេលអនាគត។ បច្ចុប្បន្ន ប្រាក់បម្រុងគណិតវិទ្យាត្រូវបានគណនាសម្រាប់ការលក់ផលិតផលរយៈពេលវែងទាំងអស់។

ប្រាក់បម្រុងសំណងធានារ៉ាប់រង គឺជាសំវិធានធនសម្រាប់ការទាមទារសំណងដែលមិនត្រូវបានរាយការណ៍ (“ប្រាក់បម្រុងសំណងធានារ៉ាប់រងដែលកើតឡើង ប៉ុន្តែមិនទាន់ទទួលបានរាយការណ៍” - IBNR) និងការទាមទារសំណងដែលបានដាក់ស្នើ ប៉ុន្តែនៅតែស្ថិតក្នុងដំណាក់កាលនៃការទូទាត់ (“ប្រាក់បម្រុងសំណងធានារ៉ាប់រង ដែលបានទទួលរាយការណ៍ ប៉ុន្តែមិនទាន់បានទូទាត់” - RBNS) នាកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ក្រុមហ៊ុនធ្វើការប៉ាន់ស្មានពាក់ព័ន្ធនឹងអត្រាមរណៈភាព អត្រាជម្ងឺ អត្រាទីឃាយុភាព ផលចំណូលវិនិយោគ ចំណាយ អត្រាអស់សុពលភាព អត្រាបោះបង់ និងអត្រាអប្បហារ សម្រាប់កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត។ ការប៉ាន់ស្មានទាំងនេះ បង្កើតនូវការសន្មតដែលប្រើដើម្បីគណនាបំណុលដែលកើតឡើងពីកិច្ចសន្យាទាំងនេះ ស្របតាមគោលការណ៍គណនា ហានិភ័យធានារ៉ាប់រងជាទូទៅ និងយោងតាមប្រកាស លេខ063 ស្តីពីនីតិវិធី និងវិធីសាស្ត្រនៃការគណនាប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង ដែលចេញដោយ IRC នៅថ្ងៃទី23 ខែធ្នូ ឆ្នាំ2022។

*(iii) អ៊ីមភែរមិននៃតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ*

ការវិនិច្ឆ័យបានតម្រូវអោយកំណត់ ថាតើមានការថយចុះ ក្នុងតម្លៃទីផ្សារនៃវិនិយោគហិរញ្ញវត្ថុមានសម្រាប់លក់ និងឥណទានព្រមទាំងគណនីត្រូវទទួល ស្ថិតក្រោមថ្លៃដើមដំបូង ឬ ថ្លៃដើមរំលស់បង្កើតបានជាអ៊ីមភែរមិននៃតម្លៃហើយបើដូច្នេះ ការខាតបង់អ៊ីមភែរមិននៃតម្លៃ ត្រូវតែមានការទទួលស្គាល់។

*(iv)* ការកំណត់តម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទដោយប្រើប្រាស់ បច្ចេកទេសវាយតម្លៃ

នៅពេលដែលតម្លៃសមធម៌នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រានៅលើសេចក្តីថ្លែងការណ៍ នៃស្ថានភាពហិរញ្ញវត្ថុមិនអាចទទួលបានពីទីផ្សារសកម្មនោះពួកវាត្រូវបានកំណត់ដោយប្រើបច្ចេកទេសវាយតម្លៃផ្សេងៗគ្នាដែលរួមមានការប្រើប្រាស់គំរូលំហូរសាច់ប្រាក់អប្បហារតម្លៃ និង/ឬគំរូគណិតវិទ្យា។ ធាតុចូលសម្រាប់ម៉ូដែលទាំងនេះគឺបានមកពីទិន្នន័យ ទីផ្សារដែលអាចសង្កេតបានប្រសិនបើអាចធ្វើទៅបានប៉ុន្តែនៅពេលដែលទិន្នន័យទីផ្សារ ដែលអាចអង្កេតបាននោះ ការវិនិច្ឆ័យគឺត្រូវបានទាមទារដើម្បីបង្កើតតម្លៃសមស្រប។

ការវិនិច្ឆ័យរួមមានការពិចារណាលើហានិភ័យនៃសន្ទនីយភាព ហានិភ័យឥណទាន និងការបញ្ចូលគំរូដូចជាភាពប្រែប្រួលសម្រាប់និស្សន្ទវត្ថុ ដែលមានកាលបរិច្ឆេទយូរជាង និងអត្រាបញ្ចុះតម្លៃអត្រាការបង់ប្រាក់ជាមុន និងការសន្មតអត្រាលំនាំដើមសម្រាប់មូលបត្រដែលគាំទ្រដោយទ្រព្យសកម្ម។

*(v)* ពន្ធ

ពន្ធត្រូវបានគណនា តាមមូលដ្ឋាននៃការបកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ។ ប៉ុន្តែបទប្បញ្ញត្តិទាំងនេះ អាស្រ័យតាមការប្រែប្រួលនៃពេលវេលា និងការកំណត់ចុងក្រោយផ្សេងៗគ្នានៃចំណាយសារពើពន្ធនឹងត្រូវធ្វើឡើងតាមការត្រួតពិនិត្យរបស់អាជ្ញាធរពន្ធដារ។ ក្នុងករណីលទ្ធផលពន្ធចុងក្រោយនៃបញ្ហាទាំងនេះ ខុសគ្នាពីចំនួនដែលបានកត់ត្រាដំបូង ភាពខុសគ្នានេះ នឹងប៉ះពាល់ដល់ពន្ធដែលលើប្រាក់ចំណូល និងសំវិធានធនលើពន្ធពន្យារនៅក្នុងឆ្នាំដែល ការកំណត់នោះត្រូវបានធ្វើឡើង។

*(vi)* ការទទួលស្គាល់ចំណូលពន្ធពន្យារជាទ្រព្យសកម្ម

ក្រុមហ៊ុនបានពិនិត្យឡើងវិញនូវតម្លៃយោងគណនេយ្យរបស់ពន្ធពន្យារជាទ្រព្យសកម្ម នៅក្នុងការិយបរិច្ឆេទរាយការណ៍នីមួយៗ និងកាត់បន្ថយពន្ធពន្យារជាទ្រព្យសកម្ម ក្នុងកម្រិតដែលមិនគួរឲ្យជឿថាចំណូលជាប់ពន្ធដែលអាចរកបានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យពន្ធពន្យារជាទ្រព្យសកម្មទាំងអស់ត្រូវបានប្រើប្រាស់។





## 7. ទ្រព្យ និងបរិក្ខារ

| | 2025 | | | | | | |
|---|---|---|---|---|---|---|---|
| | ការកែលម្អអគារជួល | សម្ភារៈកុំព្យូទ័រ | គ្រឿងសង្ហារិម និងបរិក្ខារ | យានយន្ត | ផ្សេងៗ | ការសាងសង់ កំពុង ដំណើការ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្លៃដើម** | | | | | | | |
| នាថ្ងៃទី1 ខែមករា | 2,058,870 | 2,844,527 | 697,004 | 535,762 | 15,289 | - | 6,151,452 |
| ការទិញបន្ថែម | 1,782 | 145,138 | 21,309 | - | - | 282,726 | 450,955 |
| ការផ្ទេរ | 36,633 | - | 9,561 | - | - | (46,194) | - |
| ការលក់ | - | (210,833) | (47,602) | (237,915) | - | - | (496,350) |
| ការលុបចោល | (179,551) | (86,339) | (72,355) | - | (9,065) | - | (347,310) |
| **នាថ្ងៃទី31 ខែធ្នូ** | **1,917,734** | **2,692,493** | **607,917** | **297,847** | **6,224** | **236,532** | **5,758,747** |
| **រំលស់បង្គរ** | | | | | | | |
| នាថ្ងៃទី1 ខែមករា | 826,292 | 1,873,430 | 400,320 | 535,762 | 9,471 | - | 3,645,275 |
| រំលស់ក្នុងការិយបរិច្ឆេទ | 297,776 | 325,375 | 75,524 | - | 1,250 | - | 699,925 |
| ការលក់ | - | (209,662) | (47,587) | (237,915) | - | - | (495,164) |
| ការលុបចោល | (179,551) | (81,628) | (70,365) | - | (9,065) | - | (340,609) |
| **នាថ្ងៃទី31 ខែធ្នូ** | **944,517** | **1,907,515** | **357,892** | **297,847** | **1,656** | **-** | **3,509,427** |
| **តម្លៃយោងសុទ្ធ** | | | | | | | |
| **នាថ្ងៃទី31 ខែធ្នូ** | **973,217** | **784,978** | **250,025** | **-** | **4,568** | **236,532** | **2,249,320** |
| **សមមូលពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **3,905,520** | **3,150,117** | **1,003,350** | **-** | **18,332** | **949,202** | **9,026,521** |

| | 2024 | | | | | | |
|---|---|---|---|---|---|---|---|
| | **ការកែលម្អអគារជួល** | **សម្ភារៈកុំព្យូទ័រ** | **គ្រឿងសង្ហារិម និងបរិក្ខារ** | **យានយន្ត** | **ផ្សេងៗ** | **ការសាងសង់កំពុង ដំណើរការ** | **សរុប** |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្លៃដើម** | | | | | | | |
| នាថ្ងៃទី1 ខែមករា | 1,532,678 | 2,470,785 | 615,734 | 673,262 | 80,925 | 508,964 | 5,882,348 |
| ការទិញបន្ថែម | 15,743 | 382,619 | 66,905 | - | - | 1,277,962 | 1,743,229 |
| ការផ្ទេរ | 1,352,766 | 209,680 | 224,480 | - | - | (1,786,926) | - |
| ការលក់ | - | (217,748) | - | (137,500) | - | - | (355,248) |
| ការលុបចោល | (842,317) | (809) | (210,115) | - | (65,636) | - | (1,118,877) |
| **នាថ្ងៃទី31 ខែធ្នូ** | **2,058,870** | **2,844,527** | **697,004** | **535,762** | **15,289** | **-** | **6,151,452** |
| **រំលស់បង្គរ** | | | | | | | |
| នាថ្ងៃទី1 ខែមករា | 1,351,735 | 1,735,154 | 555,018 | 673,262 | 73,595 | - | 4,388,764 |
| រំលស់ក្នុងការិយបរិច្ឆេទ | 316,874 | 345,324 | 50,021 | - | 1,512 | - | 713,731 |
| ការលក់ | - | (206,239) | - | (137,500) | - | - | (343,739) |
| ការលុបចោល | (842,317) | (809) | (204,719) | - | (65,636) | - | (1,113,481) |
| **នាថ្ងៃទី31 ខែធ្នូ** | **826,292** | **1,873,430** | **400,320** | **535,762** | **9,471** | **-** | **3,645,275** |
| **តម្លៃយោងសុទ្ធ** | | | | | | | |
| **នាថ្ងៃទី31 ខែធ្នូ** | **1,232,578** | **971,097** | **296,684** | **-** | **5,818** | **-** | **2,506,177** |
| **សមមូលពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **4,961,126** | **3,908,665** | **1,194,153** | **-** | **23,418** | **-** | **10,087,362** |

ការទិញ ទ្រព្យ និងបរិក្ខារ ជាសាច់ប្រាក់ ៖

| | 2025 | 2024 |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ការទិញ ទ្រព្យ និងបរិក្ខារ** | (450,955) | (1,743,229) |
| **គណនីត្រូវទូទាត់ជូនអ្នកផ្គត់ផ្គង់** | 236,532 | - |
| **លំហូរសាច់ប្រាក់លើការទិញទ្រព្យ និងបរិក្ខារ** | (214,423) | (1,743,229) |
| **សមមូលពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | (860,051) | (7,096,685) |





## 8. ចំណាយពន្យារ និងទ្រព្យសកម្មអរូបីផ្សេងៗ

| | 2025 | | | | | |
|---|---|---|---|---|---|---|
| | | ទ្រព្យសកម្មអរូបីផ្សេងៗ | | | | |
| | ចំណាយពន្យារ | កម្មវិធីកុំព្យូទ័រ | កម្រៃភាពជាដៃគូ | ទ្រព្យសកម្មកំពុង ដំណើរការ | សរុបរង | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្លៃដើម** | | | | | | |
| នាថ្ងៃទី1 ខែមករា | 84,088,798 | 4,028,623 | 7,928,495 | 21,182 | 11,978,300 | 96,067,098 |
| ការទិញបន្ថែម | 13,032,366 | - | - | 203,791 | 203,791 | 13,236,157 |
| **នាថ្ងៃទី31 ខែធ្នូ** | **97,121,164** | **4,028,623** | **7,928,495** | **224,973** | **12,182,091** | **109,303,255** |
| **រំលស់បង្គរ** | | | | | | |
| នាថ្ងៃទី1 ខែមករា | 35,480,326 | 2,260,752 | 4,314,013 | - | 6,574,765 | 42,055,091 |
| រំលស់ក្នុងការិយបរិច្ឆេទ | 10,336,940 | 504,137 | 461,165 | - | 965,302 | 11,302,242 |
| **នាថ្ងៃទី31 ខែធ្នូ** | **45,817,266** | **2,764,889** | **4,775,178** | **-** | **7,540,067** | **53,357,333** |
| **តម្លៃយោងសុទ្ធ** | | | | | | |
| **នាថ្ងៃទី31 ខែធ្នូ** | **51,303,898** | **1,263,734** | **3,153,317** | **224,973** | **4,642,024** | **55,945,922** |
| **សមមូលពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **205,882,543** | **5,071,365** | **12,654,261** | **902,816** | **18,628,442** | **224,510,985** |

| | 2024 | | | | | |
|---|---|---|---|---|---|---|
| | ចំណាយពន្ធារ | ទ្រព្យសកម្មរូបីផ្សេងៗ | | | | សរុប |
| | | កម្មវិធីកុំព្យូទ័រ | កម្រៃការពារដៃគូ | ទ្រព្យសកម្មកំពុងដំណើរការ | សរុបរង | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្លៃដើម** | | | | | | |
| នាថ្ងៃទី1 ខែមករា | 68,079,258 | 2,805,067 | 7,928,495 | 1,019,755 | 11,753,317 | 79,832,575 |
| ការទិញបន្ថែម | 16,009,540 | 203,801 | - | 21,182 | 224,983 | 16,234,523 |
| ការផ្ទេរ | - | 1,019,755 | - | (1,019,755) | - | - |
| **នាថ្ងៃទី31 ខែធ្នូ** | **84,088,798** | **4,028,623** | **7,928,495** | **21,182** | **11,978,300** | **96,067,098** |
| **រំលស់បង្គរ** | | | | | | |
| នាថ្ងៃទី1 ខែមករា | 27,536,611 | 1,742,966 | 3,902,258 | - | 5,645,224 | 33,181,835 |
| រំលស់ក្នុងការិយបរិច្ឆេទ | 7,943,715 | 517,786 | 411,755 | - | 929,541 | 8,873,256 |
| **នាថ្ងៃទី31 ខែធ្នូ** | **35,480,326** | **2,260,752** | **4,314,013** | - | **6,574,765** | **42,055,091** |
| **តម្លៃយោងសុទ្ធ** | | | | | | |
| **នាថ្ងៃទី31 ខែធ្នូ** | **48,608,472** | **1,767,871** | **3,614,482** | **21,182** | **5,403,535** | **54,012,007** |
| **សមមូលពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **195,649,100** | **7,115,681** | **14,548,290** | **85,257** | **21,749,228** | **217,398,328** |





ការរំលស់នៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់មានៈ

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| រំលស់នៃការចំណាយពន្ធារ | 10,336,940 | 41,461,466 | 7,943,715 | 32,338,864 |
| រំលស់ទ្រព្យសកម្មអរូបីផ្សេងៗ | 965,302 | 3,871,826 | 929,541 | 3,784,161 |
| ការរំលស់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម (កំណត់សម្គាល់លេខ 10.1) | 796,629 | 3,195,279 | 858,702 | 3,495,776 |
| ការរំលស់ទ្រព្យ និងបរិក្ខារ (កំណត់សម្គាល់លេខ 7) | 699,925 | 2,807,399 | 713,731 | 2,905,599 |
| | **12,798,796** | **51,335,970** | **10,445,689** | **42,524,400** |

## 9. ប្រាក់បញ្ញើតម្កល់តាមច្បាប់

ប្រាក់បញ្ញើតម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមមាត្រា 53 នៃ អនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការធានារ៉ាប់រងចុះថ្ងៃទី22 ខែតុលា ឆ្នាំ2001 និងមាត្រា 1 នៃសារាចរលេខ 009 ស.ហ.វ ចុះថ្ងៃទី9 ខែធ្នូ ឆ្នាំ2002 របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប្រាក់បញ្ញើតម្កល់តាមច្បាប់មានចំនួនស្មើនឹង 10% នៃដើមទុនក្រុមហ៊ុនដែលបានចុះបញ្ជីដំបូង។ ប្រាក់តម្កល់នេះពុំទទួលបានការប្រាក់ ហើយអាចដកបានមកវិញនៅពេលដែលក្រុមហ៊ុនឈប់ដំណើរការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## 10. ភតិសន្យា

### 10.1 សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម

ក្រុមហ៊ុនមានកិច្ចសន្យាជួលសម្រាប់ការិយាល័យកណ្តាល និងសាខាដែលមានលក្ខខណ្ឌជួលចាប់ពី 2 ទៅ 6 ឆ្នាំ។ ក្រុមហ៊ុនក៏មានការជួលកន្លែងការិយាល័យដាក់លាក់ជាមួយនឹងលក្ខខណ្ឌជួលរយៈពេល 12 ខែ ឬ តិចជាងនេះដែល ក្រុមហ៊ុនអនុវត្តការលើកលែងការទទួលស្គាល់ ការជួលរយៈពេលខ្លីសម្រាប់ការជួលទាំងនេះ។

កំណត់ខាងក្រោមនេះគឺជាតម្លៃយោងគណនេយ្យនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ដែលត្រូវបានទទួលស្គាល់ និងបម្រែបម្រួលរបស់ទ្រព្យសកម្មទាំងនោះក្នុងអំឡុងការិយបរិច្ឆេទនេះ ៖

| | *2025* | | | |
|---|---|---|---|---|
| | **អគារ** | **យានយន្ត** | **សរុប** | |
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| | | | | (កំណត់សម្គាល់លេខ 2.3) |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី1 ខែមករា | 3,715,449 | - | 3,715,449 | 14,954,682 |
| ការបន្ថែម | - | 545,597 | 545,597 | 2,188,390 |
| ការកែសម្រួល | 94,202 | - | 94,202 | 377,844 |
| ការដល់កាលកំណត់ | (151,820) | - | (151,820) | (608,950) |
| ការបញ្ចប់ | - | (44,487) | (44,487) | (178,437) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (43,699) |
| **នាថ្ងៃទី31 ខែធ្នូ** | **3,657,831** | **501,110** | **4,158,941** | **16,689,830** |
| **រំលស់បង្គរ** | | | | |
| នាថ្ងៃទី1 ខែមករា | 1,250,984 | - | 1,250,984 | 5,035,210 |
| រំលស់ក្នុងការិយបរិច្ឆេទ | 682,666 | 113,963 | 796,629 | 3,195,279 |
| ការដល់កាលកំណត់ | (151,820) | - | (151,820) | (608,950) |
| ការបញ្ចប់ | - | (27,805) | (27,805) | (111,526) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (13,777) |
| **នាថ្ងៃទី31 ខែធ្នូ** | **1,781,830** | **86,158** | **1,867,988** | **7,496,236** |
| **តម្លៃយោងសុទ្ធនា ថ្ងៃទី31 ខែធ្នូ** | **1,876,001** | **414,952** | **2,290,953** | **9,193,594** |

| | *2024* | | | |
|---|---|---|---|---|
| | **អគារ** | **យានយន្ត** | **សរុប** | |
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| | | | | (កំណត់សម្គាល់លេខ 2.3) |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី1 ខែមករា | 3,922,979 | 129,566 | 4,052,545 | 16,554,646 |
| ការបន្ថែម | 2,731,834 | - | 2,731,834 | 11,121,296 |
| ការកែសម្រួល | 144,249 | - | 144,249 | 587,238 |
| ការដល់កាលកំណត់ | (3,083,613) | (129,566) | (3,213,179) | (13,080,852) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (227,646) |
| **នាថ្ងៃទី31 ខែធ្នូ** | **3,715,449** | **-** | **3,715,449** | **14,954,682** |
| **រំលស់បង្គរ** | | | | |
| នាថ្ងៃទី1 ខែមករា | 3,483,896 | 121,565 | 3,605,461 | 14,728,308 |
| រំលស់ក្នុងការិយបរិច្ឆេទ | 850,701 | 8,001 | 858,702 | 3,495,776 |
| ការដល់កាលកំណត់ | (3,083,613) | (129,566) | (3,213,179) | (13,080,852) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (108,022) |
| **នាថ្ងៃទី31 ខែធ្នូ** | **1,250,984** | **-** | **1,250,984** | **5,035,210** |
| **តម្លៃយោងសុទ្ធ នាថ្ងៃទី31 ខែធ្នូ** | **2,464,465** | **-** | **2,464,465** | **9,919,472** |





## 10.2 បំណុលភតិសន្យា

| | **2025** | **2024** |
|---|---|---|
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** |
| **ការវិភាគកាលវសាន្ត - កិច្ចសន្យារមិនអប្បហារលំហូរសាច់ប្រាក់** | | |
| អំឡុងពេលមួយឆ្នាំ | 772,988 | 590,904 |
| មួយ ទៅ ប្រាំឆ្នាំ | 1,759,629 | 2,062,521 |
| **បំណុលភតិសន្យាសរុបដែលមិនទាន់ធ្វើអប្បហារ** | **2,532,617** | **2,653,425** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **10,163,392** | **10,680,036** |

តារាងខាងក្រោមនេះគឺជាតម្លៃយោងគណនេយ្យនៃបំណុលភតិសន្យា និងបម្រែបម្រួលក្នុងអំឡុងឆ្នាំនេះ៖

| | **2025** | | |
|---|---|---|---|
| | **អគារ** | **យានយន្ត** | **សរុប** |
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** |
| នាថ្ងៃទី1 ខែមករា | 2,264,010 | - | 2,264,010 |
| ការបន្ថែម | - | 497,587 | 497,587 |
| ការកែសម្រួល | 87,323 | - | 87,323 |
| ការកើននៃការប្រាក់ | 157,278 | 23,712 | 180,990 |
| ការទូទាត់ | (668,904) | (99,352) | (768,256) |
| **នាថ្ងៃទី31 ខែធ្នូ** | **1,839,707** | **421,947** | **2,261,654** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **7,382,744** | **1,693,273** | **9,076,018** |

| | *2024* | | |
|---|---|---|---|
| | **អគារ** | **ផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្ម** | **សរុប** |
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** |
| នាថ្ងៃទី1 ខែមករា | 442,546 | 8,000 | 450,546 |
| ការបន្ថែម | 2,420,611 | - | 2,420,611 |
| ការកែសម្រួល | 132,765 | - | 132,765 |
| ការកើននៃការប្រាក់ | 193,313 | - | 193,313 |
| ការទូទាត់ | (925,225) | (8,000) | (933,225) |
| **នាថ្ងៃទី31 ខែធ្នូ** | **2,264,010** | **-** | **2,264,010** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **9,112,640** | **-** | **9,112,640** |

| | *2025* | *2024* |
|---|---|---|
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** |
| តម្លៃបច្ចុប្បន្ននៃបំណុលភតិសន្យា | | |
| អំឡុងពេលមួយឆ្នាំ | 632,770 | 435,214 |
| ច្រើនជាងមួយឆ្នាំ | 1,628,884 | 1,828,796 |
| **បំណុលភតិសន្យានាថ្ងៃទី31 ខែធ្នូ** | **2,261,654** | **2,264,010** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **9,076,018** | **9,112,640** |

**ខាងក្រោមនេះជាចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត**

| | 2025 | 2024 |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ការចំណាយរំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម (កំណត់សម្គាល់លេខ 22) | 796,629 | 858,702 |
| ការចំណាយការប្រាក់លើបំណុលភតិសន្យា | 180,990 | 193,313 |
| ការចំណាយទាក់ទងនឹងការជួលរយៈពេលខ្លី និងទ្រព្យសកម្មតម្លៃទាប (កំណត់សម្គាល់លេខ 22) | 16,007 | 69,312 |
| **ចំនួនសរុបដែលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត** | **993,626** | **1,121,327** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **3,985,434** | **4,564,922** |

## 11. គណនីធានារ៉ាប់រង និងគណនីត្រូវទទួលផ្សេងៗ

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) (ដូចដែលបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ 30) |
| **គណនីត្រូវទទួលកើតពីកិច្ចសន្យាធានារ៉ាប់រង និងកិច្ចសន្យាធានារ៉ាប់រងបន្ត៖** | | | | |
| ត្រូវទទួលពីអ្នកធានារ៉ាប់រង | 4,815,116 | 19,323,061 | 8,435,311 | 33,952,127 |
| ត្រូវទទួលពីអ្នកធានារ៉ាប់រងបន្ត | 272,194 | 1,092,315 | 1,813,784 | 7,300,481 |
| | **5,087,310** | **20,415,376** | **10,249,095** | **41,252,608** |
| **គណនីត្រូវទទួលផ្សេងៗ៖** | | | | |
| ចំណូលការប្រាក់បង្គរ | 8,500,230 | 34,111,423 | 8,743,573 | 35,192,881 |
| គណនីត្រូវទទួលពីសម្ព័ន្ធញាតិ (កំណត់សម្គាល់លេខ 24.2) | 2,556,007 | 10,257,256 | 3,489,368 | 14,044,706 |
| ប្រាក់បញ្ញើ និងបុរេប្រទាន | 2,319,195 | 9,306,930 | 1,057,313 | 4,255,685 |
| ប្រាក់បញ្ញើ លើពន្ធលើប្រាក់ចំណូល និងតណទានពន្ធកាត់ទុក (កំណត់សម្គាល់លេខ 20) | 1,752,048 | 7,030,969 | 262,252 | 1,055,564 |
| ចំណាយបង់មុន និងប្រាក់កក់ | 411,440 | 1,651,109 | 740,390 | 2,980,070 |
| ពន្ធផ្សេងៗដែលត្រូវទទួលបាន | 113,757 | 456,507 | 186,841 | 752,035 |
| ផ្សេងៗ | 358,066 | 1,436,918 | 290,266 | 1,168,320 |
| | **16,010,743** | **64,251,112** | **14,770,003** | **59,449,261** |
| | **21,098,053** | **84,666,488** | **25,019,098** | **100,701,869** |

## 12. ទ្រព្យសកម្មនៃការធានារ៉ាប់រងបន្ត

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| ប្រាក់បម្រុងបុព្វលាភនៃការធានារ៉ាប់រងបន្ត | **561,950** | **2,255,105** | **342,237** | **1,377,504** |

ទ្រព្យសកម្មនៃការធានារ៉ាប់រងបន្តតំណាងឲ្យប្រាក់បម្រុង ដែលបានគណនាសម្រាប់ផ្នែកនៃគោលនយោបាយដែលបានធានាបន្តជាមួយក្រុមហ៊ុន Munich Re, CamRe, និង GenRe។





## 13. ប្រាក់បញ្ញើនៅធនាគារ

ប្រាក់បញ្ញើនៅធនាគារ គឺជាប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែងនៅធនាគារ ក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានកាលវសានចន្លោះពី 1ឆ្នាំដល់ 15ឆ្នាំ ដោយរាប់ពីកាលបរិច្ឆេទដាក់បញ្ញើ ហើយទទួលបានអត្រាការប្រាក់ពី 4.25% ទៅ 8% (2023៖ 4.75% ទៅ 8%) ក្នុងមួយឆ្នាំ។

## 14. ការវិនិយោគកាន់កាប់រហូតដល់កាលកំណត់

គណនីនេះរួមមានការវិនិយោគលើប័ណ្ណបំណុល ប័ណ្ណបំណុលរដ្ឋាភិបាលនិងបំណុលបន្ទាប់បន្សំ ដែលត្រូវបានចាត់ថ្នាក់ជាការវិនិយោគកានកាប់រហូតដល់កាលកំណត់។ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ការវិនិយោគទាំងនេះរួមមានការវិនិយោគនៅក្នុងឧស្សាហកម្មផ្សេងៗដូចជាទូរគមនាគមន៍ ការដឹកជញ្ជូន ស្ថាប័នហិរញ្ញវត្ថុ និងការអប់រំ។ ការវិនិយោគទាំងនេះមានកាលកំណត់ចាប់ពី 3 ទៅ 15ឆ្នាំ ហើយទទួលបានអត្រាការប្រាក់ចាប់ពី 4.30% ទៅ 8.50% (2024: 5.50% ទៅ 8.50%) ក្នុងមួយឆ្នាំ។ ការសងបំណុលបន្ទាប់បន្សំត្រូវមានចំនួន20% នៃចំនួនសរុបក្នុងមួយឆ្នាំដោយចាប់ផ្តើមពីចុងឆ្នាំទីបី រហូតដល់កាលកំណត់នៅចុងឆ្នាំទីប្រាំពីរ ។

## 15. មូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញ ឬ ខាត

បម្រែបម្រួលនៃការវិនិយោគរបស់ក្រុមហ៊ុនក្នុងមូលបត្រភាគហ៊ុនមានដូចខាងក្រោម៖

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| **ប័ណ្ណភាគហ៊ុនចុះបញ្ជី** | | | | |
| នាថ្ងៃទី1 ខែមករា | 1,873,292 | 7,540,000 | 2,462,668 | 10,059,999 |
| ការខាតបង់តាមតម្លៃទីផ្សារក្នុងការិយបរិច្ឆេទ | (49,220) | (197,421) | (589,376) | (2,399,350) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (22,579) | - | (120,649) |
| **នាថ្ងៃទី31 ខែធ្នូ** | **1,824,072** | **7,320,000** | **1,873,292** | **7,540,000** |

មូលបត្រ័នេះតំណាងឲ្យការវិនិយោគរបស់ក្រុមហ៊ុន ក្នុងមូលបត្រភាគហ៊ុនរបស់ ធនាគារ អេស៊ីលីដាភីអិលស៊ី បានចាត់ថ្នាក់ក្នុងតម្លៃសមស្របតាម របាយការណ៍ចំណេញ ឬខាត។ ការវិនិយោគ គឺមានគោលបំណងលក់នាពេលអនាគតខាងមុខដូចនេះការវិនិយោគនេះបានចាត់ថ្នាក់សម្រាប់ធ្វើពាណិជ្ជកម្ម។ តម្លៃសមស្របត្រូវបានកំណត់ ដោយផ្អែកលើតម្លៃទីផ្សារដែលអាចរកបានពីផ្សារមូលបត្រ័កម្ពុជា។

## 16. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់នៅក្នុងធនាគារតំណាងឲ្យគណនីចរន្ត និងគណនីសន្សំជាមួយធនាគារក្នុងស្រុកដែលមានអត្រាការប្រាក់ចាប់ពី 0.25% ទៅ 3.50% (2024៖ 0.25% ទៅ 2.75%) ក្នុងមួយឆ្នាំ។

## 17. ដើមទុន

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| បានចុះបញ្ជី អនុម័ត បោះផ្សាយ និងបានបង់គ្រប់ចំនួន៖ | | | | |
| **61,320,000 ហ៊ុន ក្នុងតម្លៃ 1 ដុល្លារអាមេរិក ក្នុងមួយហ៊ុន** | **61,320,000** | **245,280,000** | **61,320,000** | **245,280,000** |

សេចក្តីលម្អិតនៃម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន និងចំណាប់អារម្មណ៍ជាម្ចាស់កម្មសិទ្ធិរបស់ពួកគេគឺដូចខាងក្រោម៖

| | *%នៃកម្មសិទ្ធិ* | *ចំនួនភាគហ៊ុន* | *ដុល្លារអាមេរិក* |
|---|---|---|---|
| Prudential Corporation Holding Limited | 99.9999967% | 61,319,998 | 61,319,998 |
| PCA IP Services Limited | 0.0000016% | 1 | 1 |
| Prudential Holdings Limited | 0.0000016% | 1 | 1 |
| | **100%** | **61,320,000** | **61,320,000** |
| **សមមូលជាពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | | | **245,280,000** |

## 18. បំណុលកិច្ចសន្យាធានារ៉ាប់រង

| | 2025 | | |
|---|---|---|---|
| | បំណុលធានារ៉ាប់រងដុល | ទ្រព្យសកម្មធានារ៉ាប់រងបន្ត | តម្លៃសុទ្ធ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **បំណុលធានារ៉ាប់រងអាយុជីវិតដែលមិនចូលរួមចំណែក** | | | |
| បំណុលធានារ៉ាប់រងអាយុជីវិតដលៃមិនចូលរួមចំណាកៃ | 353,114,557 | (561,950) | 352,552,607 |
| សំណងកីតឡឹង ប៉ុន្តមៃិនទាន់ហានរាយការណ៍ (“IBNR”) | 14,557 | - | 14,557 |
| | **353,129,114** | **(561,950)** | **352,567,164** |
| សំណងលើមរណៈភាពត្រូវទូទាត់ | 246,528 | - | 246,528 |
| សំណងលើការបញ្ឈប់កិច្ចសន្យា | 512,269 | - | 512,269 |
| សំណងលើការកាលកំណត់ | 5,251 | - | 5,251 |
| **បំណុលកិច្ចសន្យាធានារ៉ាប់រង** | **353,893,162** | **(561,950)** | **353,331,212** |
| **សមមូលជាពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **1,420,173,259** | **(2,255,105)** | **1,417,918,154** |

| | 2024 | | |
|---|---|---|---|
| | បំណុលធានារ៉ាប់រងដុល | ទ្រព្យសកម្មធានារ៉ាប់រងបន្ត | តម្លៃសុទ្ធ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **បំណុលធានារ៉ាប់រងអាយុជីវិតដែលមិនចូលរួមចំណែក** | | | |
| បំណុលធានារ៉ាប់រងអាយុជីវិតដែលមិនចូលរួមចំណែក | 300,633,149 | (342,237) | 300,290,912 |
| សំណងកើតឡើង ប៉ុន្តែមិនទាន់បានរាយការណ៍ (IBNR) | 13,393 | - | 13,393 |
| | **300,646,542** | **(342,237)** | **300,304,305** |
| សំណងលើមរណៈភាពត្រូវទូទាត់ | 320,347 | - | 320,347 |
| សំណងលើការបញ្ឈប់កិច្ចសន្យា | 369,072 | - | 369,072 |
| **បំណុលកិច្ចសន្យាធានារ៉ាប់រង** | **301,335,961** | **(342,237)** | **300,993,724** |
| **សមមូលជាពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **1,212,877,243** | **(1,377,504)** | **1,211,499,739** |



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

បម្រែបម្រួលនៃបំណុលធានារ៉ាប់រងអាយុជីវិត ដែលមិនចូលរួមចំណែកក្នុងការបែងចែកភាគលាភរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| នាថ្ងៃទី1 ខែមករា | 300,646,542 | 1,210,102,332 | 249,139,336 | 1,017,734,188 |
| ផ្នែកពាណិជ្ជកម្មថ្មី | 1,658,791 | 6,656,728 | 1,211,854 | 4,933,458 |
| កិច្ចសន្យានៅមានសុពលភាព | 49,689,348 | 199,403,354 | 51,356,937 | 209,074,092 |
| មរណៈភាព និងការដល់កំណត់ | (1,573,478) | (6,314,367) | (584) | (2,382) |
| ផលចំណេញពីការវិនិយោគ | 12,233,044 | 49,091,206 | 11,961,209 | 48,694,083 |
| ផលប៉ះពាល់ពីការផ្លាស់ប្តូរការសន្មត និង ម៉ូឌែល | (9,525,133) | (38,224,359) | (13,022,210) | (53,013,415) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (3,607,760) | - | (17,317,692) |
| **នាថ្ងៃទី31 ខែធ្នូ** | **353,129,114** | **1,417,107,134** | **300,646,542** | **1,210,102,332** |

## 19. គណនីធានារ៉ាប់រង និងគណនីត្រូវទូទាត់ផ្សេងៗ

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| | | | (ដូចដែលបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ 30) | |
| ធានារ៉ាប់រងបន្តត្រូវទូទាត់ | 437,786 | 1,756,835 | 865,553 | 3,483,851 |
| បុព្វលាភទទួលពីប័ណ្ណធានារ៉ាប់រងមិនទាន់ចេញផ្សាយ | 746,712 | 2,996,555 | 902,898 | 3,634,164 |
| | **1,184,498** | **4,753,390** | **1,768,451** | **7,118,015** |
| អត្ថប្រយោជន៍បុគ្គលិកផ្សេងៗ | 2,784,447 | 11,173,986 | 3,117,822 | 12,549,234 |
| គណនីត្រូវទូទាត់ឲ្យសម្ព័ន្ធញាតិ (កំណត់សម្គាល់លេខ 24.2) | 641,006 | 2,572,356 | 3,166,453 | 12,744,972 |
| ពន្ធកាត់ទុក និងពន្ធផ្សេងៗ | 252,397 | 1,012,869 | 807,195 | 3,248,960 |
| សំវិធានធនលើសំណងអតីតភាពការងារ | 30,302 | 121,602 | 32,560 | 131,054 |
| គណនីត្រូវទូទាត់ និងចំណាយបង្គរ | 7,556,822 | 30,325,527 | 10,038,660 | 40,405,607 |
| | **11,264,974** | **45,206,340** | **17,162,690** | **69,079,827** |
| | **12,449,472** | **49,959,730** | **18,931,141** | **76,197,842** |

*ការចំណាយបង្គរ និងការទូទាត់ផ្សេងទៀត រួមមានថ្លៃសេវាសវនកម្មដែលមិនទាន់បានទូទាត់មានចំនួនដែលស្មើនឹង 54,087 ដុល្លារអាមេរិក ឬ 217,323 ពាន់រៀល (2024: 46,200 ដុល្លារអាមេរិក ឬ 185,955 ពាន់រៀល)

## 20. ពន្ធលើប្រាក់ចំណូល

លិខិតប្រកាសពន្ធរបស់ក្រុមហ៊ុន គឺអាចនឹងត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរពន្ធដារ។ ដោយសារតែការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពន្ធ សម្រាប់ប្រតិបត្តិការជាច្រើនប្រភេទ ដែលងាយនឹងមានការបកស្រាយខុសៗគ្នា ទឹកប្រាក់ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចនឹងមានការផ្លាស់ប្តូរនៅកាលបរិច្ឆេទក្រោយ បន្ទាប់ពីការកំណត់ចុងក្រោយរបស់អាជ្ញាធរពន្ធដារ។

*អត្រាពន្ធអនុវត្ត*

យោងតាមច្បាប់សារពើពន្ធថ្មី ដែលបានធ្វើវិសោធនកម្ម អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ 2017 សម្រាប់សកម្មភាពនៃការធានារ៉ាប់រងអាយុជីវិត ឬការធានារ៉ាប់រងបន្តដែលមានមុខងារសន្សំ និងសកម្មភាពធានារ៉ាប់រងផ្សេងទៀត លើកលែងតែការធានារ៉ាប់រង ឬការធានារ៉ាប់រងឡើងវិញលើទ្រព្យសម្បត្តិ ឬការធានារ៉ាប់រងហានិភ័យផ្សេងទៀត ពន្ធលើប្រាក់ចំណូលត្រូវកំណត់នៅ 20% លើប្រាក់ចំណូលជាប់ពន្ធ។

លើសពីនេះទៅទៀត យោងតាមសេចក្តីជូនដំណឹងលេខ 6715 ពីអគ្គនាយកដ្ឋានពន្ធដារ (GDT)ស្តីពីការអនុវត្តប្រមូលពន្ធលើប្រាក់ចំណូលសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង ចុះថ្ងៃទី25 ខែមេសា ឆ្នាំ2017 ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ឬ ក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវបង់ពន្ធលើប្រាក់រំដោះលើប្រាក់ចំណេញ 1% នៃបុព្វលាភដុលដោយគ្មានការបែងចែកផលិតផល។

នៅថ្ងៃទី 24 ខែកក្កដា ឆ្នាំ 2024 ក្រុមហ៊ុនបានទទួលការអនុលោមតាមច្បាប់ពន្ធមាសសម្រាប់ឆ្នាំសារពើពន្ធពីឆ្នាំ 2025 ដល់ឆ្នាំ 2026 ។

នៅថ្ងៃទី 23 ខែសីហា ឆ្នាំ 2024 ក្រុមហ៊ុនបានទទួលវិញ្ញាបនប័ត្រនៃការប្រកាសពន្ធ និងកំណត់ត្រាគណនេយ្យបានត្រឹមត្រូវស្របតាមប្រកាសលេខ 638 ចុះថ្ងៃទី 4 ខែកក្កដា ឆ្នាំ 2017 ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់សិទ្ធិឱ្យក្រុមហ៊ុនទទួលបានការលើកលែងពន្ធអប្បបរមាសម្រាប់ឆ្នាំសារពើពន្ធ 2024 និង 2025 ។ នៅថ្ងៃទី 13 ខែឧសភា ឆ្នាំ 2025 ក្រុមហ៊ុនបានទទួលវិញ្ញាបនប័ត្រនៃការប្រកាសពន្ធ និងកំណត់ត្រាគណនេយ្យបានត្រឹមត្រូវពីអគ្គនាយកដ្ឋានពន្ធដារ (GDT) ដែលមានសុពលភាពពីរឆ្នាំ សម្រាប់ឆ្នាំ2026 និង 2027 ។

| | 2025 | | 2024 | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ លេខ 2.3) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ លេខ 2.3) |
| ពន្ធក្នុងគ្រា | 499,551 | 2,003,699 | 1,520,759 | 6,191,010 |
| ពន្ធពន្យារ | (112,873) | (452,734) | (88,096) | (358,639) |
| និយ័តកម្មលើពន្ធប្រាក់ចំណូលនៅឆ្នាំមុន | - | - | 24,724 | 100,651 |
| | **386,678** | **1,550,965** | **1,457,387** | **5,933,022** |

*ការផ្ទៀងផ្ទាត់នៃពន្ធប្រាក់ចំណេញក្នុងគ្រា*

| | 2025 | | 2024 | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ លេខ 2.3) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ លេខ 2.3) |
| **ប្រាក់ចំណេញមុនគិតពន្ធលើប្រាក់ចំណូល** | **1,362,380** | **5,464,508** | **5,000,512** | **20,357,084** |
| ពន្ធលើប្រាក់ចំណូលគណនាតាមអត្រា 20%នៃ ប្រាក់ចំណេញជាប់ពន្ធ | 272,476 | 1,092,902 | 1,000,102 | 4,071,417 |
| និយ័តកម្មលើពន្ធប្រាក់ចំណូលនៅឆ្នាំមុន | - | - | 24,724 | 100,651 |
| ចំណាយមិនអាចកាត់កងបាន | 114,202 | 458,063 | 432,561 | 1,760,954 |
| **ចំណាយលើពន្ធលើប្រាក់ចំណូល** | **386,678** | **1,550,965** | **1,457,387** | **5,933,022** |





*ពន្ធពន្យារជាទ្រព្យសកម្ម*

ពន្ធពន្យារជាទ្រព្យសកម្មកើតឡើងពី៖

| | 2025 | | 2024 | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ លេខ 2.3) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ លេខ 2.3) |
| ការធ្វើនិយ័តកម្មឡើងវិញដែលមិនបានទទួលស្គាល់ | 247,753 | 994,232 | 189,066 | 760,991 |
| រំលស់តាមពន្ធ | 129,075 | 517,978 | 92,118 | 370,775 |
| សំវិធានធនលើការស្តារឡើងវិញ | 9,230 | 37,040 | 22,153 | 89,166 |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | 6,060 | 24,319 | 6,512 | 26,211 |
| សំណងកើតឡើងប៉ុន្តែមិនទាន់បានរាយការណ៍ IBNR | 2,911 | 11,682 | 2,679 | 10,782 |
| ភតិសន្យា | (9,719) | (39,002) | (40,091) | (161,366) |
| | **385,310** | **1,546,249** | **272,437** | **1,096,559** |

បម្រែបម្រួលនៃបំណុលពន្ធលើប្រាក់ចំណូលមានដូចខាងក្រោម៖

| | 2025 | | 2024 | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ លេខ 2.3) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ លេខ 2.3) |
| នាថ្ងៃទី1 ខែមករា | - | - | 2,398,002 | 9,795,838 |
| ចំណាយលើពន្ធលើប្រាក់ចំណូល | 499,551 | 2,003,699 | 1,520,759 | 6,191,010 |
| និយ័តកម្មលើពន្ធប្រាក់ចំណូលនៅឆ្នាំមុន | - | - | 24,724 | 100,651 |
| ពន្ធលើប្រាក់ចំណូលបានទូទាត់ | (499,551) | (2,003,699) | (2,901,048) | (11,810,166) |
| ការប្រើប្រាស់ឥណទានពន្ធកាត់ទុក | - | - | (1,042,437) | (4,243,761) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (33,572) |
| **នាថ្ងៃទី31 ខែធ្នូ** | **-** | **-** | **-** | **-** |

បម្រែបម្រួលនៃចំណាយបង់មុននៃពន្ធលើប្រាក់ចំណូល និងឥណទានលើពន្ធកាត់ទុក មានដូចខាងក្រោម (កំណត់ចំណាំ 11)

| | 2025 | | 2024 | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ លេខ 2.3) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ លេខ 2.3) |
| នាថ្ងៃទី1 ខែមករា | 262,252 | 1,055,564 | - | - |
| ការបន្ថែម | | | | |
| ពន្ធលើប្រាក់ចំណូលជាមុន | 770,121 | 3,088,955 | 816,014 | 3,321,993 |
| ឥណទានលើពន្ធកាត់ទុក | 1,219,226 | 4,890,315 | 966,997 | 3,936,645 |
| ដក៖ ប្រើប្រាស់ក្នុងឆ្នាំ | (499,551) | (2,003,699) | (1,520,759) | (6,191,010) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (166) | - | (12,064) |
| **នាថ្ងៃទី31 ខែធ្នូ** | **1,752,048** | **7,030,969** | **262,252** | **1,055,564** |

## 21. ចំណូលការប្រាក់សុទ្ធ

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ | 18,640,104 | 74,765,457 | 17,274,778 | 70,325,621 |
| ចំណូលការប្រាក់ពីការវិនិយោគមូលបត្រសាជីវកម្ម និងបំណុលរដ្ឋាភិបាល | 2,090,773 | 8,386,091 | 2,101,369 | 8,554,673 |
| ចំណូលការប្រាក់ពីការវិនិយោគមូលបត្រលើបំណុល | 430,903 | 1,728,352 | 9,445 | 38,451 |
| | **21,161,780** | **84,879,900** | **19,385,592** | **78,918,745** |

## 22. ចំណាយប្រតិបត្តិការ និងរដ្ឋបាលផ្សេងៗ

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| កម្រៃចំណាយលើការលក់ | 10,392,387 | 41,683,864 | 18,143,746 | 73,863,190 |
| ថ្លៃដើមការទិញផ្សេងៗ | 19,606,754 | 78,642,693 | 23,380,322 | 95,181,290 |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាលផ្សេងៗ | 5,817,087 | 23,332,334 | 6,936,658 | 28,239,135 |
| | **35,816,228** | **143,658,891** | **48,460,726** | **197,283,615** |
| បម្រែបម្រួលនៃចំណាយពន្យារ (កំណត់សម្គាល់លេខ 8) | (13,032,366) | (52,272,820) | (16,009,540) | (65,174,837) |
| រំលស់លើចំណាយពន្យារ (កំណត់សម្គាល់លេខ 8) | 10,336,940 | 41,461,466 | 7,943,715 | 32,338,864 |
| **បម្រែបម្រួលសុទ្ធនៃចំណាយពន្យារ** | **(2,695,426)** | **(10,811,354)** | **(8,065,825)** | **(32,835,973)** |
| | 33,120,802 | 132,847,537 | 40,394,901 | 164,447,642 |





ការវិភាគទៅលើចំណាយប្រតិបត្តិការ និងរដ្ឋបាលផ្សេងៗ (មិនរួមបញ្ចូលចំណាយពន្យារ) មានដូចខាងក្រោម៖

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| កម្រៃជើងសា និងចំណាយអថេរផ្សេងៗ (*) | 12,108,727 | 48,568,104 | 20,437,880 | 83,202,609 |
| ចំណាយលើបុគ្គលិក (កំណត់សម្គាល់លេខ 23) | 10,222,866 | 41,003,915 | 11,061,554 | 45,031,586 |
| ការថែទាំបច្ចេកវិទ្យាព័ត៌មាន | 4,754,945 | 19,072,084 | 6,343,546 | 25,824,576 |
| ថ្លៃសេវាវិជ្ជាជីវៈ (**) | 1,763,326 | 7,072,701 | 3,104,796 | 12,639,625 |
| ការចំណាយលើការប្រជុំ និងកម្មវិធី | 828,952 | 3,324,926 | 969,454 | 3,946,647 |
| រំលស់លើទ្រព្យសកម្មអរូបីផ្សេងៗ (កំណត់សម្គាល់លេខ 8) | 965,302 | 3,871,826 | 929,541 | 3,784,161 |
| រំលស់ និងការកែប្រែលើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម (កំណត់សម្គាល់លេខ 10.1) | 796,629 | 3,195,279 | 858,702 | 3,495,776 |
| រំលស់លើទ្រព្យ និងបរិក្ខា (កំណត់សម្គាល់លេខ 7) | 699,925 | 2,807,399 | 713,731 | 2,905,599 |
| ការចំណាយពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណពាណិជ្ជកម្ម | 573,480 | 2,300,228 | 613,920 | 2,499,268 |
| ការចំណាយលើថ្លៃទឹកភ្លើង និងការិយាល័យ | 457,416 | 1,834,696 | 402,179 | 1,637,271 |
| ចំណាយលើការផ្សាយពាណិជ្ជកម្ម និងផ្សព្វផ្សាយ | 436,175 | 1,749,498 | 352,949 | 1,436,855 |
| ចំណាយលើការកំសាន្ត | 308,481 | 1,237,317 | 303,185 | 1,234,266 |
| ចំណាយលើការអប់រំ និងហ្វឹកហាត់ | 227,765 | 913,565 | 245,287 | 998,563 |
| ថ្លៃសេវាធនាគារ | 151,321 | 606,949 | 154,208 | 627,781 |
| ការចំណាយលើការជួល (កំណត់សម្គាល់លេខ 10.2) | 16,007 | 64,204 | 69,312 | 282,169 |
| ចំណាយប្រតិបត្តិការផ្សេងៗ (***) | 1,504,911 | 6,036,200 | 1,900,482 | 7,736,863 |
| | **35,816,228** | **143,658,891** | **48,460,726** | **197,283,615** |

*(*) ចំណាយផ្សេងៗទាក់ទងទៅនឹងប្រាក់ខែ កម្រៃជើងសារ និងប្រភេទផ្សេងៗនៃការលើកទឹកចិត្តដែលបានផ្តល់សម្រាប់ គោលបំណងបង្កើតប្រាក់ចំណូល។*

*(**) ថ្លៃសេវាវិជ្ជាជីវៈរួមមាន ថ្លៃសេវាសវនកម្មមានចំនួន 90,145 ដុល្លារអាមេរិក ឬ 361,572 ពាន់រៀល សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ធ្នូ 2025 (2024៖ 84,190 ដុល្លារអាមេរិក ឬ 342,737ពាន់រៀល)។*

*(***) ចំណាយប្រតិបត្តិការ និងរដ្ឋបាលផ្សេងៗទៀតរួមមាន ថ្លៃបទប្បញ្ញត្តិ ចំណាយលើការធ្វើដំណើរ ចំណាយលើទំនាក់ទំនងចំណាយបណ្តុះបណ្តាល និងចំណាយប្រតិបត្តិការផ្សេងៗ។*

## 23. ចំណាយលើបុគ្គលិក

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| ប្រាក់បៀវត្សរ៍ | 5,093,568 | 20,430,301 | 5,669,400 | 23,080,127 |
| អត្ថប្រយោជន៍រយៈពេលវែង | 612,553 | 2,456,950 | 557,578 | 2,269,900 |
| ចំណាយការទូទាត់ភាគហ៊ុន | 339,883 | 1,363,271 | 304,181 | 1,238,321 |
| អត្ថប្រយោជន៍ផ្សេងៗ (*) | 4,176,862 | 16,753,393 | 4,530,395 | 18,443,238 |
| | **10,222,866** | **41,003,915** | **11,061,554** | **45,031,586** |

*(*) អត្ថប្រយោជន៍ផ្សេងទៀតរួមមាន ប្រាក់រង្វាន់លើកសមត្ថភាព ប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរ ការឧបត្ថម្ភឯកសណ្ឋាន និងសេវាធានារ៉ាប់រង។*

## 24. ការលាតត្រដាងសម្ព័ន្ធញាតិ

### 24.1 ប្រតិបត្តិការសំខាន់ៗជាមួយសម្ព័ន្ធញាតិក្នុងអំឡុងការិយបរិច្ឆេទ

ប្រតិបត្តិការសំខាន់ៗជាមួយសម្ព័ន្ធញាតិក្នុងអំឡុងឆ្នាំ និងតុល្យភាពដែលនៅសល់ដូចខាងក្រោម៖

| សម្ព័ន្ធញាតិ | លក្ខណៈនៃប្រតិបត្តិការ | 2025 | | 2024 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| Prudential Corporation Holdings Limited | ការគាំទ្របច្ចេកទេស | 3,659,507 | 14,678,282 | 298,411 | 1,214,831 |
| | ការបង្វិលសង | 783,013 | 3,140,665 | 610,551 | 2,485,553 |
| | ថ្លៃសេវាវិជ្ជាជីវៈ | 1,181,229 | 4,737,908 | 2,522,124 | 10,267,567 |
| Prudential Myanmar Life Insurance Limited | ការគាំទ្របច្ចេកទេស | 3,475 | 13,938 | 2,129,247 | 8,668,165 |
| | ការបង្វិលសង | - | - | 179,965 | 732,638 |
| Prudential Life Assurance (Laos) Company Limited | ការគាំទ្របច្ចេកទេស | 618,393 | 2,480,372 | 277,563 | 1,129,959 |
| | ការបង្វិលសង | 158,765 | 636,806 | 59,988 | 244,211 |
| Prudence Foundation | ការបង្វិលសង | 26,550 | 106,493 | 36,377 | 148,091 |
| | ការគាំទ្របច្ចេកទេស | 35,714 | 143,247 | - | - |
| Prudential Service Asia | ការបង្វិលសង | 32,151 | 128,958 | - | - |
| | តំហយចុះនៃការគាំទ្របច្ចេកទេស | 40 | 162 | 79,998 | 325,672 |
| | ថ្លៃសេវាវិជ្ជាជីវៈ | - | - | - | - |
| Prudential Service Singapore Pte Ltd | ការគាំទ្របច្ចេកទេស | 1,195,026 | 4,793,250 | 1,738,362 | 7,076,872 |
| | ការបង្វិលសង | 64,169 | 257,380 | 3,992 | 16,251 |
| Pulse Ecosystems Pte Ltd | ការគាំទ្របច្ចេកទេស | 545,913 | 2,189,659 | 1,063,239 | 4,328,446 |
| Prudential Tech & Services India Private Ltd | ការបង្វិលសង | 8,197 | 32,877 | 599,883 | 2,414,529 |
| | ការគាំទ្របច្ចេកទេស | 747,358 | 2,997,651 | - | - |
| PH - Pru Life Assurance Corp. of the UK-PLUK | ការបង្វិលសង | 66,401 | 266,333 | 130,964 | 533,154 |
| | ការគាំទ្របច្ចេកទេស | 796 | 3,193 | - | - |
| PT Prudential Life Assurance (Indonesia Life) | Reimbursement | 3,222 | 12,924 | - | - |





### 24.2 សមតុល្យជាមួយសម្ព័ន្ធញាតិ

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.3) |
| *គណនីត្រូវទទួល ៖* | | | | |
| Prudential Corporation Holdings Limited | 1,816,894 | 7,291,196 | 2,746,678 | 11,055,379 |
| Prudential Life Assurance (LAOS) Co., Ltd | 549,633 | 2,205,677 | 390,661 | 1,572,411 |
| PH - Pru Life Assurance Corp. of the UK-PLUK | 67,197 | 269,662 | 130,964 | 527,130 |
| Prudential Service Singapore Pte Ltd | 66,771 | 267,952 | 67,631 | 272,215 |
| Prudence Foundation | 35,714 | 143,320 | 5,000 | 20,125 |
| Prudential Service Asia Sdn Bhd | 8,379 | 33,625 | 10,680 | 42,987 |
| Prudential Tech & Services India Private Ltd | 8,197 | 32,894 | 8,196 | 32,988 |
| PT Prudential Life Assurance (Indonesia Life) | 3,222 | 12,930 | - | - |
| Prudential Myanmar Life Insurance Limited | - | - | 129,558 | 521,471 |
| **(កំណត់សម្គាល់លេខ 11)** | **2,556,007** | **10,257,256** | **3,489,368** | **14,044,706** |
| *គណនីត្រូវទូទាត់សង៖* | | | | |
| Prudential Corporation Holdings Limited | 350,356 | 1,405,979 | 1,266,718 | 5,098,540 |
| Prudential Tech & Services India Private Ltd | 142,018 | 569,918 | 599,883 | 2,414,529 |
| Prudential Service Singapore Pte Ltd | 145,157 | 582,515 | 201,978 | 812,961 |
| Prudential Myanmar Life Insurance Limited | 3,475 | 13,944 | 6,047 | 24,339 |
| Pulse Ecosystems Pte Ltd | - | - | 1,091,827 | 4,394,604 |
| **(កំណត់សម្គាល់លេខ 19)** | **641,006** | **2,572,356** | **3,166,453** | **12,744,973** |
| *លាភការរបស់អភិបាល និងគណៈគ្រប់គ្រងសំខាន់ៗ៖* | | | | |
| ប្រាក់កម្រៃអភិបាល | 90,198 | 361,784 | 94,120 | 383,163 |
| ប្រាក់បៀវត្សរ៍ និងប្រាក់រង្វាន់របស់គណៈគ្រប់គ្រងសំខាន់ៗ | 3,430,120 | 13,758,211 | 2,634,051 | 10,723,222 |
| ការទូទាត់តាមភាគហ៊ុន | 333,639 | 1,338,226 | 273,004 | 1,111,399 |

## 25. ការទូទាត់ជាភាគហ៊ុន

គម្រោងព្រូដិនសល អាស៊ី និងអាហ្វ្រិក ជាផែនការលើកទឹកចិត្តរយៈពេលវែង (“PAA LTIP”) ផ្តល់ជូនបុគ្គលិកដែលមានសិទ្ធិទទួលបានប្រាក់រង្វាន់តាមលក្ខខណ្ឌ។ រង្វាន់គឺជាការសម្រេចចិត្ត និងការផ្ទេរ អោយក្នុងរយៈពេលមួយ ពីរ ឬបីឆ្នាំ ទៅកាន់និយោជិតដែលធ្វើការងារជាមួយក្រុមហ៊ុន និងមានសមត្ថភាពបំពេញបានតាមលក្ខខណ្ឌ។ ក្នុងអំឡុងពេលមិនទាន់ផ្ទេរអោយនិយោជិតដែលមានសិទ្ធិ គឺមិនមានសិទ្ធិទទួលបានភាគលាភលើភាគហ៊ុនមូលដ្ឋាននោះទេ។តម្លៃទីផ្សារនៃភាគហ៊ុនគឺស្មើនឹងតម្លៃទិញភាគហ៊ុនទីមួយៗនៅថ្ងៃដែលផ្តល់អោយ។

| ចំនួនភាគហ៊ុនជារង្វាន់ | 2025 | 2024 |
|---|---|---|
| នាថ្ងៃទី1 ខែមករា | 47,720 | 26,467 |
| ការផ្តល់ឲ្យអំឡុងឆ្នាំ | 40,069 | 40,416 |
| ការកាត់ចេញអំឡុងឆ្នាំ | - | (891) |
| ការផ្ទេរឲ្យអំឡុងឆ្នាំ | (18,352) | (18,272) |
| **នាថ្ងៃទី1 ខែធ្នូ** | **69,437** | **47,720** |

នៅឆ្នាំ2025 ការចំណាយទូទាត់ជាភាគហ៊ុនក្នុងឆ្នាំមានចំនួន 339,883 ដុល្លារអាមេរិក ឬ ស្មើនឹង1,363,950ពាន់រៀល (ឆ្នាំ2024៖ មានចំនួន 304,181 ដុល្លារអាមេរិកស្មើនឹង 1,238,321 ពាន់រៀល) (កំណត់សម្គាល់លេខ 23)។

## 26. ក្របខណ្ឌនៃការគ្រប់គ្រងហានិភ័យ

### 26.1 ក្របខណ្ឌគ្រប់គ្រង

កម្មវត្ថុចម្បងនៃក្របខណ្ឌគ្រប់គ្រងហានិភ័យ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺដើម្បីការពារភាគទុនិករបស់ក្រុមហ៊ុន ពីព្រឹត្តិការណ៍ ដែលរារាំងដល់ការសម្រេចគោលដៅលទ្ធផលហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។

ក្រុមហ៊ុនទទួលស្គាល់សារសំខាន់នៃប្រសិទ្ធផល និងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហានិភ័យដែល មានស្រាប់។ ក្រុមហ៊ុនអនុវត្តតាម គោលនយោបាយគ្រប់គ្រងហានិភ័យ ការអនុវត្ត និងគោលការណ៍ណែនាំ របស់ក្រុមហ៊ុនមេ។ គោលនយោបាយ និងហានិភ័យសំខាន់ៗត្រូវបានអនុម័តត្រួតពិនិត្យ និងគ្រប់គ្រងដោយក្រុមហ៊ុនមេ។

### 26.2 កម្មវត្ថុ គោលនយោបាយ និងដំណើរការនៃការគ្រប់គ្រងហានិភ័យសម្រាប់ការគ្រប់គ្រងហានិភ័យ ធានារ៉ាប់រង

សកម្មភាពធានារ៉ាប់រងចម្បងអនុវត្តដោយក្រុមហ៊ុន គឺជាការទទួលយកហានិភ័យនៃការខាតពីបុគ្គលដែលទទួលរងផ្ទាល់ពីហានិភ័យ។ ហានិភ័យនោះអាចទាក់ទងនឹងអាយុជីវិត គ្រោះថ្នាក់ សុខភាព ហិរញ្ញវត្ថុ ឬ គ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតដែលអាចកើតឡើងពីព្រឹត្តិការណ៍ដែលអាចធានាបាន។ ដូចនេះ ក្រុមហ៊ុនត្រូវប្រឈមនឹងភាពមិនច្បាស់លាស់ជុំវិញពេលវេលា និងទំហំនៃសំណងក្រោមកិច្ចសន្យា។ ក្រុមហ៊ុនក៏ទទួលរងឥទ្ធិពលផងដែរនូវ ហានិភ័យទីផ្សារតាមរយៈសកម្មភាពធានារ៉ាប់រង និងវិនិយោគរបស់ខ្លួន។

ក្រុមហ៊ុន គ្រប់គ្រងហានិភ័យធានារ៉ាប់រងរបស់ខ្លួន តាមរយៈកម្រិតនៃការវាយតម្លៃហានិភ័យតាមគោលការណ៍ណែនាំសម្រាប់ការវាយតម្លៃហានិភ័យ និងកម្រិតនៃសិទ្ធិអំណាច នីតិវិធីក្នុងការអនុញ្ញាតសម្រាប់ផលិតផលថ្មី ឬ ហានិភ័យលើសពីការកំណត់ ការបែងចែកហានិភ័យគោលការណ៍កំណត់ថ្លៃ ការធានារ៉ាប់រងបន្ត នីតិវិធីអនុម័តលើការធានារ៉ាប់រងបន្ត និងការត្រួតពិនិត្យនៃបញ្ហាដែលលេចឡើង។

ក្រុមហ៊ុនប្រើប្រាស់វិធីសាស្ត្រជាច្រើនដើម្បីវាយតម្លៃ និងត្រួតពិនិត្យការទទួលរងហានិភ័យទាំង សម្រាប់ប្រភេទធានារ៉ាប់រងបុគ្គល នៃហានិភ័យដែលត្រូវបានធានា និងហានិភ័យជារួម។ វិធីសាស្ត្រទាំងនេះរួម មានការត្រួតពិនិត្យហានិភ័យសរុបនៃអាយុជីវិតនីមួយៗ ការត្រួតពិនិត្យកម្រិត និងការបែងចែកនៃអាជីវកម្មដោយកត្តាផ្សេងៗដូចជា ការវិភាគផលប៉ះពាល់នៃការប្រែប្រួល ការវិភាគលំដាប់នៃព្រឹត្តិការណ៍ និងការធ្វើតេស្តភាពតានតឹង សម្រាប់ការទទួលរងហានិភ័យជាសារវន្ត ឬ ការទទួលរងហានិភ័យដែលពាក់ព័ន្ធ។

ទ្រឹស្តីនៃប្រូបាបប៊ីលីតេ ត្រូវបានប្រើចំពោះការកំណត់ថ្លៃ និងការធ្វើសំវិធានធន សម្រាប់កញ្ចប់វិនិយោគនៃកិច្ចសន្យាធានារ៉ាប់រង។ ហានិភ័យចម្បង គឺនៅពេលដែលសំណងធានារ៉ាប់រងញឹកញាប់លើសពីការរំពឹងទុក។ តាមធម្មតា ព្រឹត្តិការណ៍ធានារ៉ាប់រងមានលក្ខណៈជាការចៃដន្យ ហើយចំនួនពិតនៃព្រឹត្តិការណ៍ក្នុងអំឡុងឆ្នាំណាមួយ ដែលអាចនឹងមានចំនួនខុសគ្នាពីព្រឹត្តិការណ៍ប៉ាន់ស្មានដោយប្រើប្រាស់បច្ចេកទេសស្ថិតិដែលត្រូវបានបង្កើតឡើង។

### 26.3 ការគ្រប់គ្រងដើមទុន និងក្របខណ្ឌបទប្បញ្ញត្តិ

កម្មវត្ថុចម្បងនៃការគ្រប់គ្រងដើមទុនរបស់ក្រុមហ៊ុន គឺការរក្សានូវមូលដ្ឋានដើមទុនដ៏រឹងមាំដើម្បី គាំទ្រដល់ការអភិវឌ្ឍអាជីវកម្មរបស់ខ្លួន និងដើម្បីអនុលោមតាមលក្ខខណ្ឌតម្រូវដើមទុនតាមបទប្បញ្ញត្តិគ្រប់ពេលវេលា។ ក្រុមហ៊ុនទទួលស្គាល់នូវឥទ្ធិពលទៅលើផលត្រឡប់នៃកម្រិតទុនរបស់ភាគទុនិក ដែលត្រូវបានប្រើប្រាស់ និងព្យាយាមរក្សាសមតុល្យដោយប្រុងប្រយ័ត្ន។

និយ័តករធានារ៉ាប់រងកម្ពុជា (IRC) កំណត់អំពីកម្រិតសាធនភាព និងដើមទុនតម្រូវ។ នៅថ្ងៃទី14 ខែធ្នូ ឆ្នាំ2022 IRC បានចេញនូវប្រកាសលេខ 061 ស្តីពីកម្រិតសាធនភាព ដែលណែនាំពីវិធីសាស្ត្រថ្មីក្នុងការគណនាសាធនភាពតម្រូវ ដោយផ្អែកលើប្រាក់បម្រុងគណិតវិទ្យាសុទ្ធ (“NMR”) និងទឹកប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ (“NSAR”)។ កម្រិតសោធនភាពជាអប្បបរមាគឺ 100% ខណៈពេលដែលកម្រឹតគន្លឹះដែលអនុញ្ញាតដំបូងគឺ 120% ដែលត្រូវបានគណនាជាអនុបាតនៃទ្រព្យសកម្មសុទ្ធ លើសាធនភាពតម្រូវ ដែលត្រូវបានកំណត់ដោយ IRC។ បន្ថែមពីនេះ ប្រកាសនេះក៏បានបញ្ជាក់ពីការបែងចែកមូលធនតម្រូវសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង។





សាធនភាពតម្រូវ គឺជាផលបូកនៃ 4% នៃ NMR និង 0.3% នៃ NSAR ក្រោមលក្ខខណ្ឌដែលសាធនភាពតម្រូវអប្បបរមាត្រូវស្មើនឹងចំនួន 50% នៃមូលធនអប្បបរមាចំនួន 7.0 លានដុល្លារអាមេរិក ឬ 3.5 លានដុល្លារអាមេរិក។

បន្ទាប់ពីមានការចាត់ចែងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ជាកម្មសិទ្ធិមិនអាចទទួលស្គាល់សម្រាប់គោលបំណងសមត្ថភាពទូទាត់បានមានសំណួរមួយពីឧស្សាហកម្មផ្តល់ទៅនិយ័តករ ដើម្បីបញ្ជាក់អំពីនិយមន័យ “ប្រាក់ត្រូវទទួលលើសពី 180 ថ្ងៃ”។ អ្នកគ្រប់គ្រងបានបញ្ជាក់នៅថ្ងៃទី 25 ខែកក្កដា ឆ្នាំ 2025 ក្នុងវេទិកា Regulator–CEO ថា ការប៉ាន់ស្មានការប្រាក់ត្រូវទទួល ដែលនឹងទទួលបានលើសពី 180 ថ្ងៃនៅពេលអនាគត ត្រូវចាត់ទុកជាកម្មសិទ្ធិមិនអាចទទួលស្គាល់។ និយ័តករក៏បានអនុញ្ញាតឱ្យដាក់សំណើសុំលើកលែងសម្រាប់ប្រាក់បញ្ញើ ដែលបានដាក់មុនថ្ងៃទី 25 ខែកក្កដា ឆ្នាំ 2025ដែលមានការប្រាក់កើនឡើង ដើម្បីអាចទទួលស្គាល់បានពេញលេញ។ តាមការបញ្ជាក់នេះ PCLA បានដាក់សំណើសុំការលើកលែង និងទទួលបានការអនុម័តពីនិយ័តករ ថ្ងៃទី29 ខែកញ្ញា ឆ្នាំ2025។ នៅពេលវាយតម្លៃថ្ងៃទី25 ខែកក្កដា ឆ្នាំ2025 មានចំនួន 5.2 លានដុល្លារអាមេរិកនៃការប្រាក់កើនឡើង ដែលត្រូវទទួលក្នុងរយៈពេលលើសពី 180 ថ្ងៃនៅពេលអនាគត។

តារាងខាងក្រោម សង្ខេបនូវកម្រិតសាធនភាពរបស់ក្រុមហ៊ុន។

| | 2025 | | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| សាធនភាពតម្រូវ | | | | |
| NMR (4% of NMR) | 14,094,737 | 56,562,180 | 12,005,454 | 48,321,953 |
| NSAR (0.3% of NSAR) | 11,513,523 | 46,203,768 | 14,817,073 | 59,638,720 |
| សរុប (ក) | 25,608,260 | 102,765,948 | 26,822,527 | 107,960,673 |
| មូលធនសាធនភាពអប្បបរមា (ខ) | 3,500,000 | 14,045,500 | 3,500,000 | 14,087,500 |
| **ទ្រព្យសកម្មសុទ្ធ** | **34,982,725** | **140,385,675** | **37,485,595** | **150,879,521** |
| **សាធនភាពតម្រូវ (ក ឬ ខ ដែលមានចំនួនច្រើនជាង)** | **25,608,260** | **102,765,948** | **26,822,527** | **107,960,673** |
| **កម្រិតសាធនភាព** | **137%** | | **140%** | |

ចំពោះការបែងចែកមូលធន តាមប្រកាសតម្រូវឲ្យមាន 10% នៃមូលធនអប្បបរមា ត្រូវតម្កល់នៅក្នុងគណនីរបស់ IRC ជាមួយធនាគារជាតិនៃកម្ពុជា, 50% ត្រូវតម្កល់ជាមួយធនាគារពាណិជ្ជក្នុងស្រុក ជាមួយនឹងការតម្កល់អតិបរមារ 30% ក្នុងធនាគារមួយៗ និងចំនួនដែលនៅសល់ 40% គឺជាសាច់ប្រាក់ ឬជាអចលនទ្រព្យ ប្រើប្រាស់ដោយក្រុមហ៊ុនដែលត្រូវអនុម័តដោយ IRC។ ក្នុងថ្ងៃទី6 ខែមេសា ឆ្នាំ2023 ក្រុមហ៊ុនបានទទួលការអនុម័តពី IRC ដែលអនុញ្ញាតឱ្យក្រុមហ៊ុនដាក់ប្រាក់ជាសន្សំនៅធនាគារ ACLEDA មានចំនួន 88,450,000 ដុល្លារអាមេរិក ដែលតំណាងឱ្យ 39% នៃទឹកប្រាក់ទុកជាប្រាក់បញ្ញើជាមួយធនាគារក្នុងស្រុកសរុបក្នុងឆ្នាំ2022 រហូតដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025។ គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 ការដាក់ប្រាក់បញ្ញើរបស់ក្រុមហ៊ុននៅធនាគារ ACLEDA មានចំនួន 93,450,000 ដុល្លារអាមេរិកដែលតំណាងឱ្យ 29.57% (31 ខែធ្នូ 2024: 88,450,000 ដុល្លារអាមេរិក តំណាងឱ្យ 35.5%) នៃទឹកប្រាក់បញ្ញើសរុបជាមួយធនាគារក្នុងស្រុក។

## 26.4 យុទ្ធសាស្ត្រធានារ៉ាប់រង និងយុទ្ធសាស្ត្រធានារ៉ាប់រងបន្ត

យុទ្ធសាស្ត្រធានារ៉ាប់រងក្រោមគោលបំណង ដើម្បីធានាថាហានិភ័យធានារ៉ាប់រងត្រូវបានបែងចែកទៅតាមប្រភេទហានិភ័យ និងកម្រិតអត្ថប្រយោជន៍ធានារ៉ាប់រង។ ក្រុមហ៊ុនបានបង្កើតយុទ្ធសាស្ត្រ ធានារ៉ាប់រងរបស់ខ្លួន ដោយយោងតាមផ្នែកសំខាន់ៗពីរ - ការជ្រើសរើសហានិភ័យ និងការចាត់ថ្នាក់ហានិភ័យ។

ដំណើរការជ្រើសរើសហានិភ័យ គឺកំណត់ក្រុមហានិភ័យធានារ៉ាប់រងដែលអាចទទួលយកបានចំពោះក្រុមហ៊ុន ដើម្បីឲ្យការបែងចែកប្រភេទហានិភ័យធានារ៉ាប់រងខុសៗគ្នាត្រូវបានសម្រេច។ ជាមួយគ្នានេះដែរ នេះគឺដើម្បីធានានៅក្នុងប្រភេទហានិភ័យនីមួយៗ នេះមានចំនួនច្រើនគ្រប់គ្រាន់នៃហានិភ័យ ដើម្បីកាត់បន្ថយភាពប្រែប្រួលនៃលទ្ធផលដែលបានរំពឹងទុក។

ក្រុមនីមួយៗ នៃហានិភ័យធានារ៉ាប់រងត្រូវបានចាត់ទុកថាជាប្រភេទស្តង់ដា និងកម្រិតនៃហានិភ័យស្តង់ដារងតាមរយៈធានារ៉ាប់រង។ ការជ្រើសរើសវេជ្ជសាស្ត្រ និងគោលការណ៍ណែនាំធានារ៉ាប់រងហិរញ្ញវត្ថុរួមបញ្ចូលក្នុងនីតិវិធីធានារ៉ាប់រងរបស់ក្រុមហ៊ុន ដែលអនុញ្ញាតឲ្យមានការចាត់តាំងត្រឹមត្រូវនៃហានិភ័យធានារ៉ាប់រងទៅកាន់ថ្នាក់សមស្រប។ ថ្នាក់នីមួយៗមានបុព្វលាភខុសៗគ្នា ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពសុខភាព និងប្រវត្តិវេជ្ជសាស្ត្រគ្រួសាររបស់បេក្ខជន។ ក្រុមហ៊ុនប្រើការធានារ៉ាប់រងបន្តនៅក្នុងការដំណើរការនៃអាជីវកម្ម ដើម្បីបែងចែកហានិភ័យរបស់ខ្លួន និងកំណត់សក្តានុពលនៃការខាតបង់សុទ្ធរបស់ខ្លួន។ ការរៀបចំធានារ៉ាប់រងបន្តសម្រាប់ហានិភ័យដែលធ្វើឡើងដោយក្រុមហ៊ុនបានកំណត់ការប៉ះពាល់ហានិភ័យរបស់ក្រុមហ៊ុន។

## 27. ការគ្រប់គ្រងហានិភ័យធានារ៉ាប់រង និងហានិភ័យហិរញ្ញវត្ថុ

ក្រុមហ៊ុន ចេញផ្សាយនូវកិច្ចសន្យាដែលផ្ទេរហានិភ័យធានារ៉ាប់រង ឬ ហានិភ័យហិរញ្ញវត្ថុ ឬ ហានិភ័យ ទាំងពីរប្រភេទ។ ការបកស្រាយខាងក្រោមនេះផ្តល់នូវសេចក្តីលម្អិតនៃផលិតផលចម្បងរបស់ក្រុមហ៊ុន និងមធ្យោបាយរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធ។

## 27.1 ហានិភ័យធានារ៉ាប់រង

ហានិភ័យនៃកិច្ចសន្យាធានារ៉ាប់រងមួយ គឺអាចកើតមាននៅពេលហេតុការណ៍ដែលបានធានារ៉ាប់រងកើតឡើង និងមានភាពមិនប្រាកដប្រជាពីចំនួននៃទឹកប្រាក់សំណង។

សម្រាប់ទំហំនៃកិច្ចសន្យាធានារ៉ាប់រង ដែលជាទ្រឹស្តីនៃប្រូបាប៊ីលីតេ ត្រូវបានអនុវត្តលើការកំណត់តម្លៃ និងសំវិធានធនហានិភ័យជាចម្បងដែលក្រុមហ៊ុនកំពុងប្រឈមក្នុងកិច្ចសន្យាធានារ៉ាប់រង គឺថាទឹកប្រាក់សំណងជាក់ស្តែង និងអត្ថប្រយោជន៍ដែលបង់លើសពីតម្លៃយោង នៃបំណុលកិច្ចសន្យាធានារ៉ាប់រង។ វាអាចកើតឡើងដោយសារតែប្រាក់សំណង និងអត្ថប្រយោជន៍កើតមានជាញឹកញាប់ ឬមានកម្រិតធ្ងន់ធ្ងរច្រើនជាងតម្លៃប៉ាន់ស្មាន។ ហេតុការណ៍ធានារ៉ាប់រង គឺកើតឡើងដោយចៃដន្យ ចំនួន និងទឹកប្រាក់នៃការទាមទារសំណង និងអត្ថប្រយោជន៍ គឺប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំពីការកំណត់នៅក្នុងបច្ចេកទេសស្ថិតិ។

តាមបទពិសោធន៍ បង្ហាញថាទំហំនៃកិច្ចសន្យាធានារ៉ាប់រងស្រដៀងគ្នាមានចំនួនកាន់តែធំ ភាពប្រែប្រួលនៃលទ្ធផលរំពឹងទុកកាន់តែតូច។ លើសពីនេះទៀត ភាពសម្បូរបែបនៃទំហំនៃកិច្ចសន្យា ធានារ៉ាប់រងកាន់តែច្រើន ផលប៉ះពាល់ជាទូទៅដោយការផ្លាស់ប្តូរនៅក្នុងទំហំរងនៃទំហំនៃកិច្ចសន្យាធានារ៉ាប់រង គឺប្រហែលអាចកាន់តែតូច។

ហានិភ័យជាក់លាក់នៃប្រភេទផ្សេងគ្នានៃកិច្ចសន្យាធានារ៉ាប់រងត្រូវបានបកស្រាយដូចខាងក្រោម៖

### កិច្ចសន្យាធានារ៉ាប់រងជីវិតមិនចូលរួមចំណែក

កិច្ចសន្យាធានារ៉ាប់រងជីវិតមិនចូលរួមចំណែក ដែលមានលក្ខណៈចូលរួមជាឆន្ទានុសិទ្ធិកិច្ចសន្យានេះរួមមាន ការសន្យាលើអ្នកត្រូវបានធានារ៉ាប់រង និងភ្ជាប់ជាមួយការការពារលើលក្ខខណ្ឌបន្ថែម។



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

### 27.1.1 ការប្រមូលផ្តុំនៃហានិភ័យធានារ៉ាប់រង

ការប្រមូលផ្តុំនៃហានិភ័យ អាចកើតឡើងនៅពេលដែលហេតុការណ៍ជាក់លាក់មួយ ឬស៊េរីនៃហេតុការណ៍មួយ ដែលអាចមានការប៉ះពាល់យ៉ាងខ្លាំងលើបំណុលនៃកិច្ចសន្យាធានារ៉ាប់រងរបស់ក្រុមហ៊ុន។ ការប្រមូលផ្តុំទាំងនេះអាចកើតឡើងពីកិច្ចសន្យាធានារ៉ាប់រងតែមួយ ឬតាមរយៈផ្នែកតូចមួយនៃកិច្ចសន្យាដែលពាក់ព័ន្ធ និងកាលៈទេសៈដែលបំណុលដ៏សំខាន់អាចកើតឡើង។

ហានិភ័យធានារ៉ាប់រងសម្រាប់កិច្ចសន្យាត្រូវបានរងផលប៉ះពាល់ផងដែរ ដោយសិទ្ធិរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងការបង់បន្ថយ ឬពុំមានបុព្វលាភនៅពេលអនាគត ឬដើម្បីបញ្ចប់កិច្ចសន្យាទាំងស្រុង។ ជាលទ្ធផល ទឹកប្រាក់នៃហានិភ័យធានារ៉ាប់រងគឺកំណត់ទៅតាមឥរិយាបថរបស់អ្នកត្រូវបានធានារ៉ាប់រងផងដែរ។

ផ្អែកលើការសន្មត អ្នកត្រូវបានធានារ៉ាប់រង នឹងធ្វើការសម្រេចចិត្ត ដោយសមហេតុផលហានិភ័យធានារ៉ាប់រង ជារួមអាចត្រូវបានសន្មតទៅជាសារវន្តដោយឥរិយាបថបែបនោះ។ ក្រុមហ៊ុន បានដាក់កត្តាដែលកើតពីផលប៉ះពាល់ដោយឥរិយាបថរបស់អ្នកទទួលបានធានារ៉ាប់រងក្នុងការសន្មតដើម្បីវាស់វែងបំណុល កិច្ចសន្យាធានារ៉ាប់រង។

### 27.1.2 ការសន្មត និងបម្រែបម្រួលនៃការសន្មត

*ដំណើរការត្រូវបានប្រើប្រាស់ក្នុងការកំណត់ការសន្មត*

ក្រុមហ៊ុនបានកំណត់ការសន្មតពាក់ព័ន្ធនឹងអត្រាមរណភាព និងអត្រាជម្ងឺ នាពេលអនាគត ភាពលំនឹង អត្រាអប្បហារ ការបញ្ចប់ដោយស្ម័គ្រចិត្ត ចំណាយលើការបង្កើតប័ណ្ណធានារ៉ាប់រង និងចំណាយរដ្ឋបាល។ ការសន្មតទាំងនេះត្រូវបានប្រើសម្រាប់គណនាបំណុលក្នុងអំឡុងអាយុកាលរបស់កិច្ចសន្យា។

បន្តបន្ទាប់មក តាមបទពិសោធន៍ដែលបានលាតត្រដាងឡើង ក្រុមហ៊ុននឹងធ្វើការសិក្សាលើបទពិសោធន៍ដើម្បីតាមដានភាពត្រឹមត្រូវនៃសន្មតទាំងនេះ។ ការសន្មតដំបូងនឹងត្រូវបានកែសម្រួលយោងតាមបទពិសោធន៍របស់ក្រុមហ៊ុន ជាមួយនឹងនិន្នាការនាពេលអនាគត ដែលបានរំពឹងទុក ប្រសិនជាមាន។

ការសន្មតដែលបានប្រើក្នុងការគណនាបំណុល ត្រូវបានកំណត់នៅលើមូលដ្ឋានប្រុងប្រយ័ត្ន។ ទាំងនេះអាចទទួលបានពីការបង្កើតឡើងដំបូងនៃមូលដ្ឋាន “ការប៉ាន់ស្មានដ៏ល្អបំផុត” តាមបទពិសោធន៍ជាក់ស្តែងដែលសម្មតិកម្មទាំងនេះមានព្រឹត្តិការណ៍ដែលអាចកើតឡើងចំនួន 50% ដែល ជាមធ្យមអាចប្រសើរជាង ឬ អាក្រក់ជាងសម្មតិកម្ម។ សំវិធានធនសម្រាប់ការបង្វែរសម្រាប់ការទាញ យកប្រឈមនឹងការប៉ាន់ស្មានដ៏ល្អបំផុតដូចដែលបានរៀបរាប់ខាងលើ ត្រូវបានបញ្ចូលទៅក្នុងមូលដ្ឋានវាយតម្លៃតាមមូលដ្ឋានប្រុងប្រយ័ត្ន ដើម្បីអនុញ្ញាតឲ្យមានការបង្វែរការទាញយកដែលសមហេតុផលដោយគ្រោងទុកជាមុនពីបទពិសោធន៍ប៉ាន់ស្មានដ៏ល្អបំផុត។

ព័ត៌មានទាក់ទងនឹងការសន្មតសំខាន់ៗ ដែលប្រើដើម្បីគណនាបំណុលកិច្ចសន្យាធានារ៉ាប់រងត្រូវបានផ្តល់ឲ្យនៅខាងក្រោម៖

*(i) អត្រាមរណភាព និងអត្រាជម្ងឺ*

អត្រាឧប្បត្តិហេតុនៃមរណៈភាព និងជំងឺ ត្រូវបានប៉ាន់ស្មានជាលើកដំបូងដោយយោងទៅលើបទពិសោធន៍របស Prudential Vietnam Assurance Private Limited ដែលកំពុងប្រតិបត្តិការនៅក្នុងបរិស្ថានស្រដៀងគ្នាទៅក្រុមហ៊ុន ជាមួយនឹងការកែសម្រួលបន្តិចបន្តួចដោយផ្អែកលើទម្រង់ផលិតផល និងបទពិសោធន៍ដែលបានកើតឡើង។ បទពិសោធន៍ និងការសន្មតកំពុងត្រូវបានត្រួតពិនិត្យយ៉ាងដិតដល់ ហើយការសន្មតអាចត្រូវបានកែសម្រួលដើម្បីឆ្លុះបញ្ចាំងពីបទពិសោធន៍ដែលកំពុងកើតឡើង ប្រសិនបើចាំបាច់។

### (ii) *ការបន្តកិច្ចសន្យា (Persistency)*

អត្រាការបន្តកិច្ចសន្យាខុសគ្នាទៅតាមប្រភេទផលិតផល រយៈពេលគោលនយោបាយ ភ្នាក់ងារ និងច្រកលក់ និងមុខរបរ។ ការសន្មតនេះត្រូវបានកំណត់ដោយយោងទៅលើបទពិសោធន៍ របស់ Prudential Vietnam Assurance Private Limited។ ប្រភពចម្បងនៃភាពមិនប្រាកដប្រជា គឺឥរិយាបថរបស់អ្នកកាន់ប័ណ្ណធានារ៉ាប់រង ដែលអាចបណ្តាលពីផលប៉ះពាល់នៃស្ថានភាពទីផ្សារ និងសេដ្ឋកិច្ច រួមទាំងកត្តាផ្សេងទៀត។ ការផ្លាស់ប្តូរឥរិយាបថរបស់អ្នកកាន់ប័ណ្ណធានារ៉ាប់រងអាចនាំឲ្យអត្រានៃការបញ្ចប់នាពេលអនាគតខុសគ្នា ពីអ្វីដែលក្រុមហ៊ុនបានជួបប្រទះពីមុន។ សំវិធានធនអាចត្រូវបានធ្វើឡើងសម្រាប់និន្នាការនៃ ទិន្នន័យដើម្បីទទួលបានការប៉ាន់ស្មានដ៏ល្អបំផុតមួយនៃអត្រាបន្តកិច្ចសន្យានាពេលអនាគតដោយគិតពីឥរិយាបថរបស់អ្នកកាន់ប័ណ្ណធានារ៉ាប់រង ប្រសិនបើចាំបាច់។

### (iii) *អត្រាអប្បហារ*

ទាំងនេះត្រូវមានការកំណត់ដោយយោងទៅលើការរំពឹងទុកលើផល ពីការវិនិយោគទៅលើទ្រព្យសកម្មធានាទៅលើបំណុល។ ការសន្មតទាំងនេះផ្អែកលើអត្រាជាមធ្យមនៃផលបត្រ និង ផលការវិនិយោគ ដែលរួមមានធនាគារក្នុងស្រុក និងឆ្លុះបញ្ចាំងពីការកាត់បន្ថយហានិភ័យឥណទាន។

អត្រាការប្រាក់បញ្ញើជាដុល្លារអាមេរិកមានដូចខាងក្រោម៖

| រយៈពេល | អត្រាការប្រាក់បញ្ញើ |
|---|---|
| 1 ឆ្នាំ | 4.25% ទៅ 4.50% |
| 2 ឆ្នាំ | 4.25% ទៅ 7.00% |
| 3 ឆ្នាំ | 4.35% ទៅ 7.00% |
| 4 – 5 ឆ្នាំ | 4.50% ទៅ 8.00% |
| >= 5 ឆ្នាំ | 4.25% ទៅ 4.50% |

ការវាយតម្លៃអត្រាអប្បហារចាប់ពី 4.25% ក្នុងមួយឆ្នាំ ទៅ 8.00%.ក្នុងមួយឆ្នាំ (2024៖ 3.25% ក្នុងមួយឆ្នាំ ទៅ 4.15% ក្នុងមួយឆ្នាំ)

### (iv) *ការចំណាយ*

ការគណនាបំណុលកិច្ចសន្យាធានារ៉ាប់រងអនុញ្ញាតឲ្យមានការចំណាយនាពេលអនាគត ដែលឆ្លុះបញ្ចាំងពីការបែងចែកចំណាយរបស់ក្រុមហ៊ុនទៅលើគោលនយោបាយនីមួយៗ ក្នុងរយៈពេលវែង។ នេះរួមមានការចំណាយផ្ទាល់ និងប្រយោលជាមួយនឹងការធ្វើសំវិធានធានសម្រាប់អតិផរណា។ ការសន្មតចំណាយ ដែលកើតឡើងមកពីលទ្ធផលនៃការបង្កើតម៉ូដែលបែងចែក ចំណាយក្នុងផែនការអាជីវកម្មរបស់ក្រុមហ៊ុនក្នុងឆ្នាំ2025។

### (v) *អត្រាឈប់បន្តសុពលភាព*

ការសន្មតឈប់បន្តសុពលភាព ត្រូវបានកំណត់ដោយផ្អែកលើការសិក្សាចុងក្រោយបំផុតរបស់ការឈប់បន្តសុពលភាពដែលឆ្លុះបញ្ចាំងពីបទពិសោធន៍ដែលខុសគ្នា ដោយធ្វើមានឲ្យការសន្មតខុសៗគ្នាទៅលើកម្រិតផលិតផល និងឆានែល។



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

*ការវិភាគវេទយិតភាព*

វេទយិតភាព នៃបំណុលគោលនយោបាយចំពោះកិច្ចសន្យាធានារ៉ាប់រងជីវិតរបស់ក្រុមហ៊ុនដែលមិនចូលរួមក្នុងការសន្មតសម្រាប់ប៉ារ៉ាម៉ែត្រនីមួយៗ នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ត្រូវបានបង្ហាញដូចខាងក្រោម៖

| ប៉ារ៉ាម៉ែត្រ | បម្រែបម្រួលធាតុចូល | ផលប៉ះពាល់លើបំណុល និងប្រាក់ចំណេញ ឬ ខាតបង់ '000ដុល្លារអាមេរិក |
|---|---|---|
| មរណភាព/ជម្ងឺ | +5% (ទ្វេគុណ) | (846) |
| ការមិនបន្ត (ឈប់បន្តសុពលភាព/បោះបង់) | -10% (ទ្វេគុណ) | (3,436) |
| អត្រាការប្រាក់ | -0.5% (ការបន្ថែម) | (5,820) |
| ការចំណាយលើការថែទាំ | -10% (ទ្វេគុណ) | 1,346 |

សញ្ញាអវិជ្ជមានខាងលើបង្ហាញពីការកើនឡើងនៃបំណុល និងការថយចុះនៃប្រាក់ចំណេញមុនបង់ពន្ធ។

ក្រុមហ៊ុន បានធ្វើការប៉ាន់ស្មាន និងកំណត់សម្មតិកម្មសម្រាប់កិច្ចសន្យាធានារ៉ាប់រងជីវិត។ការប៉ាន់ស្មានទាំងនេះបង្កើតនូវសម្មតិកម្ម ដែលប្រើដើម្បីគណនាបំណុលដែលកើតឡើងពីកិច្ចសន្យាទាំងនេះស្របតាមគោលការណ៍ជាក់ស្តែង ដែលបានទទួលស្គាល់ជាទូទៅ និងប្រកាសលេខ 063 ស្តីពីនីតិវិធី និងវិធីសាស្ត្រនៃការគណនាទុនបម្រុងបច្ចេកទេសធានារ៉ាប់រងដែលចេញដោយ IRC នៅថ្ងៃទី23 ខែធ្នូ ឆ្នាំ2022។

## 27.2 ហានិភ័យហិរញ្ញវត្ថុ

ប្រតិបត្តិការនៅក្នុងឧបករណ៍ហិរញ្ញវត្ថុ អាចជាលទ្ធផលនៅក្នុងការសន្មតលើហានិភ័យហិរញ្ញវត្ថុ ក្រុមហ៊ុន។ ហានិភ័យហិរញ្ញវត្ថុ រួមមានហានិភ័យទីផ្សារ ហានិភ័យឥណទាន និងហានិភ័យសាច់ប្រាក់សន្ទនីយភាព។ ហានិភ័យហិរញ្ញវត្ថុនីមួយៗត្រូវបានពណ៌នាដូចខាងក្រោមជាមួយនឹងសេចក្តីសង្ខេបនៃវិធីដែលក្រុមហ៊ុនគ្រប់គ្រងហានិភ័យទាំងនេះ។

### 27.2.1 ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ គឺជាហានិភ័យនៃការប្រែប្រួលតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារ ការប្រែប្រួលអត្រាការប្រាក់ ថ្លៃមូលធន និងអត្រាប្តូរប្រាក់បរទេស។

#### (i) ហានិភ័យអត្រាការប្រាក់

ការប្រឈមហានិភ័យទីផ្សាររបស់ក្រុមហ៊ុន ដោយការប្រែប្រួលអត្រាការប្រាក់ត្រូវបានយកចិត្ត ទុកដាក់នៅក្នុងផលបត្រវិនិយោគ។ ក្រុមហ៊ុនតាមដានការប្រឈមហានិភ័យនេះតាមរយៈការ ត្រួតពិនិត្យជាទៀងទាត់នៃស្ថានភាពទ្រព្យសកម្ម និងបំណុលរបស់ខ្លួន។ ការប៉ាន់ស្មានលើលំហូរសាច់ប្រាក់ ក៏ដូចជាឥទ្ធិពល នៃបម្រែបម្រួលអត្រាការប្រាក់ ទាក់ទងទៅនឹងផលបត្រវិនិយោគ និងប្រាក់បម្រុងធានារ៉ាប់រងត្រូវបានផ្តល់គំរូ និងត្រួតពិនិត្យយ៉ាងទៀងទាត់។ កម្មវត្ថុរួមនៃយុទ្ធសាស្ត្រវិនិយោគ គឺដើម្បីកំណត់បម្រែបម្រួលសុទ្ធនៅក្នុងតម្លៃនៃទ្រព្យសកម្ម និងបំណុលដែលកើតឡើងពីការប្រែប្រួលអត្រាការប្រាក់។

#### (ii) ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស

ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស គឺជាហានិភ័យនៃការខាតបង់ដែលកើតចេញពីបម្រែបម្រួលអត្រាប្តូរប្រាក់លើរូបិយប័ណ្ណដែលមិនមែនជារូបិយប័ណ្ណមុខងារ។ ការប្រែប្រួលនៃអត្រាប្តូរប្រាក់រវាងដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណដទៃទៀត ដែលក្រុមហ៊ុន ប្រកបអាជីវកម្មអាចជះឥទ្ធិពលទៅលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលនៃប្រតិបត្តិការ។ ហានិភ័យ បច្ចុប្បន្នដែលក្រុមហ៊ុនប្រឈម ភាគច្រើនបណ្តាលមកពីបម្រែបម្រួលអត្រាប្តូរប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល។ ក្រុមហ៊ុនស្វែងរកការកម្រិតនៃហានិភ័យរូបិយប័ណ្ណនេះដោយបន្ថយស្ថានភាពនៃរូបិយប័ណ្ណបរទេសសុទ្ធមកកម្រិតអប្បរមា។

មួយផ្នែកធំនៃទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុនជាដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងារ ដែលអាចបន្ថយហានិភ័យលើរូបិយប័ណ្ណបរទេស។ ចំពោះទ្រព្យសកម្មដែលនៅសល់ គឺជាប្រាក់រៀល។

### (iii) តម្លៃទីផ្សារនៃឧបករណ៍ហិរញ្ញវត្ថុ

សាច់ប្រាក់ និងសាច់ប្រាក់សមមូល គណនីធានារ៉ាប់រងត្រូវទទួល ការប្រាក់បង្គរ គណនីធានារ៉ាប់រងត្រូវសង បំណុលភតិសន្យា និង គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវសងផ្សេងៗ។

តម្លៃយោងប្រហាក់ប្រហែលនឹងតម្លៃទីផ្សារ ដោយសារតែកាលកំណត់រយៈពេលខ្លីនៃគណនី ទាំងនេះ។

*ចំនួនត្រូវទទួល និងចំនួនត្រូវសងភាគីពាក់ព័ន្ធ*

តម្លៃយោងគណនេយ្យនៃចំនួនត្រូវទទួលពីភាគីពាក់ព័ន្ធ និងចំនួនត្រូវសងទៅភាគីពាក់ព័ន្ធដែលត្រូវសងតាមតម្រូវការប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់ពួកគេ។

*ការលាតត្រដាងតម្លៃទីផ្សារស្ថិតក្រោមវិសោធនកម្មនៃ CIFRS 4*

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ក្រុមហ៊ុនបានវាយតម្លៃលើតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុដូចខាងក្រោម៖

- ទ្រព្យសកម្មដែលមានលំហូរសាច់ប្រាក់តាមកិច្ចសន្យា តំណាងឲ្យការទូទាត់របស់ប្រាក់ដើម និងការប្រាក់ (SPPI) ដោយមិនរាប់បញ្ចូលទ្រព្យសកម្មហិរញ្ញវត្ថុណាមួយដែលត្រូវបានកាន់កាប់សម្រាប់ការធ្វើពាណិជ្ជកម្ម ឬ ដែលត្រូវបានគ្រប់គ្រង ហើយប្រតិបត្តិការត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋានតម្លៃទីផ្សារ និង
- ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ក្រៅពីទ្រព្យសកម្មដែលបានបញ្ជាក់នៅក្នុង SPPI ខាងលើ (ឧទាហរណ៍ ទ្រព្យសកម្មដែលលំហូរសាច់ប្រាក់តាមកិច្ចសន្យាមិនតំណាងឲ្យ SPPI ទ្រព្យសកម្មដែលត្រូវបានកាន់កាប់សម្រាប់ការធ្វើពាណិជ្ជកម្ម និងទ្រព្យសកម្មដែលត្រូវបានគ្រប់គ្រង ហើយប្រតិបត្តិការត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋានតម្លៃទីផ្សារ)។

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សំដៅលើសាច់ប្រាក់នៅធនាគារ ប្រាក់បញ្ញើជាមួយធនាគារ ការវិនិយោគទុកដល់កាលកំណត់ មូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញឬខាត គណនីធានារ៉ាប់រងត្រូវទទួល។ លំហូរសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះតំណាងឲ្យការទូទាត់សុទ្ធនៃប្រាក់ដើម និងការប្រាក់តែប៉ុណ្ណោះ ហើយតម្លៃយោងដែលត្រូវយកមកប្រើប្រាស់ គឺតម្លៃប្រហាក់ប្រហែលដែលសមហេតុផលទៅនឹងតម្លៃទីផ្សារលើកលែងតែ ការវិនិយោគទុកដល់ការកំណត់ ជាមួយនឹងតម្លៃយោងគណនេយ្យចំនួន 38,757,017 ដុល្លារអាមេរិក ឬ 155,531,909 ពាន់រៀល (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024: 27,940,668 ដុល្លារអាមេរិក ឬ 112,461,189 ពាន់រៀល) និងតម្លៃសមរម្យ 39,451,953 ដុល្លារអាមេរិក ឬ 158,320,687 ពាន់រៀល (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024: 28,662,281 ដុល្លារអាមេរិក ឬ 115,365,681 ពាន់រៀល)។ ការវិនិយោគដែលនៅសេសសល់ពីការវិនិយោគកាន់កាប់រហូតដល់កាលកំណត់គឺពាក់ព័ន្ធនឹងការវិនិយោគលើបំណុលបន្ទាប់បន្សំ ដែលមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃទីផ្សារ។

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ក្រៅពីទ្រព្យសកម្មដែលបានបញ្ជាក់នៅក្នុងSPPI ខាងលើទាក់ទងទៅនឹងមូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញ ឬខាតដែលមានតម្លៃទីផ្សារ 1,824,072 ដុល្លារអាមេរិក ឬ 7,320,000 ពាន់រៀល (2024៖ 1,873,292 ដុល្លារអាមេរិក ឬ7,540,000ពាន់រៀល)។

តម្លៃសមស្របនៃការវិនិយោគទុកដល់កាលកំណត់ និងមូលប័ត្រក្នុងតម្លៃពិតប្រាកដតាមចំណេញឬខាត គឺស្ថិតនៅក្រោមតម្លៃសមស្របកម្រិត1 នៅក្នុងឋានានុក្រមតម្លៃសមស្រប។



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

### 27.2.2 ហានិភ័យឥណទាន

ផលបត្រវិនិយោគមានកាលកំណត់ថេររបស់ក្រុមហ៊ុន (រួមបញ្ចូលប្រាក់បញ្ញើនៅធនាគារពាណិជ្ជ) គឺអាចប្រឈមនឹង ហានិភ័យឥណទាន។ ហានិភ័យឥណទានត្រូវបានកំណត់ថាជាការខាតបង់ខ្លាំងនៃតម្លៃទីផ្សារ ដែលបណ្តាលមកពីការប្រែប្រួលខ្លាំងលើសមត្ថភាពក្នុងការសងបំណុលរបស់អ្នកខ្ចីប្រាក់ ឬ សមភាគី។ គោលបំណងរបស់ក្រុមហ៊ុន គឺដើម្បីទទួលបានលទ្ធផលដែលមានការប្រកួត ប្រជែង ដោយធ្វើការវិនិយោគនៅក្នុងផលបត្រវិនិយោគដែលបានធ្វើពិពិធកម្ម។ ហានិភ័យឥណទាននៃការវិនិយោគនីមួយៗ រួមបញ្ចូលប្រាក់បញ្ញើជាមួយធនាគារពាណិជ្ជត្រូវបានពិចារណា និងធ្វើការវិភាគ។ កម្រិតកំណត់ត្រូវបានបង្កើតដើម្បីគ្រប់គ្រងគុណភាពឥណទាន និងការប្រមូលផ្តុំហានិភ័យ។

ក្រុមហ៊ុនមានគណនីធានារ៉ាប់រងត្រូវទទួល និងគណនីធានារ៉ាប់រងបន្តត្រូវទទួល និងគណនីត្រូវទទួលផ្សេងទៀត ក៏ប្រឈមនឹងហានិភ័យឥណទានផងដែរ។ ដើម្បីកាត់បន្ថយហានិភ័យនៃភាគីម្ខាងទៀត ដែលមិនបានទូទាត់សាច់ប្រាក់ទាន់ពេលវេលា ក្រុមហ៊ុនបានបង្កើតគោលការណ៍ហិរញ្ញវត្ថុ និង អាជីវកម្មដាក់លាក់ដើម្បីទទួលបានការអនុញ្ញាតលើក្រុមហ៊ុនធានារ៉ាប់រងបន្តដោយការកំណត់អត្រារួមគ្នាពីភ្នាក់ងារចម្បងៗ និងការពិចារណាព័ត៌មានទីផ្សារនាពេលបច្ចុប្បន្ន។ ក្រុមហ៊ុនក៏ត្រួតពិនិត្យយ៉ាងទៀងទាត់ លើស្ថិរភាពហិរញ្ញវត្ថុនៃក្រុមហ៊ុនធានារ៉ាប់រងបន្តចេញពីតាមប្រភពសាធារណៈ និងប្រភពផ្សេងទៀត និងនិន្នាការនៃការទូទាត់ប្រាក់ដែលដល់កំណត់ត្រូវសងដោយក្រុមហ៊ុនធានារ៉ាប់រងបន្ត។

សេចក្តីលម្អិត ពីគុណភាពឥណទាន តាមប្រភេទនៃទ្រព្យសកម្ម សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ដែលប្រឈមនឹងហានិភ័យឥណទាននាការិយបរិច្ឆេទនៃតារាងតុល្យការមានដូចខាងក្រោម៖

| | 2025 | | | |
|---|---|---|---|---|
| | មិនទាន់ដល់កំណត់សង | ហួសកំណត់ត្រូវសង ប៉ុន្តែមិនត្រូវបានធ្វើអ៊ីមភែរមិននៃតម្លៃជាឯកវ័ន្ត | អ៊ីមភែរមិននៃតម្លៃជាឯកវ័ន្ត | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីធានារ៉ាប់រងត្រូវទទួលនិងកិច្ចសន្យាធានារ៉ាប់រងបន្ត | 5,087,310 | - | - | 5,087,310 |
| គណនីត្រូវទទួលផ្សេងៗ | 11,135,541 | - | - | 11,135,541 |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | 561,950 | - | - | 561,950 |
| ប្រាក់បញ្ញើនៅធនាគារ | 315,982,268 | - | - | 315,982,268 |
| ការវិនិយោគកាន់កាប់ដល់កាលកំណត់ | 57,681,915 | - | - | 57,681,915 |
| មូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញ ឬ ខាត | 1,873,292 | (49,220) | - | 1,824,072 |
| ចំនួនទឹកប្រាក់ដែលត្រូវទទួលបានពីសម្ព័ន្ធញាតិ | 2,556,007 | - | - | 2,556,007 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 4,032,848 | - | - | 4,032,848 |
| **សរុប** | **398,911,131** | **(49,220)** | **-** | **398,861,911** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **1,600,830,369** | **(197,520)** | **-** | **1,600,632,849** |

| | 2024 | | | |
|---|---|---|---|---|
| | មិនទាន់ដល់កំណត់សង | ហួសកំណត់ត្រូវសង ប៉ុន្តែមិនត្រូវបានធ្វើអ៊ីមភែរមិននៃតម្លៃជាឯកវ័ន្ត | អ៊ីមភែរមិននៃតម្លៃជាឯកវ័ន្ត | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីធានារ៉ាប់រងត្រូវទទួលនិងកិច្ចសន្យាធានារ៉ាប់រងបន្ត | 10,249,095 | - | - | 10,249,095 |
| គណនីត្រូវទទួលផ្សេងៗ | 10,036,481 | - | - | 10,036,481 |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | 342,237 | - | - | 342,237 |
| ប្រាក់បញ្ញើនៅធនាគារ | 289,982,268 | - | - | 289,982,268 |
| ការវិនិយោគកាន់កាប់ដល់កាលកំណត់ | 32,940,668 | - | - | 32,940,668 |
| មូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញ ឬ ខាត | 2,462,668 | (589,376) | - | 1,873,292 |
| ចំនួនទឹកប្រាក់ដែលត្រូវទទួលបានពីសម្ព័ន្ធញាតិ | 3,489,368 | - | - | 3,489,368 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 5,591,084 | - | - | 5,591,084 |
| **សរុប** | **355,093,869** | **(589,376)** | **-** | **354,504,493** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **1,429,252,823** | **(2,372,239)** | **-** | **1,426,880,584** |





### 27.2.3 ហានិភ័យសន្ទនីយភាព

ហានិភ័យសន្ទនីយភាព គឺជាហានិភ័យដែលក្រុមហ៊ុននឹងជួបប្រទះការលំបាកនៅក្នុងការ បំពេញកាតព្វកិច្ចហិរញ្ញវត្ថុដោយសារតែកង្វះខាតមូលនិធិ។

ក្រុមហ៊ុនត្រូវតែបំពេញតាមតម្រូវការប្រចាំថ្ងៃលើធនធានសាច់ប្រាក់ ពីសំណងដែលកើតឡើងលើកិច្ចសន្យាធានារ៉ាប់រង និងការបញ្ចប់ប័ណ្ណសន្យារ៉ាប់រងមុនពេលកំណត់ដើម្បីទទួលបានប្រាក់នៃការបញ្ចប់កិច្ចសន្យា។ ហេតុដូចនេះ បានជាមានហានិភ័យ ដែលសាច់ប្រាក់ពុំមានគ្រប់គ្រាន់ បានដើម្បីទូទាត់បំណុលនៅពេលដល់កាលកំណត់ការទូទាត់តាមថ្លៃដើមមួយដែលសមស្រប។ ក្រុមហ៊ុនគ្រប់គ្រងហានិភ័យនេះ ដោយត្រួតពិនិត្យតាមដាន និងកំណត់កម្រិតដ៏សាកសម នៃមូលនិធិប្រតិបត្តិការដើម្បីទូទាត់បំណុលទាំងនេះ។ ផលបត្រវិនិយោគត្រូវបានរៀបចំ ដោយយោងទៅតាមតម្រូវការសន្ទនីយភាពនៃមូលនិធិនីមួយៗ និងការផាកពិន័យចំពោះការលះបង់មុនកាលកំណត់ និងលក្ខខណ្ឌនៃការកែសម្រួលទីផ្សារ ដែលត្រូវបានប្រើដើម្បីជម្រះថ្លៃដើមនៃតម្រូវការសាច់ប្រាក់ពុំបានរំពឹងទុក។

កាលវសានតាមកិច្ចសន្យា

ទាក់ទងនឹងទ្រព្យសកម្មហិរញ្ញវត្ថុដែលទទួលបានពីប្រាក់ចំណូល នាកាលបរិច្ឆេទនៃតារាងតុល្យការពត៌មាននៃកិច្ចសន្យាមានអាយុកាល មានដូចខាងក្រោម៖

| | 2025 | | | | | | |
|---|---|---|---|---|---|---|---|
| | រហូតដល់ 1ឆ្នាំ | ពី 1ឆ្នាំដល់ 3ឆ្នាំ | ពី3ឆ្នាំដល់5ឆ្នាំ | ពី 5ឆ្នាំ ដល់ 15ឆ្នាំ | លើសពី 15ឆ្នាំ | គ្មានកាលកំណត់ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| គណនីធានារ៉ាប់រងត្រូវទទួល និងកិច្ចសន្យាធានារ៉ាប់រងបន្ត | 5,087,310 | - | - | - | - | - | 5,087,310 |
| គណនីត្រូវទទួលផ្សេងៗ | 24,626,891 | 38,428,607 | 32,482,788 | 38,724,242 | - | - | 134,262,528 |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | 12,179.00 | 37,333.00 | 107,451.00 | 368,633.00 | 36,354.00 | - | 561,950 |
| ប្រាក់បញ្ញើនៅធនាគារ | 37,000,000 | 52,242,400 | 42,114,268 | 184,625,600 | - | - | 315,982,268 |
| ការវិនិយោគកាន់កាប់ដល់កាលកំណត់ | 3,324,601 | 13,635,610 | 12,315,278 | 29,481,527 | - | - | 58,757,016 |
| មូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញឬខាត | - | - | - | - | - | 1,824,072 | 1,824,072 |
| ចំនួនទឹកប្រាក់ដែលត្រូវបង់ពីសម្ព័ន្ធញាតិ | 2,556,007 | - | - | - | - | - | 2,556,007 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 4,032,848 | - | - | - | - | - | 4,032,848 |
| **សរុប** | **76,639,836** | **104,343,950** | **87,019,785** | **253,200,002** | **36,354** | **1,824,072** | **523,063,999** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **307,555,662** | **418,732,271** | **349,210,397** | **1,016,091,608** | **145,889** | **7,320,001** | **2,099,055,828** |



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

| | 2024 | | | | | | |
|---|---|---|---|---|---|---|---|
| | រហូតដល់ 1ឆ្នាំ | ពី 1ឆ្នាំដល់ 3ឆ្នាំ | ពី3ឆ្នាំដល់5ឆ្នាំ | ពី 5ឆ្នាំ ដល់ 15ឆ្នាំ | លើសពី 15ឆ្នាំ | គ្មានកាលកំណត់ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| គណនីធានារ៉ាប់រងត្រូវទទួល និងកិច្ចសន្យាធានារ៉ាប់រងបន្ត | 10,249,095 | - | - | - | - | - | 10,249,095 |
| គណនីត្រូវទទួលផ្សេងៗ | 20,511,734 | 35,102,297 | 26,831,631 | 41,858,412 | - | - | 124,304,074 |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | 6,095 | 16,531 | 39,133 | 269,014 | 11,464 | - | 342,237 |
| ប្រាក់បញ្ញើនៅធនាគារ | 23,300,000 | 58,573,200 | 30,483,668 | 177,625,400 | - | - | 289,982,268 |
| ការវិនិយោគកាន់កាប់ដល់កាលកំណត់ | 8,638,396 | 7,556,991 | 7,518,847 | 9,226,434 | - | - | 32,940,668 |
| មូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញឬខាត | - | - | - | - | - | 1,873,292 | 1,873,292 |
| ចំនួនទឹកប្រាក់ដែលត្រូវបង់ពីសម្ព័ន្ធញាតិ | 3,489,368 | - | - | - | - | - | 3,489,368 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 5,591,084 | - | - | - | - | - | 5,591,084 |
| **សរុប** | **71,785,772** | **101,249,019** | **64,873,279** | **228,979,260** | **11,464** | **1,873,292** | **468,772,086** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **288,937,732** | **407,527,301** | **261,114,948** | **921,641,522** | **46,143** | **7,540,000** | **1,886,807,646** |

តារាងខាងក្រោមបង្ហាញពីកាលកំណត់តាមកិច្ចសន្យានៃបំណុលហិរញ្ញវត្ថុ ជាកិច្ចសន្យានិស្សន្ទ និងកិច្ចសន្យាមិនមែននិស្សន្ទ (non-derivative and derivative) របស់ក្រុមហ៊ុន (លើមូលដ្ឋានមិនអប្បហារ) និងការប៉ាន់ស្មានពេលវេលានៃលំហូរសាច់ប្រាក់ ដែលកើតឡើងពីបំណុលក្រោមកិច្ចសន្យាធានារ៉ាប់រង (លើមូលដ្ឋានអប្បហារ) នាកាលបរិច្ឆេទតារាងតុល្យការ៖

| | 2025 | | | | | | |
|---|---|---|---|---|---|---|---|
| | រហូតដល់ 1ឆ្នាំ | ពី 1ឆ្នាំដល់ 3ឆ្នាំ | ពី3ឆ្នាំដល់5ឆ្នាំ | ពី 5ឆ្នាំ ដល់ 15ឆ្នាំ | លើសពី 15ឆ្នាំ | គ្មានកាលកំណត់ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | 8,430,753 | 23,459,170 | 67,519,698 | 231,639,368 | 22,844,173 | - | 353,893,162 |
| គណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗ | 12,197,075 | - | - | - | - | - | 12,197,075 |
| បំណុលភតិសន្យា | 772,988 | 1,583,588 | 176,041 | - | - | - | 2,532,617 |
| **សរុប** | **21,400,816** | **25,042,758** | **67,695,739** | **231,639,368** | **22,844,173** | **-** | **368,622,854** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **85,881,475** | **100,496,588** | **271,663,001** | **929,568,784** | **91,673,665** | **-** | **1,479,283,513** |

តារាងខាងក្រោមបង្ហាញរយៈពេលផុតកំណត់តាមកិច្ចសន្យានៃបំណុលហិរញ្ញវត្ថុ ជាកិច្ចសន្យានិស្សន្ទ និងកិច្ចសន្យាមិនមែននិស្សន្ទ (non-derivative and derivative) របស់ក្រុមហ៊ុន (លើមូលដ្ឋានមិនអប្បហារ) និងការប៉ាន់ស្មានពេលវេលានៃលំហូរសាច់ប្រាក់ ដែលកើតឡើងពីបំណុលក្រោមកិច្ចសន្យាធានារ៉ាប់រង (លើមូលដ្ឋានអប្បហារ) នាកាលបរិច្ឆេទតារាងតុល្យការ៖

| | 2024 | | | | | | |
|---|---|---|---|---|---|---|---|
| | រហូតដល់ 1ឆ្នាំ | ពី 1ឆ្នាំដល់ 3ឆ្នាំ | ពី3ឆ្នាំដល់5ឆ្នាំ | ពី 5ឆ្នាំ ដល់ 15ឆ្នាំ | លើសពី 15ឆ្នាំ | គ្មានកាលកំណត់ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | 6,057,194 | 14,521,101 | 34,375,692 | 236,311,375 | 10,070,599 | - | 301,335,961 |
| គណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗ | 13,841,281 | 2,017,939 | 2,010,942 | 2,014,188 | 6,802 | - | 19,891,152 |
| បំណុលភតិសន្យា | 590,904 | 1,271,516 | 791,005 | - | - | - | 2,653,425 |
| **សរុប** | **20,489,379** | **17,810,556** | **37,177,639** | **238,325,563** | **10,077,401** | **-** | **323,880,538** |
| **ពាន់រៀល** (កំណត់សម្គាល់លេខ 2.3) | **82,469,750** | **71,687,488** | **149,639,997** | **959,260,391** | **40,561,539** | **-** | **1,303,619,165** |

*ការប្រើប្រាស់ ឬ ការទូទាត់ដែលរំពឹងទុកនៃទ្រព្យសកម្ម និងបំណុល*

ពុំមានភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងការប្រើប្រាស់ ឬ ការទូទាត់ដែលរំពឹងទុក នៃទ្រព្យសកម្ម និងបំណុល និងកាលកំណត់តាមកិច្ចសន្យាដូចបានបង្ហាញខាងលើនោះទេ។





## 28. កាលវិភាគអាយុកាលនៃទ្រព្យសកម្ម និងបំណុល

តារាងខាងក្រោមបង្ហាញពីការវិភាគលើទ្រព្យសកម្ម និងបំណុល ស្របតាមពេលដែលរំពឹងថា នឹងប្រមូលបាន ឬ ទូទាត់បាន៖

| | 2025 | | | |
|---|---|---|---|---|
| | ក្នុងរយៈពេល 1ឆ្នាំ | លើសពី 1ឆ្នាំ | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីធានារ៉ាប់រងត្រូវទទួល និងកិច្ចសន្យាធានារ៉ាប់រងបន្ត | 5,087,310 | - | 5,087,310 | 20,415,376 |
| គណនីត្រូវទទួលផ្សេងៗ | 7,271,930 | 3,863,611 | 11,135,541 | 44,686,926 |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | 12,179 | 549,771 | 561,950 | 2,255,105 |
| ប្រាក់បញ្ញើនៅធនាគារ | 37,000,000 | 278,982,268 | 315,982,268 | 1,268,036,841 |
| ការវិនិយោគកាន់កាប់រហូតដល់កាលកំណត់ | - | 57,681,915 | 57,681,915 | 231,477,525 |
| មូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញ ឬ ខាត | - | 2,818,620 | 2,818,620 | 11,311,121 |
| ចំនួនទឹកប្រាក់ដែលត្រូវទទួលបានពីសម្ព័ន្ធញាតិ | 2,556,007 | - | 2,556,007 | 10,257,256 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 4,032,848 | - | 4,032,848 | 16,183,819 |
| | **55,960,274** | **343,896,185** | **399,856,459** | **1,604,623,969** |
| **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ** | | | | |
| ទ្រព្យ និងបរិក្ខារ | - | 5,758,747 | 5,758,747 | 23,109,853 |
| ការចំណាយពន្យារ និងទ្រព្យសកម្មអរូបីផ្សេងៗ | - | 109,303,255 | 109,303,255 | 438,633,962 |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | - | 4,158,941 | 4,158,941 | 16,689,830 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | - | 700,000 | 700,000 | 2,809,100 |
| ទ្រព្យសកម្មផ្សេងៗ | 2,319,195 | - | 2,319,195 | 9,306,930 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 385,310 | - | 385,310 | 1,546,249 |
| | **2,704,505** | **119,920,943** | **122,625,448** | **492,095,924** |
| | **58,664,779** | **463,817,128** | **522,481,907** | **2,096,719,893** |
| ដក៖ រំលស់បង្គរ និងរំលស់ | | | (58,734,748) | (235,702,545) |
| បង្គរតម្លៃទីផ្សារលើមូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញ ឬ ខាត | | | (994,548) | (3,991,121) |
| **ទ្រព្យសកម្មសរុប** | | | **462,752,611** | **1,857,026,227** |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | 8,430,753 | 345,462,409 | 353,893,162 | 1,420,173,259 |
| គណនីធានារ៉ាប់រងត្រូវសង | 1,184,498 | - | 1,184,498 | 4,753,390 |
| គណនីត្រូវសងផ្សេងៗ | 11,012,577 | - | 11,012,577 | 44,193,471 |
| បំណុលភតិសន្យា | 1,628,884 | 632,770 | 2,261,654 | 9,076,018 |
| | **22,256,712** | **346,095,179** | **368,351,891** | **1,478,196,138** |
| **បំណុលមិនមែនហិរញ្ញវត្ថុ** | | | | |
| គណនីត្រូវសងផ្សេងៗ | 252,397 | - | 252,397 | 1,012,869 |
| | **252,397** | **-** | **252,397** | **1,012,869** |
| **បំណុលសរុប** | **22,509,109** | **346,095,179** | **368,604,288** | **1,479,209,007** |

| | *2024* | | | |
|---|---|---|---|---|
| | ក្នុងរយៈពេល 1ឆ្នាំ | លើសពី 1ឆ្នាំ | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| **Financial assets** | | | | |
| គណនីធានារ៉ាប់រងត្រូវទទួល និងកិច្ចសន្យាធានារ៉ាប់រងបន្ត | 10,249,095 | - | 10,249,095 | 41,252,607 |
| គណនីត្រូវទទួលផ្សេងៗ | 6,847,293 | 3,376,029 | 10,223,322 | 41,148,871 |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | 6,095 | 336,142 | 342,237 | 1,377,504 |
| ប្រាក់បញ្ញើនៅធនាគារ | 23,300,000 | 266,682,268 | 289,982,268 | 1,167,178,629 |
| ការវិនិយោគកាន់កាប់រហូតដល់កាលកំណត់ | 6,467,863 | 26,472,805 | 32,940,668 | 132,586,189 |
| មូលប័ត្រក្នុងតម្លៃសមស្របតាមចំណេញ ឬ ខាត | - | 2,818,620 | 2,818,620 | 11,344,946 |
| ចំនួនទឹកប្រាក់ដែលត្រូវទទួលបានពីសម្ព័ន្ធញាតិ | 3,489,368 | - | 3,489,368 | 14,044,706 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 5,591,084 | - | 5,591,084 | 22,504,113 |
| | **55,950,798** | **299,685,864** | **355,636,662** | **1,431,437,565** |
| **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ** | | | | |
| ទ្រព្យ និងបរិក្ខារ | - | 6,151,452 | 6,151,452 | 24,759,595 |
| ការចំណាយពន្យារ និងទ្រព្យសកម្មអរូបីផ្សេងៗ | - | 96,067,098 | 96,067,098 | 386,670,069 |
| សិទ្ធប្រើប្រាស់ទ្រព្យសកម្ម | - | 3,715,449 | 3,715,449 | 14,954,682 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | - | 700,000 | 700,000 | 2,817,500 |
| ទ្រព្យសកម្មផ្សេងៗ | 1,057,313 | - | 1,057,313 | 4,255,685 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 272,437 | - | 272,437 | 1,096,559 |
| | **1,329,750** | **106,633,999** | **107,963,749** | **434,554,090** |
| | **57,280,548** | **406,319,863** | **463,600,411** | **1,865,991,655** |
| ដកៈ រំលស់បង្គរ នឹងរំលស់ | | | (46,951,350) | (188,979,184) |
| បង្គរតម្លៃទីផ្សារលើមូលប័ត្រក្នុងតម្លៃសមស្រប តាមចំណេញ ឬ ខាត | | | (945,328) | (3,804,946) |
| **ទ្រព្យសកម្មសរុប** | | | **415,703,733** | **1,673,207,525** |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | 6,057,194 | 295,278,767 | 301,335,961 | 1,212,877,243 |
| គណនីធានារ៉ាប់រងត្រូវសង | 1,768,451 | - | 1,768,451 | 7,118,015 |
| គណនីត្រូវសងផ្សេងៗ | 11,801,027 | 4,741,309 | 16,542,336 | 66,582,902 |
| បំណុលភតិសន្យា | 1,828,796 | 435,214 | 2,264,010 | 9,112,640 |
| | **21,455,468** | **300,455,290** | **321,910,758** | **1,295,690,800** |
| **បំណុលមិនមែនហិរញ្ញវត្ថុ** | | | | |
| គណនីត្រូវសងផ្សេងៗ | 620,354 | - | 620,354 | 2,496,925 |
| | **620,354** | **-** | **620,354** | **2,496,925** |
| **បំណុលសរុប** | **22,075,822** | **300,455,290** | **322,531,112** | **1,298,187,725** |





## 29. យថាភាព

*ផ្លូវច្បាប់*

ក្រុមហ៊ុនដែលធ្វើប្រតិបត្តិការអាជីវកម្ម នៅក្នុងវិស័យធានារ៉ាប់រង ត្រូវប្រឈមនឹងបណ្តឹងតាមផ្លូវច្បាប់នៅក្នុងដំណើរការអាជីវកម្មជាធម្មតា។ ទោះបីជាមិនអាចធ្វើការព្យាករណ៍ ឬ កំណត់លទ្ធផលចុងក្រោយ តាមនីតិវិធីផ្លូវច្បាប់ លើករណីសំណុំរឿងដែលពុំទាន់សម្រេចទាំងអស់ ឬមានការគម្រាមកំហែងតាមនីតិវិធីច្បាប់ក៏ដោយ ក៏គណៈគ្រប់គ្រងជឿជាក់ថា នឹងមិនមានផលប៉ះពាល់ជាសារវន្ត បណ្តាលមកពីដំណើរការនីតិវិធីទាំងនេះ (រួមទាំងការប្តឹងតវ៉ា) ទៅលើរបាយការណ៍លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

*ពន្ធដារ*

ក្រុមហ៊ុនបានទទួលបានការកំណត់ពន្ធឡើងវិញផ្សេងៗ ពីនាយកដ្ឋានអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ (GDT)។ ក្រុមហ៊ុនជឿជាក់យ៉ាងមុតមាំថាខ្លួនមានមូលហេតុ និងមូលដ្ឋានសមហេតុសមផល ក្នុងការប្រជែងនឹងការកំណត់ពន្ធឡើងវិញរបស់ GDT។ ក្រុមហ៊ុនកំពុងបន្តការពិភាក្សាជាបន្តបន្ទាប់ជាមួយ GDT ដើម្បីទទួលបានដំណោះស្រាយសមស្រប លើបញ្ហាកំណត់ពន្ធឡើងវិញដែលមិនទាន់ដោះស្រាយទាំងនេះជាមួយនឹង គោលជំហរយ៉ាងរឹងមាំ។

ប្រព័ន្ធពន្ធដារនៅកម្ពុជាមានលក្ខណៈពន្ធច្រើនប្រភេទ ដែលមានការផ្លាស់ប្តូរច្បាប់ជាញឹកញាប់ និងមានភាពមិនច្បាស់លាស់ ហើយមានលក្ខណៈខុសគ្នាទៅតាមការបកស្រាយ។ ជាញឹកញាប់មានការបកស្រាយខុសៗគ្នា និងការស៊ើបអង្កេតដោយអាជ្ញាធរពន្ធ និងអាជ្ញាធរពាក់ព័ន្ធ។ ពន្ធត្រូវបានពិនិត្យ និងស៊ើបអង្កេតដោយអាជ្ញាធរផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ដើម្បីដាក់ការផ្តន្ទាទោស ពិន័យផ្សេងៗ និងការពិន័យជាការប្រាក់។ គណៈគ្រប់គ្រងជឿជាក់ថា ខ្លួនបានកត់ត្រាបំណុលពន្ធគ្រប់គ្រាន់ ដោយផ្អែកលើការបកស្រាយច្បាប់ពន្ធរបស់ខ្លួន។ទោះជាយ៉ាងណាក៏ដោយអាជ្ញាធរពាក់ព័ន្ធអាចមានការបកស្រាយខុសគ្នា ហើយផលប៉ះពាល់តាំងពីពេលចុះបញ្ជីក្រុមហ៊ុន អាចមានលក្ខណៈជាសារវន្ត។

## 30. ចំណាត់ថ្នាក់ឡើងវិញនៃតួលេខដែលត្រូវគ្នា

គណនីខាងក្រោមនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ត្រូវបានចាត់ចែងឡើងវិញ ដើម្បីអនុលោមតាមការបង្ហាញរបស់ការិយបរិច្ឆេទបច្ចុប្បន្ន ដូចសង្ខេបខាងក្រោម៖

| | ការបង្ហាញពីមុន | | ចំណាត់ថ្នាក់ឡើងវិញ | | ចំណាត់ថ្នាក់ឡើងវិញ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| **របាយការណ៍លទ្ធផលពេញលេញ** | | | | | | |
| ចំណូលការប្រាក់ | 19,214,063 | 78,220,450 | 171,529 | 698,295 | 19,385,592 | 78,918,745 |
| ចំណាយហិរញ្ញវត្ថុ | - | - | (171,529) | (698,295) | (171,529) | (698,295) |
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | | | | | |
| គណនីធានាវ៉ាប់រង និងគណនីត្រូវទទួលផ្សេងៗ | 24,832,257 | 99,949,834 | 186,841 | 752,035 | 25,019,098 | 100,701,869 |
| គណនីធានាវ៉ាប់រង និងគណនីត្រូវទូទាត់ផ្សេងៗ | 18,744,300 | 75,445,807 | 186,841 | 752,035 | 18,931,141 | 76,197,842 |
| របាយការណ៍លំហូរសាច់ប្រាក់ - សកម្មភាពប្រតិបត្តិការ | | | | | | |
| គណនីធានាវ៉ាប់រង និងគណនីត្រូវទទួលផ្សេងៗ | (5,190,492) | (21,130,493) | (186,841) | (760,630) | (5,377,333) | (21,891,123) |
| គណនីធានាវ៉ាប់រង និងគណនីត្រូវទូទាត់ផ្សេងៗ | (430,255) | (1,751,568) | 186,841 | 760,630 | (243,414) | (990,938) |

## 31. ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

ក្រៅពីការបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ នាកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានព្រឹត្តិការណ៍គួរឲ្យកត់សម្គាល់ណាបានកើតឡើង ក្រោយថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ដែលតម្រូវឲ្យមានការកែសម្រួល ឬ ការបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ឡើយ។



ព័ត៌មានសង្ខេបអំពីអាជីវកម្ម | ព័ត៌មានអំពីអាជីវកម្ម | ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម | ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**